

# ការអនុវត្តន៍អនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្រ្តីភេទ នៅកម្ពុជា ឆ្នាំ២០១០


រៀបរៀងដោយៈ **គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្រ្តីភេទ(NGO-CEDAW) និង គណៈកម្មាធិការស្រ្តីកម្ពុជា (CAMBOW)**



ខែមីនា ឆ្នាំ២០១១



The Cambodian NGO Committee on CEDAW
NGO-CEDAW

AMBOW

គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាល
ដើម្បីដើម្បីលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្រ្តីភេទ

គណៈកម្មាធិការស្រ្តីកម្ពុជា

# មាតិកា


**សេចក្តីថ្លែងអំណរគុណ** ........ ១
**បុព្វកថា** ........ ២
**ជំពូក ១. បរិបទប្រទេសជាតិ** ........ ៥
១. ស្ថានភាព ........ ៥
១.១ សិទ្ធិមនុស្ស ........ ៦
១.២ ធនធានធម្មជាតិ ........ ៨
១.៣ ក្រុមជនជាតិដើមភាគតិច ........ ៩
២. ការផ្សព្វផ្សាយ និងការអនុវត្តន៍អនុសញ្ញា CEDAW ........ ១០
២.១ ឧបសគ្គក្នុងការផ្សព្វផ្សាយ និងការអនុវត្តន៍អនុសញ្ញា CEDAW ........ ១១
២.២ អនុសាសន៍ដើម្បីកែលំអការផ្សព្វផ្សាយ និងការអនុវត្តន៍អនុសញ្ញា CEDAW ........ ១២
**ជំពូក ២. ការអប់រំ និងប្រព័ន្ធផ្សាយព័ត៌មាន** ........ ១៣
១. ស្ថានភាព ........ ១៣
១.១ នីតិបញ្ញត្តិ និងគោលនយោបាយ ........ ១៤
១.២ ការចុះឈ្មោះចូលរៀន ........ ១៦
១.៣ អត្រាបោះបង់ការសិក្សា ........ ១៨
១.៤ អក្ខរភាព ........ ១៨
១.៥ គុណភាពអប់រំ ........ ១៨
១.៦ កម្មវិធីអប់រំ ........ ២១
១.៧ ស្ត្រីក្នុងប្រព័ន្ធផ្សាយព័តិមាន ........ ២១
១.៨ ស្ត្រី និងបច្ចេកទេសទូរគមនាគមន៍ និងព័ត៌មានវិទ្យាថ្មីៗ ........ ២៥
១.៩ ស្ត្រីជនជាតិភាគតិចពូជសាសន៍ខុសៗគ្នា និងស្ត្រីពិការ ........ ២៨
២. ប្រស្នា ........ ២៩
២.១ ប្រស្នាស្នូល ........ ៣០
៣. អនុសាសន៍ ........ ៣១
**ជំពូក ៣. នយោបាយ និងការសម្រេចចិត្ត** ........ ៣២
១. ស្ថានភាព ........ ៣២
១.១ ច្បាប់ និងគោលនយោបាយ ........ ៣២

១.២ តំណាងស្ត្រីនៅក្នុងឆាកនយោបាយ ..... ៣៥
១.៣ ការចូលរួមក្នុងឆាកនយោបាយរបស់ស្ត្រីជនជាតិដើម និងស្ត្រីពិការ ..... ៤២
២. បញ្ហា ..... ៤៤
២.១ ការផ្សព្វផ្សាយសម្លេងស្ត្រី: ការកែប្រែសង្គមតាមរយៈការចូលរួម ..... ៤៨
២.២ ការចូលរួមរបស់ស្ត្រីក្នុងឆាកនយោបាយ ..... ៤៨
៣. អនុសាសន៍ ..... ៤៩
**ជំពូក ៤. សិទ្ធិសុខភាព និងសិទ្ធិផ្លូវភេទ ព្រមទាំងសិទ្ធិក្នុងការបន្តពូជ ..... ៥២**
១. ស្ថានភាព ..... ៥២
១.១ ច្បាប់ និងគោលនយោបាយ ..... ៥៣
១.២ សុខភាពបន្តពូជ និងផ្លូវភេទ ..... ៥៥
១.៣ ការគាំពារមាតា ..... ៥៨
២. បញ្ហា ..... ៦០
៣. អនុសាសន៍ ..... ៦០
**ជំពូក ៥. សេដ្ឋកិច្ច និងសិទ្ធិប្រើប្រាស់ធនធាន ..... ៦២**
១. ស្ថានភាព ..... ៦២
១.១ ច្បាប់ និងគោលនយោបាយ ..... ៦៤
២. ស្ត្រីក្នុងវិស័យសេដ្ឋកិច្ចក្នុងប្រព័ន្ធ ..... ៦៥
២.១ ស្ត្រីក្នុងវិស័យកាត់ដេរ: ស្ត្រីជាមេដឹកនាំសហជីព ..... ៦៥
២.២ ស្ត្រីក្នុងវិស័យសំណង់ ..... ៦៧
២.៣ ស្ត្រីក្នុងវិស័យសេវាកម្មកំសាន្ត ..... ៦៩
២.៤ ការងារស្ត្រីក្នុងវិស័យសាធារណៈ ..... ៦៩
៣. ស្ត្រីក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ..... ៧០
៣.១ ស្ត្រីបម្រើការងារតាមផ្ទះ ..... ៧០
៣.២ ស្ត្រីក្នុងវិស័យកសិកម្ម ..... ៧០
៣.៣ ស្ត្រីក្នុងវិស័យសហគ្រាសខ្នាតតូច ..... ៧១
៣.៤ ភាពខុសគ្នាក្នុងការទទួលបានប្រាក់ចំណូល ..... ៧១
៣.៥ ស្ត្រី និងចំណាកស្រុក ..... ៧២
៣.៦ ស្ត្រីជនជាតិដើមភាគតិច និងស្ត្រីពិការ ..... ៧៣
៤. បញ្ហា ..... ៧៤

៥. អនុសាសន៍..........................................................................................................................................៧៦
**ជំពូក ៦. អំពើហិង្សាទាក់ទងនឹងយេនឌ័រ: ហិង្សាក្នុងគ្រួសារ..................................................៧៨**
១. ស្ថានភាព...........................................................................................................................................៧៨
១.១ និយមន័យ និងប្រភេទនៃអំពើហិង្សាក្នុងគ្រួសារ ...................................................... ៧៩
១.២ ច្បាប់ និងគោលនយោបាយ ..................................................................................................... ៧៩
១.៣ ស្ត្រីជនជាតិដើមភាគតិច និងស្ត្រីពិការ ............................................................................... ៨០
១.៤ ការផ្សព្វផ្សាយ និងការអនុវត្តន៍ច្បាប់ .................................................................................. ៨១
២. មូលហេតុចំបងដើម្បីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនៅកម្ពុជា ............................................ ៨៣
៣. ប្រស្នា................................................................................................................................................ ៨៣
៤. អនុសាសន៍.......................................................................................................................................... ៨៥
**ជំពូក ៧. អំពើហិង្សាទាក់ទងនឹងយេនឌ័រ: អំពើរំលោភសេពសន្ថវៈ ការជួញដូរ និងការបៀតបៀនកេរ្តិ៍ខ្មាស ........................................................................................................................................៨៦**
១. ស្ថានភាព............................................................................................................................................៨៦
១.១ ច្បាប់ និងគោលនយោបាយ.......................................................................................................៨៧
១.២ ការរំលោភសេពសន្ថវៈ ............................................................................................................ ៨៩
១.៣ ការជួញដូរ និងការធ្វើអាជីវកម្មផ្លូវភេទ ................................................................................៩៣
១.៤ បទរុកគួនខាងផ្លូវភេទ (Sexual Harrasment)..................................................................... ៩៦
១.៥ ប្រស្នា ............................................................................................................................................... ៩៦
២. អនុសាសន៍ .......................................................................................................................................... ៩៨
**សេចក្តីសន្និដ្ឋាន ......................................................................................................................................៩៩**
**ឧបសម្ព័ន្ធ.............................................................................................................................................១០២**
ឯកសារយោង ..................................................................................................................................... ១០២
ពាក្យបំព្រួញ .......................................................................................................................................... ១០៦
បញ្ជីអង្គការសមាជិក NGO-CEDAW ........................................................................................... ១០៧
បញ្ជីអង្គការសមាជិក CAMBOW ..........................................................................................................១០៩

# សេចក្ដីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ អង្គការជំនួយព្រះវិហារ/គ្រិស្តសាសនិកដាណឺម៉ាក (DCA/CA) ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិកាណាដា (The Canadian International Development Agency) ចំពោះការជួយឧបត្ថម្ភដោយនិរន្តភាពដល់គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទំរង់នៃការរើសអើងលើស្ត្រីភេទ (NGO-CEDAW)។

សូមថ្លែងអំណរគុណជាពិសេសចំពោះ អង្គការសន្តិភាព និងការអភិវឌ្ឍន៍ (PYD) របស់ប្រទេសអេស្ប៉ាញដែលបានឧបត្ថម្ភផ្នែកបច្ចេកទេស និងទីប្រឹក្សា។

សូមថ្លែងអំណរគុណចំពោះអង្គការ សមាគមជាសមាជិកគណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិ-បាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ អនុគណៈកម្មាធិការទាំង ៦ បុគ្គលិក និងអស់លោកលោកស្រីដែលបានគាំទ្រដល់កម្មវិធីនេះ។

NGO-CEDAW ក៏សូមអរគុណជាអតិបរមាផងដែរចំពោះ ឃែមបូវ (CAMBOW) បានផ្តល់យោបល់ដែលមានសារៈសំខាន់ជាច្រើន។

សូមថ្លែងអំណរគុណផងដែរ ជាពិសេសដល់សាធារណៈជនទាំងអស់ដែលបានទូរស័ព្ទមកពិភាក្សា ក្នុងកម្មវិធីវិទ្យុ ព្រមទាំងបានចែករំលែកបទពិសោធន៍នានាថែមទៀត។ NGO-CEDAW សង្ឃឹមថា បទពិសោធន៍ របស់អ្នកទាំងអស់នោះ អាចនឹងជួយលើកទឹកចិត្តដល់ជនរងគ្រោះផ្សេងៗទៀតឱ្យមានសេចក្តីក្លាហានមក បង្ហាញនូវបទពិសោធន៍។

NGO-CEDAW សង្ឃឹមថា របាយការណ៍នេះនឹងត្រួសត្រាយផ្លូវឱ្យឈានទៅរកការផ្លាស់ប្តូរដើម្បីឱ្យមាន សមភាពរវាងស្ត្រី និងបុរសជាលក្ខខណ្ឌចាំបាច់ ដើម្បីឱ្យមានការអភិវឌ្ឍសង្គមមួយប្រកបដោយស្ថេរភាព និងសុខដុមរមនា។

# បុព្វកថា

ការទទួលស្គាល់តួនាទីរបស់ស្ត្រី ជាភ្នាក់ងារដើម្បីឈានទៅរកការផ្លាស់ប្តូរក្នុងការអភិវឌ្ឍសង្គម គឺជាសមិទ្ធិផលដ៏យូរអង្វែងមួយរបស់ចលនាស្ត្រីអន្តរជាតិ។ ក្នុងគោលបំណងដើម្បីរក្សា និងធ្វើឲ្យរីកចំរើនថែមទៀតនូវចលនាអង្គការសហប្រជាជាតិបានបង្កើតឡើងនូវអនុសញ្ញាជាគោលយ៉ាងច្បាស់លាស់ ស្តីពីសិទ្ធិស្ត្រីគឺ: អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ ហៅកាត់ថា CEDAW ។

អនុសញ្ញានេះ ត្រូវបានព្រះរាជាណាចក្រកម្ពុជាផ្តល់សច្ចាប័ននៅឆ្នាំ១៩៩២ ដោយទទួលយកទាំងស្រុង ដែលមានន័យថា កម្ពុជាបានសន្យាចាប់ផ្តើមនូវដំណើរការដើម្បីធានានូវសមភាពរវាងបុរស និងស្ត្រី។ ការប្តេជ្ញាចិត្តនេះ តម្រូវឱ្យធ្វើការចាត់វិធានការផ្នែកច្បាប់ និងតាក់តែងគោលនយោបាយក៏ដូចជាគោលការណ៍ណែនាំនានាដើម្បីកាត់បន្ថយនូវគំលាតរវាងយេនឌ័រ និងការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទនៅកម្ពុជា។ ការប្តេជ្ញាចិត្តនេះ ក៏តម្រូវឱ្យកម្ពុជាដាក់ជូនទៅគណៈកម្មាធិការនៃអង្គការសហប្រជាជាតិទទួលបន្ទុក CEDAW នូវរបាយការណ៍ប្រចាំអាណត្តិស្តីពីដំណើរការត្រួតពិនិត្យ និងវាយតម្លៃការផ្សព្វផ្សាយ និងការអនុវត្តន៍ CEDAW នៅប្រទេសកម្ពុជាផងដែរ។ រហូតមកដល់ពេលនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ជូននូវរបាយការណ៍រួមមួយ គឺរបាយការណ៍លើកទី១ លើកទី២ និងលើកទី៣។ របាយការណ៍នេះត្រូវបានពិនិត្យនៅក្នុងសម័យប្រជុំទី៣៤ របស់គណៈកម្មាធិការនៃអង្គការសហប្រជាជាតិទទួលបន្ទុក CEDAW កាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៦។ លើសពីនេះទៅទៀត រាជរដ្ឋាភិបាលកម្ពុជាក៏បានសរសេររបាយការណ៍រួមមួយទៀតលើកទី៤ និងលើកទី៥ ដែលបានបញ្ចប់នៅខែវិច្ឆិកា ឆ្នាំ២០០៩ ហើយនៅមិនទាន់បានវាយតម្លៃដោយគណៈកម្មាធិការនៃអង្គការសហប្រជាជាតិទទួលបន្ទុក CEDAW នៅឡើយទេ។ របាយការណ៍ចុងក្រោយនេះ ត្រូវបានដាក់ជូនទៅគណៈកម្មាធិការនៃអង្គការសហប្រជាជាតិទទួលបន្ទុក CEDAW កាលពីខែកញ្ញា ឆ្នាំ២០១០ កន្លងទៅ។

នៅឆ្នាំ២០០៥ គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (NGO-CEDAW) និងគណៈកម្មាធិការស្ត្រីកម្ពុជា (CAMBOW) បានសរសេររបាយការណ៍របស់អង្គការមិនមែនរដ្ឋាភិបាល ស្តីពីការអនុវត្តន៍អនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (CEDAW) លើកទី៣ ដែលត្រូវបានដាក់ជូនជាលើកដំបូងទៅគណៈកម្មាធិការនៃអង្គការសហប្រជាជាតិទទួលបន្ទុក CEDAW។ NGO-CEDAW ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៥ បន្ទាប់ពីសកម្មជនស្ត្រីកម្ពុជាមួយចំនួនបានត្រឡប់មកពីការចូលរួមក្នុងសន្និសីទពិភពលោកស្តីពីស្ត្រីនៅទីក្រុងប៉េកាំង។ តួនាទីរបស់ NGO-CEDAW គឺដើម្បីត្រួតពិនិត្យ និងលើកស្ទួយការអនុវត្តន៍ CEDAW នៅកម្ពុជាព្រមទាំងចូលរួមក្នុងការតស៊ូមតិបន្ទាប់ពីបានចេញផ្សាយនូវរបាយការណ៍ស្រមោល។

ចាប់តាំងពីឆ្នាំ១៩៩២ រហូតមក កម្ពុជាបានដាក់ចេញនូវវិធានការគោលការណ៍នានាដើម្បីសម្រេចបាននូវសិទ្ធិផ្នែកច្បាប់ នយោបាយ និងសង្គម ដែលសំដៅកែលំអទាំងលក្ខខណ្ឌ និងស្ថានភាពស្ត្រីក្នុងសង្គមកម្ពុជា។ វិធានការទាំងនេះ ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍របស់រដ្ឋាភិបាល។ ក៏ប៉ុន្តែទោះបីជាមានការរីកចំរើនខ្លះក៏ដោយ ក៏នៅតែមានបញ្ហាជាច្រើនទៀតដែលត្រូវធ្វើដើម្បីឱ្យមានការផ្លាស់ប្តូរ។ ដូចដែលបាន

បញ្ជាក់នៅក្នុងបទអត្ថាធិប្បាយសន្និដ្ឋានរបស់គណៈកម្មាធិការនៃអង្គការសហប្រជាជាតិទទួលបន្ទុក CEDAW នៅក្នុងការពិនិត្យឡើងវិញនូវរបាយការណ៍របស់រដ្ឋាភិបាលប្រចាំឆ្នាំ២០០៦។ ទោះបីជាមានការផ្លាស់ប្តូរខ្លះៗ ក៏ដោយក៏គម្លាតរវាងបុរស និងស្ត្រីនៅតែឃ្លាតពីគ្នាឆ្ងាយដដែល ហើយគម្លាតទាំងនោះ ឃើញមាននៅក្នុងសូចនាករមួយចំនួនដូចជា ផ្នែកសុខភាព អក្ខរភាព ការចូលរួមក្នុងឆាកនយោបាយ និងការទទួលបាននូវធនធានសេដ្ឋកិច្ចជាដើម។ សមភាពយេនឌ័រនៅតែជាបញ្ហាប្រឈមដដែលនៅកម្ពុជា។

រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ និងនីតិកម្មនានា ដូចជាច្បាប់ពាក់ព័ន្ធវិស័យអប់រំឆ្នាំ២០០៧ បានកំណត់ពីការប្តេជាចិត្តរបស់រដ្ឋាភិបាលនៅក្នុងវិស័យច្បាប់ចំពោះសិទ្ធិកុមារ ដែលត្រូវមានប្រព័ន្ធអប់រំមួយប្រកបដោយគុណភាព។ ក្របខណ្ឌច្បាប់ត្រូវបានតាក់តែងឡើងដើម្បីស្វែងរកដំណោះស្រាយ ចំពោះបញ្ហាអនក្ខរភាពនៅក្នុងប្រទេស ជាពិសេសនៅក្នុងសហគមន៍ក្រីក្របំផុត ឬក្នុងចំណោមជនជាតិដើមភាគតិចព្រមទាំងក្នុងចំណោមជនពិការផងដែរ។

អាស្រ័យដោយសម្ពាធសង្គម និងភាពក្រីក្រ កុមារីភាគច្រើនពុំបានទទួលកំរិតនៃការអប់រំស្មើកុមារាទេ។ កង្វះការអប់រំនេះ បានរារាំងស្ត្រីមិនឱ្យចូលរួមក្នុងឆាកនយោបាយ ដោយស្ត្រីតែងតែខ្វះទំនុកចិត្តក្នុងការធ្វើការងារជាសាធារណៈ។ ការបាត់បង់ឱកាសសិក្សារបស់ស្ត្រីបែបនេះ ក៏ទំនងជាឧបសគ្គមួយសម្រាប់ស្ត្រីក្នុងការឈោងចាប់បាននូវតំណែងសំខាន់ៗក្នុងវិស័យឯកជនដែរ។

បច្ចុប្បន្ន ថ្វីត្បិតតែមានហេដ្ឋារចនាសម្ព័ន្ធនៅក្នុងរដ្ឋធម្មនុញ្ញដែលមានស្រាប់ហើយក៏ដោយក៏ភាពខុសគ្នារវាងច្បាប់ និងស្ថានភាពជាក់ស្តែងនៅតែជាឧបសគ្គមួយដ៏ចំបង។ ឧបសគ្គចំបងនេះ កើតឡើងដោយសារតែបរិបទនយោបាយសង្គមកម្ពុជា។ ការទទួលស្គាល់សិទ្ធិ និងសេរីភាពដែលចែងនៅក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ផ្សេងៗ ក៏ដូចជានៅក្នុងនីតិបុគ្គលពាក់ព័ន្ធនានា គឺពុំបានផ្តល់ប្រយោជន៍ដល់ស្ត្រី ដូចមានចែងក្នុងច្បាប់ទាំងនោះទេ។ បញ្ហានេះ គឺអាស្រ័យដោយការប្រតិបត្តិតាមក្រមសីលធម៌ និងការអនុវត្តន៍នានានៅក្នុងសង្គម ដូចជា «ច្បាប់ស្រី» ជាដើម ដែលបានចែងជាបញ្ញត្តិសម្រាប់ស្ត្រីទូទៅ។ បញ្ហានេះ បាននាំមកនូវអត្រាអនក្ខរភាពខ្ពស់ក្នុងចំណោមស្ត្រី ព្រមទាំងជាគំនាបដល់ចលនា និងឱកាសលើស្ត្រីថែមទៀតផង។

ជាលទ្ធផល ស្ត្រីកម្ពុជាគ្រប់លំដាប់ថ្នាក់ទាំងអស់ គឺងាយរងគ្រោះពីភាពក្រីក្រជាងបុរស។ ស្ត្រីមិនគ្រាន់តែមានប្រាក់ចំណូលទាបប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពុំសូវមានឱកាសទទួលបានវិស័យសេដ្ឋកិច្ចទៀតផងអាស្រ័យដោយឥរិយាបទរើសអើង ដែលគាបសង្កត់ដល់ឱកាសជម្រើសរបស់ស្ត្រី។

នេះគឺជាបញ្ហាធម្មតាទៅហើយ ដែលស្ត្រីមានការគ្រប់គ្រងតិចតួចលើវិស័យធនធាន ហើយជាពិសេសជាក់ស្តែង គឺស្ត្រីជនជាតិដើមភាគតិច និងស្ត្រីភាគតិចផ្សេងទៀត ដូចជាស្ត្រីពិការជាដើម។ ដូចនៅក្នុងប្រទេសភាគច្រើននៅអាស៊ីអាគ្នេយ៍ដែរ កម្ពុជាក៏នៅមានអត្រាស្ត្រីចូលរួមក្នុងឆាកនយោបាយទាបជាងប្រទេសនានានៅលើពិភពលោកដែរ (អង្គការសហប្រជាជាតិឆ្នាំ២០១០)។ ដើម្បីធានាឱ្យមានការបន្តការរីកចំរើនសង្គមថែមទៀតចំណុចសំខាន់យ៉ាងច្បាស់សម្រាប់កម្ពុជា គឺការធ្វើគំរូអភិវឌ្ឍន៍ដែលធានាបាននូវសមភាពយេនឌ័រ។

ការផ្តល់អំណាចខាងសេដ្ឋកិច្ច ព្រមទាំងការអភិវឌ្ឍន៍ផ្នែកសង្គម និងនយោបាយដល់ស្ត្រី គឺជាភាពចាំបាច់ក្នុងការកែលំអនូវជីវិតរបស់ប្រជាពលរដ្ឋ ដែលជាប់គាំងនៅក្នុងវដ្តនៃភាពក្រីក្រ និងការមិនឲ្យចូលរួមក្នុងសង្គម។ ការផ្តល់ឱកាសក្នុងវិស័យសេដ្ឋកិច្ច និងអប់រំស្ត្រី គឺជាកត្តាមួយយ៉ាងសំខាន់រួមជាមួយការជួយឧបត្ថម្ភផ្សេងៗទៀត ដែលចាំបាច់ដើម្បីជំនះបានលើភាពក្រីក្រ និងការមិនឲ្យចូលរួមក្នុងសង្គម។ ជំហ៊ានដំបូងនៅក្នុងដំណើរការនេះ គឺត្រូវយល់អំពីជំហររបស់កម្ពុជាជាមុនសិន ថាតើកម្ពុជាកំពុងឈរនៅថ្នាក់ណាក្នុងការលុបបំបាត់ការរើសអើងផ្នែកយេនឌ័រ។ ការយល់ដូច្នេះ គឺជាយុទ្ធសាស្ត្រដែលបើកផ្លូវឱ្យយើងដើម្បីធ្វើការងារទៅអនាគត នេះហើយដែលជាគោលបំណងសំខាន់របស់របាយការណ៍នេះ។

របាយការណ៍នេះ ផ្តោតការយកចិត្តទុកដាក់ចំពោះការវាយតម្លៃលើការផ្សព្វផ្សាយ និងការអនុវត្តន៍អនុសញ្ញា CEDAW ចាប់តាំងពីរាជរដ្ឋាភិបាលបានចេញផ្សាយនូវរបាយការណ៍ឆ្នាំ២០០៣ កន្លងមក។

របាយការណ៍បច្ចុប្បន្ននេះ គឺជារបាយការណ៍តាមដានដែលបានលើកឡើងក្នុងការវាយតម្លៃរបស់អនុគណៈកម្មាធិការរបស់ NGO-CEDAW ដែលចែកចេញជាផ្នែកផ្សេងៗ ដែលមានចែងនៅក្នុងអនុសញ្ញា។ ការវាយតម្លៃនេះ ត្រូវបានបង្កើតឡើងកាលពី៤ឆ្នាំកន្លងទៅព្រមទាំងបានដាក់បញ្ចូលនូវអនុសាសន៍នានា ដែលចេញផ្សាយដោយគណៈកម្មាធិការនៃអង្គការសហប្រជាជាតិទទួលបន្ទុក CEDAW នៅឆ្នាំ២០០៦។ ការវាយតម្លៃមានគោលបំណង ដើម្បីដោះស្រាយបញ្ហាគម្លាតរវាងច្បាប់ និងស្ថានភាពពិតជាក់ស្តែង ហើយធ្វើការវាយតម្លៃដ៏ត្រឹមត្រូវមួយអំពីស្ថានភាពបច្ចុប្បន្ននៃបញ្ហាទាំងនេះ។ នៅក្នុងរបាយការណ៍នេះ មានការវិភាគ ៣ ផ្នែកសំខាន់ៗផ្សេងៗគ្នា:

១) ផ្នែករចនាសម្ព័ន្ធ: បញ្ហាសេដ្ឋកិច្ចសង្គម ដូចជាការងារលំនៅឋាន សុខភាព ការអប់រំ និងការរៀប ចំក្រុមគ្រួសាររវាងស្ត្រី និងបុរសជាដើម។

២) ផ្នែករចនាសម្ព័ន្ធច្បាប់ និងនយោបាយ: សិទ្ធិ និងករណីយកិច្ចសម្រាប់ស្ត្រី និងបុរស ដើម្បីធានា នូវសមភាពចំពោះមុខច្បាប់ដែលមាន: ការទទួលស្គាល់ជាពលរដ្ឋ សិទ្ធិស្មើភាពគ្នា និងការធានា នូវការប្រព្រឹត្តិស្មើគ្នាក្នុងសង្គម។

៣) ផ្នែកសីលធម៌ និងផ្នែកដែលនៅតែប្រើប្រាស់: ចំណេះដឹង ការទទួលបាននូវសិទ្ធិស្មើភាព និងសេរីភាពសម្រាប់ស្ត្រីកម្ពុជា។

នេះគឺជាការទទួលខុសត្រូវរបស់រដ្ឋាភិបាលកម្ពុជា ដែលអនុញ្ញាតឱ្យមានការផ្លាស់ប្តូរក្នុងសង្គម។ របាយការណ៍នេះ មានគោលបំណងដើម្បីផ្តល់នូវការវិភាគទស្សនៈអំពីការអនុវត្តន៍អនុសញ្ញា CEDAW និងការទទួលបាននូវសិទ្ធិដែលមានចែងនៅក្នុង CEDAW របស់ស្ត្រីកម្ពុជា។

# ជំពូក១. បរិបទប្រទេសជាតិ

## ១. ស្ថានភាព

ព្រះរាជាណាចក្រកម្ពុជាមានទីតាំងស្ថិតនៅអនុតំបន់អាស៊ី ហៅថា អាស៊ីអាគ្នេយ៍។ ប្រទេសនេះមាន ផ្ទៃក្រឡាទំហំ ១៨១,០៣៥ គីឡូម៉ែត្រក្រឡា មានព្រំប្រទល់ខាងលិចជាប់ជាមួយប្រទេសថៃ ខាងជើងជាប់ជាមួយប្រទេសឡាវ ហើយខាងកើតជាប់ជាមួយប្រទេសវៀតណាម ខាងត្បូងជាប់ជាមួយប្រទេសវៀតណាម និងឈូងសមុទ្រថៃ។ កម្ពុជាត្រូវបានបែងចែកជា១៩៣ក្រុង/ស្រុក/ខណ្ឌ ក្រុងចំនួន២៦ ស្រុកចំនួន១៥៩ និងខណ្ឌចំនួន០៨។ ក្រុង ស្រុក ខណ្ឌ ចែកចេញជា១,៦២១ ឃុំ/សង្កាត់ (១,៤១៧ឃុំ និង២០៤សង្កាត់) ដែលមាន១៤,០៧៣ភូមិ។ យោងតាមទិន្នន័យផ្លូវការបានប៉ាន់ប្រមាណថា អត្រាកំណើនប្រជាពលរដ្ឋបានកើនឡើងជាង ២លាននាក់ ចាប់តាំងពីឆ្នាំ១៩៩៨ ដែលសរុបជិត១៤,៥០០,០០០នាក់ (ដប់បួនលានប្រាំសែននាក់) យោងតាមជំរឿនឆ្នាំ២០០៨ ឃើញថាអត្រាកំណើនប្រចាំឆ្នាំកើនដល់ទៅ ២.៧៧% ។ ប្រជាពលរដ្ឋភាគច្រើន (៩០%) ជាពូជអំបូរខ្មែរ ដែលមានដើមកំណើតចេញពីអំបូរម៉ាឡេ ហើយក្រៅពីនោះ គឺជនជាតិឡាវ វៀតណាម ចាម និងជនជាតិដើមភាគតិច។ ភាសាផ្លូវការ គឺភាសាខ្មែរ ដែលមានមនុស្សប្រហែល៩០% និយាយភាសានេះ។ សាសនាដែលប្រជាពលរដ្ឋគោរព គឺព្រះពុទ្ធសាសនា (៩៦%) បន្ទាប់មកមានសាសនា អ៊ីស្លាម (៣%) និងសាសនាគ្រិស្ត (២%) ។

តាមលក្ខណៈប្រជាសាស្ត្រ គេសង្កេតឃើញមានបញ្ហាធំៗពីរ គឺផ្លាស់ប្តូរទីលំនៅនៅក្នុងស្រុក។ ទី១ គឺប្រជាពលរដ្ឋផ្លាស់ប្តូរពីជនបទមកទីក្រុង ពាក់ព័ន្ធទៅនឹងភាពខ្សត់ខ្សោយផ្នែកកសិកម្មនៅជនបទ ដោយការបាត់បង់សិទ្ធិក្នុងការប្រើប្រាស់ដីធ្លី និងក្តីសង្ឃឹមអំពីភាពរុងរឿងនៅក្នុងបរិយាកាសឧស្សាហកម្មដែលកំពុងតែអភិវឌ្ឍន៍។ ទី២ គឺការតាំងទីលំនៅថ្មីនៅក្នុងតំបន់ដែលពីដើមជាកន្លែងជនជាតិដើមខ្មែរភាគតិចអាស្រ័យដោយមានការកាប់បំផ្លាញព្រៃឈើនៅក្នុងតំបន់ដ៏ធំល្វឹងល្វើយ ការធ្វើអាជីវកម្មធនធានធម្មជាតិ និងបញ្ហាកម្មសិទ្ធិលើដីធ្លី។ បាតុភាពទាំងនេះ ជាបញ្ហាធំនៅក្នុងខេត្តមួយចំនួនដូចជា ស្ទឹងត្រែង រតនៈគីរី និងមណ្ឌលគីរី ដែលប្រជាពលរដ្ឋខ្មែរមានការរីកចំរើនច្រើននៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ហើយបច្ចុប្បន្នប្រជាពលរដ្ឋខ្មែរមានចំនួនច្រើនជាងសហគមន៍ជនជាតិដើម។

ចាប់តាំងពីមានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសនាឆ្នាំ១៩៩១ កម្ពុជាមានការផ្លាស់ប្តូរយ៉ាងលឿន និងមានការប្រសើរឡើងនូវសូចនាករផ្នែកសេដ្ឋកិច្ចសង្គម។ ប៉ុន្តែ ធៀបទៅនឹងប្រទេសនានានៅអាស៊ីអាគ្នេយ៍ កម្ពុជាក៏នៅតែមានអត្រាភាពក្រីក្រ ជំងឺអេដស៍ ប្រជាពលរដ្ឋដែលពុំទាន់មានអគ្គិសនីប្រើប្រាស់ គ្មានទឹកស្អាត ខ្វះការអប់រំ និងអត្រារើសអើងលើស្ត្រីភេទជាដើមនៅខ្ពស់នៅឡើយ។ គេបានប៉ាន់ស្មានថា ប្រជាពលរដ្ឋប្រហែល៧៧% រស់នៅក្នុងភាពក្រីក្រក្នុងនោះមាន៣៤% រស់នៅក្នុងភាពក្រីក្របំផុត។

ប្រជាពលរដ្ឋកម្ពុជាភាគច្រើនរស់នៅតាមទីជនបទ។ អត្រាមរណភាពរបស់កុមារ គឺមានកុមារស្លាប់៨២នាក់ ក្នុងចំណោមកុមារកើត ១,០០០នាក់[១] ហើយអត្រាមរណៈមាតា គឺស្លាប់ ៤៦១នាក់ក្នុងចំណោម

[១] របាយការណ៍ថ្នាក់ជាតិរបស់រដ្ឋាភិបាលស្តីពី CEDAW ខែឧសភា ឆ្នាំ២០១០ ។

១០០,០០០នាក់ ដែលបានសម្រាលកូន[២]។ ស្ត្រីប្រហែល ៨៥%សម្រាលកូននៅផ្ទះ។

អំពីបញ្ហាយេនឌ័រ កម្ពុជាគឺជាប្រទេសមួយដែលមានអត្រាវើសអើងផ្នែកយេនឌ័រខ្ពស់ បញ្ហានេះត្រូវ បានច្រានបន្ថែមដោយវប្បធម៌ និងប្រពៃណីខ្មែរដែលហាក់ដូចជាដាក់ស្ត្រីឱ្យនៅទាបជាងបុរស។

បញ្ហាចំបងមួយដែលស្ត្រីខ្មែរប្រឈមមុខខ្លាំងជាងគេបំផុត គឺអំពើហិង្សាក្នុងគ្រួសារ។ តាមតួលេខបានឱ្យដឹងថាស្ត្រីកម្ពុជា ២៣% បានរងគ្រោះដោយសារអំពើហិង្សា ដែលទាក់ទងនឹងយេនឌ័រ។ ការកេងប្រវ័ញ្ចផ្លូវភេទពាក់ព័ន្ធជាមួយនឹងអំពើជួញដូរមនុស្ស គឺជាបញ្ហាធ្ងន់ធ្ងរមួយទៀត ដែលស្ត្រីនៅកម្ពុជាកំពុងប្រឈម។

នៅកម្ពុជា ប្រជាពលរដ្ឋចំនួន ១៨.៥% មានកំរិតអាយុរស់នៅមធ្យមក្រោម៤០ឆ្នាំ ហើយពលរដ្ឋចំនួន ៣៥% ខ្វះប្រព័ន្ធទឹកដែលអាចទទួលទានបាន ហើយនេះជាភាគរយដែលកើនឡើងដល់ ៤០-៤៥% នៅក្នុងខេត្តមួយចំនួន ដូចជាមណ្ឌលគីរី និងរតនៈគីរីជាដើម។ អត្រាអនក្ខរកម្មក្នុងចំណោមមនុស្សពេញវ័យគឺ ២៣.៧% រីឯកុមារវិញមានចំនួន៣៦% ដែលទទួលអាហារ (អាហារូបត្ថម្ភ) មិនគ្រប់គ្រាន់។

## ១.១ សិទ្ធិមនុស្ស

កម្ពុជាបានផ្តល់សច្ចាប័នលើសន្ធិសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិមនុស្សសំខាន់ៗទាំងអស់ ព្រមទាំងមានចែងនៅក្នុងរដ្ឋធម្មនុញ្ញផងដែរ។ ក៏ប៉ុន្តែការប្រើប្រាស់ និងការអនុវត្តន៍នូវសន្ធិសញ្ញាទាំងនេះ នៅតែមានការយឺតយ៉ាវ។ កង្វះខាតអព្យាក្រឹតភាព និងឯករាជ្យភាពព្រមទាំងអំពើពុករលួយនៅតែមាននៅក្នុងស្ថាប័នរដ្ឋ។ និទណ្ឌភាព និងកង្វះជំនួយផ្នែកច្បាប់សម្រាប់ជនក្រីក្រ នៅតែធ្វើឱ្យមានការខ្វាយខ្វល់យ៉ាងខ្លាំង។ ការទទួលបានព័ត៌មានដែលផ្សព្វផ្សាយ ដោយអាជ្ញាធរសាធារណៈនៅមានកំរិត ដូចជាការទទួលបានផ្នែកច្បាប់ និងបទបញ្ញត្តិនានា ពាក់ព័ន្ធនឹងសិទ្ធិប្រជាពលរដ្ឋ។



ឆ្នាំ២០០៩ និងឆ្នាំ២០១០ គឺជាឆ្នាំ ដែលកត់សម្គាល់ឃើញមានការកើនឡើងនូវគំនាបមកលើសេរីភាពខាងការបញ្ចេញមតិ ជាពិសេសគឺចំពោះអ្នកនយោបាយ និងតំណាងអង្គការសង្គមស៊ីវិលនានា ក្នុងជំហរិះគន់ដល់រដ្ឋាភិបាល។ សេរីភាពក្នុងការជួបជុំគ្នា (តាមរយៈការតវ៉ាដោយសន្តិវិធី) ត្រូវបានដាក់ក្នុងព្រំដែនមួយដែលចង្អៀត ជាពិសេសពាក់ព័ន្ធនឹងជនរងគ្រោះដោយការបណ្តេញចេញ ដោយបង្ខំដែល ជាការអនុវត្តន៍មួយកើតឡើងជាការធម្មតា។ ការកំ

[២] របាយការណ៍ដូចខាងលើ។

រិតសិទ្ធិនៅតែមានឃើញនៅថ្នាក់ភូមិ និងឃុំ ដើម្បីបំបែកបាតុករ និងដើម្បីរារាំងកុំឱ្យមានចលនាមហាជនទាមទារនៅក្នុងរាជធានី។

បច្ចុប្បន្នការអនុវត្តន៍នូវការបណ្តេញចេញដោយបង្ខំ និងការរំលោភយកដីធ្លី គឺបានក្លាយជាបញ្ហាចម្រូងចម្រាស់ជាងគេបំផុតនៅកម្ពុជា។ មានទំនាស់ដែលកើតឡើងថ្មីៗពីបញ្ហាដីធ្លី ជាពិសេសពាក់ព័ន្ធជាមួយនឹងបញ្ហាដីសម្បទានដែលផ្តល់ឱ្យក្រុមហ៊ុនឯកជនធ្វើកិច្ចសន្យាសម្រាប់កសិ-ឧស្សាហកម្ម និងក្នុងគោលបំណងសេដ្ឋកិច្ចនានា ហើយដូចករណីនៅរាជធានីភ្នំពេញ គឺកើតឡើងដោយសារការពង្រីកនូវអាជីវ-កម្មរបស់ក្រុមហ៊ុនឯកជន។ ក្នុងកំឡុងឆ្នាំ២០០៩ យ៉ាងតិចមានការធ្វើកូដកម្ម និងបាតុកម្មចំនួន ១៥៦ដងនៅកម្ពុជាក្នុងចំណោមនោះ មាន៧១ដងទាក់ទងជាមួយបញ្ហាដីធ្លី ៣៧ដងទាក់ទងជាមួយបញ្ហាសិទ្ធិ និងលក្ខខណ្ឌការងារនៅតាមបណ្តារោងចក្រនានា ហើយ ៤៨ដងអំពីបញ្ហាផ្សេងៗ។ សរុបមានចំនួន ៣៤ករណីត្រូវបានបង្ក្រាបដោយអាជ្ញាធរ។ បញ្ហាដីធ្លី និងផលប៉ះពាល់មកលើជីវភាពរស់នៅរបស់ជនជាតិដើមភាគតិចគឺជាចំណុចមួយផ្សេងទៀត។

ការគំរាមកំហែងមកលើអ្នកការពារសិទ្ធិមនុស្ស នៅតែជាបញ្ហាកង្វល់ចំបងដដែលនៅកម្ពុជា។ នៅក្នុងឆ្នាំ២០០៩ មានអ្នកការពារសិទ្ធិមនុស្សចំនួន ២៣៥នាក់ (ដែលសុទ្ធតែជាអ្នកធ្វើយុទ្ធនាការទាមទារសិទ្ធិដីធ្លី) ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ហើយ ១៤៧នាក់ត្រូវបានចាប់ខ្លួន។ នៅក្នុងឆ្នាំ២០០៨ មានប្រជា-ពលរដ្ឋចំនួន ១៦៨នាក់ត្រូវបានចោទប្រកាន់[៣]។ ចំពោះបញ្ហាសិទ្ធិបញ្ចេញមតិនៅក្នុងប៉ុន្មានឆ្នាំថ្មីៗកន្លងទៅនេះ គេបានកត់សម្គាល់ឃើញមានការកើនឡើងនូវចំនួនសារព័ត៌មាន និងចំនួនវិទ្យុថែមទៀត ព្រមទាំងចំនួនស្ថានីយ៍ផ្សាយទូរទស្សន៍ផងដែរ។ ប៉ុន្តែ សេរីភាពក្នុងការរិះគន់នៅតែមានកំរិតនៅឡើយ ដោយអាជ្ញាធរនៅតែប្រើប្រាស់ច្បាប់ស្តីពីការផ្សាយព័ត៌មានមិនពិត និងបរិហារកេរ្តិ៍ដើម្បីរារាំងដល់សេរីភាពខាងការបញ្ចេញមតិ ដែលត្រូវបានធានានៅក្នុងរដ្ឋធម្មនុញ្ញ (ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួនឆ្នាំ២០០៩)។ ក្រមនីតិវិធីព្រហ្មទណ្ឌថ្មី ដែលត្រូវបានអនុម័តយល់ព្រមដោយរដ្ឋសភា កាលពីឆ្នាំ២០០៩ កន្លងទៅ ហើយចូលជាធរមាននៅខែធ្នូ ឆ្នាំ២០១០ មានចែងនូវបទបញ្ញត្តិមួយចំនួន ដែលអាចនាំឱ្យមានការផ្តន្ទាទោសអ្នកសារព័ត៌មានដាក់ពន្ធនាគារ។

នៅក្នុងឆ្នាំ២០០៧ កម្ពុជាបានផ្តល់សច្ចាប័នលើពិធីសារបន្ថែមស្តីពីអនុសញ្ញាប្រឆាំងនឹងទារុណកម្ម និងការផ្តន្ទាទោស ឬការប្រព្រឹត្តទាំងឡាយណាដែលឃោរឃៅ អមនុស្សធម៌ ឬដែលនាំអោយបាត់បង់តម្លៃជាមនុស្ស។ នេះគឺជាសញ្ញាវិជ្ជមានមួយ ដែលរដ្ឋាភិបាលមានចេតនាក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើទារុណកម្ម។ ប៉ុន្តែ ផ្ទុយទៅវិញ អង្គការជាច្រើនបានកត់សម្គាល់ឃើញថា កម្ពុជានៅតែខ្វះយន្តការប្រកបដោយប្រសិទ្ធិភាព និងឯករាជ្យដើម្បីស៊ើបអង្កេតលើអំពើដែលចោទគ្មានភស្តុតាង "ការចោទប្រកាន់ដោយគ្មានភស្តុ-តាងនូវបទទារុណកម្ម"។

[៣] តាមរបាយការណ៍សិទ្ធិមនុស្ស សមាគមអាដហុក ឆ្នាំ២០០៩។

## ១.២ ធនធានធម្មជាតិ

ប្រជាពលរដ្ឋកម្ពុជាពឹងផ្អែកយ៉ាងខ្លាំងទៅលើវិស័យកសិកម្ម នេសាទ និងធនធានធម្មជាតិ ដែលជាប្រព័ន្ធអេកូឡូស៊ី ប្រមូលផ្តុំភាគច្រើននៅក្នុងបឹងទន្លេសាប។ ក៏ប៉ុន្តែការគ្រប់គ្រងបរិស្ថាននៅមានភាពទន់ខ្សោយនៅឡើយ ថែមទាំងខ្វះខាតក្របខណ្ឌការពារតាមច្បាប់។ មានការខ្វះខាតព័ត៌មាន និងគោលការណ៍ណែនាំ ឬខ្វះការអនុវត្តន៍សម្រាប់គ្រប់គ្រងបញ្ហាសំខាន់ៗមួយចំនួនដូចជា ការកាប់ឈើខុសច្បាប់ និងការប្រើប្រាស់ធនធានទឹកជាដើម ។ សមត្ថភាពគ្រប់គ្រងនៅថ្នាក់ខេត្តនៅមានកំរិតនៅឡើយ ហើយការសម្រេចចិត្តគ្រប់គ្រងបរិស្ថានសំខាន់ៗត្រូវបានសម្រេចនៅថ្នាក់ជាតិ។

ការគ្រប់គ្រងដីធ្លីក៏នៅតែជាបញ្ហាធំនៅឡើយ។ ថ្មីៗនេះ រដ្ឋាភិបាលបានទទួលស្គាល់ការលំបាកក្នុងការប្រឈមជាមួយគោលនយោបាយគ្រប់គ្រងបរិស្ថាន: ១. ការថយចុះចំនួនព្រៃឈើបានធ្វើឱ្យជីវចម្រុះនានាមានការថយចុះ ហើយកើនឡើងនូវការសឹករិចរិល និងកករល្បាក់ចុះទៅបាតទន្លេធ្វើឱ្យរាក់ទៅៗ ព្រមទាំងកើនឡើងទឹកជំនន់ផង ២. ទឹកស្អុយដែលមិនធ្វើប្រព្រឹត្តិកម្ម ៣. ប្រព័ន្ធស្រោចស្រពដែលគ្មាននិរន្តរភាព ៤. ការបាត់បង់ធនធាននៅតាមឆ្នេរសមុទ្រ និងនៅឆ្ងាយពីមាត់សមុទ្រ និង៥. ភាពទន់ខ្សោយក្នុងកិច្ចការពារជីវចម្រុះ និងតំបន់ការពារនានា។

បញ្ហាបរិស្ថានធំៗពាក់ព័ន្ធជាមួយផលប៉ះពាល់ដោយដីសម្បទានផ្តល់ឱ្យក្រុមហ៊ុនឯកជន ដើម្បីធ្វើចម្ការដំណាំឧស្សាហកម្មធំៗ។ នេះ គឺជាបញ្ហាចម្រូងចម្រាស់យ៉ាងខ្លាំងនៅកម្ពុជា ដោយសារប្រជាពលរដ្ឋណា ដែលពឹងផ្អែកលើព្រៃឈើត្រូវទទួលរងការប៉ះពាល់ក្នុងការបាត់បង់ប្រភពសំខាន់នៃជីវភាពរបស់អ្នកទាំងនោះ។ នៅឆ្នាំ២០០២ ទោះបីជាមានការផ្អាកកាប់ឈើខុសច្បាប់ដែលមានទ្រង់ទ្រាយធំយ៉ាងណាក៏ដោយក៏នៅតែមានការកាប់ខុសច្បាប់នៅតែបន្ត ដែលមិនអាចគ្រប់គ្រងបានឥតឈប់ឈរក្រោមរូបភាពជាប្រព័ន្ធផ្តល់ដីសម្បទាន។ ដីសម្បទានសេដ្ឋកិច្ចដល់គម្រោងកសិ-ឧស្សាហកម្មធំៗ ច្រើនតែបង្កឱ្យមានការខូចខាតដល់និរន្តរភាពរបស់ប្រព័ន្ធអេកូបរិស្ថាន។

ចំពោះដីរបស់ជនជាតិដើម ដែលថ្មីៗនេះត្រូវបានធ្វើសម្បទានឱ្យក្រុមហ៊ុននានា សហគមន៍ជនជាតិដើម ដែលរស់នៅនៅក្នុងតំបន់នោះមានសម្លេងតិចតួចបំផុត ហើយបំណងមិនរំលោភយកដីក៏មានតិចតួចដែរ។ ការបំពុលបរិស្ថាន និងការខូចខាតពីការជីកយករ៉ែ និងការបំផ្លាញព្រៃឈើយ៉ាងសន្ធឹកសន្ធាប់លើផ្ទៃដីធំល្វឹងល្វើយ ដែលជាតំរូវការសម្រាប់សាងសង់សណ្ឋាគារ ទីលានវាយកូនគោល និងតំបន់កំសាន្តផ្សេងៗទៀតសម្រាប់ទេសចរណ៍ គឺពិតជាបានជះឥទ្ធិពលអវិជ្ជមានមកលើសហគមន៍ជនជាតិដើមភាគតិច។

ក្នុងរយៈពេល ១០ឆ្នាំកន្លងទៅនេះ មានសេចក្តីរាយការណ៍ជាច្រើនអំពីបញ្ហាធ្ងន់ធ្ងរកើតចេញមកពីការកសាងទំនប់វារីអគ្គីសនីកាលពីទសវត្សរ៍ឆ្នាំ១៩៩០ នៅក្នុងទន្លេសេសានក្នុងប្រទេសវៀតណាម ដែលហូរកាត់តាមខេត្តរតនៈគីរី និងខេត្តស្ទឹងត្រែង នៅភូមិភាគឦសានប្រទេសកម្ពុជា ។ ទំនប់នេះ បានបណ្តាលឱ្យមនុស្សស្លាប់ដោយសារទឹកជំនន់ កម្ពស់ទឹកទន្លេមិនទៀងទាត់ ការបំពុលគុណភាពទឹក កំណើនបញ្ហាសុខភាព និងការបាត់បង់ត្រី ព្រមទាំងជីវចម្រុះនៅក្នុងទន្លេថែមទៀតផង។ ទំនប់នេះនៅតែបន្តការគំរាមកំហែងមកលើជីវភាព និងជីវិតមនុស្សដែលអាស្រ័យផលពីទន្លេនោះ។ ទោះបីជាមានបញ្ហាបែបនេះក៏ដោយក៏រដ្ឋាភិបាលកម្ពុជាបានប្រកាសកាលពីឆ្នាំមុនថា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយរដ្ឋាភិបាលវៀត

ណាមដើម្បីកសាងទំនប់វារីអគ្គិសនីចំនួនពីរទៀតនៅតាមដងទន្លេសេសាន និងស្រែពក ក្នុងទឹកដីកម្ពុជា។ មានការព្រួយបារម្ភយ៉ាងខ្លាំងអំពីការអភិវឌ្ឍន៍ផ្នែកឧស្សាហកម្ម ដែលគាំទ្រដល់ការកសាងឧស្សាហកម្មអគ្គិសនីនឹងបង្កឱ្យមានផលប៉ះពាល់ជាអវិជ្ជមានយ៉ាងច្រើន និងយូរអង្វែងមកលើជីវភាពរបស់ជនជាតិដើមភាគតិច។

## ១.៣ ក្រុមជនជាតិដើមភាគតិច

នៅកម្ពុជាមានក្រុមជនជាតិដើមភាគតិចចំនួន ១៦ ក្រុមផ្សេងៗគ្នា ដែលភាគច្រើនរស់នៅខេត្តភាគឦសាន្ត ហើយក្រុមទាំងនោះមានដូចជា ទំពួន ចារ៉ាយ ក្រឹង ព្រៅ កាវែត ភ្នង កាចក់ ព្រៅ ស្អូច ធិចខុង ធួនក្រូល មិល គួយ សួយ និងស្ទៀងជាដើម។ ប្រជាពលរដ្ឋទាំងនេះ កំពុងជួបការលំបាកក្នុងការថែរក្សាវប្បធម៌ប្រពៃណីរបស់អ្នកទាំងនេះក្នុងសម័យអភិវឌ្ឍន៍បច្ចុប្បន្ន។ កង្វះចំណេះដឹងផ្នែកភាសាខ្មែរក្នុងចំណោមជនជាតិភាគតិចទាំងនោះជាឧបសគ្គមួយសម្រាប់អ្នកមួយចំនួន ក្នុងការធ្វើសមាហរណកម្មសេដ្ឋកិច្ច។ បញ្ហាសុខភាព និងស្ថានភាពរស់នៅរបស់សហគមន៍ទាំងនេះ នៅមានការអន់ថយ និងជាបញ្ហាចោទនៅឡើយដោយសារជាតំបន់ដាច់ស្រយាល និងការបាត់បង់នូវសិទ្ធិគ្រប់គ្រងលើដីធ្លីរបស់អ្នកទាំងនោះ។

ជនជាតិដើមភាគតិចជាច្រើន បានប្រកបរបរចិញ្ចឹមជីវិតដោយការងារកសិកម្ម ហើយភាគច្រើនជាកសិកម្មជាទំនៀមទំលាប់នៃការដាំដុះវិលជុំ (កាប់ហើយដុត)។ ការប្រើប្រាស់ថវិកានៅមានកំរិត តែផ្ទុយទៅវិញអ្នកទាំងនោះមានការដោះដូររវាងទំនិញនឹងទំនិញ គឺជាវិធីទូទៅទៅវិញ។ ក្រុមជនជាតិដើមភាគតិចច្រើនតែទៅផ្សារម្តងប៉ុណ្ណោះក្នុងមួយឆ្នាំ ឬនៅពេលរបស់របរដែលស្តុកទុកសម្រាប់ប្រើប្រាស់ត្រូវបានអស់ទៅហើយ ។ អ្នកទាំងនោះ មិនសូវចេះលក់ផលិតផលនៅក្នុងសហគមន៍នោះទេ។ ចំណូលជាមធ្យមសម្រាប់មនុស្សម្នាក់ក្នុង ១ខែ ប្រហែល ៥ ដុល្លារសហរដ្ឋអាមេរិក។

បញ្ហាដ៏ធំមួយប៉ះពាល់ដល់សិទ្ធិរបស់សហគមន៍ជនជាតិដើម គឺការចុះបញ្ជីដីធ្លី។ ដំណើរការនៃការចុះបញ្ជីដីធ្លីនេះ ត្រូវបានកែសម្រួលសារឡើងវិញជាច្រើនដងក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗកន្លងទៅនេះ (ការកែទម្រង់ថ្មីបំផុត គឺនៅឆ្នាំ២០០៩) ហើយដំណើរការនៅតែយឺតទំនងដូចជាមិនសូវយកចិត្តទុកដាក់ដល់តំរូវការរបស់ប្រជាពលរដ្ឋក្រីក្រ និងប្រជាពលរដ្ឋងាយរងគ្រោះ។

ចំណែកការចុះបញ្ជីដីធ្លីរួមគ្នារបស់សហគមន៍ជនជាតិដើម ច្បាប់ភូមិបាលឆ្នាំ២០០១ បានទទួលស្គាល់នូវសិទ្ធិដីធ្លីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ហើយយុទ្ធសាស្ត្របណ្តោះអាសន្ននៃក្របខណ្ឌគោលនយោបាយដីធ្លីឆ្នាំ២០០២ បានចែងថា ក្រុមជនជាតិដើមភាគតិចនឹងត្រូវបានធានាដល់សិទ្ធិជនជាតិដើមចំពោះដីធ្លី។ ប៉ុន្តែមកដល់ចុងឆ្នាំ២០០៩ ដំណើរការចុះបញ្ជីដីធ្លីនេះត្រូវបានអនុវត្តនៅក្នុងសហគមន៍ចំនួន៣ តែប៉ុណ្ណោះ អង្គការមួយចំនួនដោយមានការជួយឧបត្ថម្ភពីសហគមន៍អន្តរជាតិបានព្យាយាមជួយផ្នែកព័ត៌មានចាំបាច់នានា និងជំនាញផ្នែកច្បាប់ដល់ជនជាតិដើមក្នុងដំណើរការចុះបញ្ជីដីធ្លីនេះ។ ក៏ប៉ុន្តែរហូតមកដល់ពេលនេះក៏នៅពុំទាន់ទទួលបានជោគជ័យនៅឡើយដែរ។

បញ្ហាមួយទៀតដែលប៉ះពាល់ដល់សហគមន៍ជនជាតិដើមធ្ងន់ធ្ងរដែរនោះ គឺច្បាប់ស្តីពីដីសម្បទានសេដ្ឋកិច្ច។ រាជរដ្ឋាភិបាលបានផ្តល់ដីសម្បទានសេដ្ឋកិច្ចតាំងពីទសវត្សរ៍ឆ្នាំ១៩៩០ ជាដីដែលមានទំហំរាប់

រយពាន់ហិកតា។ គោលបំណងផ្លូវការរបស់គោលនយោបាយនេះ គឺដើម្បីលើកកម្ពស់ផលិតផលពាណិជ្ជកម្មផ្សេងៗ ដូចជា ស្រូវ ឈើម៉ៃសាក់ ដើមប្រេងខ្យល់ ដូងប្រេង ពោត អំពៅ ដំឡូងមី កៅស៊ូ ស្វាយចន្ទី ល្ហុង ខ្វង និងសណ្តែកជាដើម។ គោលបំណងនេះក៏ដើម្បីបង្កើនចំណូលពន្ធដារផងដែរ និងចំណូលពីការជួលដីសម្រាប់រដ្ឋ។ យោងតាមក្រុមអ្នកតាមដានបានបង្ហាញឱ្យឃើញថា ជាការពិតការធ្វើបែបនេះ គឺបានផលចំណេញតែក្រុមហ៊ុនធំៗប៉ុណ្ណោះ ទាំងក្រុមហ៊ុនជាតិ និងអន្តរជាតិ។ ក្រុមអ្នកតាមដាននេះក៏លើកឡើងផងដែរថា គោលនយោបាយនេះបានជួយបង្កើនកម្រិតអំពើពុករលួយនៅក្នុងប្រទេស។



លទ្ធផលមួយក្នុងចំណោមលទ្ធផលទាំងឡាយរបស់គោលនយោបាយនេះ គឺការបង្ខំឱ្យប្រជាពលរដ្ឋចាកចេញពីដី ជាពិសេសក្រុមពលរដ្ឋដែលត្រូវគេបណ្តេញចេញ និងក្រុមទន់ខ្សោយដែលងាយរងគ្រោះ ដោយពុំមានការផ្តល់សំណង បានសមរម្យឡើយ។ ផលវិបាកភ្លាម ដែលកើតឡើងដោយសារការអនុវត្តន៍គោលនយោបាយនេះ គឺប្រជាពលរដ្ឋបានបាត់បង់ដីធ្លី និងលំនៅឋាន ដែលឈានទៅដល់ការបាត់បង់ការងារ និងសិទ្ធិបោះឆ្នោតថែមទៀតផង។ ជនរងគ្រោះដែលត្រូវគេបណ្តេញចេញ ហើយបាត់បង់ដីធ្លី និងលំនៅឋានអាចរងការផ្តន្ទាទោសដាក់ពន្ធនាគារ និងការធ្វើទុក្ខបុកម្នេញថែមទៀតផង។

ទំនាស់នេះ អាចអូសបន្លាយអស់រយៈពេលជាច្រើនឆ្នាំ ថែមទាំងនាំឱ្យមានការខ្វះស្បៀងអាហារ បាត់បង់ដីស្រែចម្ការ និងធនធាននានា ព្រមទាំងបាត់បង់នូវការផ្តល់ពលកម្មដាច់មុខនៅក្នុងតំបន់ ដែលប៉ះពាល់។ កត្តាទាំងនេះនឹងនាំមកនូវភាពក្រីក្រ ការបាត់បង់ព្រៃឈើ និងប៉ះពាល់ដល់បរិស្ថាន។

## ២. *ការផ្សព្វផ្សាយ និងការអនុវត្តន៍អនុសញ្ញា* CEDAW

អំពីស្ថានភាពយេនឌ័រ កម្ពុជាបានស្ថិតនៅលំដាប់លេខទី ១១៣ នៃបញ្ជីសន្ទស្សន៍ការអភិវឌ្ឍន៍ទាក់ទងជាមួយយេនឌ័រហៅថា GDI និងស្ថិតនៅលំដាប់លេខទី៩១នៃបញ្ជីវិធានការផ្តល់អំណាចយេនឌ័រហៅថា GEM[៨] ។ តួលេខទាំងពីរនេះ ត្រូវបានដកស្រង់ចេញពីរបាយការណ៍អភិវឌ្ឍន៍មនុស្សឆ្នាំ២០០៩ របស់អង្គការសហប្រជាជាតិ UNDP[៩]។

កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញា CEDAW នៅឆ្នាំ១៩៩២ ប៉ុន្តែការផ្តល់សច្ចាប័ននេះ មិនត្រូវបានផ្សព្វផ្សាយនៅក្នុងរាជកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជាឡើយ។ ដូច្នេះចៅក្រម និងមន្ត្រីផ្នែកច្បាប់មួយចំនួននៅពុំទាន់បានដឹងអំពីអនុសញ្ញា CEDAW នេះនៅឡើយ។

---

[៨] បាយការណ៍អភិវឌ្ឍន៍របស់ UNDP។ ការវាស់វែងគុណភាព: សន្ទស្សន៍អភិវឌ្ឍន៍ទាក់ទងយេនឌ័រ (GDI) និងវិធានការផ្តល់អំណាចយេនឌ័រ។

[៩] http://hdr.undp.org/reports/lobal/hdr2009/

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តកាលពីឆ្នាំ១៩៩៣ បានបញ្ជាក់នូវកិច្ចការពារពេញលេញដល់សិទ្ធិជាមូលដ្ឋានរបស់ជនជាតិខ្មែរគ្រប់រូបនៅក្នុងជំពូក៣ រួមទាំងការការពារសិទ្ធិស្ត្រីផងដែរ។ កិច្ចការពារនេះ រួមមានសិទ្ធិស្មើភាពចំពោះមុខច្បាប់ (មាត្រា ៣១) និងការហាមឃាត់នូវរាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ(មាត្រា ៤៦)។ រដ្ឋធម្មនុញ្ញបានធានានូវសមភាពរវាងបុរស និងស្ត្រី ប៉ុន្តែគេក៏អាចរកឃើញនូវភាពផ្ទុយនេះដែរនៅក្នុងច្បាប់បច្ចុប្បន្នមួយចំនួន។ ឧទាហរណ៍ មាត្រា៩ នៃច្បាប់ស្តីពីអាពាហ៍-ពិពាហ៍ និងគ្រួសារបានចែងថា "ក្រោយពីការរំលាយនូវអាពាហ៍ពិពាហ៍ ស្ត្រីអាចរៀបការថ្មីទៀតបាន។ ប៉ុន្តែស្ត្រីនោះ ត្រូវនៅជាប់ចំណងអាពាហ៍ពិពាហ៍ចាស់យ៉ាងតិច១២០ថ្ងៃទៀត ក្រោយពីប្តីទទួលមរណៈភាព ឬ ១២០ថ្ងៃ បន្ទាប់ពីចៅក្រមចេញសាលក្រមលែងលះជាស្ថាពរ"។ ចាប់តាំងពីការចេញរបាយការណ៍របស់គណៈកម្មការធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (NGO-CEDAW) នៅឆ្នាំ២០០៥ ច្បាប់នេះបានបន្ថយចំនួនថ្ងៃពី៣០០ថ្ងៃ មកត្រឹម១២០ថ្ងៃវិញ។ ប៉ុន្តែការរើសអើងលើស្ត្រីភេទនៅតែមានដដែលក្នុងច្បាប់នេះ។

គណៈកម្មាធិការរបស់អង្គការសហប្រជាជាតិទទួលបន្ទុក CEDAW បានផ្តល់អនុសាសន៍នៅក្នុងរបាយការណ៍មុនថា ច្បាប់ត្រូវតែផ្តល់ការយកចិត្តទុកដាក់ជាពិសេសលើស្ត្រីកម្ពុជាដែលងាយរងគ្រោះ ដូចជាស្ត្រីជនជាតិដើមភាគតិច និងស្ត្រីពិការ។ ស្ត្រីក្នុងក្រុមនេះមិនទាន់ទទួលបានកិច្ចការពារសមរម្យពីសំណាក់រដ្ឋនៅឡើយ ។

អាស្រ័យដោយទំនាស់ដូចដែលបានលើកឡើងពីខាងលើ ស្ថានភាពស្ត្រីជនជាតិដើមភាគតិច គឺមានភាពផុយស្រួយណាស់ ដោយសារការបំផ្លាញដល់ជីវភាពរស់នៅរបស់អ្នកទាំងនោះ ព្រមទាំងផលវិបាកនៃការបែកបាក់សង្គម និងក្រុមគ្រួសារដែលនាំមកនូវការកើនឡើងនៃហានិភ័យនានា នៅក្នុងនោះមានដូចជាអំពើហិង្សាក្នុងគ្រួសារទាក់ទងយេនឌ័រជាដើម។

តាំងពីឆ្នាំ១៩៩២ កម្ពុជាបានតាក់តែងគោលនយោបាយ យុទ្ធសាស្ត្រ និងឧបករណ៍ច្បាប់នានា ដើម្បីទប់ស្កាត់ការរើសអើងលើស្ត្រីភេទ ប៉ុន្តែប្រសិទ្ធិភាពរបស់គោលនយោបាយទាំងនោះ នៅតែមានកម្រិតទាបនៅឡើយអាស្រ័យដោយការអនុវត្តន៍នៅមានកម្រិត ។

## ២.១ ឧបសគ្គក្នុងការផ្សព្វផ្សាយ និងការអនុវត្តន៍អនុសញ្ញា CEDAW

ឧបសគ្គធំៗគឺ:

- រដ្ឋាភិបាលបានផ្តល់សច្ចាប័នលើបទបញ្ញត្តិនៃអនុសញ្ញា CEDAW នៅឆ្នាំ១៩៩២ ប៉ុន្តែអនុសញ្ញានេះ នៅតែមិនទាន់ត្រូវបានផ្សព្វផ្សាយផ្លូវការជាភាសាខ្មែរ នៅក្នុងរាជកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជានៅឡើយទេ។ ដូច្នេះចៅក្រម និងមន្ត្រីផ្នែកច្បាប់មួយចំនួន នៅមិនទាន់បានយល់ដឹងច្បាស់នៅឡើយ អំពីការផ្តល់សច្ចាប័នលើអនុសញ្ញានេះ។
- រដ្ឋធម្មនុញ្ញកម្ពុជាបានហាមប្រាមរាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ។ ក៏ប៉ុន្តែ នៅមិនទាន់មាននិយមន័យណាមួយកំណត់ច្បាស់លាស់អំពីការរើសអើងលើស្ត្រីភេទ ត្រូវបានដាក់បញ្ចូលក្នុងច្បាប់ជាតិទេ។

- ពុំមានសេចក្តីសម្រេចរបស់តុលាការណាមួយដែលបានយកអនុសញ្ញា CEDAW មកអនុវត្តនៅឡើយទេ។ មកដល់ពេលនេះ មិនទាន់មានពាក្យបណ្តឹងណាមួយត្រូវបានប្តឹងឡើងដោយអះអាងអំពីការរំលោភលើសិទ្ធិជាក់លាក់ណាមួយរបស់ស្ត្រី ឬអំពីការរើសអើងទាក់ ទងនឹងយេនឌ័រនៅឡើយ។
- មានគោលនយោបាយមួយចំនួនដែលមានសូចនាករខុសៗគ្នា ដើម្បីសម្រេចបាននូវសម ភាពយេនឌ័រ ប៉ុន្តែគ្មានការសម្របសម្រួលប្រកបដោយប្រសិទ្ធិភាពណាមួយត្រូវបានធ្វើឡើងទេ។ របាយការណ៍របស់រដ្ឋាភិបាលស្តីពីអនុសញ្ញា CEDAW មិនមានការបញ្ជាក់ឱ្យបានច្បាស់លាស់ក្នុងការអនុវត្តន៍ឱ្យមានប្រសិទ្ធិភាពលើគោលនយោបាយនានានេះទេ។
- ឥរិយាបទរិតត្បិតចំពោះស្ត្រី ដែលចាក់ឫសគល់យ៉ាងជ្រៅនៅតែមាន នេះហើយជាបញ្ហាកង្វល់ជាចំបង។
- សិទ្ធិស្ត្រីជនជាតិដើមភាគតិច និងស្ត្រីពិការនានា មិនសូវបានយកចិត្តទុកដាក់ខ្លាំងពីរដ្ឋាភិបាលទេ។

### ២.២ អនុសាសន៍ដើម្បីកែលំអការផ្សព្វផ្សាយ និងការអនុវត្តន៍អនុសញ្ញា CEDAW

សូមរាជរដ្ឋាភិបាលកម្ពុជាមេត្តាទទួលយកអនុសាសន៍ដូចខាងក្រោមនេះ៖

- ធានាឱ្យបានថា រាល់បទបញ្ញត្តិទាំងអស់នៃអនុសញ្ញា CEDAW ត្រូវបានដាក់បញ្ចូលពេញលេញនៅក្នុងគ្រប់ច្បាប់ជាតិទាំងអស់។
- ត្រូវឱ្យមានភាពស្របគ្នារវាងច្បាប់ជាតិទាំងអស់ និងអនុសញ្ញា CEDAW (សូមកុំឱ្យមានភាពផ្ទុយគ្នារវាងច្បាប់ជាតិ និងអនុសញ្ញា CEDAW)។
- មកដល់ត្រឹមនេះ សូមរាជរដ្ឋាភិបាលចាប់ផ្តើមពិនិត្យឡើងវិញឱ្យបានហ្មត់ចត់នូវច្បាប់ទាំងឡាយ ដែលមានជាធរមាន។

# ជំពូក ២. ការអប់រំ និងប្រព័ន្ធផ្សាយព័ត៌មាន

## ១. ស្ថានភាព

ការអប់រំគឺជាមូលដ្ឋានគ្រឹះនៃសិទ្ធិមនុស្ស ហើយមានសារៈសំខាន់ដើម្បីអនុវត្តសិទ្ធិផ្សេងៗទៀតទាំងអស់។ ការអប់រំជួយលើកស្ទួយដល់សេរីភាព និងធ្វើឱ្យបុគ្គលមានសេរីភាពចាត់ចែងកិច្ចការគ្រប់យ៉ាងដោយច្បាប់ និងការយល់ដឹងរបស់ខ្លួន (ស្វ័យភាពបុគ្គល) ព្រមទាំងផ្តល់ផលប្រយោជន៍ដល់ការអភិវឌ្ឍ។ ក៏ប៉ុន្តែកុមារ និងពលរដ្ឋពេញវ័យនៅកម្ពុជាជាច្រើននាក់ នៅតែមិនមានឱកាសសិក្សារៀនសូត្រ។ បញ្ហានេះអាស្រ័យដោយភាពក្រីក្រ និងស្ថានភាពនយោបាយសង្គម។

ឧបករណ៍គោលនយោបាយ (Policy Instruments) របស់អង្គការសហប្រជាជាតិបានកំណត់ថា ការអប់រំ គឺសិទ្ធិជាសកល។ ឧបករណ៍នេះ លើកស្ទួយ និងអភិវឌ្ឍសិទ្ធិរបស់មនុស្សគ្រប់គ្នាដើម្បីទទួលបានការអប់រំស្មើៗគ្នាដោយពុំមានការរើសអើង ឬការមិនអនុញ្ញាតឱ្យចូលរួមពីនរណាម្នាក់។ ក៏ប៉ុន្តែទាំងអស់នេះ គឺអាស្រ័យលើរដ្ឋាភិបាលនៃប្រទេសនីមួយៗ ក្នុងការចាត់វិធានការដើម្បីធានាឱ្យបាននូវការអប់រំប្រកបដោយគុណភាពសម្រាប់ទាំងអស់គ្នា ។

ការអប់រំគួរតែជាបញ្ហាអាទិភាពសម្រាប់កម្ពុជា ហើយជាឧបករណ៍មូលដ្ឋានគ្រឹះសម្រាប់ឱ្យមានការផ្លាស់ប្តូរសង្គម និងដើម្បីឱ្យមានការអភិវឌ្ឍន៍ឥរិយាបទជាវិជ្ជមានចំពោះសិទ្ធិពលរដ្ឋ។ ការចំណាយលើការសិក្សារៀនសូត្រមិនមែនគ្រាន់តែសាងសង់សាលារៀនឱ្យគ្រប់គ្រាន់នោះទេ ប៉ុន្តែត្រូវផ្តល់លទ្ធភាពឱ្យពលរដ្ឋបានចូលរៀនទាំងអស់គ្នា ព្រមទាំងផ្តល់នូវកម្មវិធីសិក្សារៀនសូត្រសមរម្យថែមទៀតផង។ កម្មវិធីសិក្សាត្រូវតែចងក្រងដោយយកចិត្តទុកដាក់ដើម្បីលុបបំបាត់នូវការរើសអើងលើផ្នត់គំនិតយេនឌ័រ ដើម្បីធ្វើឲ្យមនុស្សជំនាន់ក្រោយយល់តម្លៃនៃសមភាព និងមានការគោរពគ្នាទៅវិញទៅមក។

លើសពីនេះទៅទៀត រដ្ឋាភិបាលគួរតែមានការហ្វឹកហ្វឺនដល់ស្ត្រីពេញវ័យឱ្យបានច្រើនជាងនេះដែលមិនធ្លាប់បានរៀនសូត្រសោះកាលពីមុនមក។ ប្រព័ន្ធផ្សាយព័ត៌មានដូចជាហាងអ៊ីនធឺណេត គួរត្រូវបានដាក់បញ្ចូលរូបភាពអប់រំដ៏ទូលំទូលាយក្នុងដំណើរឆ្ពោះទៅរកភាពមិនរើសអើងទៅលើស្ត្រី។

ថ្វីត្បិតតែមានកិច្ចប្រឹងប្រែងខាងផ្នែកច្បាប់ ដើម្បីកាត់បន្ថយការរើសអើងលើស្ត្រីភេទទាក់ទងការអប់រំក៏ដោយ ក៏នៅតែមានការកត់សម្គាល់ឃើញនូវភាពមិនស្របគ្នារវាងច្បាប់ និងស្ថានភាពពិតជាក់ស្តែងដែរ។ ថ្វីត្បិតតែមានការទទួលស្គាល់របស់សង្គម ស្តីពីសិទ្ធិទទួលបានការអប់រំ និងផលប្រយោជន៍នៃសិទ្ធិនោះក៏ដោយ ជាក់ស្តែង គឺនៅមិនទាន់មានផ្តល់លទ្ធផលវិជ្ជមានដល់ឱកាសទទួលបានការអប់រំដល់ស្ត្រីភាគច្រើន នៅឡើយទេ។ នេះគឺជាបញ្ហាមួយផ្នែកដែលកើតមកពីក្រមសីលធម៌សង្គមដែលមានដល់សព្វថ្ងៃនេះ និងមានកម្រិត និងនៅតែគិតថាជាការត្រឹមត្រូវសម្រាប់សីលធម៌ស្ត្រី ហៅថា ច្បាប់ស្រី "សូមមើលការពន្យល់លំអិតនៅក្នុងចំណុច ១.៦ខាងក្រោម"។ ខ្លឹមសារនៃក្រមនេះ មានផលប៉ះពាល់ដល់ជីវភាពរបស់ស្ត្រីកម្ពុជាដែលជាផ្នែកមួយរួមចំណែកឱ្យមានអត្រាអនក្ខរភាពខ្ពស់ រឹតត្បឹតដល់ការដើរហើរ និងរឹតត្បឹតដល់ឱកាសក្នុងការសិក្សារៀនសូត្រ និងធ្វើកិច្ចការនានារបស់ស្ត្រី។

ថ្វីត្បិតតែការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងគោលនយោបាយលុបបំបាត់ការរើសអើងលើស្ត្រី ភេទមិនទាន់មានប្រសិទ្ធិភាពច្បាស់លាស់ដូចយើងទាំងអស់គ្នាចង់បានក៏ដោយ ក៏ប៉ុន្តែបញ្ហាដែលធ្ងន់ធ្ងរជាង នេះ គឺប្រហែលជាមកពីឥរិយាបទប្រពៃណីដែលបានចាក់ឫសគល់យ៉ាងជ្រៅ នេះហើយជាមូលហេតុធ្វើឱ្យ មិនមានសមភាពរវាងបុរស និងស្ត្រី។ ដូច្នេះ នេះមានន័យថា ទ្វារដែលបើកសម្រាប់សមភាពយេនឌ័រនេះគឺ ត្រូវបានបើកតែពាក់កណ្តាលតែប៉ុណ្ណោះ។

## ១.១ នីតិបញ្ញត្តិ និងគោលនយោបាយ

រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ ធានានូវសេរីភាពបុគ្គល និងសិទ្ធិជាមូលដ្ឋាន រួមមានសមភាពរវាង បុរស និងស្ត្រី ឱកាសការងារស្មើៗគ្នាចំពោះស្ត្រី ផលប្រយោជន៍មាតុភាព និងសិទ្ធិស្មើគ្នាក្នុងការបោះឆ្នោត។ មាត្រា ៦៥ នៃច្បាប់រដ្ឋធម្មនុញ្ញចែងថា "រដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលការ អប់រំប្រកបដោយគុណភាពនៅគ្រប់កម្រិត និងត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាជំហានៗ ដើម្បីឱ្យការអប់រំ នេះបានទៅដល់ប្រជាពលរដ្ឋគ្រប់រូប"។ លើសពីនេះទៅទៀត មាត្រា ៦៨ ក៏បានចែងដែរថា "រដ្ឋផ្តល់កិច្ចការ អប់រំផ្នែកបឋម និងមធ្យមសិក្សានៅសាលារៀនសាធារណៈ សម្រាប់ប្រជាពលរដ្ឋគ្រប់រូបដោយឥតបង់ថ្លៃ។ ប្រជាពលរដ្ឋត្រូវបានទទួលការអប់រំយ៉ាងតិច ៩ ឆ្នាំ"។

ស្របជាមួយមាត៌ារបស់រដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីការអប់រំឆ្នាំ២០០៧ ចែងថា "ពលរដ្ឋគ្រប់រូបមានសិទ្ធិ ទទួលបានការអប់រំប្រកបដោយគុណភាពយ៉ាងតិច ៩ ឆ្នាំ នៅសាលារដ្ឋដោយឥតបង់ថ្លៃ។ ក្រសួងទទួល បន្ទុកវិស័យអប់រំ ត្រូវរៀបចំជាជំហានៗនូវគោលនយោបាយ និងផែនការយុទ្ធសាស្ត្រដើម្បីធានាឱ្យប្រជា ពលរដ្ឋបានទទួលការអប់រំប្រកបដោយគុណភាព ដូចដែលមានចែងនៅក្នុងច្បាប់នេះ"។

លទ្ធផលនៅជុំវិញច្បាប់នេះគឺ គោលនយោបាយជាច្រើនពាក់ព័ន្ធជាមួយការកែលំអគុណភាពអប់រំ ត្រូវបានឯកភាពដោយរាជរដ្ឋាភិបាលកម្ពុជា។ ឧទាហរណ៍ ក្រសួងអប់រំ យុវជន និងកីឡា[៦] បានធ្វើ "ផែនការ យុទ្ធសាស្ត្រអភិវឌ្ឍន៍ថ្នាក់ជាតិ"។ ផែនការនេះ បានទទួលស្គាល់ថា ការអប់រំគឺជាមូលដ្ឋានគ្រឹះនៃសិទ្ធិមនុស្ស និងប្រឹងប្រែងដើម្បីធានាឱ្យរាល់កុមារ និងយុវជនកម្ពុជាទាំងអស់មានឱកាសស្មើៗគ្នាដើម្បីទទួលបានការ អប់រំប្រកបដោយគុណភាព ដោយមិនគិតពីស្ថានភាពសង្គម ភូមិសាស្ត្រ ពូជសាសន៍ តំបន់ ភាសា យេនឌ័រ ឬពិការភាពឡើយ ។

"ផែនការផ្នែកអប់រំ" បានកំណត់អាទិភាពខ្ពស់លើការកាត់បន្ថយគម្លាតយេនឌ័រក្នុងការចុះឈ្មោះ ចូលរៀន ហើយក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវវិធានការជាក់លាក់មួយចំនួនសម្រាប់គោល បំណងនេះ រួមមានការផ្តល់អាហារូបករណ៍ដល់កុមារីក្រីក្រ និងការសាកល្បងប្រើប្រាស់អន្តេវាសិកដ្ឋាន (កន្លែងស្នាក់នៅព្រមទាំងមានម្ហូបអាហារ) សម្រាប់សិស្សស្រី ដែលចុះឈ្មោះចូលរៀននៅអនុវិទ្យាល័យ (មធ្យមសិក្សា)។

[៦] ក្រសួងអប់រំ យុវជន និងកីឡា។

"ផែនការសកម្មភាពបញ្រ្ជាបយេនឌ័ររបស់ក្រសួងអប់រំ យុវជន និងកីឡា" មានគោលបំណង ដើម្បីធានាឱ្យកុមារីបានទទួលនូវការអប់រំថ្នាក់មូលដ្ឋានប្រកបដោយគុណភាពពេញលេញ និងស្មើគ្នានៅត្រឹមឆ្នាំ២០១០ តាមរយៈការបង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងការគ្រប់គ្រង និងការផ្តល់សេវាកម្មអប់រំ។ ផែនការនេះក៏មានគោលបំណង ដើម្បីបង្កើននូវតវិយាបទវិជ្ជមានកាន់តែច្រើនឡើងចំពោះការអប់រំកុមារី និងសមភាពយេនឌ័រក្នុងចំណោមផ្នែកពាក់ព័ន្ធនានាក្នុងវិស័យអប់រំ និងក្នុងចំណោមសាធារណៈជនទូទៅ។

ជាការពិតណាស់ ដែលកម្ពុជាមានរចនាសម្ព័ន្ធច្បាប់នៅក្នុងទ្រឹស្តី គឺអាចសម្រេចបាននូវប្រព័ន្ធអប់រំប្រកបដោយសមភាព។ ក៏ប៉ុន្តែភាពទន់ខ្សោយក្នុងការអនុវត្តន៍ច្បាប់នឹងមិនអាចដោះស្រាយបាននូវរាល់ការរើសអើងផ្នត់គំនិតយេនឌ័រ ដែលចាក់ឬសយ៉ាងជ្រៅនៅក្នុងសង្គមបានទេ។ ការបញ្ចូលគ្នានូវផ្នត់គំនិត និងភាពក្រីក្រនៅក្នុងគ្រួសារពលរដ្ឋកម្ពុជាមួយភាគធំ នាំឱ្យគ្រួសារភាគច្រើនមិនបញ្ជូនកូនស្រីទៅរៀននៅសាលាទេ។ ក្រុមគ្រួសារកម្ពុជានៅយល់ថា ការអប់រំនេះ មិនអាចទទួលបានប្រយោជន៍សេដ្ឋកិច្ចរយៈពេលខ្លីឡើយ។

ការសន្យារបស់រដ្ឋាភិបាលក្នុងការសាងសង់សាលាថែមទៀត នៅមិនទាន់ជាមធ្យោបាយដ៏សំខាន់ដែលកើតឡើងជាក់ស្តែងនៅឡើយទេ។ ជាពិសេសជួបបញ្ហាច្រើននៅតាមជនបទ ដែលគ្រួសារក្រីក្រជាច្រើនពុំមានលទ្ធភាពក្នុងការបញ្ជូនកូនទៅរៀនក្រៅផ្ទះបានទេ ដោយខ្លាចបាត់បង់នូវកម្លាំងពលកម្មប្រចាំថ្ងៃរបស់ក្រុមគ្រួសារ មិនតែប៉ុណ្ណោះថែមទាំងត្រូវចំណាយលើការធ្វើដំណើរ និងសំភារៈសិក្សាថែមទៀតផង។ រីឯកុមារីកាន់តែជួបហានិភ័យខ្លាំងជាងមុននៅពេលដែលត្រូវធ្វើដំណើរផ្លូវឆ្ងាយទៅសាលា។

សូម្បីតែការសន្យាថាសិក្សាដោយពុំមានការបង់ប្រាក់ ក៏ស្ទើរតែមិនទាន់ធ្វើបានគ្រប់ជ្រុងជ្រោយនៅឡើយដែរ។ នៅកម្ពុជាលោកគ្រូអ្នកគ្រូទទួលបានប្រាក់បៀវត្សរ៍ទាប ហើយសិស្សភាគច្រើនត្រូវចំណាយថវិកាដើម្បីចូលរៀន នេះមានន័យថាមានក្រុមគ្រួសារមួយចំនួនមិនអាចមានលទ្ធភាពក្នុងការចំណាយផ្សេងៗដើម្បីឱ្យកូនទាំងអស់ទៅសាលាបានទេ។ ដូច្នេះ ច្រើនតែកូនប្រុសប៉ុណ្ណោះអាចទៅរៀនបាន។

ទោះបីជាច្បាប់ និងគោលនយោបាយលុបបំបាត់អនក្ខរភាពមានរួចហើយក៏ដោយ ក៏ស្ត្រីជាច្រើននៅតែរងគ្រោះ។ វិធានការដ៏មានប្រសិទ្ធិភាពក្នុងការឱ្យកូនស្រីចូលរៀនសាលាមិនទាន់ធ្វើបាននៅឡើយទេ។

នៅឆ្នាំ២០០៦ គណៈកម្មាធិការរបស់អង្គការសហប្រជាជាតិទទួលបន្ទុក CEDAW បានធ្វើការកត់សម្គាល់ឃើញថា ភាពមិនស្មើគ្នារវាងស្ត្រី និងបុរស បានបង្ហាញឱ្យឃើញយ៉ាងច្បាស់តាមរយៈអត្រាអនក្ខរ-ភាពខ្ពស់ក្នុងចំណោមស្ត្រីកម្ពុជា[៧] បញ្ហានេះនៅមិនទាន់បានដោះស្រាយនៅឡើយទេ។ បច្ចុប្បន្ននេះអត្រាអនក្ខរភាពស្ត្រីមាន ៥០% ធៀបជាមួយបុរសដែលមានត្រឹមតែ១៨% ប៉ុណ្ណោះ។

ចំណុចសំខាន់ក៏ត្រូវលើកឡើងផងដែរ គឺប្រព័ន្ធអប់រំបច្ចុប្បន្ននេះ មិនទាន់ប្រឹងប្រែងឱ្យអស់ពីលទ្ធភាពដើម្បីដក "ច្បាប់ស្រី" នេះចេញឱ្យអស់ពីកម្មវិធីសិក្សានៅឡើយទេ ហើយនៅតាមសាលារៀនក៏សង្កេតឃើញនៅមានទំនោរនៃកង្វះខាតសំភារៈ ឬបុគ្គលិកដែលមានសមត្ថភាពគ្រប់គ្រាន់ ដែលអាចនឹងបក

[៧] យោបល់សន្និដ្ឋានរបស់គណៈកម្មាធិការនៃអង្គការសហប្រជាជាតិទទួលបន្ទុក CEDAW៖ កម្ពុជា ថ្ងៃទី១៦ ខែមករា-ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០០៦។

ស្រាយពីក្រមសីលធម៌របស់ "ច្បាប់ស្រី" នេះ ឱ្យមានប្រសិទ្ធិភាពនៅឡើយដែរ។ ក្រមសីលធម៌នេះ បានចាក់ឫសយ៉ាងរឹងមាំនៅក្នុងសង្គមខ្មែរ។

តាមនិយមន័យ ការដែលមានក្រិត្យក្រមណាមួយដែលនៅតែអនុវត្តចំពោះយេនឌ័រណាមួយនោះ គឺជាអំពើរើសអើងទៅហើយ។ ដូច្នេះ មានតែការលុបបំបាត់ចោលនូវក្រិត្យក្រមនោះទេ ដែលអាចនាំមកសមភាពរវាងយេនឌ័រឡើងវិញ។ សម្រាប់ពេលនេះ គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (NGO-CEDAW) កំពុងស្ថិតក្នុងដំណើរការរៀបចំបោះពុម្ពផ្សាយមួយ ដែលធ្វើការវិភាគក្រមសីលធម៌ "ច្បាប់ស្រី" និងក្នុងគោលបំណងដើម្បីកែទម្រង់ខ្លឹមសារមួយចំនួនរបស់ក្រមសីលធម៌នេះ។

## ១.២ ការចុះឈ្មោះចូលរៀន

រដ្ឋាភិបាលបានធ្វើឱ្យមានការរីកចម្រើនខ្លះអំពីការងារនេះ ជាពិសេសការចុះឈ្មោះចូលរៀនផ្នែកបឋមសិក្សានៅថ្នាក់ជាតិ។ យោងតាមប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ EMIS[៨] ២០០៨/២០០៩ និងស្ថិតិរបស់ក្រសួងអប់រំ យុវជន និងកីឡា មាន៩៤.៤% នៃកុមារដែលដល់អាយុចូលរៀន ហើយបានចូលរៀននៅកម្រិតបឋមសិក្សា និងមាន ៣៣.៩% ផ្សេងទៀតបានចូលរៀននៅកម្រិតអនុវិទ្យាល័យ (ក្រសួងអប់រំ ឆ្នាំ២០០៩)។

អត្រាជាក់ស្តែងសម្រាប់ថ្នាក់ទី១ គឺ ៩១.៩% (ក្រសួងអប់រំ ឆ្នាំ២០០៩ ខ:៤៥) ស្ទើរតែសម្រេចបានតាមគោលដៅផែនការយុទ្ធសាស្ត្រអប់រំ ESP[៩] ដែលបានកំណត់ត្រឹម៩៤%។ ហើយភាពខុសគ្នារវាងយេនឌ័រនៅកម្រិតបឋមសិក្សាកំពុងថយចុះ ប៉ុន្តែនៅកម្រិតអនុវិទ្យាល័យវិញ បញ្ហានេះនៅតែបន្តមាននៅឡើយដោយសិស្សស្រីមាន ៣២% និងសិស្សប្រុសមាន ៣៦% បានចុះឈ្មោះចូលរៀននៅកម្រិតអនុវិទ្យាល័យ (UNESCO ឆ្នាំ២០០៩ ខ:២)។ តួលេខនេះ ពិតជាបានបង្ហាញនូវការរីកចំរើនខ្លះៗ។ ប៉ុន្តែប្រសិនបើរដ្ឋាភិបាលត្រូវសម្រេចឱ្យបានការអប់រំបឋមជាសកលតាមគោលដៅអភិវឌ្ឍន៍សហស្សវត្ស MDG[១០] នោះនឹងអាចមានការរីកចំរើនថែមទៀត ប្រសិនបើសហគមន៍ចូលរួមកាន់តែសកម្មជាងមុននៅក្នុងការងារសាលា។

ការសិក្សាថ្មីៗរបស់គណៈកម្មាធិការអឺរ៉ុបបានកត់សម្គាល់ឃើញថា មានការរីកចំរើនគួរឱ្យកត់សម្គាល់ចំពោះចំនួនសិស្សានុសិស្សដែលបានបញ្ចប់ថ្នាក់ទី៦ (កើនឡើង ៩៨% ជាទូទៅកុមារីកើនឡើង ១៣១%) បញ្ចប់ថ្នាក់ទី៩ (កើនទូទៅ ២៧៤% សិស្សស្រីកើន ៤៦០%) និងបញ្ចប់ថ្នាក់ទី១២ (កើនទូទៅ ១២៤% សិស្សស្រីកើន ១៨៩%) នៅក្នុងឆ្នាំសិក្សា ២០០០ - ២០០១ រហូតដល់ឆ្នាំសិក្សា ២០០៧-២០០៨) (EC &Quinn 2008)។

ទោះបីជាយ៉ាងនេះក៏ដោយ កុមារមិនបានចូលរៀន (ជាពិសេសកុមារី) នៅតែជាបញ្ហានៅឡើយនៅកម្ពុជា ទោះបីជាស្ថិតិ និងសូចនាករវិស័យអប់រំឆ្នាំសិក្សា២០០៧-២០០៨ បានបង្ហាញនូវសមាមាត្រជាក់ស្តែងនៃការចុះឈ្មោះចូលរៀននៅថ្នាក់បឋមសិក្សាបាន៩៣.៣% និងនៅថ្នាក់អនុវិទ្យាល័យបាន៣៤.៨% ក៏

[៨] ប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ។

[៩] ផែនការយុទ្ធសាស្ត្រអប់រំ។

[១០] គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។

ដោយ។ តួលេខទាំងពីរនេះ មើលទៅទំនងជាស្ថិតនៅឆ្ងាយពីតួលេខដែលរដ្ឋាភិបាលបានសង្ឃឹមទុកសម្រាប់ឆ្នាំ២០១០ ដែលចង់បាន ៩៦% នៅបឋមសិក្សា និង៥០% នៅអនុវិទ្យាល័យ (ប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ ២០០៨៖ ៩៥)។

ការអប់រំពលរដ្ឋពេញវ័យនៅមានកម្រិតទាបនៅឡើយ ទាំងបរិមាណ និងគុណភាព[១១]។ នៅក្នុងឆ្នាំ ២០០០ មានមនុស្សពេញវ័យមិនចេះអក្សរត្រឹមតែ ២% ប៉ុណ្ណោះ ដែលបានចុះឈ្មោះចូលរៀនទាំងនៅក្នុងកម្មវិធីសិក្សារបស់រដ្ឋ (៣០,៥០០នាក់) និងកម្មវិធីសិក្សាដែលជួយឧបត្ថម្ភដោយអង្គការមិនមែនរដ្ឋាភិបាល ដែលមានសិស្សសរុបចំនួន (២០,០០០នាក់)[១២]។ រហូតមកដល់ឆ្នាំ២០០៨ ស្ថានភាពបានប្រសើរឡើង ដោយមានអនក្ខរជនពេញវ័យចំនួន ៥៨,៩៦៧នាក់ ក្នុងចំណោមនេះ (៣៧,៣៣៧ នាក់ ដែលជាស្ត្រី) បានចុះឈ្មោះចូលរៀនថ្នាក់អក្ខរកម្ម (ក្រសួងអប់រំ ឆ្នាំ២០០៩)។

ស្ត្រីបំរើការកំសាន្ត គឺជាក្រុមមួយដែលមានគុណវិបត្តិច្រើន។ តាមការប៉ាន់ស្មាន ៣០% នៃស្ត្រីបំរើការកំសាន្តមានអាយុទាបជាង១៨ឆ្នាំ ហើយបានចូលរៀននៅថ្នាក់មូលដ្ឋានមិនដល់៣ឆ្នាំផង ឬតិចជាងនេះទៀត ឬមិនដែលបានរៀនជំនាញវិជ្ជាជីវៈអ្វីសោះ ទាំងនេះបានធ្វើឱ្យស្ត្រីទាំងអស់នោះជាប់គាំងនៅក្នុងស្ថានភាពក្រីក្រ និងងាយរងគ្រោះដែលមិនអាចរើខ្លួនបានឡើយ (UNICEF & Stark-Marklein ២០០៦)។

រដ្ឋាភិបាលកម្ពុជាមានការយឺតយ៉ាវក្នុងការផ្តល់សេវាដល់ស្ត្រីបំរើការកំសាន្ត។ ប៉ុន្តែ ក៏មានអង្គការមិនមែនរដ្ឋាភិបាល[១៣] មួយចំនួនដែរ ដែលបច្ចុប្បន្នកំពុងផ្តល់សេវាអប់រំដល់ស្ត្រីបំរើការកំសាន្ត និងក្រុមស្ត្រីដែលងាយរងគ្រោះទាំងនោះ ( ដូចជាកម្មវិធី OPTIONS នៃអង្គការអប់រំពិភពលោកជាដើម)។

ទោះជាយ៉ាងណាក៏ដោយ កន្លងមកក៏យើងសង្កេតឃើញមានសញ្ញារីកចំរើនខ្លះៗដែរ។ មានការសាងសង់អន្តេវាសិកដ្ឋានជាច្រើនសម្រាប់សិស្សស្រីដែលបន្តរៀនមធ្យមសិក្សា និងឧត្តមសិក្សាផងដែរ។ ចំនួនអាហារូបករណ៍សម្រាប់សិស្សក្រីក្រ ជាពិសេសសិស្សស្រីក៏មានការកើនឡើងដែរនៅក្នុងថវិការដ្ឋ និងការជួយឧបត្ថម្ភពីសំណាក់ដៃគូអភិវឌ្ឍ និងគម្រោងអង្គការមិនមែនរដ្ឋាភិបាល។

ស្ត្រី និងកុមារីត្រូវបានជម្រុញឱ្យចូលរៀនតាមរយៈការលើកទឹកចិត្តរបស់រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលនានា ដូចជាការផ្តល់អាហារូបករណ៍ និងកម្ចីឥណទាន ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការឧបត្ថម្ភជាអង្ករជាដើម។ ប៉ុន្តែការផ្តួចផ្តើមនេះ មិនទាន់បានធ្វើឡើងឱ្យបានគ្រប់ជ្រុងជ្រោយ និងគ្រប់ខេត្តនៅឡើយទេ។ ការពង្រីកកម្មវិធីលើកទឹកចិត្តសម្រាប់ស្ត្រីឱ្យបន្តការរៀនសូត្រ គឺជាការងារចាំបាច់ដើម្បីសម្រេចបាននូវសមភាពយេនឌ័រនៅសាលារៀន និងសហគមន៍។ ត្បិតតែមានមូលហេតុ ធ្វើឱ្យមានសុទិដ្ឋិនិយម យ៉ាងណាក៏ដោយ ក៏ប៉ុន្តែត្រូវបង្ហាញឱ្យបានហ្មត់ចត់នៅពេលធ្វើការវាយតម្លៃការអភិវឌ្ឍន៍ទាំងនេះ។

---

[១១] Rosenbloom 2004

[១២] Rosenbloom 2004

[១៣] NGOs

## ១.៣ អត្រាបោះបង់ការសិក្សា

អត្រាបោះបង់ការសិក្សារបស់កុមារី ហាក់ដូចជាមានទំនោរស្របទៅនឹងគុណភាពសាលាក្នុងទិសដៅដូចគ្នាជាមួយកុមារាដែរ។ ក៏ប៉ុន្តែកុមារីមានលក្ខណៈងាយទទួលបញ្ហានេះជាងកុមារា (ធនាគារពិភពលោកឆ្នាំ២០០៥)។ លើសពីនេះទៅទៀត នៅពេលដែលកុមារកាន់តែធំពេញវ័យទៅៗ នោះការផ្លាស់ចិត្តពីការសិក្សារៀនសូត្រ ទៅធ្វើការងារផលិតកម្មរកចំណូលកាន់តែកើនខ្លាំងឡើងៗ។ នេះគឺជាបញ្ហាពិតរបស់កុមារី នៅពេលមានអាយុចាប់ពី ១៥ ដល់១៧ ឆ្នាំ ដែលតែងតែមានទំនោរស្វែងរកការងាររកប្រាក់ចំណូលជំនួសឱ្យការសិក្សារៀនសូត្រទៅវិញ ច្រើនជាងកុមារាដែលមានអាយុស្រករគ្នា (ធនាគារពិភពលោកឆ្នាំ ២០០៥) ។

ដូច្នេះ ដើម្បីកាត់បន្ថយបញ្ហានេះ តម្រូវឱ្យមានការខិតខំប្រឹងប្រែងខ្លាំងថែមទៀត ជាពិសេសការអភិវឌ្ឍកុមារភាពដើម្បីកាត់បន្ថយការត្រួតថ្នាក់ និងការបោះបង់ការសិក្សា ព្រមទាំងបង្កើនការអភិវឌ្ឍអគារសិក្សា ក៏ដូចជាឱកាសរៀនសូត្រនៅឧត្តមសិក្សាផងដែរ។ តម្រូវការថ្នាក់រៀន និងសំភារៈសិក្សាសម្រាប់កុមារដែលមានអាយុខុសៗគ្នា និងក្រុមពូជសាសន៍ផ្សេងៗគ្នានៅទូទាំងប្រទេសកម្ពុជាចេះតែកើនឡើងឥតឈប់ឈរលើសពីបរិមាណធនធានដែលរដ្ឋាភិបាលមានសម្រាប់បំពេញតម្រូវការនេះ។

## ១.៤ អក្ខរភាព

កំឡុងពេល ៤ ឆ្នាំកន្លងទៅនេះ ក្រសួងអប់រំយុវជន និងកីឡាក៏ទទួលបាននូវលទ្ធផលជាវិជ្ជមានដែរ ក្រោយពីការជួយឧបត្ថម្ភដល់ការបោះពុម្ពឯកសារអក្ខរកម្ម ការហ្វឹកហ្វឺនគ្រូបង្រៀនថ្នាក់អក្ខរកម្ម និងការបង្កើតឱ្យមានមជ្ឈមណ្ឌលសិក្សារៀនសូត្រតាមសហគមន៍នានារួចមក។ អត្រាអក្ខរភាពជាផ្លូវការទូទៅសម្រាប់ប្រជាពលរដ្ឋដែលមានអាយុ ១៥ឆ្នាំ និងលើសពី១៥ឆ្នាំឡើងទៅ គឺមាន៧៦.៣% ទន្ទឹមនឹងភាពខុសគ្នារវាងយេនឌ័រដ៏គួរឱ្យកត់សម្គាល់ គឺមាន៨៥.៨% សម្រាប់បុរស ចំណែកឯស្ត្រីវិញមានតែ ៦៧.៧% ប៉ុណ្ណោះទេ (UNESCO 2009)។ ភាពខុសគ្នាដូចដែលបានលើកឡើងពីខាងដើមនេះ ហាក់ដូចជាស្របគ្នាជាមួយការសម្រេចចិត្តរបស់ក្រុមគ្រួសារកម្ពុជាជាច្រើន ដែលគិតថាឱ្យកូនប្រុសរៀនបានខ្ពស់មានប្រយោជន៍ និងត្រឹមត្រូវជាងឱ្យកូនស្រីទៅរៀន។

## ១.៥ គុណភាពអប់រំ

គេសង្កេតឃើញមានការរីកចំរើនខ្លះនៅក្នុងផ្នែកមួយចំនួន សំដៅកែលំអគុណភាពអប់រំតាមរយៈការអនុវត្តន៍សាលាមិត្តភាពរបស់កុមារ (CFS)[១៤] កម្មវិធីសិក្សាថ្មី ការវាយតម្លៃបទដ្ឋាន និងសាលាដែលមានការវាយតម្លៃដោយខ្លួនឯងសម្រាប់បឋមសិក្សា និងមធ្យមសិក្សា។ គម្រោងគាំទ្រវិស័យអប់រំកម្ពុជា (CESSP)[១៥] បន្តជួយគាំទ្រកែលំអផ្នែកមធ្យមសិក្សាតាមរយៈវិធីសាស្ត្រនៃការវាយតម្លៃដោយខ្លួនឯងរបស់គម្រោងនេះ និងផែនការកែលំអសាលារៀន (ក្រសួងអប់រំឆ្នាំ២០០៩)។

---

[១៤] សាលាមិត្តភាពរបស់កុមារ។

[១៥] គម្រោងគាំទ្រវិស័យអប់រំកម្ពុជា។

គុណភាពអប់រំក្តោបយកទិដ្ឋភាពជាច្រើនក្នុងវិស័យអប់រំ រួមទាំងសមត្ថភាព និងការលើកទឹកចិត្តគ្រូបង្រៀន កង្វះគ្រូបង្រៀន កង្វះពេលដើម្បីចូលរួមយ៉ាងសកម្ម និងការអនុវត្តន៍ក្នុងថ្នាក់ ការបង់ថ្លៃសាលាក្នុង និងក្រៅម៉ោងសិក្សា។ល។ ហេតុដូច្នេះហើយទើបបានជាពុំទាន់មានការយល់ស្របគ្នានៅឡើយ អំពីធាតុជាមូលដ្ឋាននៃគុណភាពអប់រំក្នុងចំណោមផ្នែកពាក់ព័ន្ធនានា។ នេះហើយ គឺជាការលំបាកមួយ។

សាលារៀនភាគច្រើននៅកម្ពុជាមានដំណើរការក្រោមបរិយាកាស ជាសាលាមិត្តភាពកុមារ ដែលរួមមានការអភិវឌ្ឍស្ត្រី និងកុមារីក្នុងវិស័យអប់រំតាមរយៈការបង្កើតបរិយាកាសគាំទ្រដែលអាចឱ្យស្ត្រី និងកុមារីទទួលបានជោគជ័យ។

បញ្ហាមួយក្នុងចំណោមបញ្ហាសំខាន់ទាំងឡាយនៅក្នុងវិស័យអប់រំ គឺកុមារមានពេលតិចតួចបំផុតដើម្បីចូលរួមយ៉ាងសកម្ម និងអនុវត្តនៅក្នុងសាលារៀន។ នៅកម្ពុជា សិស្សានុសិស្សនៅបឋមសិក្សាទៅរៀននៅសាលាត្រឹមតែ ៤ម៉ោងប៉ុណ្ណោះក្នុងមួយថ្ងៃ ចាប់ពីថ្ងៃច័ន្ទដល់ថ្ងៃពុធ និងពីថ្ងៃសុក្រដល់ថ្ងៃសៅរ៍។ យោងតាមរបាយការណ៍ត្រួតពិនិត្យសកលឆ្នាំ២០០៨ នៃកម្មវិធីអប់រំសម្រាប់ទាំងអស់គ្នា (FA)[១៦] របស់ UNESCO បានបង្ហាញថាពេលវេលាសម្រាប់បង្ហាត់បង្ហាញនៅក្នុងថ្នាក់គឺមានតែ៣ម៉ោង និង២០នាទីតែប៉ុណ្ណោះក្នុងមួយថ្ងៃ។ ចំនួនសិស្សក្នុងថ្នាក់បឋមសិក្សាមានចាប់ពី ៤០នាក់ ទៅ ៥០នាក់ ហើយពី ៤០ ទៅ ៤៥នាក់នៅថ្នាក់អនុវិទ្យាល័យ។ ចំនួនសិស្សច្រើនបែបនេះ ជាការលំបាកណាស់សម្រាប់គ្រូបង្រៀនក្នុងការគ្រប់គ្រងសិស្សក្នុងថ្នាក់ ហើយមានពេលតិចតួចណាស់សម្រាប់ការចូលរួម និងការអនុវត្តន៍ឱ្យបានពេញលេញនៅក្នុងថ្នាក់ (UNESCO ឆ្នាំ ២០០៨)ហេតុនេះហើយមាតាបិតាត្រូវយល់ដឹងពីសារៈសំខាន់នៃកិច្ចការសាលាដែលត្រូវធ្វើនៅផ្ទះ ដោយត្រូវជួយពិនិត្យមើលសៀវភៅលំហាត់ ហើយការជួយពីសំណាក់មាតាបិតាគឺជាការធានាឱ្យកុមារមានសិទ្ធិត្រឹមត្រូវដើម្បីសិក្សារៀនសូត្រ និងលូតលាស់។



បន្ថែមពីលើបញ្ហានេះ ការយល់ស្របគ្នាអំពីអ្វី ដែលមាននៅក្នុងគុណភាពអប់រំ ជាកត្តាតម្រូវចាំបាច់នៅក្នុងចំណោមស្ថាប័នសំខាន់ៗ មានដូចជា ក្រសួងអប់រំ យុវជន និងកីឡា អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងស្រុក សាលារៀន (នាយកសាលា និងគ្រូបង្រៀន) សមាគមមាតាបិតា សិស្សានុសិស្ស និងសហជីពជាដើម។

[១៦] ការអប់រំសម្រាប់ទាំងអស់គ្នា។

របាយការណ៍រូបធាតុបង្រៀននៃអង្គការស្ម័គ្រចិត្តបំរើនៅបរទេស VSO[១៧] និងអង្គការអប់រំដៃគូ (NEP)[១៨] (VSO&NEP ឆ្នាំ២០០៨) ធ្វើការកត់សម្គាល់ថា ការចូលរួមយ៉ាងសកម្មពីសំណាក់សហគមន៍ជួយធ្វើឱ្យមានទំនាក់ទំនងយូរអង្វែងរវាងសហគមន៍ និងគ្រូបង្រៀន។ ការចូលរួមរបស់សហគមន៍កាន់តែច្រើន ក៏ជាការបញ្ជាក់ឱ្យឃើញនូវការនាំទៅរកគុណភាពអប់រំដែរ។

ការបង្កើតប្រព័ន្ធក្រុមហ្វឹកហ្វឺន និងត្រួតពិនិត្យថ្នាក់ស្រុកថ្មីៗដែលមានរៀបរាប់នៅក្នុងការអនុវត្តន៍ផែនការសាលាមិត្តភាពកុមារ ត្រូវការជំនួយគាំទ្រក្នុងការហ្វឹកហ្វឺន និងត្រួតពិនិត្យមុខងារនៅក្នុងខេត្តនានា។ ក្រុមនេះនៅថ្មីនៅឡើយ ហើយត្រូវបានបែកបាក់ទៅវិញ។ អ្នកទាំងនោះ ត្រូវឱ្យមានការគាំទ្រក្នុងការអភិវឌ្ឍផែនការសម្រាប់បណ្តុះបណ្តាល និងត្រួតពិនិត្យការអនុវត្តន៍របស់សាលា។ មុខងារត្រួតពិនិត្យសំខាន់បំផុតដូចជាការសង្កេតថ្នាក់រៀន គឺជាកិច្ចការមួយដែលថ្មីបំផុតសម្រាប់សមាជិកជាច្រើនក្នុងក្រុមនេះ។ មន្ទីរអប់រំប្រចាំខេត្ត (POEs)[១៩] នឹងត្រូវការការគាំទ្រដើម្បីធានាឱ្យក្រុមដំណើរការទៅបាន និងអនុវត្តតួនាទីរបស់ខ្លួនប្រកបដោយប្រសិទ្ធិភាព ។

សាលារៀនស្រុក និងខេត្តជួបប្រទះការលំបាកក្នុងការយកគោលនយោបាយរបស់ក្រសួងអប់រំទៅអនុវត្តតាមវិធីមួយ ដែលផ្តល់ប្រយោជន៍ដល់កុមារគ្រប់គ្នា។ ហេតុនេះ ទើបមានតម្រូវការផ្តល់ការបណ្តុះបណ្តាលបន្ថែម និងផ្តល់ជំនួយឧបត្ថម្ភប្រចាំថ្ងៃយូរអង្វែងទៀតផង។

លើសពីនេះទៅទៀត លទ្ធផលមិនប្រក្រតីនៃការសិក្សារបស់សិស្សានុសិស្ស បានបង្ហាញជាពិសេសថា ចំពោះសិស្សានុសិស្សចាប់ពីថ្នាក់ទី១-៣ ខាងផ្នែកភាសា និងគណិតវិទ្យាមានប្រហែលតែ ៥៥% ប៉ុណ្ណោះ ដែលសម្រេចបានតាមបទដ្ឋានគុណភាពអប់រំដែលក្រសួងអប់រំបានកំណត់។ ទស្សនៈរួមមួយយល់ឃើញថា គ្រូបង្រៀនមិនទាន់មានជំនាញក្នុងការផ្តល់ការបង្រៀនប្រកបដោយគុណភាពខ្ពស់នៅឡើយទេ។ ធាតុពិតអាចមកពីចំនួនសិស្សច្រើនពេកក្នុងថ្នាក់នីមួយៗ រួមផ្សំជាមួយគ្រូបង្រៀនដែលទទួលបានការបណ្តុះបណ្តាលគុណភាពទាបធ្វើឱ្យគុណភាពបង្រៀនកាន់តែពិបាកសម្រេចបានថែមទៀតផងដែរ។

ការគាំទ្រជាប្រចាំ គឺជាសេចក្តីត្រូវការចាំបាច់បំផុតដើម្បីជួយឱ្យគ្រូបង្រៀនសម្រេចបានតាមបទដ្ឋានបង្រៀន និងដើម្បីធានាឱ្យសិស្សានុសិស្សសម្រេចបានតាមបទដ្ឋានកម្មវិធីសិក្សា។ បញ្ហានេះ តម្រូវឱ្យមានការតស៊ូមតិនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងនៅថ្នាក់មូលដ្ឋានដើម្បីដាក់បញ្ចូលនូវសម្លេងដ៏ខ្លាំងរបស់គ្រូបង្រៀន និងសហគមន៍ទៅក្នុងការពិភាក្សាបញ្ហាអប់រំ។ អនុសាសន៍របស់របាយការណ៍រូបធាតុបង្រៀនត្រូវបានទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា (MoEYs)[២០] ប៉ុន្តែការបន្តការងារតស៊ូមតិនឹងត្រូវមានជាចាំបាច់ដើម្បីធានាឱ្យអនុសាសន៍ទាំងនោះត្រូវបានអនុវត្ត។ ជាពិសេសការតស៊ូមតិអំពីអនុសាសន៍ ដែលរួមមាននៅក្នុងការពង្រឹងយន្តការទំនាក់ទំនង និងកិច្ចពិភាក្សាដំណើរការធានាគុណភាព និងលើកកម្ពស់តម្លៃនៃគុណភាពសិក្សាចំពោះមាតាបិតា និងសហគមន៍ គឺជាតម្រូវការចាំបាច់” (VSO&NEP ឆ្នាំ២០០៨)។

---

[១៧] អង្គការស្ម័គ្រចិត្តបំរើបរទេស។

[១៨] អង្គការដៃគូអប់រំ។

[១៩] មន្ទីរអប់រំខេត្ត។

[២០] ក្រសួងអប់រំ យុវជន និងកីឡា។

## ១.៦ កម្មវិធីអប់រំ

ថ្វីត្បិតតែមានគោលនយោបាយ និងច្បាប់ដែលមានគោលបំណងដើម្បីសម្រេចបាននូវសមភាពយ៉ាងណាក៏ដោយ ក៏ប៉ុន្តែផ្នត់គំនិតដែលចាក់ឫសយ៉ាងជ្រៅ និងតួនាទីយេនឌ័រនៅក្នុងសង្គមកម្ពុជា ហើយក្រមសីលធម៌ "ច្បាប់ស្រី" នៅតែបន្តរាំងដល់ការអភិវឌ្ឍន៍នៅក្នុងវិស័យអប់រំដែរ។ "ច្បាប់ស្រី" គឺជា "ក្រិត្យក្រមសម្រាប់អប់រំចរិយាមាយាទ" ដែលមានគោលការណ៍សីលធម៌ជាច្រើនក្នុងនោះ បញ្ជាក់អំពីតួនាទី "សមរម្យ" របស់ស្ត្រីនៅក្នុងសង្គម ក្រមនេះពិតជាមានការរើសអើងលើស្ត្រីភេទយ៉ាងជាក់ស្តែងនៅក្នុងផ្នែកជាច្រើនក្នុងជីវិតរបស់ស្ត្រី។ តាមក្រមសីលធម៌នេះ ស្ត្រីត្រូវតែយល់ស្របតាមការសម្រេច និងបំណងរបស់ឪពុក និងស្វាមីទាំងស្រុងគ្រប់កាលៈទេសៈទាំងអស់។ ក្រមនេះ ក៏បានកំណត់នូវឥរិយាបទសមរម្យ និងមិនសមរម្យផងដែរ។ "ស្ត្រីដែលគួរឱ្យគេគោរព" ត្រូវបានបង្គាប់ឱ្យនៅស្ងៀមស្ងាត់ និងប្រុងប្រយ័ត្នជានិច្ច ព្រមទាំងមិនឱ្យសួរដេញដោលអំពីការសម្រេចចិត្តណាមួយរបស់ស្វាមីឡើយ។ ស្ត្រីតែងតែចុះចូល ទាបជាង និងមានឋានៈក្រោមស្វាមីជានិច្ច។

ម្យ៉ាងវិញទៀត ក្រមសីលធម៌នេះ ក៏អាចជាការជំរុញ និងបកស្រាយចំពោះឥរិយាបទដែលមិនប្រក្រតីរបស់ស្វាមី ដោយអះអាងថា តួនាទីរបស់ភរិយាត្រូវតែទ្រាំទ្រ អត់ធ្មត់ចំពោះបញ្ហាដែលកើតឡើងបែបនេះ ដោយបានបន្ថែមថា បញ្ហាទាំងនេះអាចបណ្តាលមកពីភរិយាផ្ទាល់ក៏មានដែរ។ ដូច្នេះ វត្តមាននៃច្បាប់ និងគោលនយោបាយនានា ដែលមានបំណងផ្តល់អំណាចឱ្យស្ត្រីត្រូវបន្ទុះបង្អាប់ដោយក្រមសីលធម៌នេះ។

ក្រមសីលធម៌នេះ ត្រូវផ្ទេរមកកុមារីតាមរយៈក្រុមគ្រួសារ និងបង្ហាញឱ្យឃើញយ៉ាងច្បាស់តាមរយៈសហគមន៍ជាទូទៅ ជួនកាលនៅតាមសាលារៀននានាយល់ថា ស្ត្រីមិនស្មើនឹងបុរស និងស្ថិតនៅក្នុងផ្នត់គំនិតរបស់ពលរដ្ឋកម្ពុជាគ្រប់រូប។ គេសង្កេតឃើញមានការខ្វែងគំនិតគ្នាអំពីការកសាងសមភាពយេនឌ័រ ហើយបញ្ហានេះបង្ហាញឱ្យឃើញច្បាស់នៅក្នុងគ្រប់ស្រទាប់សង្គមទាំងអស់។

បើនិយាយពីភាពធ្ងន់ធ្ងរនៃបញ្ហានេះ ក្រមសីលធម៌មានលក្ខណៈផ្ទុយទៅនឹងចលនាឆ្ពោះទៅរកសមភាព ហើយបណ្តាលឱ្យមានផលវិបាកមួយចំនួន។ ពិតជាប្រសើរ បើមានប្រព័ន្ធអប់រំមួយដែលអាចបកស្រាយពន្យល់ពីក្រមសីលធម៌ ហើយសួរដេញដោលក្រមនោះ ព្រមទាំងបង្ហាញពីស្ត្រីដែលជាគំរូថ្មីផ្អែកលើសមភាពយេនឌ័រ។ ទិដ្ឋភាពទាំងនេះ គួរត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សារបស់សាលានៅគ្រប់កម្រិតសិក្សាទាំងអស់។

## ១.៧ ស្ត្រីក្នុងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

នៅកម្ពុជាបច្ចុប្បន្ន ស្ត្រីមានចំនួនច្រើនជាងបុរសគឺ ៥២% នៃចំនួនប្រជាពលរដ្ឋសរុប។ ប៉ុណ្ណឹងហើយ ក៏ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននៅតែពិពណ៌នាអំពីស្ត្រីក្នុងលក្ខណៈអវិជ្ជមានជាច្រើនទៀត ហើយថែមទាំងបានជួយជំរុញឱ្យមានការមើលស្រាលស្ត្រី និងជាផ្នត់គំនិតថាជារបស់សម្រាប់បម្រើផ្លូវភេទ "តុបតែងលំអ" និងជាជនរងគ្រោះ។ ស្ត្រីក៏មិនសូវមានសម្លេងច្រើននៅក្នុងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែរ ថែមទាំងប្រឈមក្នុងភាពក្រីក្រ ក្នុងកម្រិតខ្ពស់ ទទួលបានការអប់រំទាប និងច្រើនតែមានបញ្ហាសុខភាព។ បញ្ហាទាំងអស់នេះបង្កើតបានជាឧបសគ្គយ៉ាងធំចំពោះសិទ្ធិស្ត្រី ហើយនឹងជះឥទ្ធិពលអវិជ្ជមានដល់ការរីកចំរើននៅក្នុងគោល

ដៅអភិវឌ្ឍន៍សហស្សវត្សរបស់កម្ពុជានាឆ្នាំ២០១៥។ ដូច្នេះ ការសម្រេចគោលដៅសំខាន់ៗទាំង៩ នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សនឹងត្រូវអូសបន្លាយពេលយូរជាងការសង្ឃឹមទុក ហើយតាមពិតប្រហែលជាមិនអាចសម្រេចបានទេ។

បើពិនិត្យមើលសារៈសំខាន់របស់ប្រព័ន្ធផ្សាយព័ត៌មាន ទំនាក់ទំនងសម្រាប់បញ្ជូនតំលៃ និងឥរិយាបទ ប្រព័ន្ធផ្សាយព័ត៌មានក៏អាចជាកម្លាំងមួយយ៉ាងខ្លាំងដែលអាចជួយក្នុងការលុបបំបាត់ការរើសអើងលើស្ត្រីភេទផងដែរ។ ប្រព័ន្ធផ្សាយព័ត៌មាននេះ អាចបញ្ចូលនូវគំរូថ្មីៗរបស់លក្ខណៈជាស្ត្រី និងលក្ខណៈជាបុរស ព្រមទាំងជំរុញឱ្យមានការគោរពសម្រាប់សេរីភាពផងដែរ។ ម្យ៉ាងទៀតប្រព័ន្ធនេះ ក៏អាចផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីសិទ្ធិ និងកាតព្វកិច្ចរបស់អ្នកទាំងនោះទាក់ទងជាមួយច្បាប់ និងគោលនយោបាយផងដែរ។ អំណាចរបស់ប្រព័ន្ធផ្សាយព័ត៌មាន ដែលជាឧបករណ៍សម្រាប់ផ្លាស់ប្តូរអប្បកិរិយា និងគំនិត ក៏ដូចជាលុបបំបាត់ផ្នត់គំនិតដែរ គឺត្រូវតែទទួលយកមិនអាចប្រកែកបានឡើយ។ ប៉ុន្តែ នៅក្នុងលក្ខណៈ និងកម្លាំងនេះដដែល ប្រព័ន្ធផ្សាយព័ត៌មានក៏អាចបែរជាជួយបង្កើនឱ្យមានការរើសអើងលើស្ត្រីភេទ គាំទ្រផ្នត់គំនិត និងទស្សនៈជាប្រពៃណីនានាទាក់ទងនឹងយេនឌ័រ។ ប្រព័ន្ធផ្សាយព័ត៌មាននេះ អាចផ្សព្វផ្សាយនូវគំរូអវិជ្ជមានរបស់លក្ខណៈជាស្ត្រី ព្រមទាំងចាត់ទុកថា អំពើហិង្សាលើស្ត្រីជារឿងធម្មតាថែមទៀតផង។ ស្ត្រីមិនសូវមានវត្តមាន និងតំណាងនៅលើប្រព័ន្ធផ្សាយព័ត៌មានទេ អាស្រ័យដោយកង្វះការយល់ដឹង និងការបណ្តុះបណ្តាលអំពីបញ្ហាយេនឌ័រក្នុងចំណោមអ្នកមានវិជ្ជាជីវៈផ្នែកនេះ ដែលមានមុខងារជាអ្នកដឹកនាំ និងសម្របសម្រួលនៅក្នុងប្រព័ន្ធផ្សាយព័ត៌មាននេះ ព្រមទាំងកង្វះការយកចិត្តទុកដាក់ពីសំណាក់រដ្ឋាភិបាលផងដែរ។ ទាំងអស់នេះគឺជាបញ្ហាដែលត្រូវបន្តការដោះស្រាយ។ ប្រព័ន្ធផ្សាយព័ត៌មាននេះ គឺមិនទាន់ត្រូវបានប្រើប្រាស់ជាយុទ្ធសាស្ត្រដើម្បីលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទនៅឡើយទេ ប៉ុន្តែប្រព័ន្ធនេះ នៅតែបន្តដើរតួជាឧបករណ៍មួយ ដែលគាំទ្រដល់ការរើសអើងលើស្ត្រីថាជាអំពើត្រឹមត្រូវទៅវិញ។

តាមការសិក្សាស្រាវជ្រាវរបស់មណ្ឌលព័ត៌មានស្ត្រីកម្ពុជា បានរកឃើញថា ស្ត្រីគឺជាក្រុមភាគតិចនៅក្នុងគ្រប់ផ្នែកទាំងអស់នៃប្រព័ន្ធផ្សាយព័ត៌មាន ដែលមានត្រឹមតែ១៧% ក្នុងចំណោមវិជ្ជាជីវៈខាងសារព័ត៌មាន ចំណែកឯ ២១%នៅក្នុងតួនាទីបច្ចេកទេស និង២៨% ក្នុងមុខងាររដ្ឋបាល។

លោកនាយកនៃសកលវិទ្យាល័យភូមិន្ទភ្នំពេញបានឱ្យដឹងថា យោងតាមព័ត៌មានពីវិទ្យាស្ថានទូរគមនាគមន៍កម្ពុជា ចំនួននិស្សិតភេទស្រីដែលចូលរៀនវិជ្ជាជីវៈខាងសារព័ត៌មាននៅក្នុងវិទ្យាស្ថាននេះ មានការកើនឡើងគួរឱ្យកត់សម្គាល់: នៅឆ្នាំ២០០៥ ចំនួននិស្សិតទាំងអស់ ២០នាក់ មាននិស្សិតស្រីតែ ២ នាក់ទេ ចំណែកឯឆ្នាំ២០០៩ ចំនួននិស្សិតទូទៅសរុប ៩០នាក់ ក្នុងនោះមាន ៣៥នាក់ជានិស្សិតស្រី។ កម្មវិធីបរិញ្ញាប័ត្រត្រូវរៀនរយៈពេល ៤ឆ្នាំ។

តាមការសិក្សាស្រាវជ្រាវរបស់មណ្ឌលព័ត៌មានស្ត្រីកម្ពុជានៅឆ្នាំ២០០៥ បានរាយការណ៍ថា មានឱកាសល្អៗច្រើនណាស់សម្រាប់និស្សិតកម្ពុជា ដែលមានចំណង់ចំណូលចិត្តរៀនសូត្រខាងវិជ្ជាជីវៈតាមប្រព័ន្ធផ្សាយព័ត៌មាន។ នៅក្នុងការសិក្សាស្រាវជ្រាវឆ្នាំ២០០៥ បានរកឃើញថា ក្នុងចំណោមវិទ្យាស្ថានអប់រំចំនួន៤៥ មានវិទ្យាស្ថានចំនួន ៧ (១៦%) ដែលបើកវគ្គ និងផ្តល់សញ្ញាប័ត្រផ្នែកផ្សព្វផ្សាយព័ត៌មាន ឬវិជ្ជាជីវៈ

ខាងសារព័ត៌មាន។ ក្នុងចំណោមនិស្សិតសរុប ៧៩៥នាក់ ដែលបានបញ្ចប់ការសិក្សាក្នុងនោះមាន ២០%ជាស្ត្រី។

យោងតាមមណ្ឌលព័ត៌មានស្ត្រីកម្ពុជាបានឱ្យដឹងថា ក្រសួងព័ត៌មានពុំមានស្ថិតិអំពីចំនួនអ្នកសារព័ត៌មានជាស្ត្រីនៅកម្ពុជាទេ។ ប៉ុន្តែតាមការសិក្សារបស់មណ្ឌលព័ត៌មានស្ត្រីកម្ពុជានៅឆ្នាំ២០០៥ ដែលធ្វើទៅលើអង្គការប្រព័ន្ធផ្សាយព័ត៌មានចំនួន ១៩៥ ហើយបានរាយការណ៍ថា ចំនួនអ្នកធ្វើការងារក្នុងប្រព័ន្ធផ្សាយព័ត៌មាន និងការងារទាក់ទងផ្នែកនេះមានសរុប ៤,៦២៣នាក់ ក្នុងនោះបុរសមាន ៣,៦៥២នាក់ (៧៩% ) និងស្ត្រីមាន ៩៧១នាក់ (២១%)។

អ្នកដែលធ្វើការផ្នែកប្រព័ន្ធផ្សាយព័ត៌មាន គឺស្ថិតនៅក្នុងតំណែង ៣ប្រភេទផ្សេងៗគ្នា: អ្នកសារព័ត៌មាន អ្នកបច្ចេកទេស និងរដ្ឋបាល។ ផ្នែកសារព័ត៌មានរួមមាន: អគ្គនិពន្ធនាយក បណ្ណាធិការ អ្នកនិពន្ធ អ្នកយកព័ត៌មាន អ្នកផ្សាយអានព័ត៌មាន និងផលិតករ។ ផ្នែកបច្ចេកទេសរួមមាន: អ្នកបច្ចេកទេស ប្រតិបត្តិករ (អ្នកកាន់កាមេរ៉ា វិទ្យុ និងឧបករណ៍ផ្សេងៗ)។ ផ្នែករដ្ឋបាលរួមមាន: បុគ្គលិករដ្ឋបាល គណនេយ្យ និងបុគ្គលិកទីផ្សារ។ ការសិក្សាស្រាវជ្រាវឆ្នាំ២០០៥ របស់មណ្ឌលព័ត៌មានស្ត្រីកម្ពុជា (WMC) ក៏នៅបានរកឃើញថា ក្នុងចំណោមអ្នកសារព័ត៌មានចំនួន ១៣៧នាក់ មានស្ត្រីតែ៦% ប៉ុណ្ណោះ ដែលស្ថិតក្នុងតំណែងអាចធ្វើការសម្រេចចិត្តបាន។ការសិក្សានោះ ត្រូវបានធ្វើទៅលើអង្គការប្រព័ន្ធផ្សាយព័ត៌មានគ្រប់គ្រងដោយរដ្ឋទូរទស្សន៍ជាតិ និងអន្តរជាតិឯកជន វិទ្យុ ភ្នាក់ងារសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយបោះពុម្ពនានានៅកម្ពុជា។

យោងតាមការសិក្សាថ្នាក់ជាតិឆ្នាំ២០០៥ របស់មណ្ឌលព័ត៌មានស្ត្រីកម្ពុជានេះដដែល បានបង្ហាញថារូបភាពស្ត្រីមានលក្ខណៈផ្សេងៗគ្នាទៅតាមប្រភេទប្រព័ន្ធផ្សាយព័ត៌មាននីមួយៗ។ ទូរទស្សន៍ និងវិទ្យុ ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយថា បានផ្សព្វផ្សាយរូបភាពស្ត្រីជាវិជ្ជមាន ប៉ុន្តែប្រព័ន្ធផ្សាយព័ត៌មានបោះពុម្ពវិញ បានផ្សព្វផ្សាយរូបភាពស្ត្រីជាអវិជ្ជមាន។ រូបភាពអវិជ្ជមានរបស់ស្ត្រីនៅក្នុងសារព័ត៌មានបោះពុម្ព គឺពាក់ព័ន្ធទៅនឹងភាពមិនខ្វល់ខ្វាយអ្វីទាល់តែសោះរបស់បុគ្គលិកផ្នែកនេះ និងដើម្បីបំពេញតម្រូវការទីផ្សារ។

ការសិក្សាក៏បានរកឃើញផងដែរថា ៦៩% នៃសាធារណៈជនទូទៅបានវិនិច្ឆ័យអំពីរូបភាពស្ត្រីលើប្រព័ន្ធផ្សាយព័ត៌មានថាជារូបអវិជ្ជមាន។ ប៉ុន្តែក្រុមគោលដៅនានាក៏បានរកឃើញនូវគុណសម្បត្តិមួយចំនួនដែលអាចកើតចេញពីរូបភាពមិនសមរម្យ (អវិជ្ជមាន) របស់ស្ត្រីនៅក្នុងប្រព័ន្ធផ្សាយព័ត៌មានដែរ។ ការចុះផ្សាយបែបនេះ អាចជួយអប់រំ ការពារស្ត្រីពីអំពើហិង្សានានា ហើយក៏បានដើរតួជាកត្តាលីករមួយដើម្បីជម្រុញរដ្ឋាភិបាល និងសហគមន៍ទូទៅឱ្យជួយអន្តរាគមន៍ និងការពារស្ត្រី និងកុមារដែលងាយរងគ្រោះ។

ប្រព័ន្ធផ្សាយព័ត៌មាន ជាពិសេសផ្នែកបោះពុម្ព គួរធ្វើការផ្លាស់ប្តូររបៀបចុះផ្សាយរូបភាពស្ត្រីជាអវិជ្ជមាន ដោយការលុបបំបាត់ចោលនូវការរៀបរាប់លំអិតអំពីករណីរំលោភសេពសន្ថវៈ និងមិនគួរចុះផ្សាយរូបថតជនរងគ្រោះឡើយ។

តាមប្រព័ន្ធផ្សាយព័ត៌មានទាំងអស់បានបង្ហាញពីតួនាទីសំខាន់ៗ ជាងគេចំនួនបីរបស់រូបភាពស្ត្រីគឺ: ជាជនរងគ្រោះ (៥៨%) តួនាទីវិជ្ជមាន (២៧%) និងជាឧបករណ៍សម្រាប់ផ្លូវភេទ (២២%) ។ បើប្រៀបធៀបទៅនឹងការស្រាវជ្រាវនៅឆ្នាំ១៩៩៥ ការស្រាវជ្រាវនៅឆ្នាំ២០០៥ នេះ បានបង្ហាញនូវកំណើនរូបភាពស្ត្រីដែល

ជាជនរងគ្រោះ ប៉ុន្តែមានការថយចុះតួនាទីវិជ្ជមាន ហើយមានការថយចុះបន្តិចបន្តួចពីបញ្ហាស្ត្រីដែលជាឧបករណ៍សម្រាប់ផ្លូវភេទ។

ការស្រាវជ្រាវដដែលនេះ ក៏បានរកឃើញអំពី "តួនាទីដែលមានការពេញចិត្ត" ចំនួន៥ ចំពោះរូបភាពស្ត្រីនៅក្នុងប្រព័ន្ធផ្សាយព័ត៌មានគឺ: ជាជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ ជាជនរងគ្រោះនៃអំពើរំលោភសេពសន្ថវៈ ជាមាតា ជាស្ត្រីដែលមានការខ្វាយខ្វល់ចំពោះបញ្ហាសុខភាព ដូចជាសុខភាពផ្លូវភេទ និងតួនាទីផ្សេងទៀត: ករណីផ្សេងទៀតដែលស្ត្រីជាជនរងគ្រោះដែរ ស្ត្រីទទួលបានជោគជ័យនៅក្នុងអាជីពផ្សេងៗ ស្ត្រីជាអ្នកដឹកនាំ អ្នកនិពន្ធ ជាស្ត្រីជួយស្ត្រីដូចគ្នា លើកស្ទួយស្ត្រីឱ្យទទួលបានការអប់រំ។ល។ មូលហេតុ ៣ សំខាន់ៗដែលលើកឡើងនៅក្នុងការពេញចិត្តនេះគឺ: ដើរតួជាការព្រមាន ឬរំឭកដល់បុរសៗកុំឱ្យប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារទៀត ដើម្បីអប់រំបុរសៗកុំឱ្យរំលោភស្ត្រី និងដើម្បីលើកទឹកចិត្តស្ត្រីឱ្យក្លាយជាមាតាដ៏ល្អ ដែលដឹកនាំគ្រួសារ និងចិញ្ចឹមកូនៗឱ្យបានល្អប្រសើរ។

យោងតាមការឃ្លាំមើលដែលធ្វើឡើងដោយមណ្ឌលព័ត៌មានស្ត្រីកម្ពុជាបានឱ្យដឹងថា ទស្សនាវដ្តីមួយចំនួន ដែលកំពុងធ្វើការចែកផ្សាយនៅកម្ពុជា បានកើនឡើងយ៉ាងខ្លាំងអាស្រ័យដោយមានកំណើននៃតម្រូវការរបស់អ្នកអាន។ តែការបោះពុម្ពផ្សាយដ៏ច្រើននេះ បានធ្វើឱ្យមានការលំបាកក្នុងការត្រួតពិនិត្យឃ្លាំមើលផងដែរចំពោះការរៀបរាប់អំពីស្ត្រីនៅក្នុងប្រព័ន្ធផ្សាយព័ត៌មាននេះ។ ប៉ុន្តែមណ្ឌលព័ត៌មានស្ត្រីកម្ពុជាបានរកឃើញថា ស្ត្រីនៅតែត្រូវបានគេផ្សព្វផ្សាយក្នុងប្រព័ន្ធផ្សាយព័ត៌មានទាំងពីរបែប គឺវិជ្ជមាន និងអវិជ្ជមានដដែល។ ឧទាហរណ៍ខ្លះៗអំពីការចុះផ្សាយរឿងរ៉ាវស្ត្រីជាអវិជ្ជមានដូចជា "ការក្លាយជាជនរងគ្រោះ" របស់ស្ត្រី ដោយករណីខ្លះស្ត្រីជាជនរងគ្រោះដោយល្បែងស្នេហា ដោយស្វាមីនាងមានស្នេហាថ្មី អំពើហិង្សាក្នុងគ្រួសារ និងរំលោភសេពសន្ថវៈជាដើម។ លើសពីនេះទៅទៀត ពេលដែលស្ត្រីត្រូវបានចុះផ្សាយជាលក្ខណៈមានសមភាព និងមានអំណាចនោះ ស្ត្រីដែលត្រូវបានរៀបរាប់ជាស្ត្រីដែលមានប្រជាប្រិយភាព ឬអ្នកចម្រៀង និងតារាល្បីៗ ដែលទាំងអស់នេះរួមបញ្ចូលគ្នា មានចំនួនតិចក្នុងចំណោមប្រជាពលរដ្ឋសរុប។ បញ្ហានេះ អាចនាំឱ្យកើនគ្រោះថ្នាក់កាន់តែច្រើនដងថែមទៀត: ទីមួយគឺ ស្ត្រីកម្ពុជាធម្មតា គឺកម្រត្រូវបានលេចមុខជាស្ត្រីមានអំណាចណាស់ ឬសូម្បីតែមានភាពស្មើគ្នាជាមួយបុរសក៏គ្មានដែរ។ ទីពីរគឺ ស្ត្រីវ័យក្មេងត្រូវបានលើកទឹកចិត្តឱ្យយកគំរូតាមតួអង្គស្ត្រីដែលមានប្រជាប្រិយភាព ហើយបែរជាមានបំណងប្រាថ្នាមិនពិតក្លាយជាអ្នកចម្រៀង ឬតារាល្បីល្បាញទៅវិញ។

អ្វីដែលគួរឱ្យកត់សម្គាល់គឺ តាំងពីឆ្នាំ២០០៥មក ក្រសួងព័ត៌មានបានដាក់ចេញនូវបទបញ្ញត្តិមួយចំនួនដល់ប្រព័ន្ធផ្សាយព័ត៌មានទាំងអស់ ព្រមទាំងរំឭកអ្នកទាំងអស់នោះឲ្យគោរពច្បាប់ស្តីពីរបបសារព័ត៌មានត្រង់ជំពូក២ មាត្រា៧ ដែលចែងថា "ហាមបោះពុម្ពផ្សាយអត្ថបទ ឬ រូបភាពអាសអាភាស និងរូបភាពនៃអំពើហិង្សា"។ ក្រសួងព័ត៌មានថែមទាំងបានផ្ញើលិខិតជូនដល់ក្រុមហ៊ុនទស្សនាវដ្តីមួយចំនួនឱ្យឈប់ចុះផ្សាយអត្ថបទអាសអាភាស និងរូបភាពហិង្សានៅលើទំព័រទស្សនាវដ្តី។

ក្នុងសម័យប្រជុំប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ស្តីពីសកម្មភាពរបស់ក្រុមប្រឹក្សានេះនៅឆ្នាំ២០០៧ នាយករដ្ឋមន្ត្រីក៏បានផ្តល់អនុសាសន៍ឱ្យក្រសួងមហាផ្ទៃបិទហាងបញ្ចាំង និងលក់វីស៊ីឌី ឬឌីវីឌីអាសអាភាស។

ជាសេចក្តីសន្និដ្ឋាន មណ្ឌលព័ត៌មានស្ត្រីកម្ពុជាបានផ្តល់យោបល់ឱ្យធ្វើការតស៊ូមតិ ដើម្បីកែលំអការចុះផ្សាយបញ្ហាស្ត្រីនៅក្នុងប្រព័ន្ធផ្សាយព័ត៌មាននានា ហើយថាគួរតែឈានទៅមុខ និងបន្តជានិច្ចដោយនៅមានបញ្ហាជាច្រើនទៀតដែលត្រូវតែអនុវត្ត។

## ១.៨ ស្ត្រី និងបច្ចេកទេសទូរគមនាគមន៍ និងព័ត៌មានវិទ្យាថ្មីៗ

ដូចដែលគណៈកម្មាធិការនៃអង្គការសហប្រជាជាតិទទួលបន្ទុក CEDAW បានលើកអនុសាសន៍នៅក្នុងរបាយការណ៍មុនរួចហើយ ថាកម្ពុជាត្រូវប្រឹងប្រែងឱ្យអស់ពីលទ្ធភាពដើម្បីលើកស្ទួយឱ្យស្ត្រីអាចទទួលបាននូវបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ថ្មីៗ។ ជំនាញប៉ិនប្រសប់ខាងឧបករណ៍គ្រប់គ្រងព័ត៌មានទាំងនេះ គឺមានសារៈសំខាន់ខ្លាំងណាស់ មិនមែនគ្រាន់តែសម្រាប់ទំនាក់ទំនង និងការទទួលបានភ្លាមៗនូវខ្លឹមសារ និងចំណេះដឹងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយសម្រួលឱ្យមានភាពងាយស្រួលក្នុងការហាក់ចូលទៅក្នុងទីផ្សារការងារ និងការបណ្តុះបណ្តាលបន្តថែមទៀតផង។

ស្ត្រីកម្ពុជាភាគច្រើនមិនមានចំណេះដឹងក្នុងការប្រើប្រាស់បច្ចេកទេសព័ត៌មានវិទ្យាទេ។ ការយល់ដឹងអំពីបច្ចេកទេសព័ត៌មានវិទ្យា និងអំពីរបៀបដែលត្រូវប្រើប្រាស់ជាយុទ្ធសាស្ត្រ ដើម្បីលុបបំបាត់អំពើហិង្សាលើស្ត្រីនោះ នៅមានកម្រិតនៅឡើយ។ ឧទាហរណ៍ បច្ចេកទេសព័ត៌មានវិទ្យាអាចជួយស្ត្រីឲ្យចេះចែករំលែកបទពិសោធន៍ ប្រមូលផ្តុំការគាំទ្រសម្រាប់សកម្មភាពជាក់លាក់ណាមួយ ព្រមទាំងបង្កើតយុទ្ធសាស្ត្រជាសកលដើម្បីបញ្ចប់អំពើហិង្សាលើស្ត្រី។ ទន្ទឹមនឹងនេះ ជីវភាពរបស់ស្ត្រីក៏នៅតែមានទំនាក់ទំនងរវាងការយល់ដឹងអំពីបច្ចេកទេសព័ត៌មានវិទ្យាជាមួយនឹងការជោគជ័យក្នុងការអប់រំ និងការងារ។

ការសិក្សាស្រាវជ្រាវមួយធ្វើឡើងដោយក្រសួងកិច្ចការនារី និងក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយវិទ្យាស្ថានបើកទូលាយក្នុងឆ្នាំ២០១០ កន្លងទៅ គេរកឃើញថាមានគម្លាតយេនឌ័រយ៉ាងធំទាក់ទងនឹងចំនួនសិស្សរៀនមុខវិជ្ជាបច្ចេកទេសព័ត៌មានវិទ្យានេះ។ ក្នុងចំណោមសិស្សជាង ១,០០០ នាក់បានរៀនចប់មុខវិជ្ជានេះ ក្នុងរយៈពេល៩ឆ្នាំកន្លងមក គេសង្កេតឃើញមានស្ត្រីត្រឹមតែ ១២% ប៉ុណ្ណោះទេ។ ហើយឆ្នាំ២០០៥ ដល់ ឆ្នាំ២០០៩ ភាគរយនៃសិស្សស្រីរៀនខាងបច្ចេកទេសព័ត៌មានវិទ្យានេះបានកើនឡើងត្រឹម ១២.៥%។ ភាគរយនៃស្ត្រីរៀនមុខវិជ្ជានេះពីឆ្នាំ២០០៩ ដល់ ឆ្នាំ២០១០ ក្នុងពេលបច្ចុប្បន្ននេះ គឺត្រឹមតែ ៩.១% ប៉ុណ្ណោះ។

ក្នុងចំណោមផ្នែកបច្ចេកទេសព័ត៌មានវិទ្យាធំៗទាំងបី (វិទ្យាសាស្ត្រកុំព្យូទ័រ និងវិស្វករ/ព័ត៌មានវិទ្យាអេឡិកត្រូនិក និងវិទ្យាសាស្ត្រអគ្គិសនី ព្រមទាំងប្រព័ន្ធផ្សាយព័ត៌មាន និងទូរគមនាគមន៍) វិទ្យាសាស្ត្រកុំព្យូទ័រ និងវិស្វករ/ព័ត៌មានវិទ្យា គឺជាមុខវិជ្ជាដែលទាក់ទាញបានសិស្សច្រើនជាងគេបំផុត។ ខាងប្រព័ន្ធផ្សាយព័ត៌មាន និងទូរគមនាគមន៍មានសមាមាត្រសិស្សស្រីខ្ពស់ជាងគេបង្អស់។ ក្នុងឆ្នាំសិក្សា២០០៩ – ២០១០ ចំនួនសិស្សសរុបបានកើនឡើងបីដងរហូតដល់ជាង ៣,០០០ នាក់ ប្រៀបធៀបនឹងបួនឆ្នាំមុន។ បើប្រៀបធៀបនឹងពីរឆ្នាំមុនកើនពីរដង។ នៅស្ថាប័នក្រោយឧត្តមសិក្សា សិស្សស្រី ៣៥% បានបង្ហាញនូវចំណាប់អារម្មណ៍ក្នុងការរៀនមុខវិជ្ជាទាក់ទងនឹងព័ត៌មានវិទ្យាក្នុងឆ្នាំសិក្សា២០០៧ -២០០៨។ ប៉ុន្តែនៅឆ្នាំក្រោយៗមកទៀតចំនួននេះបានថយចុះអស់១/៣ ដែលថយពី ៣២០ មកនៅត្រឹមតែ ១៣០នាក់ប៉ុណ្ណោះ។ ក្នុងឆ្នាំសិក្សា ២០០៩ - ២០១០

ចំនួនសិស្សបន្តការសិក្សានៅឆ្នាំទី២ បានថយចុះមកនៅត្រឹមតែ ៧៤ នាក់ ប៉ុណ្ណោះទោះបីជាចំនួននេះបានឡើងនៅឆ្នាំទី១ក៏ដោយ។ ប៉ុន្តែសមាមាត្រ សិស្សស្រីនៅក្នុងឆ្នាំសិក្សានេះ គឺត្រឹមតែ ៥% ប៉ុណ្ណោះ។

ការសិក្សាបន្ទាប់ពីធ្វើការពិភាក្សាជាមួយក្រុមនិស្សិតព័ត៌មានវិទ្យា បានរកឃើញថា និស្សិតស្រីដែលជ្រើសរើសរៀនខាងបច្ចេកទេសព័ត៌មានវិទ្យា មិនសូវមានច្រើនដូចនិស្សិតបុរសទេ អាស្រ័យកត្តាមួយចំនួនគឺ: គេយល់ថា ការងារខាងបច្ចេកទេសព័ត៌មានវិទ្យានេះ គឺជាការងារលំបាក ហើយជាធម្មតា គឺមានតែបុរសទេដែលអាចធ្វើបាន។ គេយល់ថា មុខវិជ្ជានេះពិបាកសិក្សា ដោយសារតែទាក់ទងនឹងគណិតវិទ្យាច្រើន ហើយដោយសារតែជំនាញនេះត្រូវរៀនមុខវិជ្ជាច្រើន ពុំមានការលើកទឹកចិត្តពីសំណាក់ក្រុមគ្រួសារ ហើយក្រុមហ៊ុនច្រើនតែជ្រើសរើសបុគ្គលិកបុរសៗ។ ដោយសារនិស្សិតស្រីពុំសូវមានចំណាប់អារម្មណ៍ក្នុងការរៀនខាងបច្ចេកទេសព័ត៌មានវិទ្យា គួបផ្សំនឹងកត្តាប្រពៃណីខ្មែរ(សម្ពាធផ្នត់គំនិត និងប្រពៃណីដែលបង្អាក់ស្ត្រីពីការសិក្សា)។ គេយល់ជាទូទៅថា បច្ចេកទេសព័ត៌មានវិទ្យាជាការងារខាងជួសជុល ត្រូវចំណាយថវិកាច្រើន ហើយម្យ៉ាងទៀតស្ត្រីត្រូវធ្វើការងារផ្ទះទៀតផង។

*ក្នុងការងារស្ត្រី និងបច្ចេកទេសព័ត៌មានវិទ្យាត្រូវដើរតាមក្រោយបុរសៗ ដូចបង្ហាញខាងក្រោម:*

លទ្ធផលនៃការសិក្សាបានបង្ហាញថា ស្ត្រីចំនួន ៤៤.៤% ដែលធ្វើការក្នុងអង្គការមិនមែនរដ្ឋាភិបាល មានចំណេះដឹងខាងបច្ចេកទេសព័ត៌មានវិទ្យា។ ចំនួននេះមានត្រឹមតែ ១៥.៥% ប៉ុណ្ណោះនៅក្នុងស្ថាប័នសាធារណៈ ៣២.៥% នៅក្នុងសេវាកម្មផ្តល់អ៊ីនធឺណិតហើយ៣៣.៣% ក្នុងវិស័យអប់រំ។

ការសិក្សាក៏បានបង្ហាញឱ្យឃើញដែរថា នៅតាមក្រសួងរដ្ឋនានាមានតម្រូវការខ្លាំងបំផុតនូវបុគ្គលិកដែលមានចំណេះដឹងផ្នែកបច្ចេកទេសព័ត៌មានវិទ្យាដល់ទៅ ៥៣% ជាមធ្យម ក្នុងចំណោម ១០នាក់ (មាន ៦០% ជាស្ត្រី)។ បន្ទាប់មក គឺស្ថាប័នអប់រំមានតម្រូវការ ៣៥% គឺជាមធ្យម ៥នាក់ (៤០% ជាស្ត្រី) ខាងអង្គការមិនមែនរដ្ឋាភិបាលមានតម្រូវការ ២៥% ជាមធ្យម ២នាក់ (៥០%ជាស្ត្រី) ម្នាក់គឺជាស្ត្រី (៥០%) ហើយផ្នែកឯកជន (ផ្នែកបំរើសេវាកម្មអ៊ីនធឺណិតនិងអ៊ីធឺណិតកាហ្វេ) ១១.៧% ជាមធ្យម ២នាក់ (៥០% ជាស្ត្រី)។

ចំពោះការសិក្សាអំពីការប្រកាសជ្រើសរើសបុគ្គលិកតាមគេហទំព័រ ជាទូទៅមានការងារកម្រិតខ្ពស់ប្រហែល ៥% ប៉ុណ្ណោះដែលមិនត្រូវការជំនាញបច្ចេកទេសព័ត៌មានវិទ្យាកម្រិតខ្ពស់។ ហើយភាគច្រើនតម្រូវឱ្យមានជំនាញខាងបច្ចេកទេសព័ត៌មានវិទ្យាក្នុងកម្រិតមធ្យម (៩៣.៩%) ។ ក្នុងការងារគ្រប់កម្រិតទាំងអស់ ១៤.៨% តម្រូវឱ្យមានជំនាញបច្ចេកទេសព័ត៌មានវិទ្យាកម្រិតមធ្យម។

បុរសប្រើប្រាស់អ៊ីនធឺណិតញឹកញាប់ជាងស្ត្រី។ ចំពោះអ្នកដែលមានឱកាសប្រើប្រាស់អ៊ីនធឺណិតគេប្រើស្ទើរតែរាល់ថ្ងៃ។ បុរសប្រើក្នុងកម្រិត ១៧% ហើយស្ត្រី ១៥.៣% ។ ចំពោះអ្នកដែលមានឱកាសប្រើប្រាស់អ៊ីនធឺណិតប្រើលើសពីរដងក្នុងមួយថ្ងៃ បើគិតជាភាគរយ បុរសប្រើ ១២.១% ហើយស្ត្រីប្រើក្នុងកម្រិត ៩.៥%។ ចំពោះអ្នកប្រើប្រចាំថ្ងៃ ភាគរយនៃបុរសគឺ ៤៥% ហើយស្ត្រីគឺ ៣៧.៨% ។

*ស្ថាប័នដែលមានគោលការណ៍លើកកម្ពស់ការរីកចម្រើនរបស់ស្ត្រី:*

អង្គការមិនមែនរដ្ឋាភិបាលប្រមាណ ២២.៥% មានគោលការណ៍លើកកម្ពស់ការ

អង្គការមិនមែនរដ្ឋាភិបាលប្រមាណ ២២.៥% មានគោលការណ៍លើកកម្ពស់ការកសាងសមត្ថភាពស្ត្រី។ ហើយនៅក្នុងស្ថាប័នរដ្ឋមានប្រមាណ ៣៥.៣% និងសេវាកម្មផ្តល់សេវាអ៊ីនធឺណេតមាន ៩.៣% ហើយស្ថាប័នអប់រំមាន ៣៤.៦%។

### *ការលំបាក និងឧបសគ្គនានាដែលរារាំងស្ត្រីពីការចូលរួមក្នុងវិស័យព័ត៌មានវិទ្យាៈ*

អ្នកឆ្លើយតបការសម្ភាសន៍ប្រមាណ ៦៦% បានបញ្ជាក់ថា ស្ត្រីត្រូវទទួលខុសត្រូវក្នុងក្រុមគ្រួសារច្រើនជាងបុរស ចំណែក ៦៤% យល់ថាមាតាបិតាភាគច្រើនផ្តល់ការគាំទ្រដល់កូនប្រុសជាងកូនស្រីនៅក្នុងការរៀនសូត្រថ្នាក់ខ្ពស់។ ប្រហែល៦០% យល់ថា គោលនយោបាយនានា និងគោលការណ៍អនុវត្តក៏ជាឧបសគ្គម៉្យាងដែរ។ ការលើកឡើងខ្លះទៀតមានៈ បញ្ហាភាសា (៥៧%) ហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេសព័ត៌មានវិទ្យានៅមានកម្រិត (៥៣%) តម្លៃការប្រើប្រាស់អ៊ីនធឺណិត(៥២%) បច្ចេកវិទ្យាទំនើបពេក (៤០%) ឧបសគ្គកើតឡើងដោយទម្លាប់សង្គម និងវប្បធម៌ (៣១%) ហើយស្ត្រីមិនត្រូវបានលើកទឹកចិត្ត ដោយអ្នកដឹកនាំរបស់ខ្លួនក្នុងការចូលរួមក្នុងផ្នែកបច្ចេកទេសព័ត៌មានវិទ្យា (២៦%)។

### *អនុសាសន៍*

ដោយសារកម្ពុជាភាគច្រើនជាតំបន់ជនបទ ហេតុនេះឱកាសទទួលបានចំណេះដឹងផ្នែកព័ត៌មានវិទ្យានេះនៅមានកម្រិតទាបនៅឡើយ។ ដូច្នេះសំខាន់ គឺត្រូវផ្តល់អាទិភាពក្នុងការកសាងបណ្តាញហេដ្ឋារចនាសម្ព័ន្ធដល់សហគមន៍ណាដែលពុំសូវទទួលបានសេវាកម្មច្រើន និងផ្តល់ការបណ្តុះបណ្តាលដើម្បីឱ្យស្ត្រីចេះពីរបៀបប្រើប្រាស់ធនធានទាំងនេះ។ ការងារជាច្រើនទៀតនៅតែសេសសល់ខាងមុខ។ មានតែនៅទីក្រុងប៉ុណ្ណោះ ដែលមានហេដ្ឋារចនាសម្ព័ន្ធរឹងមាំ ដែលអាចឱ្យស្ត្រីបានចូលរួមខ្លះៗក្នុងការបណ្តុះបណ្តាលលើផ្នែកនេះ។ រដ្ឋាភិបាលគួរបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេសព័ត៌មានវិទ្យានេះទូទាំងប្រទេស ហើយគួរដាក់បញ្ចូលព័ត៌មានវិទ្យានេះទៅក្នុងកម្មវិធីសិក្សាថ្នាក់វិទ្យាល័យនៅទីណាដែលអាចធ្វើទៅបាន។ លើសពីនេះទៅទៀតរដ្ឋាភិបាលគួរបន្តជម្រុញលើកទឹកចិត្តសិស្សស្រីឱ្យសិក្សាព័ត៌មានវិទ្យាតាមរយៈការផ្តល់អាហារូបករណ៍ និងបញ្ចុះតម្លៃសិក្សា។

សហគ្រាសឯកជន ក្រសួង និងស្ថាប័នសាធារណៈនានាគួរផ្តល់ឱកាសកម្មសិក្សា និងការងារដល់និស្សិតដែលទើបបញ្ចប់ការសិក្សាថ្មីៗ ជាពិសេសនិស្សិតស្រី។ ជាពិសេសផ្នែកខាងការហាត់ការ (ស្ម័គ្រចិត្ត) និងផ្តល់ឱកាសការងារឱ្យបានច្រើនដល់ស្ត្រី។

រដ្ឋាភិបាលគួរលើកទឹកចិត្តឱ្យមានការបង្កើតកម្មវិធីកុំព្យូទ័រ ដែលប្រើប្រាស់ភាសាខ្មែរច្រើនថែមទៀត។

ជាចុងក្រោយបង្អស់ បើអាចធ្វើបាន គួរធ្វើការសិក្សា និងស្រាវជ្រាវទូទាំងប្រទេសអំពីបញ្ហានេះ។

## ១.៩ ស្ត្រីជនជាតិភាគតិចពូជសាសន៍ខុសៗគ្នា និងស្ត្រីពិការ

បញ្ហាមួយក្នុងចំណោមបញ្ហានានា ក្នុងការវាយតម្លៃសមភាពយេនឌ័រនៅក្នុងប្រព័ន្ធអប់រំកម្ពុជា គឺការមិនទាន់បញ្ចូលគ្នាឱ្យបានល្អនៃស្ត្រីជនជាតិដើម និងស្ត្រីពិការភាពរាងកាយ ឬផ្លូវចិត្ត។ ក្នុងករណីទាំងពីរនេះ ប្រព័ន្ធអប់រំខ្វះការទទួលស្គាល់អំពីតម្រូវការពិសេសរបស់អ្នកទាំងនោះ។

ចំពោះក្រុមស្ត្រីជនជាតិភាគតិចពូជសាសន៍ខុសៗគ្នា ភាសានៅតែជាបញ្ហាមួយចម្បង ដើម្បីឈានចូលទៅក្នុងការអប់រំក្នុងប្រព័ន្ធ ដោយកម្មវិធីសិក្សា ពុំបានផ្តល់លទ្ធភាពជាភាសាផ្សេងឡើយ។ ស្ត្រីជនជាតិដើមភាគតិច ពុំបានដាក់បញ្ចូលទៅក្នុងរូបភាពនៃសៀវភៅអាន និងសំភារៈសិក្សានានាទេ ដែលជាការលំបាកសម្រាប់ពួកគេទាំងនោះ ក្នុងការលើកឧទាហរណ៍ និងលំហាត់ ដែលគ្រូដាក់នៅក្នុងថ្នាក់រៀន។



កម្ពុជា គឺជាសង្គមមួយដែលមានពូជសាសន៍ចម្រុះគ្នា ហើយភាគច្រើនគឺជាខ្មែរ។ នៅសល់ពីនេះគឺ មានដូចជា វៀតណាម ចាម ចិន ឥណ្ឌា និងក្រុមពូជសាសន៍ភាគតិចចំនួន១៦ក្រុមផ្សេងទៀត ដែលភាគច្រើនរស់នៅភូមិភាគឦសាន្ត។ ជនជាតិដើមទាំងនោះមាន ទំពួន ចារាយ គ្រឹង ព្រៅ កាវែត ភ្នង កាចក់ ព្រៅ ស្អូច ធិចខុង ផ្ទុន ក្រូល មីល គួយ ស្ងួយ និងស្ទៀង។ ប្រជាពលរដ្ឋទាំងនេះជួបការលំបាកក្នុងការរក្សាការពារប្រពៃណីរបស់ខ្លួន នៅសម័យអភិវឌ្ឍសេដ្ឋកិច្ចពិភពលោកគំរូនេះ។

ភាសា គឺជាឧបសគ្គរាំងដល់ការធ្វើសមាហរណកម្មសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋទាំងនេះ។ ស្ថានភាពសុខភាព និងស្ថានភាពរស់នៅរបស់សហគមន៍ទាំងនេះ គឺក្រីក្រអាស្រ័យដោយជាតំបន់ដាច់ស្រយាល និងការបាត់បង់សិទ្ធិលើការគ្រប់គ្រងដីធ្លីរបស់អ្នកទាំងនោះ។ ការសាងសង់សាលារៀន ឬកន្លែងបង្រៀននៅក្នុងសហគមន៍ជនជាតិដើមភាគតិចត្រូវផ្តោតទៅលើលក្ខណៈពិសេសរបស់អ្នកទាំងនោះ។ ត្រូវតែផ្តល់គ្រូជាជនជាតិដើម ឬគ្រូដែលចេះនិយាយភាសារបស់ជនជាតិដើមទាំងនោះបាន។ បើធ្វើបានដូច្នេះ អាចជាការជួយសម្រួលយ៉ាងខ្លាំងក្នុងការដាក់បញ្ចូលស្ត្រីទាំងនេះទៅក្នុងប្រព័ន្ធអប់រំ។ បែបនេះក៏អាចជួយកាត់បន្ថយអត្រាអនក្ខរភាពបានមួយកម្រិត ហើយនាំឱ្យមានការរាប់បញ្ចូលជនជាតិដើមភាគតិច ជាពលរដ្ឋនៅក្នុងសង្គមកម្ពុជា។ ធ្វើបានដូច្នេះ នឹងនាំទៅរកភាពប្រសើរឡើងនូវស្ថានភាពរស់នៅ ដោយសារតែអ្នកទាំងអស់នោះបានប្រឈមមុខចំពោះការបាត់បង់ទម្រង់នៃការប្រកបរបរចិញ្ចឹមជីវិត ដែលជាប្រពៃណីរបស់អ្នកទាំងនោះទៅហើយ។

ស្ត្រីពិការក៏ជួបប្រទះបញ្ហានៅក្នុងប្រព័ន្ធអប់រំ ដែលខ្វះការទទួលស្គាល់តម្រូវការជាក់លាក់របស់អ្នកទាំងនោះផងដែរ។ គ្មាននរណាម្នាក់បានដឹងថាមានកុមារី និងស្ត្រីចំនួនប៉ុន្មាននាក់ទេ ដែលមានបញ្ហាក្នុង

ការធ្វើដំណើរ និងបញ្ហាខាងផ្នែកសតិបញ្ញា ដែលជាឧបសគ្គមិនអាចឱ្យអ្នកទាំងអស់នោះទៅរៀននៅសាលា បានព្រមទាំងមិនបានដឹងអំពីចំនួនសិស្សដែលមានការលូតលាស់ខាងប្រាជ្ញាផងដែរ។ ប្រព័ន្ធអប់រំកម្ពុជានាពេលបច្ចុប្បន្ន គឺពុំមានលក្ខណៈសម្បត្តិដោះស្រាយបញ្ហានេះឡើយ ទាំងគ្រូ និងកម្មវិធីសិក្សាសុទ្ធតែមិនទាន់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងការជួយបំពេញតាមតម្រូវការពិសេសរបស់សិស្សានុសិស្សទាំងនោះឡើយ ។

កម្ពុជាប្រឈមមុខនឹងការលំបាកយ៉ាងច្រើន ប្រសិនបើចង់ជម្រុញឱ្យប្រជាពលរដ្ឋទាំងអស់ក្លាយជាសិស្សសក្តានុពល (ភាពដែលអាចធ្វើអ្វីៗមួយទៅបាន) បានចូលសាលារៀននៅថ្ងៃមុខ។ ការរៀបចំកម្មវិធីសិក្សានៅក្នុងគោលដៅនេះមិនទាន់បានធ្វើនៅឡើយទេ។ ផលវិបាកនៃការមិនទទួលយក និងមិនឱ្យចូលរួមនៅក្នុងសង្គមរបស់ស្ត្រី ដែលស្ថិតនៅក្នុងក្រុមអន់ខ្សោយនេះនឹងនៅតែមានបន្ត។

## ២. បញ្ហា

កុមារកម្ពុជាប្រហែលជា ១០% មិនបានទទួលការអប់រំទេ។ ភាគច្រើនអ្នកទាំងនោះមកពីគ្រួសារក្រីក្រ គ្មានផ្ទះសំបែង និង/ឬជាកុមារបំរើការងារទាំងផ្លូវការ និងមិនផ្លូវការ។ យោងតាមស្ថិតិរបស់ក្រសួងអប់រំសម្រាប់ឆ្នាំសិក្សា២០០៧-២០០៨ អត្រាសិស្សរៀនបន្តពីថ្នាក់ទី១-ទី៦ គឺ៥៩.៥% ហើយពីថ្នាក់ទី១-ទី៩ គឺមានតែ៣៣.២% ប៉ុណ្ណោះទេ។ ទោះបីជាអត្រាចុះឈ្មោះចូលរៀនមានលក្ខណៈប្រសើរឡើងក៏ដោយ ក៏អត្រាបោះបង់ការសិក្សានៅក្នុងខេត្តគោលដៅមួយចំនួននៅតែខ្ពស់ដដែល។

គេសង្កេតឃើញមានតម្រូវការបន្តជួយឧបត្ថម្ភយូរអង្វែងមួយដល់សាលារៀន និងសហគមន៍នានា ដើម្បីស្វែងរកមូលហេតុផ្សេងៗដែលនាំឱ្យកុមារបោះបង់ការសិក្សា រួចហើយនឹងដោះស្រាយបញ្ហាទាំងអស់នោះ។ លទ្ធផលការសិក្សារបស់សិស្សានុសិស្សទាំងឡាយ ជាលទ្ធផលមួយគួរឱ្យភ្ញាក់ផ្អើល ជាពិសេសសិស្សថ្នាក់ទី១ ដល់ ទី៣ ផ្នែកភាសា និងគណិតវិទ្យា គឺមានប្រហែលតែ ៤៥% ប៉ុណ្ណោះទេ ដែលអាចទទួលបានតាមបទដ្ឋានគុណភាពអប់រំ ដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា (ក្រសួងអប់រំ ឆ្នាំ២០០៩)។ លោកគ្រូ អ្នកគ្រូមិនទាន់មានជំនាញក្នុងការបង្រៀនបែបទាក់ទាញក្នុងបទដ្ឋានខ្ពស់នៅឡើយទេ។ ការបន្តជួយឧបត្ថម្ភ នៅតែត្រូវការជាចាំបាច់ដើម្បីជួយឱ្យគ្រូបង្រៀនទទួលបានតាមបទដ្ឋានបង្រៀន និងដើម្បីធានាឱ្យសិស្សានុសិស្សទទួលបានតាមបទដ្ឋានកម្មវិធីសិក្សាផងដែរ។

អង្គការសង្គ្រោះកុមារន័រវេស (SCN) បានធ្វើការសិក្សាស្រាវជ្រាវមួយលើសាលាបឋមសិក្សានៅក្នុងខេត្តចំនួន៧ នៅកម្ពុជា រួមទាំងភ្នំពេញផងដែរ បានរកឃើញថា អត្រាចុះឈ្មោះចូលរៀនសម្រាប់កុមារីគឺនៅតែទាបជាងអត្រារបស់កុមារាៈ កុមារីមាន ៤៨% រីឯកុមារា៥២% (SCN ឆ្នាំ២០០៩) ។ នៅថ្នាក់អនុវិទ្យាល័យភាពខុសគ្នារវាងយេនឌ័រកាន់តែខ្ពស់ៈ កុមារី៤៦% រីឯកុមារា ៥៤%។ សាលារៀនតាមស្រុក និងខេត្ត មានការលំបាកក្នុងការអនុវត្តន៍គោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា តាមវិធីដែលផ្តល់ផលប្រយោជន៍ដល់កុមារទាំងអស់។ បញ្ហាទាំងអស់នេះ បង្ហាញឱ្យឃើញថា នៅមានតំរូវការបណ្តុះបណ្តាល និងការជួយឧបត្ថម្ភប្រចាំថ្ងៃយូរអង្វែងតទៅទៀត។

នៅថ្នាក់ជាតិ តំបន់ និងមូលដ្ឋាន ពិតជាមានតម្រូវការចាំបាច់ក្នុងការតស៊ូមតិដើម្បីឱ្យមានការដាក់បញ្ចូលសម្លេងរបស់គ្រូបង្រៀន និងសហគមន៍ ទៅក្នុងការពិភាក្សាអំពីការអប់រំឱ្យកាន់តែច្រើនជាងមុន។ អនុសាសន៍ដែលទទួលបានពីរបាយការណ៍វាយតម្លៃគ្រូបង្រៀន[២១] ត្រូវបានទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡាក៏ប៉ុន្តែការតស៊ូមតិត្រូវតែអនុវត្តបន្តដើម្បីធានាឱ្យអនុសាសន៍ទាំងនោះ ត្រូវបានអនុវត្តត្រឹមត្រូវ។

ជាពិសេស ការតស៊ូមតិអំពីអនុសាសន៍នៅក្នុង "ការពង្រឹងយន្តការទំនាក់ទំនង និងការពិភាក្សាដំណើរការធានាគុណភាព និងលើកស្ទួយតម្លៃគុណភាពអប់រំដល់សហគមន៍ និងមាតាបិតា" គឺជាតម្រូវការចាំបាច់បំផុត។

## ២.១ ប្រស្នាសួល

- កង្វះគោលនយោបាយច្បាស់លាស់ក្នុងការជ្រើសរើស ការអភិវឌ្ឍអាជីព បៀវត្សរ៍ ការតម្លើងឋានៈ/ទណ្ឌកម្ម និងការផ្ទេរគ្រូបង្រៀន ក៏ដូចជាការផ្សព្វផ្សាយជាសាធារណៈនៃផែនការអនុវត្ត។
- បញ្ហាធ្ងន់ធ្ងរចំពោះគុណភាពអប់រំ ជាលទ្ធផលកុមាររៀនចប់ថ្នាក់ទី៦ នៅមិនទាន់ចេះសរសេរ ឬធ្វើគណិតវិទ្យានៅក្នុងកម្រិតដែលបានរៀននោះនៅឡើយទេ។
- កង្វះយន្តការដើម្បីជៀសវាងកុំឱ្យសិស្សបង់ថ្លៃក្រៅផ្លូវការដល់គ្រូបង្រៀន (ផែនការអប់រំជាតិឆ្នាំ ២០០៧)។
- អត្រាបោះបង់ការសិក្សានៅតែខ្ពស់ និងកើតឡើងដដែលៗ ហើយមូលហេតុច្បាស់ចំពោះបញ្ហានេះ នៅមិនទាន់បានដោះស្រាយនៅឡើយទេ ហើយពុំទាន់រកឃើញដំណោះស្រាយណាមួយនៅឡើយទេ។
- ទោះបីជាក្រសួងអប់រំ យុវជន និងកីឡា ធ្លាប់ទទួលបានជោគជ័យច្រើនក្នុងការដាក់ពង្រាយគ្រូបង្រៀនទៅដល់តំបន់ដាច់ស្រយាលក៏ដោយក៏គេនៅពុំទាន់បានដឹងថា តើគ្រូបង្រៀនប៉ុន្មាននាក់នៅតែបន្តនៅក្នុងតំបន់ទាំងនោះតទៅទៀត។
- យោងតាមប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ នាយកសាលាដែលអនុវត្តកម្មវិធីអាហារូបករណ៍នៃ "កម្មវិធីជំនួយឧបត្ថម្ភវិស័យអប់រំកម្ពុជា (CESSP)"[២២] បានធ្វើការកត់សម្គាល់អំពីមូលហេតុមួយចំនួនចំពោះការបោះបង់ការសិក្សានេះ៖ ទី១ គឺបរិមាណអាហារូបករណ៍ មិនគ្រប់គ្រាន់សម្រាប់ក្រុមគ្រួសារដែលអាចឱ្យអ្នកទាំងនោះទុកកូនឱ្យរៀនតទៅទៀត ហើយទី២ គឺឪពុកម្តាយត្រូវការកូនដើម្បីជួយការងារក្រុមគ្រួសារតាមរយៈការដើរស៊ីឈ្នួលគេដើម្បីទទួលបានកម្រៃ។

---

[២១] សារៈសំខាន់ក្នុងការបង្រៀន គឺជាគោលនយោបាយស្តីពីការលើកទឹកចិត្ត និងសីលធម៌របស់គ្រូនៅកម្ពុជា។ ដៃគូអប់រំអង្គការមិនមែនរដ្ឋាភិបាល និងVSO ខែធ្នូ ឆ្នាំ២០០៨។

[២២] កម្មវិធីជំនួយឧបត្ថម្ភវិស័យអប់រំកម្ពុជា។

- មូលនិធិរដ្ឋាភិបាលសម្រាប់វិស័យអប់រំបានថយចុះជាលំដាប់ពី ១៩.២% នៅឆ្នាំ២០០៧ នៃថវិកាជាតិចុះមកនៅត្រឹមតែ ១៧% នៅឆ្នាំ២០០៩ប៉ុណ្ណោះ។ (ក្រសួងអប់រំ ឆ្នាំ២០០៩)។

## ៣. អនុសាសន៍

១) ត្រួតពិនិត្យ ពង្រឹង និងពង្រីកការអនុវត្តន៍សាលាមិត្តភាពកុមារតាមរយៈកម្មវិធីបណ្តុះបណ្តាលក្នុងប្រព័ន្ធនៅហ្នឹងកន្លែង និងហ្មត់ចត់។

២) អនុវត្តគោលនយោបាយជឿនលឿនស្តីពីការអប់រំកុមារពិការ។

៣) ធានាឱ្យបានរាល់កុមារគ្រប់អាយុចូលរៀន ជាពិសេសកុមារីឱ្យមានលទ្ធភាពចូលរៀនបាន។

៤) បង្កើនចំនួនគ្រូបង្រៀន ជាពិសេសនៅតំបន់ដាច់ស្រយាល ឬ តំបន់មានការខ្វះខាតច្រើន។

៥) បង្កើនថវិកាអាហារូបករណ៍របស់រដ្ឋាភិបាលសម្រាប់កម្រិតបឋមសិក្សា និងអនុវិទ្យាល័យ ដើម្បីកាត់បន្ថយអត្រាការបោះបង់ការសិក្សាក្នុងចំណោមកុមារក្រីក្រ និងកុមារី។

៦) បង្កើនថវិកាប្រតិបត្តិស្របទៅតាមផែនការសាលា។

៧) ប្រើប្រាស់ថវិការដ្ឋដើម្បីចំណាយផលិតឯកសារបង្រៀនពីរភាសា។

៨) លុបបំបាត់ចោលការបង់ថ្លៃក្រៅផ្លូវការ។

៩) បង្កើនចំនួនអាហារូបករណ៍ និងចំនួនទោចក្រយានសម្រាប់កុមារីថ្នាក់ទី៧-៩។

១០) ជម្រុញឱ្យមានការយល់ដឹង និងសមត្ថភាពក្នុងការវិភាគបញ្ហាយេនឌ័រនៅគ្រប់កម្រិត (ចាប់ពីសាលាថ្នាក់ជាតិរហូតដល់សហគមន៍)។

១១) បង្កើនកម្មវិធីអាហារូបករណ៍ដល់កុមារីក្រីក្របំផុត។

១២) ធានាឱ្យមានសុវត្ថិភាពដល់កុមារីទាំងអស់ដែលទៅសាលា។

១៣) តម្រូវឱ្យនាយកសាលា និង/ឬគ្រូបង្រៀនទៅជួបក្រុមគ្រួសារដែលមានកូនស្រីមានអាយុត្រូវចូលរៀនពីថ្នាក់ទី៤-៦។

១៤) សហការជាមួយសហគមន៍ ដើម្បីទប់ស្កាត់កុមារីពីការបោះបង់ការសិក្សា។

# ជំពូក៣ . នយោបាយ និងការសម្រេចចិត្ត

## ១. ស្ថានភាព

កម្ពុជាបានស្តាបនាច្បាប់ និងយន្តការជាច្រើនដែលមានន័យថា ដើម្បីធានាឱ្យបាននូវសមភាពក្នុងវិស័យអភិបាលកិច្ច និងការចូលរួមក្នុងនយោបាយ។ ទោះបីជាច្បាប់ទាំងនេះ ជាច្បាប់មានអព្យាក្រឹតចំពោះយេនឌ័រក្តី ក៏នៅតែមានអន្តរកម្មជាមួយទស្សនៈសង្គមអំពីតួនាទីដែលបុរស និងស្ត្រីគួរដើរតួនៅក្នុងសង្គម។ ឧទាហរណ៍ ការដឹកនាំត្រូវបានគេចាត់ទុកថាជាវិស័យមួយរបស់បុរសនៅក្នុងវប្បធម៌នានានៃប្រទេសតំបន់អាស៊ីអាគ្នេយ៍។

នៅផ្ទះត្រូវបានគេចាត់ទុកថា ជាកន្លែងដែលស្ត្រីកម្ពុជាធ្វើការសម្រេចចិត្តសម្រាប់ម្ហូបអាហារប្រចាំថ្ងៃ ប៉ុន្តែ ការគ្រប់គ្រងលើសពីនេះនៅក្នុងសង្គម គឺស្ថិតនៅក្នុងដៃរបស់បុរសៗ។ សញ្ញាណដែលស្ត្រីអាចមានការទទួលខុសត្រូវសង្គមលើសពីការងារផ្ទះរបស់អ្នកទាំងនោះ គឺច្រើនតែជួបការលំបាកលើមូលដ្ឋាន ដែលលើកឡើងថា ស្ត្រីពុំមានឧបករណ៍ ឬពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើការទាំងនោះទេ។ អាស៊ីអាគ្នេយ៍ គឺជាតំបន់មួយដែលការចូលរួមរបស់ស្ត្រីក្នុងការសម្រេចចិត្ត មានកម្រិតទាបជាងគេបំផុតនៅលើពិភពលោក។ ទំនៀមទម្លាប់ និងទស្សនៈសង្គមអំពីឋានៈរបស់ស្ត្រី គឺជាឧបសគ្គដ៏ធំបំផុតចំពោះការចូលរួមនៅក្នុងឆាកនយោបាយរបស់អ្នកទាំងនោះ។

នៅកម្ពុជា "ច្បាប់ស្រី" ដែលជាក្រមសីលធម៌របស់ស្ត្រី គឺមានភាពទូលំទូលាយណាស់។ ក្រមនេះចាត់ទុកថា ការចុះចូលរបស់ស្ត្រីចំពោះស្វាមី និងបុរសផ្សេងៗគឺជាកាយវិការសមរម្យត្រឹមត្រូវតាមច្បាប់ព្រមទាំងលើកទឹកចិត្តឱ្យស្ត្រីគោរពស្វាមី និងបុរសៗដោយឥតលក្ខខណ្ឌ។ អ្វីៗទាំងអស់ត្រូវតែគោរពតាមយកចិត្តទុកដាក់ និងស្វាត់ស្ញៀមនៅក្នុងក្រុមគ្រួសារនៅសាលា និងក្នុងជីវភាពប្រចាំថ្ងៃក្នុងសហគមន៍។ ទន្ទឹមនឹងនោះដែរ រដ្ឋបានទទួលស្គាល់តាមផ្លូវច្បាប់នូវសិទ្ធិរបស់ស្ត្រីក្នុងការមានសម្លេងផ្ទាល់ខ្លួនដើម្បីចូលរួមក្នុងការសម្រេចចិត្តដែលពាក់ព័ន្ធនឹងជីវិត និងសហគមន៍របស់ស្ត្រីទាំងអស់នោះ។

និយាយឱ្យចំទៅ គឺការចុះចូល និងការចូលរួមជាទស្សនៈផ្ទុយគ្នាស្រឡះ ហើយក្រិតក្រមសង្គមដែលមានសម្រាប់ស្ត្រី ហាក់ដូចជាមានឥទ្ធិពលខ្លាំងជាងសិទ្ធិស្របច្បាប់ទៅទៀត។ ប្រទេសហ្វីលីពីន និងវៀតណាមក៏ជួបប្រទះបញ្ហាស្រដៀងគ្នានេះដែរ។ ដូច្នេះការអនុវត្តន៍សិទ្ធិ និងកាតព្វកិច្ចផ្នែកច្បាប់តែមួយប៉ុណ្ណោះ មិនអាចមានប្រសិទ្ធិភាពផ្ទាល់យ៉ាងងាយទៅលើការលុបបំបាត់វិសមភាពយេនឌ័រឡើយ។ ឧទាហរណ៍ សិទ្ធិស្ត្រីក្នុងការបោះឆ្នោត មិនមានការធានាដែលស្ត្រីទាំងអស់នោះអាចអនុវត្តបានដោយសេរីទេ ដោយហេតុថា នៅក្នុងករណីជាច្រើន ក្រុមគ្រួសារ និងស្វាមីជាអ្នកសម្រេចចិត្តនូវជោគវាសនា និងមុខងារនៃការបោះឆ្នោតនោះ។

### ១.១ ច្បាប់ និងគោលនយោបាយ

រដ្ឋបានអនុម័តយុទ្ធសាស្ត្រជាច្រើន ដើម្បីលើកទឹកចិត្តឱ្យស្ត្រីចូលរួមក្នុងការសម្រេចចិត្តខាងនយោបាយ និងសាធារណៈ។ យុទ្ធសាស្ត្រទាំងនោះ រួមមាន យុទ្ធសាស្ត្រចតុកោណ និងផែនការអនុវត្តន៍

យុទ្ធសាស្ត្រជាតិ។ រដ្ឋាភិបាលក៏បានដាក់ចេញនូវគោលដៅ និងក្របខណ្ឌពេលវេលាដែលអាចកម្រិតចំនួនបានសម្រាប់ស្ត្រីក្នុងការសម្រេចចិត្តតាមរយៈគោលដៅអភិវឌ្ឍសហស្សវត្សរ៍ ហើយផែនការយុទ្ធសាស្ត្ររបស់ក្រសួងកិច្ចការនារីហៅថា ផែនការនារីរតនៈ ១ និង២ ជាដើម។ ផែនការនារីរតនៈ ៣ កំពុងត្រូវបានអនុវត្ត។ យោងតាមយុទ្ធសាស្ត្រចតុកោណរបស់កម្ពុជាដើម្បីរីកចំរើនការងារសមធម៌ និងប្រសិទ្ធិផល សមភាពយេនឌ័រជាផ្នែកមួយនៃយុទ្ធសាស្ត្រចតុកោណរីកចំរើនទាំងបួន គឺជាគោលនយោបាយអាទិភាព។ យុទ្ធសាស្ត្របានចែងថា "ស្ត្រី គឺជាសសរទ្រូងនៃសេដ្ឋកិច្ច និងសង្គមរបស់យើង"។

ជាងនេះទៅទៀត យុទ្ធសាស្ត្រចតុកោណទាំងមូល មានគោលបំណងដើម្បីកសាងដោយឈរលើគោលការណ៍អភិបាលកិច្ចល្អដើម្បីធានាឱ្យ "សម្លេងរបស់ជនដែលងាយរងគ្រោះជាទីបំផុតនៅក្នុងសង្គមត្រូវឮ និងពិចារណាយ៉ាងពេញលេញនៅក្នុងដំណើរនៃការសម្រេចចិត្ត" (រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៤) ។ នារីរតនៈទី២ ផ្អែកលើយុទ្ធសាស្ត្រចតុកោណ និងបញ្ជាក់ថាការដាក់ស្ត្រីឱ្យស្ថិតក្នុងស្ថានភាពជាអ្នកធ្វើការសម្រេចចិត្ត គឺជាអាទិភាពមួយសម្រាប់រយៈពេល ២០០៥-២០០៩។ អនុកម្មវិធីត្រង់ចំណុច ២.៣ នៅក្នុងនារីរតនៈទី២ មានគោលបំណងដើម្បី "អភិវឌ្ឍជំនាញ និងជំនឿជឿជាក់របស់ស្ត្រីដើម្បីរួមចំណែកកាន់តែខ្លាំងឡើងនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តគ្រប់លំដាប់ថ្នាក់ទាំងអស់នៃអភិបាលកិច្ច" និងដាក់ចេញនូវយុទ្ធសាស្ត្រច្បាស់លាស់អំពីរបៀបក្នុងការសម្រេចនេះ (រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៥)។ ដូចគ្នានេះដែរ ផែនការអភិវឌ្ឍយុទ្ធសាស្ត្រជាតិ និងច្បាប់រៀបចំអង្គការ ក៏បង្ហាញនូវការប្តេជ្ញាខ្ពស់ដើម្បីដាក់បញ្ចូលស្ត្រីនៅក្នុងការសម្រេចចិត្ត។

កម្ពុជាបានផ្តល់សច្ចាប័នលើវេទិកាសកម្មភាពក្រុងប៉េកាំង និងឈានជាជំហ៊ានៗដើម្បីអនុវត្តសកម្មភាពនេះ ដោយបានដាក់ចេញនូវគោលដៅច្បាស់លាស់ ដើម្បីសម្រេចឱ្យបានតំណាងស្ត្រីកាន់តែច្រើនឡើង។ ប៉ុន្តែកន្លងមក រដ្ឋាភិបាលបានប្រឹងប្រែងតិចតួចពេកក្នុងការកែទម្រង់ប្រព័ន្ធបោះឆ្នោត និងលើកទឹកចិត្តឱ្យគណបក្សនយោបាយអនុម័តវិធានការនានាដើម្បីសម្រេចឱ្យបានតំណាងស្មើគ្នារវាងបុរស និងស្ត្រី។

យ៉ាងណាក៏ដោយ កម្ពុជាក៏បានដាក់ចេញនូវវិធានការពិសេសៗមួយចំនួនដើម្បីធានាឱ្យមានតំណាងស្ត្រីនៅក្នុងថ្នាក់ក្រោមជាតិដែរ។ នៅឆ្នាំ២០០៨ សម្តេចនាយករដ្ឋមន្ត្រីបានប្រកាសថា សេចក្តីសម្រេចចិត្តក្នុងការតែងតាំងស្ត្រីម្នាក់ជាអភិបាលរងគ្រប់ខេត្ត និងស្រុក (អនុក្រឹត្យចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៩) ហើយបែបនេះ គឺនឹងមានអភិបាលរងខេត្ត២៤នាក់ និងអភិបាលរងស្រុក/ខណ្ឌ១៨៥នាក់ ត្រូវបានតែងតាំង។ ជំហានសំខាន់មួយទៀត គឺមាត្រា១១៨ នៃច្បាប់រៀបចំអង្គការ (ឆ្នាំ២០០៨) ដែលបានចែងថា ក្រុមប្រឹក្សាថ្នាក់ ក្រោមជាតិគួរតែមានតំណាងស្ត្រីនៅក្នុងគណៈកម្មាធិការ ដោយមានជាប្រធាន និងអនុប្រធានជាដើម។

នៅថ្នាក់ភូមិ មានម្នាក់ក្នុងចំណោមប្រធាន អនុប្រធាន និងសមាជិកភូមិ៣នាក់ត្រូវតែជាស្ត្រីភេទ និងនៅក្នុងក្រុមប្រឹក្សាឃុំ/សង្កាត់នីមួយៗត្រូវតែមានជនបង្គោលស្ត្រី និងកុមារ និងគណៈកម្មាធិការឃុំ/សង្កាត់សម្រាប់ស្ត្រី និងកុមារ។ អាស្រ័យដោយការខកខាន ឬកង្វះថវិកា ដូច្នេះក្រុមប្រឹក្សា និងគណៈកម្មាធិការជាច្រើននៅតែពុំទាន់មានជនបង្គោល និងគណៈកម្មាធិការដដែល ហើយគណៈកម្មាធិការដែលមានស្រាប់ច្រើនតែពុំមានសមត្ថភាព (Thon/Ou ឆ្នាំ២០០៩)។

ចំណុចសំខាន់ត្រូវកត់សម្គាល់ថា រាជរដ្ឋាភិបាលកម្ពុជាបានខកខានក្នុងការដាក់ឱ្យប្រើនូវកម្មវិធីពិសេសដើម្បីពង្រឹងតំណាងស្ត្រីនៅក្នុងផ្នែកយុត្តិធម៌ ទោះបីជាបញ្ហានេះត្រូវបានស្នើដោយគណៈកម្មាធិការនៃអង្គការសហប្រជាជាតិទទួលបន្ទុក CEDAW យ៉ាងច្បាស់នៅក្នុងបទអត្ថាធិប្បាយសន្និដ្ឋាន(អនុសាសន៍)នៃរបាយការណ៍អាណត្តិកន្លងមករបស់កម្ពុជា (ក្រសួងកិច្ចការនារី ឆ្នាំ២០០៨)។

ស្ទើរតែគ្រប់ក្រសួងទាំងអស់ បានបង្កើតឡើងក្រុមសកម្មភាពបញ្ជ្រាបយេនឌ័រ (GMAGs) និងផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ (GMAPs)។ ផែនការសកម្មភាពបញ្ជ្រាបយេនឌ័រនៅក្នុងក្រសួងចំនួន ១០ មានផែនការតែងតាំងស្ត្រីឱ្យមានឋានៈនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងរៀបចំបង្កើតគោលដៅសំខាន់ៗ ឧទាហរណ៍ គោលដៅដើម្បីតម្លើងស្ត្រីឱ្យដល់ឋានៈជាន់ខ្ពស់ (ក្រសួងកិច្ចការនារី ឆ្នាំ២០០៨)។ ចំណែកឯការបញ្ជ្រាបយេនឌ័រត្រូវបានផ្តល់ការយកចិត្តទុកដាក់យ៉ាងខ្លាំង ហើយគឺជាឧបករណ៍មួយយ៉ាងសំខាន់ដើម្បីសម្រេចបាននូវចំនួនស្ត្រីយ៉ាងច្រើននៅក្នុងឋានៈធ្វើការសម្រេចចិត្ត។ ជាធម្មតាច្រើនតែផ្តោតទៅលើការបង្កើតស្ថាប័ន ដើម្បីឱ្យទទួលបាននូវសមភាពយេនឌ័រកាន់តែខ្លាំងឡើងៗ ប៉ុន្តែមិនបង្កើតគោលនយោបាយ ឬកម្មវិធីទេ។ ផែនការសកម្មភាពបញ្ជ្រាបយេនឌ័រនេះ ក៏ច្រើនតែមិនអនុវត្តតាមវិធីសាស្ត្រដែលមានរចនាសម្ព័ន្ធយ៉ាងច្បាស់លាស់ទេ ហើយក៏មិនសូវយកចិត្តទុកដាក់ចំពោះបុព្វហេតុជាឫសគល់នៃវិសមភាពយេនឌ័រឡើយ នៅពេលបង្កើតយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនេះ (Hail ឆ្នាំ២០០៧)។ គួរមានមធ្យោបាយច្រើនថែមទៀតសម្រាប់ស្ត្រីចូលរួមក្នុងឆាកនយោបាយ ប្រសិនបើផែនការសកម្មភាពបញ្ជ្រាបយេនឌ័រដាក់ទិដ្ឋភាពទាំងនេះចូល និងយកចិត្តទុកដាក់ថែមទៀតដើម្បីផ្សះផ្សាក្រុមគ្រួសារ និងការទទួលខុសត្រូវខាងវិជ្ជាជីវៈដូចដែលមានចែងនៅក្នុងវេទិកាសកម្មភាពក្រុងប៉េកាំង។

ពុំមានការវាយតម្លៃ ឬត្រួតពិនិត្យនូវលទ្ធផលដើម្បីបង្ហាញឱ្យឃើញប្រសិទ្ធិភាពយ៉ាងណាចំពោះការអនុវត្តន៍ផែនការសកម្មភាពបញ្ជ្រាបយេនឌ័រនេះនាពេលកន្លងមកទេ។ ស្របជាមួយគ្នានេះដែរ អ្នកសង្កេតការណ៍មួយចំនួនបានកត់សម្គាល់ឃើញថា ការកែលំអផ្នែកច្បាប់នៅតែជាឯកសារនៅឡើយ ហើយពុំមានចេញជាផ្លែផ្កាប្រកបដោយប្រសិទ្ធិភាព ព្រមទាំងមិនទាន់មានសកម្មភាពច្បាស់លាស់នៅឡើយដែរ។



ដូចដែលគណៈកម្មាធិការនៃអង្គការសហប្រជាជាតិទទួលបន្ទុក CEDAW បានផ្តល់អនុសាសន៍រួចហើយថា ក្រសួងកិច្ចការនារីបានលើកស្ទួយយ៉ាងសកម្មដល់ស្ត្រីជាមេដឹកនាំ ព្រមទាំងបានគាំទ្រអង្គការមិនមែនរដ្ឋាភិបាល និងបណ្តាញនានាដែលបានកសាងសមត្ថភាពប្រកដោយជោគជ័យ ចំពោះស្ត្រីដែលអាចជាមេដឹកនាំនាពេលអនាគត តាមរយៈសកម្មភាពមួយចំនួនដូចជាកម្មវិធីការដឹកនាំស្ត្រីរបស់ក្រសួងកិច្ចការនារី និងកម្មវិធីកសាងសមត្ថភាព (CPWP) សម្រាប់មេដឹកនាំស្ត្រីថ្នាក់មូលដ្ឋាន បេក្ខជនជាស្ត្រីភេទ និងសមាជិកក្រុមប្រឹក្សាជាដើម។ សកម្មភាពជាច្រើនត្រូវបានបង្កើតឡើង និងអនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាល ហើយទទួលបានមូលនិធិតាមម្ចាស់ជំនួយអន្តរជាតិ ដោយមានការគាំទ្ររបស់ក្រសួងនានា។ លើសពីនេះក៏មានសកម្មភាព

ដើម្បីលើកកម្ពស់ការយោគយល់ និងការយល់ដឹងសម្រាប់បុរសៗចំពោះបញ្ហានេះផងដែរ។ ប៉ុន្តែការបណ្តុះបណ្តាល និងសកម្មភាពទាំងឡាយដែលសំដៅបញ្ជ្រាបចូលដល់បុរសផ្ទាល់ គេមិនដែលឃើញមានបុរសណាម្នាក់ដែលជាមន្ត្រីជាន់ខ្ពស់ក្នុងលំដាប់ម្រេចចិត្ត ចូលរួមក្នុងបណ្តុះបណ្តាលបែបនេះឡើយ។ នៅក្នុងសង្គមមួយដែលពោរពេញដោយឋានានុក្រមដូចជាកម្ពុជានេះ ជាការលំបាកបំផុតក្នុងការទាមទារឱ្យមានការផ្លាស់ប្តូរនៅពេលដែលធ្វើការជាមួយតែមន្ត្រីថ្នាក់ក្រោម និងថ្នាក់កណ្តាលតែប៉ុណ្ណោះ។

នៅក្នុងកម្មវិធីដែលគ្មានគោលបំណងយេនឌ័រផ្ទាល់នោះ មើលទៅដូចជាមានការខ្វះខាតគួរកត់សម្គាល់ពីការចូលរួមពីសំណាក់ស្ត្រីភេទ។ ចំពោះស្ត្រីដែលស្ថិតក្នុងឋានៈធ្វើការសម្រេចចិត្តលំដាប់ខ្ពស់ជាការសំខាន់ណាស់ក្នុងការកសាងវិជ្ជាជីវៈជំនាញ និងសមត្ថភាព ហើយមិនត្រឹមតែការយល់ដឹងរបស់អ្នកទាំងអស់នោះអំពីបញ្ហាយេនឌ័រឡើយ (ក្រសួងកិច្ចការនារី ឆ្នាំ២០០៨- Haile ឆ្នាំ២០០៧) ។

## ១.២ តំណាងស្ត្រីនៅក្នុងឆាកនយោបាយ

នៅក្នុងបទអត្ថាធិប្បាយសន្និដ្ឋាន (អនុសាសន៍) ឆ្នាំ២០០៦[២៣] គណៈកម្មាធិការនៃអង្គការសហប្រជាជាតិទទួលបន្ទុក CEDAW បានទទួលស្គាល់ថា ការចូលរួមរបស់ស្ត្រីមានការកើនឡើង ប៉ុន្តែរបាយការណ៍នោះនៅតែមានកង្វល់អំពីតំណាងស្ត្រី ដែលនៅពុំទាន់មាននៅគ្រប់លំដាប់ថ្នាក់ទាំងអស់ដែលធ្វើការសម្រេចចិត្ត។ គណៈកម្មាធិការនៃអង្គការសហប្រជាជាតិទទួលបន្ទុក CEDAW ក៏បានជំរុញរាជរដ្ឋាភិបាលកម្ពុជាឲ្យអនុវត្តផែនការយុទ្ធសាស្ត្រដែលមានសូចនាករ និងកាលវិភាគយ៉ាងច្បាស់លាស់ដើម្បីបង្កើនការចូលរួម និងតំណាងស្ត្រីនៅក្នុងសេចក្តីសម្រេចចិត្ត ។ គណៈកម្មាធិការនៃអង្គការសហប្រជាជាតិទទួលបន្ទុក CEDAW ក៏បានលើកអនុសាសន៍ ដើម្បីឱ្យមានការអនុម័តវិធានការពិសេសបណ្តោះអាសន្នផងដែរ[២៤] និងបើកកម្មវិធីបណ្តុះបណ្តាលលើកកម្ពស់ការយល់ដឹង អំពីការដឹកនាំស្តីពីសារៈសំខាន់នៃការចូលរួមរបស់ស្ត្រីនៅក្នុងការសម្រេចចិត្ត ( CEDAW ឆ្នាំ២០០៦)។

កន្លងមកមានការប្រឹងប្រែងឱ្យមានការរីកចំរើនគួរឱ្យកត់សម្គាល់ ឈានទៅរកការទទួលស្គាល់ជាផ្លូវការនៃសារៈសំខាន់របស់តំណាងស្ត្រី ដែលមានបញ្ញត្តិច្បាប់ និងស្ថាប័នបង្ហាញនូវកំណើននៃការយល់ដឹងចំពោះបញ្ហាយេនឌ័រ។ ជាពិសេស ក្រសួងកិច្ចការនារីបានធ្វើការលើកទឹកចិត្ត និងលើកស្ទួយយ៉ាងខ្លាំងឱ្យស្ត្រីបានចូលរួមក្នុងការសម្រេចចិត្តប្រកបដោយជោគជ័យគ្រប់លំដាប់ថ្នាក់។ ក្រសួងនានាក៏បានបង្កើនកិច្ចសហការអនុម័តយុទ្ធសាស្ត្រ សកម្មភាពបញ្ជ្រាបយេនឌ័រ និងស្វះស្វែងរកកិច្ចពិគ្រោះយោបល់ពីសំណាក់សង្គមស៊ីវិល។

គោលដៅអភិវឌ្ឍសហស្សវត្សរបស់កម្ពុជា បានកំណត់គោលដៅច្បាស់លាស់ចំពោះការចូលរួម និងតំណាងរបស់ស្ត្រីក្នុងឆាកនយោបាយ។ ត្រឹមឆ្នាំ២០១៥ សមាជិកសភា និងព្រឹទ្ធសភា ៣០% ត្រូវកាន់កាប់ដោយស្ត្រី។ ការប្រមើលមើលនូវសមាមាត្ររបស់ស្ត្រីក្នុងតួនាទីសម្រេចចិត្តផ្សេងៗទៀត គឺ១៥% ជារដ្ឋមន្ត្រី

[២៣] បទអត្ថាធិប្បាយសន្និដ្ឋានលេខ ២៣។

[២៤] បទអត្ថាធិប្បាយសន្និដ្ឋានលេខ ២៤។

និង១៨% ជារដ្ឋលេខាធិការ ។ ២០% ជាអនុរដ្ឋលេខាធិការ ១០% ជាអភិបាលខេត្ត និង២៥% ជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រីភេទ (រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៥) ។

ទោះបីជាចំនួនតំណាងស្ត្រីនៅក្នុងរដ្ឋសភាបានកើនឡើងដល់ ២២% បន្ទាប់ពីការបោះឆ្នោតឆ្នាំ២០០៨ ក៏ដោយ (ពី១៩% នៅឆ្នាំ២០០៣) ក៏ស្ត្រីនៅតែមិនទាន់បានចូលរួមយ៉ាងពេញលេញក្នុងឆាកនយោបាយរបស់អ្នកទាំងនោះដែរ។ មានស្ត្រីតិចតួចបំផុតនៅក្នុងតំណែងខ្ពស់ៗក្នុងជួររដ្ឋាភិបាល។ មានរដ្ឋមន្ត្រីតែ ២នាក់ប៉ុណ្ណោះ (៧.៧%) រដ្ឋលេខាធិការ ១៦នាក់ (៨.១%) និងអនុរដ្ឋលេខាធិការ ៣០នាក់ (១៥.៤%) ជាស្ត្រី។ មានក្រសួងចំនួន៦ ដែលគ្មានស្ត្រីទាល់តែសោះក្នុងតំណែងខ្ពស់បំផុត ដែលត្រូវធ្វើការសម្រេចចិត្ត (CPWP ឆ្នាំ២០០៨)។ ដូចគ្នានេះដែរ មានសមាជិកព្រឹទ្ធសភាជាស្ត្រី៩នាក់តែប៉ុណ្ណោះក្នុងចំណោម ៦១នាក់ (១៤.៨%) ។ នេះមានន័យថា កម្ពុជាមិនបានជោគជ័យក្នុងការសម្រេចឱ្យបាននូវគោលដៅសហស្សវត្ស ដែលកំណត់ថា សម្រេចឱ្យបាន១៧% ត្រឹមឆ្នាំ២០០៥ ហើយក៏មិនអាចបង្កើនសមាមាត្រ ដើម្បីសម្រេចឱ្យបានតាមគោលដៅនេះដែលបានកំណត់ឆ្នាំ២០១០ ទេ។

កម្ពុជានៅមិនទាន់មានស្ត្រីក្នុងតួនាទីជាអភិបាលខេត្តនៅឡើយទេ។ នៅក្នុងការបោះឆ្នោតថ្នាក់ស្រុកនិងខេត្តថ្មីៗបំផុត កាលពីខែឧសភា ឆ្នាំ២០០៩ មានតំណាងស្ត្រីតែ៣៧នាក់ប៉ុណ្ណោះ (១៣%) ដែលត្រូវបានជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សានៅរាជធានី និងខេត្តនានា ហើយស្ត្រី៣៦២នាក់ (១០%) ជាប់ជាសមាជិកក្រុមប្រឹក្សាក្រុង/ស្រុក/ខណ្ឌ (គជប ឆ្នាំ២០០៩) ។ តំណាងស្ត្រីនៅក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ បានកើនឡើងដល់ ១៤.៦% (សរុប ១.៦៦២នាក់) នៅក្នុងឆ្នាំ២០០៧ ចំណែកឯឆ្នាំ២០០៣ មានតែ ៨%ប៉ុណ្ណោះ។ ដូច្នេះគោលដៅ ១៥% ក្នុងឆ្នាំ២០១០ ស្ទើរតែបានសម្រេចទាំងស្រុង។ ប៉ុន្តែស្ត្រីជាមេឃុំមានចំនួនទាប ដែលមានត្រឹមតែ៦៩នាក់ (៤.៣%) នៃមេឃុំទាំងអស់នៅកម្ពុជា (UNDP ឆ្នាំ២០០៧)។



នៅក្នុងប្រព័ន្ធតុលាការមានស្ត្រីកាន់តែតិចថែមទៀត ក្នុងតំណែងធ្វើការសម្រេចចិត្ត ដែលស្ត្រីតែម្នាក់ប៉ុណ្ណោះនៅតុលាការកំពូល និងម្នាក់ទៀតនៅតុលាការឧទ្ធរណ៍។ ស្ត្រីកម្ពុជាជាចៅក្រមមានត្រឹមតែ៨.៥% ប៉ុណ្ណោះ ហើយព្រះរាជអាជ្ញាគិតជាភាគរយកាន់តែទាបថែមទៀតគឺត្រឹមតែ ២.៧% ប៉ុណ្ណោះ (ក្រសួងកិច្ចការនារី ឆ្នាំ២០០៨)។

កំណែទម្រង់វិមជ្ឈការកម្ពុជាអាចផ្តល់នូវក្របខណ្ឌមួយ ដែលអាចជួយបានច្រើនក្នុងការពង្រឹងការចូលរួមរបស់ស្ត្រី ក្នុងឆាកនយោបាយនៅគ្រប់លំដាប់ថ្នាក់ដែលធ្វើការសម្រេចចិត្ត។ ទន្ទឹមនឹងនេះដែរ ក្របខណ្ឌនេះ តម្រូវឱ្យមានការយល់ដឹងយ៉ាងទូលំទូលាយ និងល្អិតល្អន់នូវរចនាសម្ព័ន្ធ ព្រមទាំងការបង្កើនការយល់ដឹងអំពីបញ្ហាសមភាពយេនឌ័រជាពិសេសនៅក្នុងតំណែងជាន់ខ្ពស់។

ច្បាប់កម្ពុជានៅមានចំណុចខ្សោយមួយចំនួន ហើយបញ្ហាធំ គឺការអនុវត្តន៍ និងប្រតិបត្តិច្បាប់ដែលមានស្រាប់នៅទន់ខ្សោយនៅឡើយ។ ភាពលំអិត ការផ្តល់ថវិកា និងយុទ្ធសាស្ត្រច្បាស់លាស់ដើម្បីសម្រេចបានការកែលំអរប្រកបដោយអត្ថន័យ ច្រើនតែខកខាន ឬមិនត្រូវបានរៀបចំត្រឹមត្រូវ។ ការអនុវត្តន៍យុទ្ធសាស្ត្រដែលមានស្រាប់ មិនទាន់មានការវាយតម្លៃ និងត្រួតពិនិត្យតាមវិធីជាចំហរ និងមានតម្លាភាពនៅឡើយទេ ដែលជាការលំបាកសម្រាប់ប្រជាពលរដ្ឋ និងសង្គមស៊ីវិលក្នុងការជំរុញឱ្យរដ្ឋាភិបាលមានការទទួលខុសត្រូវចំពោះសកម្មភាពរបស់រដ្ឋាភិបាល។

### *១.២.១. ការបោះឆ្នោតនៅកម្ពុជាឆ្នាំ២០០៨ និងការចូលរួមរបស់ស្ត្រី*

ការបោះឆ្នោតជ្រើសតាំងរដ្ឋសភាជាតិ ឆ្នាំ២០០៨ គឺជាការបោះឆ្នោតអាណត្តិទី៤ នៅកម្ពុជាចាប់តាំងពីមានកិច្ចព្រមព្រៀងទីក្រុងប៉ារីស នាឆ្នាំ១៩៩១ មក ។ ប្រព័ន្ធនយោបាយកម្ពុជា គឺជាប្រព័ន្ធនយោបាយរាជានិយមសភា។ រដ្ឋសភាជាតិ គឺជាស្ថាប័នមួយនៃនីតិបញ្ញត្តិកម្ពុជា។ នៅឆ្នាំ១៩៩៣ អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិ (អ៊ុនតាក់) រៀបចំ និងគ្រប់គ្រងការបោះឆ្នោតលើកដំបូងក្រោយជម្លោះដោយបានគ្រប់គ្រងយ៉ាងមានប្រសិទ្ធិភាពនូវអន្តរកាលពីអំពើហិង្សា និងជម្លោះទៅជាសន្តិភាព និងស្ថេរភាព។ ប៉ុន្តែការវាយតម្លៃចំពោះបរិយាកាសនយោបាយនៅកម្ពុជារយៈពេល ១៥ឆ្នាំក្រោយ បានចោទជាសំណួរយ៉ាងច្រើនថា តើប្រទេសកម្ពុជាបានឈរយ៉ាងរឹងមាំនៅលើមាគ៌ាប្រជាធិបតេយ្យបង្រួបបង្រួមហើយឬនៅ។

អ្នកបោះឆ្នោតជាស្ត្រីមានចំនួនច្រើនជាងបុរស។ នៅក្នុងការបោះឆ្នោតជ្រើសតាំងរដ្ឋសភាជាតិឆ្នាំ២០០៨ មានអ្នកចុះឈ្មោះបោះឆ្នោតជាស្ត្រី ៥៤% ក្នុងចំណោមអ្នកចុះឈ្មោះទាំងអស់៧៥% តែប៉ុណ្ណោះ ដែលបានទៅបោះឆ្នោត ដោយភាគច្រើនជាស្ត្រី[២៥]។ នៅក្នុងសម័យបោះឆ្នោតឆ្នាំ២០០៨ មានអ្នកបោះឆ្នោត២១% (ទាំងបុរស និងស្ត្រី) បានទៅកន្លែងបោះឆ្នោត ប៉ុន្តែមិនអាចបោះឆ្នោតបាន ដោយមានបញ្ហាក្នុងបញ្ជី និងការចុះឈ្មោះបោះឆ្នោតជាបញ្ហាមួយធ្ងន់ធ្ងររារាំងដល់ការចូលរួមយ៉ាងពេញលេញរបស់ស្ត្រី (និងបុរសដែរ)[២៦]។

គណបក្សធំៗដែលបានទទួលអាសនៈនៅរដ្ឋសភា និងក្រុមប្រឹក្សាឃុំ សង្កាត់ បានលើកឡើងនូវបញ្ហាស្រដៀងគ្នានេះដែរ ទាក់ទងទៅនឹងការតែងតាំងបេក្ខជន។ មេដឹកនាំគណបក្សនយោបាយមួយចំនួនបានត្អូញត្អែរអំពីការថយចុះនូវចំនួនសន្លឹកឆ្នោត និងមិនបានទទួលសន្លឹកឆ្នោត ឬអាសនៈនៅរដ្ឋសភា បន្ទាប់ពីបានតែងតាំងស្ត្រីជាច្រើនដើម្បីឈរឈ្មោះបោះឆ្នោតនោះ។ ការដាក់ឈ្មោះស្ត្រីនៅក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត គឺត្រូវបានគេយល់ឃើញថាជាការ "ខាតបង់"។ ភាពខ្លាំងនៃបញ្ជីឈ្មោះបោះឆ្នោតរបស់បក្សនយោបាយ គឺអាស្រ័យទៅលើសមត្ថភាព ប្រជាប្រិយភាព ការប្តេជ្ញាចិត្តខ្ពស់ និងប្រវត្តិនយោបាយយូរអង្វែង។

---

[២៥] ខុមហ្វ្រែល ឆ្នាំ២០០៩ ។

[២៦] ខុមហ្វ្រែល ឆ្នាំ២០០៩ ។

កំឡុងពេលចុះឈ្មោះបោះឆ្នោត រដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល (CSO)[២៧] បានជម្រុញឱ្យគណបក្សនយោបាយឱ្យមានការឆ្លាស់ឈ្មោះរបស់បុរស និងស្ត្រីនៅខាងលើនៃបញ្ជីឈ្មោះបេក្ខជនរបស់បក្សនីមួយៗ (វិធីសាស្ត្រឆ្លាស់គ្នាតាមបែបខ្សែរូត) ដើម្បីធានាឱ្យឃើញមានឈ្មោះបេក្ខជនជាស្ត្រីកាន់តែច្រើនជាងមុន។

ជាលទ្ធផល យោងតាមតួលេខដែលទទួលបានពីសម័យបោះឆ្នោតជ្រើសតាំងរដ្ឋសភាឆ្នាំ២០០៨ ក្នុងចំណោមគណបក្សធំៗ៣ (គណបក្សប្រជាជន សមរង្ស៊ី និងហ្វ៊ុនស៊ីនប៉ិច[២៨]) គណបក្សប្រជាជនបានកើនឡើងនូវចំនួនបេក្ខជនជាស្ត្រីដែលត្រូវបានដាក់ឈ្មោះនៅខាងលើក្នុងបញ្ជីបេក្ខជន កើនឡើងពី៣.៦១% ដល់ ១០.២៧% ។ ចំណែកឯគណបក្សសមរង្ស៊ីវិញ មានការកើនឡើងតិចតួច ដែលចំនួនបេក្ខជនស្ត្រីសរុបកើនពី ១២.២២% ទៅ១៣.០៦% ។ បេក្ខជនជាស្ត្រី និងសមាជិកគណបក្សនយោបាយមួយចំនួនបានលាតត្រដាងឱ្យអ្នកសង្កេតការណ៍បានដឹងថា ការរើសអើងចំពោះបេក្ខជនស្ត្រីបានកើតឡើងនៅក្នុងរង្វង់គណបក្សនយោបាយក្នុងពេលរៀបចំជ្រើសរើសឱ្យឈរឈ្មោះ និងចាត់តាំងបេក្ខជនបោះឆ្នោត។ អ្នកនយោបាយបុរសភាគច្រើនបញ្ជាក់ថា ពួកគេមានការលំបាកក្នុងការលើកស្ទួយ និងលើកទឹកចិត្តស្ត្រីកាន់តែច្រើនដើម្បីចូលរួមក្នុងការងារនយោបាយ។

បេក្ខជនជាបុរសមួយចំនួន អាចមានអារម្មណ៍ទទួលការគំរាមកំហែងពីការប្រកួតប្រជែងដោយសារការដាក់ឈ្មោះបេក្ខជនជាស្ត្រីនៅខាងលើនៃបញ្ជីឈ្មោះបេក្ខជន។ លើសពីនេះទៅទៀត បរិយាកាសនយោបាយក្នុងដំណើរការបោះឆ្នោត គឺច្របូកច្របល់ពោរពេញទៅដោយការបំភិតបំភ័យ ជាកត្តាមួយដែលនាំឱ្យស្ត្រីមួយចំនួនមានការស្ទាក់ស្ទើរក្នុងការចូលរួមក្នុងឆាកនយោបាយ។

គួរឱ្យកត់សម្គាល់ដែរថា អ្នកនយោបាយស្ត្រីចូលរួមតិចតួច នៅក្នុងកិច្ចប្រជុំជាមួយអ្នកសង្កេតការណ៍បោះឆ្នោតសហភាពអឺរុប មេដឹកនាំគណបក្សនយោបាយ និងមន្ត្រីជាន់ខ្ពស់រាជរដ្ឋាភិបាល ដើម្បីពិភាក្សាអំពីការបោះឆ្នោតឆ្នាំ២០០៨។ មានបេក្ខជនជាស្ត្រីតែ១៧២នាក់ប៉ុណ្ណោះ ដែលបានចូលរួមក្នុងកិច្ចប្រជុំនេះ ឬ ១៤.៨០% នៃចំនួនបេក្ខជនសរុប ១.១៦២នាក់។

នៅក្នុងការបោះឆ្នោតជ្រើសតាំងរដ្ឋសភាឆ្នាំ២០០៣ មានបេក្ខជនចំនួន ២៧%ជាស្ត្រីនៅក្នុងគណបក្សចំនួន២៣។ នេះមានន័យថា ចំនួនស្ត្រីមានការថយចុះ១២.២០% នៅក្នុងសម័យបោះឆ្នោតឆ្នាំ ២០០៨។ ប៉ុន្តែចំនួនបេក្ខជនស្ត្រីនៃគណបក្សប្រជាជនបានកើនឡើងពី១៤នាក់ (១១.៣៨%) ក្នុងឆ្នាំ២០០៣ ដល់២០នាក់ (១៦.២៦%) ក្នុងសម័យបោះឆ្នោតឆ្នាំ២០០៨ នៃបេក្ខជនទាំងអស់។ ស្រដៀងគ្នានេះដែរ ចំនួនបេក្ខជនស្ត្រីរបស់គណបក្សសមរង្ស៊ីក៏បានកើនឡើងពី ១៥នាក់ (១២.១៩% នៅឆ្នាំ២០០៣) ដល់១៧នាក់ (១៣.៨២% នៅឆ្នាំ២០០៨) ផងដែរ។

---

[២៧] គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ។ អង្គការមិនមែនរដ្ឋាភិបាលចំនួន ៧ បានបង្កើតគណៈកម្មាធិការនេះឡើងក្នុងនោះមាន: ខុមហ្វ្រែល និកហ្វិច ចម្រើនស្ត្រី GAD/C, CDRI, Silaka និង CWPD ។

[២៨] គណបក្សប្រជាជនកម្ពុជា សមរង្ស៊ី និងហ្វ៊ុនស៊ីនប៉ិច (គណបក្សរាជានិយម)។

ចំនួនបេក្ខជនស្ត្រី ដែលបានជាប់ឆ្នោតផ្ទាល់ក្នុងឆ្នាំ២០០៨ នៅពេលបោះឆ្នោតជ្រើសតាំងរដ្ឋសភាមានការកើនឡើងតិចតួចបើប្រៀបធៀបជាមួយឆ្នាំ២០០៣។ នៅឆ្នាំ២០០៨ គឺមាន១៨នាក់ (ឬ១៤.៦៣%) ធៀបនឹងឆ្នាំ២០០៣ ដែលមានត្រឹមតែ ១៥នាក់ (ឬ១២.១៩%) តែប៉ុណ្ណោះ។ សង្គមស៊ីវិលអបអរសាទរចំពោះរដ្ឋាភិបាលថ្មីនេះ ដែលបានជ្រើសរើសបេក្ខជនបុរសដែលជាប់ឆ្នោតផ្ទាល់មួយចំនួនយកទៅបញ្ចូលក្នុងជួររដ្ឋាភិបាល ដូចនេះ បេក្ខជនស្ត្រីដែលមានឈ្មោះបន្ទាប់ ក៏បានឡើងជំនួសជាតំណាងរាស្ត្រ។ ដូច្នេះ ក្រោយពីការបង្កើតរាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី៤ រួចមក ស្ត្រីក៏ជាប់ឈ្មោះជាតំណាងរាស្ត្រចំនួន២៧នាក់ ដែលត្រូវជា ២២% នៃអាសនៈចំនួន១២៣។ គណបក្សប្រជាជនមានតំណាងរាស្ត្រ៩០នាក់ ក្នុងនោះមាន២១នាក់ ជាស្ត្រី (២៣.៣៣%)។ រីឯគណបក្សសមរង្ស៊ីវិញមានសមាជិក ២៦នាក់ ក្នុងនោះមាន៦នាក់ ជាស្ត្រី(២៣.០៧%។ ចំណែកគណបក្សផ្សេងទៀត ដូចជា (ហ៊្វុនស៊ិនប៉ិច នរោត្តមរណឫទ្ធិ និងគណបក្សសិទ្ធិមនុស្ស[២៩]) ដែលមានអសនៈនៅរដ្ឋសភាដែរ ប៉ុន្តែពុំមានស្ត្រីជាតំណាងរាស្ត្រទេ។

សមាជិកសភាស្ត្រីសរុបនៅក្នុងអាណត្តិទី៣ (២០០៣-២០០៨) កើនឡើងជាបន្តបន្ទាប់ពី ១៥នាក់ (១២.១៩%) ឡើងដល់ ២៥នាក់ (២០.៣២%) នៃសមាជិកសភាជាប់ឆ្នោតសរុបទាំងអស់។ តួលេខនេះ គួរឱ្យមានការចាប់អារម្មណ៍ ប៉ុន្តែតួលេខនេះ គឺមានសមាជិកសភាដែលត្រូវជាប់ឆ្នោតពាក់កណ្តាលអាណត្តិផងដែរ ។ បញ្ហានេះ ក៏នៅមានចំណោទផងដែរថា តើស្ត្រីជាសមាជិកសភាមួយចំនួនតូចនេះអាចសម្រេចតួនាទីរបស់ខ្លួនប្រកបដោយប្រសិទ្ធិភាពដែរឬទេ នៅពេលដែលអាណត្តិរបស់អ្នកតំណាងរាស្ត្រនោះនៅសល់ពេលតែ១ ឬ ២ ឬ ៣ឆ្នាំ តែប៉ុណ្ណោះ។ ពេលវេលា និងឱកាសមិនគ្រប់គ្រាន់ ដើម្បីប្រតិបត្តិភារកិច្ចបែបនេះ មិនត្រឹមតែបណ្តាលឱ្យពិបាកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានធ្វើឱ្យមានការថយចុះនូវតម្លៃក្នុងការអនុវត្តន៍ការងារ និងទំនុកចិត្តចំពោះស្ត្រីថែមទៀតផង។




មានកំណើនតិចតួច(២.៤៥%) ចំពោះសមាជិកសភាស្ត្រីដែលត្រូវបានជាប់ឆ្នោតរវាងឆ្នាំ២០០៣ និងឆ្នាំ២០០៨ (១៨នាក់ ឬ១៤.៦៣% ក្នុងការបោះឆ្នោតឆ្នាំ២០០៨ និង១៥នាក់ ឬ១២.១៩% ក្នុងសម័យបោះឆ្នោតឆ្នាំ២០០៣) ដែលមានកំណើននៅចុងបញ្ចប់នៃដំណើរនេះត្រឹមតែ១.៦៨% (២៥នាក់ ស្មើ២០.៣២% ក្នុងឆ្នាំ២០០៣ និង២៧នាក់ ស្មើ២២% ក្នុងឆ្នាំ២០០៨ រហូតមកដល់បច្ចុប្បន្ន)។ នេះ គឺជាកំណើនយឺត និងតិចតួចបំផុតដែលនៅឆ្ងាយពីការកំណត់ក្នុងគោលដៅអភិវឌ្ឍសហស្សវត្សរបស់កម្ពុជា ដែលគ្រោងសម្រេចឱ្យបានយ៉ាងតិចស្ត្រី៣០% នៅក្នុងតំណែងដែលធ្វើការសម្រេចចិត្តថ្នាក់ជាតិត្រឹមឆ្នាំ២០១៥។ រហូតដល់ពេលនោះនៅ

[២៩] NRP: គណបក្សនរោត្តមរណឫទ្ធិ HRP: គណបក្សសិទ្ធិមនុស្ស។

មានតែការបោះឆ្នោតជាតិម្តងទៀតប៉ុណ្ណោះ គឺនៅឆ្នាំ២០១៣។ ប្រសិនបើអត្រាកំណើននៅត្រឹមតែ ១.៦៨% សម្រាប់ការបោះឆ្នោតអាណត្តិទី៥ នោះចំនួនសមាជិកសភាជាស្ត្រីនឹងត្រូវជា២៣.៦៨% តែប៉ុណ្ណោះ (បើមានការសន្មតថា: យុទ្ធសាស្ត្រ និងកំណែទម្រង់នយោបាយរបស់គណបក្សដែលបានចុះឈ្មោះ និងរដ្ឋបាល គឺដូចគ្នានឹងអាណត្តិទី៤ដែរ)។

**ចំនួនស្ត្រីដែលឈរឈ្មោះបោះឆ្នោតជាតិក្នុងអាណត្តិទី៤ ពីគណបក្សចំនួន ១១ ដែលបានចុះឈ្មោះ**

| | គណបក្ស | ចំនួនស្ត្រីមានឈ្មោះជាបេក្ខជន | % | ចំនួនបេក្ខជនស្ត្រីជាបន្លាស់ | % | ចំនួនមណ្ឌលដែលស្ត្រីឈរឈ្មោះបោះឆ្នោត |
|---|---|---|---|---|---|---|
| ១ | ប្រជាជនកម្ពុជា | ២០ | ១៦.២៦ | ២៦ | ១៨.៣០ | ២៤ |
| ២ | ហង្សតារាចលនាប្រជាធិបតេយ្យ | ១០ | ៨.១៣ | ១៧ | ១២.០៥ | ២៤ |
| ៣ | នរោត្តមឫទ្ធិ | ១១ | ៨.៩៤ | ១៥ | ១០.៦៤ | ២៤ |
| ៤ | ហ្វ៊ុនស៊ិនប៉ិច | ១០ | ៨.១៣ | ១៦ | ១១.៣៤ | ២៤ |
| ៥ | សិទ្ធិមនុស្ស | ៦ | ៤.៨៧ | ៣ | ២.១២ | ២៤ |
| ៦ | យុត្តិធម៌សង្គម | ១៤ | ៣០.៤៣ | ១៨ | ៣៩.១៣ | ៧ |
| ៧ | សម្ព័ន្ធប្រជាធិបតេយ្យ | ២៤ | ១៩.៥១ | ៤៣ | ៣០.៤៩ | ២៤ |
| ៨ | សមរង្ស៊ី | ១៧ | ១៣.៨២ | ១៦ | ១១.៣៤ | ២៤ |
| ៩ | ប្រឆាំងភាពក្រីក្រ | ១៤ | ២៣.៣៣ | ២៩ | ៤៨.៣៣ | ៧ |
| ១០ | ប្រជាធិតេយ្យខ្មែរ | ៣៧ | ៣០ | ៥៣ | ៣៥.៨១ | ២៤ |
| ១១ | រួបរួមជាតិកម្ពុជា | ៩ | ១២.៥០ | ១៤ | ១៩.៤៤ | ៩ |
| **គណបក្សសរុប** | | **១៧២** | **១៤.៨០** | **២៥០** | **១៩** | |

**បេក្ខជនស្ត្រីឈរឈ្មោះសម័យបោះឆ្នោតឆ្នាំ២០០៨៖ ៤២២ ក្នុងចំណោម ២.៤៧៨នាក់**

- ស្ត្រីមានឈ្មោះជាប់ក្នុងក្របខណ្ឌ: ១៧២ នាក់ ឬ១៤.៨%(សរុប ១.១៦២ បេក្ខជន)
- បេក្ខជនស្ត្រីដែលជំនួសបាន: ២៥០ នាក់ ឬ ១៩%(សរុប ១.៣១៦ បេក្ខជន)
- (បេក្ខជនដែលមានការប្រកួតប្រជែងគ្នាដើម្បីយកអាសនៈទាំង១២៣ ក្នុងសម័យបោះឆ្នោតជាតិ)

**ចំនួន និងការបែងចែកស្ត្រីដែលបានជាប់ឆ្នោតជាសមាជិកសភាក្នុងអាណត្តិទី៤**

| | ស្ត្រីជាប់ឆ្នោតតំណាងរាស្ត្រអាណត្តិទី៤ | | | អាសនៈទទួលបាន |
|---|---|---|---|---|
| | បក្សនយោយ | ចំនួនស្ត្រីជាប់ឆ្នោត | % | |
| ១ | ប្រជាជនកម្ពុជា | ២១ | ២៣.៣៣ | ៩០ |
| ២ | សមរង្ស៊ី | ៦ | ២៣.០៧ | ២៦ |
| ៣ | សិទ្ធិមនុស្ស | ០ | | ៣ |
| ៤ | ហ្វ៊ុនស៊ិនប៉ិច | ០ | | ២ |

| | | | | |
|---|---|---|---|---|
| ៥ | នរោត្តមប្ញទ្ធិ | ០ | | ២ |
| **សរុប** | | **២៧** | **២២%** | **១២៣** |

ស្ត្រីជាប់ឆ្នោតសភាៈ ២៧ នាក់ ស្មើ ២២% នៃចំនួនអាសនៈសរុប ១២៣ ក្នុងការបោះឆ្នោតឆ្នាំ ២០០៨

ចំនួនស្ត្រីក្នុងព្រឹទ្ធសភា៖

| | ចំនួន និងប្រភេទ | % |
|---|---|---|
| សមាជិកព្រឹទ្ធសភា | ៩ ក្នុងចំណោម ៦១ | ១៤.៨% |

ចំនួនស្ត្រីក្នុងតំណែងជាន់ខ្ពស់ក្នុងរដ្ឋាភិបាល បន្ទាប់ពីការបោះឆ្នោត ឆ្នាំ២០០៨ -តំណែងជ្រើសរើសយោងទៅតាមគោលដៅអភិវឌ្ឍសហស្សវត្សរ៍កម្ពុជា៖

| | ចំនួន និងប្រភេទ | % |
|---|---|---|
| រដ្ឋមន្ត្រី | ២ | ៧.៧ |
| រដ្ឋលេខាធិការ | ១៦ | ៨.១ |
| អនុរដ្ឋលេខាធិការ | ៣០ | ១៥.៤ |
| **សរុប** | **៤៨** | **៣១.២** |

ចំនួនស្ត្រីថ្នាក់ខេត្ត និងស្រុកបន្ទាប់ពីការបោះឆ្នោត ខែឧសភា ឆ្នាំ២០០៩៖

| | ចំនួន | % |
|---|---|---|
| អភិបាលខេត្ត | ០ | ០ |
| ក្រុមប្រឹក្សារាជធានី និងខេត្ត | ៣៧ | ១៣ |
| ក្រុមប្រឹក្សាក្រុង ស្រុក និងខណ្ឌ | ៣៦២ | ១០ |
| ក្រុមប្រឹក្សាឃុំ សង្កាត់ | ១.៦៦២ | ១៤.៦ |

អភិបាលរងក្រុង ស្រុក ខណ្ឌៈ ១៦៩នាក់ ជាស្ត្រី (គ្រប់ក្រុង ស្រុក ខណ្ឌ)

| | ទីកន្លែង | ចំនួន | % |
|---|---|---|---|
| មេឃុំ | | ៦៩ | ៤.៣ |

## ១.៣ ការចូលរួមក្នុងឆាកនយោបាយរបស់ស្ត្រីជនជាតិដើម និងស្ត្រីពិការ

ស្ត្រីជនជាតិដើមក៏ប្រឈមនឹងឧបសគ្គទូទៅដូចគ្នានឹងឧបសគ្គក្នុងការចូលរួមនយោបាយ ដូចដែលស្ត្រីកម្ពុជាទូទៅកំពុងប្រឈមមុខដែរ ប៉ុន្តែស្ត្រីជនជាតិដើមប្រឈមនឹងបញ្ហាមួយចំនួនថែមទៀត។ ឧទាហរណ៍ សិទ្ធិរបស់ជនជាតិភាគតិចមិនទាន់ត្រូវបានថែងឱ្យគ្រប់គ្រាន់នៅឡើយ ហើយស្ត្រីជនជាតិដើមថែមទាំងប្រឈមុខនឹងបញ្ហាភាសាថែមទៀត ដែលរារាំងពួកគេមិនអាចចូលរួមក្នុងនយោបាយបាន។ ពេលដែលស្ត្រីជនជាតិដើមភាពតិច ត្រូវបានលើកទឹកចិត្តក្នុងការចូលរួមក្នុងសង្គម គេសង្កេតឃើញថា មានផ្នត់គំនិត (Sterotype) និងការចាប់ផ្តើមរកផ្លូវដោះស្រាយមានភាពលំអៀង ព្រមទាំងមានការខ្វះខាតក្នុងការទទួលស្គាល់អំពីតម្រូវការខុសគ្នារបស់ស្ត្រីទាំងនោះដែរ។ កន្លងមកគេសង្កេតឃើញមានកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល ក៏ប៉ុន្តែមានតិចតួចទេ ក្នុងការធានាឱ្យមានការចូលរួមពេញលេញរបស់ស្ត្រីជនជាតិដើម តាមរយៈការភ្ជាប់យេនឌ័រ និងតម្រូវការរបស់ជនជាតិដើម (Maffii, Hong ឆ្នាំ២០០៨)។

ស្ត្រីពិការក៏ស្ថិតក្នុងស្ថានភាពស្រដៀងគ្នានេះដែរ។ យោងតាមការសិក្សាឆ្នាំ២០០៥ របស់ក្រសួងសង្គមកិច្ចបានឱ្យដឹងថា ប្រជាពលរដ្ឋកម្ពុជា៤.៧% ជាជនពិការ ហើយក្នុងចំណោមនោះគេប៉ាន់ស្មានថាប្រហែល ៩៦.៣៦៧នាក់ ជាស្ត្រីពិការ(ក្រសួងសង្គមកិច្ច ២០០៩)។ ស្ត្រីពិការភាគច្រើនកំពុងរស់នៅក្នុងជីវភាពលំបាកលំបិនជាទីបំផុតអាស្រ័យដោយភាពក្រីក្រ និងការរើសអើងរបស់សង្គម។ ស្ត្រីពិការជាច្រើនបានបោះបង់ការសិក្សាតាំងពីនៅថ្នាក់ទាបនៅឡើយ អាស្រ័យដោយមានការរកការងារធ្វើ និងប្រកបរបរចិញ្ចឹមជីវិតចេះតែលំបាកទៅៗ។ យោងតាមរបាយការណ៍របស់បណ្តាញជនពិការខេត្តមួយ បានឲ្យដឹងថាស្ត្រីពិការច្រើនស្ថិតក្នុងភាពគ្រោះថ្នាក់ដោយអំពើរំលោភសេពសន្ថវៈ ជាពិសេសស្ត្រីពិការដែលគហើយថ្លង់ផងដែរ។ ករណីបែបនេះ មានតែមួយចំនួនតូចប៉ុណ្ណោះដែលត្រូវបានដោះស្រាយ ជាពិសេសអាស្រ័យដោយការលំបាកក្នុងការទំនាក់ទំនងរវាងអាជ្ញាធរ និងជនរងគ្រោះ។

ស្ត្រីពិការភាគច្រើនមិនចូលរួមក្នុងសកម្មភាពសង្គមទេ ដោយសារតែភាពអាម៉ាស់។ ហើយចំណុចសំខាន់បំផុតនោះគឺគេបានយល់ថាស្ត្រីពិការភាគច្រើនមិនអាចធ្វើការងារអ្វីបានទេ ដោយសង្គមយល់ថាខ្វះសមត្ថភាព និងគំនិតប្រាជ្ញា ។ លើសពីនេះទៅទៀត ច្បាប់ស្រីបានដាក់សម្ពាធលើស្ត្រីឱ្យដកថយពេលជួបប្រទះបញ្ហាអ្វីមួយ ។ អង្គការជនពិការកម្ពុជាជឿជាក់ថា នេះគឺជាកត្តាប៉ះពាល់ធ្ងន់ធ្ងរមួយដល់ការអភិវឌ្ឍន៍និងការចូលរួមរបស់ជនពិការនៅក្នុងសង្គម។

បញ្ហារបស់ជនពិការ (ជាពិសេសស្ត្រីពិការ) ត្រូវបានដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៩-២០១៣។ ច្បាប់ស្តីពីការការពារ និងលើកស្ទួយសិទ្ធិជនពិការត្រូវបានអនុម័ត។ ផែនការសកម្មភាពជាតិសម្រាប់ជនពិការដោយសារគ្រាប់មីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះក៏ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្តដែរ។ តំណាងស្ត្រីពិការត្រូវបានបញ្ជូនទៅចូលរួមក្នុងកិច្ចប្រជុំរបស់បណ្តាញអង្គការអភិវឌ្ឍន៍ស្ត្រី។

សារាចរណែនាំ ស្តីពីការពង្រឹងការបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការត្រូវបានអនុម័ត។ យោងតាមរបាយណ៍របស់ក្រសួងសង្គមកិច្ចបានឱ្យដឹងថា ស្ត្រីពិការចំនួន១១៥នាក់ បានទទួលការបណ្តុះបណ្តាលនៅឆ្នាំ២០០៧ ហើយ១១៧នាក់ ត្រូវបានបណ្តុះបណ្តាលនៅឆ្នាំ២០០៨ និង១១០នាក់ ត្រូវបានបណ្តុះបណ្តាលនៅឆ្នាំ២០០៩។ វគ្គបណ្តុះបណ្តាលនោះ ត្រូវបានបើកនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលជនពិការ ដែលជាកម្ម-វិធីសហប្រតិបត្តិការរវាងក្រសួងសង្គមកិច្ច និងអង្គការមិនមែនរដ្ឋាភិបាល។ ក្រសួងកិច្ចការនារីក៏បានចូលរួមក្នុងការបង្កើតសកម្មភាពរបស់ស្ត្រីពិការផងដែរ ជាពិសេសក្នុងទិវាសិទ្ធិនារីអន្តរជាតិ ៨ មីនា។ គោលការណ៍របស់កុមារពិការត្រូវបានអនុវត្តដោយត្រូវផ្តល់សិទ្ធិជាអាទិភាពដល់កុមារីពិការក្នុងការរៀនសូត្រ។

ប៉ុន្តែ សេវាកម្មសង្គមសម្រាប់ស្ត្រីពិការនៅតែមានកម្រិតនៅឡើយ ហើយថែមទាំងគ្មានស្ថិតិណាមួយត្រឹមត្រូវគួរឱ្យជឿជាក់បានទាក់ទងនឹងស្ត្រីពិការទៀតផង។ ការអនុម័តច្បាប់ស្តីពីការការពារ និងលើកស្ទួយសិទ្ធិជនពិការដោយរដ្ឋាភិបាល និងការចុះហត្ថលេខាលើអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិជនពិការត្រូវបានធ្វើឡើង ប៉ុន្តែតំណាក់កាលផ្តល់សច្ចាប័ន និងអនុវត្តមិនទាន់បានចាប់ផ្តើមនៅឡើយទេ។ ក្រោមអនុសញ្ញាស្តីពី ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទបានកំណត់ថា រាល់កម្មវិធីលើកស្ទួយដែលពាក់ព័ន្ធនឹងបញ្ហាស្ត្រីត្រូវតែដាក់បញ្ចូលនូវបញ្ហាស្ត្រីពិការផងដែរ។

រដ្ឋាភិបាលត្រូវតែបង្កើតគោលនយោបាយ និងផែនការសកម្មភាពយុទ្ធសាស្រ្តដែលមានការដាក់បញ្ចូលទាំងស្រ្តីពិការ និងស្រ្តីជនជាតិដើមភាគតិចផងក្នុងការសម្រេចចិត្ត។

## ២. ឫស្នារ

នៅកម្ពុជា បុរសជាអ្នកកំណត់វិន័យនានា ហើយគេសង្ឃឹមថា ស្រ្តីត្រូវតែរស់នៅក្រោមវិន័យទាំងនោះ ទោះបីជាមិនបានចូលរួមក្នុងការបង្កើតវិន័យទាំងនោះក៏ដោយ ហើយស្រ្តីច្រើនតែពុំបានដឹងថាមានវិន័យទាំងនោះទៀតផង។ ជាឧទាហរណ៍អំពីស្ថានភាព គឺលោកអតីតប្រធានាធិបតីហ្វីលីពីន ហ្វេណង់ដូ ម៉ាកូស បានមានប្រសាសន៍ម្តងថា ស្រ្តីហ្វីលីពីនគួរតែឆ្លាត ប៉ុន្តែត្រូវចេះស្តាប់បង្គាប់។ ស្រ្តីទាំងអស់នោះ អាចរីកចម្រើនបានជាមួយស្វាមី ប៉ុន្តែអ្នកទាំងនោះគួរតែរីកចម្រើនជាមួយស្វាមីចំពោះបញ្ហាបន្ទប់ទទួលទានដំណេក។

បញ្ហាអំពើពុករលួយ និងសិទ្ធិអំណាចសម្រាប់ប្រទានយសសក្តិរបស់អ្នកនយោបាយ និងដំណើរបញ្ច្រាសពីការផ្លាស់ប្តូរយូរអង្វែងអាចបណ្តាលឱ្យប្រព័ន្ធនយោបាយត្រូវដួលរលំ។ ការអនុវត្តន៍បែបនេះ ក៏ជាការរារាំងដល់បុរស និងស្រ្តីមកពីក្រុមប្រជាពលរដ្ឋផ្សេងៗគ្នាពីការចូលរួមក្នុងឆាកនយោបាយដែរ។ អំពើរើសអើងលើស្រ្តីភេទនៅក្នុងបរិបទនយោបាយនៅកម្ពុជា ត្រូវបានបញ្ចេញឱ្យឃើញយ៉ាងច្បាស់តាមវិធីផ្សេងៗជាច្រើន កង្វះករណីកិច្ចក្នុងសភា លទ្ធភាពតិចតួចក្នុងការទទួលបានហិរញ្ញវត្ថុសម្រាប់ធ្វើយុទ្ធនាការបោះឆ្នោត ព្រមទាំងត្រូវមានបណ្តាញនយោបាយដែលបានបង្កើតឡើងមិនសូវឱ្យមានការចូលរួមថែមទៀតផង។

ជាពិសេស បុរសដែលជាអ្នកមានអំណាចត្រួតត្រាលើនយោបាយ ទុកស្រ្តីឱ្យស្ថិតក្នុងតួនាទីប្រពៃណី "មានបីតួនាទី" គឺៈ ការបង្កើតកូន ការបន្តពូជ និងការរស់នៅជាមួយគ្នា។ ហើយបានរារាំងស្រ្តីពីការចូលរួមក្នុងវេទិកាសម្រេចចិត្តនានា។ លើសពីនេះទៅទៀត រចនាសម្ព័ន្ធអំណាចបុរសមិនស្វាគមន៍ស្រ្តីជាភ្នាក់ងារផ្លាស់ប្តូរនយោបាយទេ។ នៅទូទាំងកម្ពុជា នៅតែមានទស្សនៈទូទៅមួយថា នយោបាយគឺជាវិស័យមិនប្រក្រតីជាល្បែងមួយមានការលំបាកដែលត្រូវចំណាយច្រើន ហើយទទួលបានផលប្រយោជន៍តិចតួចពីការចូលរួមនោះ ជាពិសេសចំពោះអ្នកណាដែលមិនធ្លាប់ចូលរួមក្នុងពិភពនេះ ព្រមទាំងពុំមានធនធានគ្រប់គ្រាន់ និងទំនាក់ទំនងច្រើនផងដែរ។ ស្រ្តីដែលទទួលបាននូវតួនាទីសំខាន់ៗក្នុងជួរនយោបាយ អ្នកទាំងនោះបានទទួលបែបនេះដោយសារស្ថិតក្នុងសន្តិវង្ស (ខ្សែស្រឡាយ) នយោបាយ ឬក្រុមគ្រួសារអ្នកមានអំណាចតែប៉ុណ្ណោះ។ ទន្ទឹមនឹងនេះ ស្រ្តីខ្លះប្រហែលត្រូវបានគេចាត់ទុកជាអ្នកធ្វើតាមបញ្ជាគេទាំងអស់ ដែលគ្រាន់តែជាតំណាងនូវបំណងប្រាថ្នា និងទស្សនៈរបស់អ្នកដទៃដោយពុំមានអំណាចផ្ទាល់ខ្លួនពិតប្រាកដក្នុងការសម្រេចចិត្តផងដែរ។ រឿងដែលគួរឱ្យចាប់អារម្មណ៍ គឺស្រ្តីដែលចូលរួមក្នុងឆាកនយោបាយមួយចំនួន (ជាពិសេសអ្នកដែលចេញមកពីក្រុមជនក្រីក្រ ឬមកពីក្រុមមនុស្សដែលត្រូវគេមិនឱ្យចូលរួមសង្គម) តែងតែប្រឈមមុខនឹងការគំរាមកំហែង ចំពោះការព្យាយាមប្រឹងប្រែងឱ្យមានការផ្លាស់ប្តូរស្ថានភាពដែលនៅតែដដែលៗ។

ស្រ្តីដែលបានជាប់ឆ្នោតក៏ច្រើនតែប្រឈមមុខនឹងឧបសគ្គជាច្រើនដែរក្នុងការបញ្ចេញទស្សនៈក្នុងឆាកនយោបាយ។ សំណើ និងបញ្ហារបស់ស្រ្តីទាំងនោះអាចត្រូវបានបញ្ចប់ ឬទុករឿងនេះជាតូចតាច ឬមិនទទួលយកតែម្តង ហើយទន្ទឹមនឹងនោះស្រ្តីដែលបានជាប់ឆ្នោតបានត្រូវគេសន្និដ្ឋានថា ការដឹកនាំរបស់អ្នក

អស់នោះមាន "ភាពទន់ខ្សោយ" (បើប្រៀបធៀបជាមួយបុរស)។ ដោយសារមានការចោទប្រកាន់លើស្ត្រីទាំងអស់នោះកាន់តែខ្លាំងឡើងៗ ស្ត្រីគិតថាមានតែប្រើមធ្យោបាយមួយ គឺត្រូវប្រកាន់ចរិកមួយឱ្យខ្លាំង ហើយកាចដូច "ប្រុស" ទេ ទើបគេខ្លាច និងគោរព។ លើសពីនេះទៅទៀត ស្ត្រីចូលរួមក្នុងការងារនយោបាយអាចប្រឈមនឹងតួនាទីជាមាតាធ្ងន់ធ្ងរពេក ដែលរារាំងដល់ការសម្រេចបាននូវការងារនយោបាយរបស់អ្នកទាំងអស់នោះ។ តួនាទីយេនឌ័របានដាក់បញ្ចូលនូវការកំណត់អំពីលទ្ធភាព និងសមត្ថភាពស្មើគ្នារបស់បុរស និងស្ត្រី ហើយការកំណត់នេះ ជាមគ្គុទេសន៍សម្រាប់ការវិភាគរបស់មនុស្សអំពីការងារ ហេតុដូច្នេះហើយទើបគេយល់បែបនេះជាប់ជាផ្នត់គំនិតរហូតមក។

ការប្រើប្រាស់ និងអនុវត្តច្បាប់ដែលមានស្រាប់មិនទាន់បានល្អ បានលេចចេញជាបញ្ហាដ៏សំខាន់មួយក្នុងចំណោមបញ្ហាផ្សេងៗរបស់កម្ពុជាក្នុងការសម្រេចបាននូវសមភាពយេនឌ័រ។ នៅថ្នាក់មូលដ្ឋាន គេច្រើនតែមិនបានដឹងអំពីនីតិកម្មដែលមានស្រាប់។ កង្វះទំនាក់ទំនងល្អរវាងអាជ្ញាធរជាតិ និងអាជ្ញាធរមូលដ្ឋានប៉ះពាល់ដល់ការអនុវត្តន៍សកម្មភាពនានា។ ពីព្រោះអាជ្ញាធរមូលដ្ឋានច្រើនតែពុំបានដឹងអំពីកម្មវិធីផ្សេងៗ ថ្វីត្បិតតែមន្ត្រីទាំងនោះត្រូវបានដំឡើងតួនាទីដោយមន្ត្រីរដ្ឋាភិបាលថ្នាក់ជាតិក៏ដោយ (ចម្រើនស្ត្រី ឆ្នាំ២០០៩)។ សមត្ថភាពនៅតាមមូលដ្ឋាននៅតែខ្សោយ ទាក់ទងនឹងការប្រើប្រាស់ និងអនុវត្ត ព្រមទាំងថវិកាដែលត្រូវទទួលបាននោះស្ទើរតែគ្មានសោះតែម្តង។ គេអាចឃើញមានមន្ត្រីរាជការ ដែលមានការប្តេជ្ញាចិត្តមួយចំនួនដែរ ប៉ុន្តែក្នុងចំណោមមន្ត្រីទាំងនោះ មានតិចតួចណាស់ដែលយល់អំពីបញ្ហាយេនឌ័រច្បាស់លាស់ (ក្រុមការងារអង្គការមិនមែនរដ្ឋាភិបាល ឆ្នាំ២០០៩)។ ថវិកាសម្រាប់ក្រសួងកិច្ចការនារី ក៏នៅទាបនៅឡើយដែរ បើប្រៀបធៀបនឹងក្រសួងផ្សេងៗទៀត។ ក្រសួងកិច្ចការនារី បានធ្វើផែនការគ្រប់គ្រងសកម្មភាពទូទៅ GMAPs ប៉ុន្តែនៅមិនទាន់បានពិចារណាអំពីចំណុចថវិកានៅឡើយទេ សម្រាប់ការអនុវត្តន៍ផែនការគ្រប់គ្រងនោះ (GAD/C ឆ្នាំ២០០៩)។ ធនធានមនុស្ស និងសមត្ថភាពដើម្បីធ្វើឲ្យផែនការគ្រប់គ្រងសកម្មភាពទូទៅនេះដំណើរការទៅមុខបាន គឺកំពុងមានការខ្វះខាតនៅឡើយ។

ដូចគ្នានេះដែរ ជនបង្គោលជាស្ត្រី និងកុមារនៅថ្នាក់មូលដ្ឋានច្រើនតែមិនដំណើរការ ហើយគ្មានទៀតផង ពេលដែលគ្មានស្ត្រីក្នុងតួនាទីជាក្រុមប្រឹក្សាឃុំ (Thon, Ou ឆ្នាំ២០០៩)។ តាមការសម្ភាសន៍ជាមួយសមាជិកគណៈកម្មាធិការឃុំ សង្កាត់ដើម្បីស្ត្រី និងកុមារ (CCWC)[៣០] បានបង្ហាញនូវរូបភាពចម្រុះជាច្រើន។ ក្នុងខណៈ ដែលរបាយការណ៍ភាគច្រើនបង្ហាញអំពីស្ថានភាពកាន់តែប្រសើរឡើង ព្រមទាំងមានការគាំទ្រយ៉ាងខ្លាំងពីសំណាក់ខាងក្រៅនោះ ក៏នៅតែមានបញ្ហាសេសសល់ជាច្រើន ដែលរារាំងសមាជិកគណៈកម្មាធិការឃុំសង្កាត់ដើម្បីស្ត្រី និងកុមារមិនឱ្យដំណើរការទៅមុខបានយ៉ាងពេញលេញឡើយ។ កង្វះទំនុកចិត្ត សមត្ថភាពនៅមានកម្រិត និងកិច្ចសហប្រតិបត្តិការតិចតួចក្នុងចំណោមក្រុមប្រឹក្សាឃុំ សង្កាត់ ច្រើនតែរារាំងដល់ការចូលរួមប្រកបដោយប្រសិទ្ធិភាពរបស់សមាជិកគណៈកម្មាធិការឃុំ សង្កាត់សម្រាប់ស្ត្រី និងកុមារក្នុងការចូលរួមធ្វើសេចក្តីសម្រេចចិត្តនៅថ្នាក់មូលដ្ឋាន។ ចំណុចព្រួយបារម្ភជាចម្បង គឺបញ្ហាថវិកាតិចតួចបំផុតសម្រាប់គណៈកម្មាធិការនេះ។ គណៈកម្មាធិការបែបនេះភាគច្រើនមានថវិកាប្រចាំឆ្នាំតែ២០០ដុល្លារ ប៉ុណ្ណោះទេ ដែលមិនគ្រប់គ្រាន់សម្រាប់បំពេញតួនាទីឱ្យមានប្រសិទ្ធិភាព និងដើម្បីធ្វើសកម្មភាពនានាឡើយ។ សមាជិកគណៈកម្មាធិការខ្លះបានរាយការណ៍ថា មិនបានទទួលថវិកាទាល់តែសោះ។ ជាការពិត គឺគណៈកម្មាធិការ

[៣០] ជាមួយគណៈកម្មាធិការឃុំ សង្កាត់ដើម្បីស្ត្រី និងកុមារ។

នេះបាននិយាយថា បើគ្មានការជួយជ្រោមជ្រែងបន្ថែមពីសំណាក់អង្គការជាតិ និងអន្តរជាតិទេ គណៈកម្មាធិការនោះច្រើនតែគ្មានដំណើរការទេ (CPWP ឆ្នាំ២០០៩)។

ថ្វីត្បិតតែរដ្ឋាភិបាល កំពុងគាំទ្រដល់អង្គការមិនមែនរដ្ឋាភិបាលទាំងឡាយដែលខិតខំលើកកម្ពស់សិទ្ធិស្ត្រី និងកសាងសមត្ថភាពស្ត្រីដើម្បីចូលរួមក្នុងជីវភាពសាធារណៈយ៉ាងណាក៏ដោយ ក៏អង្គការមិនមែនរដ្ឋាភិបាលទាំងនោះ នៅតែមានការលំបាកក្នុងការតាមដានលើការអនុវត្តន៍គោលនយោបាយរបស់រដ្ឋាភិបាលណាស់ ជាពិសេសអំពីផែនការចាត់ចែង និងបែងចែកថវិកាដល់ថ្នាក់មូលដ្ឋាន។ ទោះបីជាកម្ពុជាបានបង្ហាញនូវការប្តេជ្ញាចិត្តខ្ពស់ចំពោះដំណើរការវិមជ្ឈការឆ្លើយតបយេនឌ័រយ៉ាងណាក៏ដោយ ក៏នីតិវិធីនានានៅខ្វះតម្លាភាព និងការផ្ទេរអំណាចក្នុងការសម្រេចចិត្តពិតៗ ព្រមទាំងការផ្តល់ថវិកាឱ្យថ្នាក់មូលដ្ឋាន នៅតែមានកម្រិតទាបជាទីបំផុតនៅឡើយ។ បញ្ហានេះ គឺស្ទើរតែមិនអាចទម្លាក់ការទទួលខុសត្រូវដល់ថ្នាក់មូលដ្ឋានបានទេ។

កង្វះទំនុកចិត្តក្នុងការចូលរួមយ៉ាងសកម្មក្នុងការងារនយោបាយ ច្រើនតែគួបផ្សំជាមួយសមត្ថភាពទាប។ ស្ត្រីច្រើនតែទទួលការអប់រំថ្នាក់ឧត្តមតិចជាងបុរស ដូច្នេះឱកាសក្នុងការអភិវឌ្ឍន៍អាជីពរបស់អ្នកទាំងនោះច្រើនតែត្រូវរារាំងដោយការរៀបចំកម្មវិធីបណ្តុះបណ្តាល និងការទទួលខុសត្រូវក្នុងសង្គមផ្សេងៗទៀតរបស់ស្ត្រី។ ឱកាសរៀនសូត្ររបស់កុមារី និងស្ត្រីវ័យក្មេងច្រើនតែពុំសូវធានាបានការងារ និងចំណូលគ្រប់គ្រាន់ទេ ដែលកត្តានេះក៏ជាបញ្ហាមួយរារាំងដល់ការចូលរួមរបស់ស្ត្រីដែរ (ចម្រើនស្ត្រី ឆ្នាំ២០០៩)។

ស្ត្រីកម្ពុជាមានចំណូល ៥៩% ក្នុងចំណោមប្រជាពលរដ្ឋសកម្មក្នុងផ្នែកសេដ្ឋកិច្ចទាំងអស់ ទោះបីជាបន្ទុកការងារទូទៅរបស់អ្នកទាំងនោះមិនត្រូវបាន (ឧ."សេដ្ឋកិច្ចថែទាំ") ពិចារណានៅក្នុងស្ថិតិផ្លូវការរបស់រដ្ឋាភិបាលយ៉ាងណាក៏ដោយ។ ប៉ុន្តែ ចំណូលរបស់ស្ត្រីទាបជាងចំណូលរបស់បុរសឆ្ងាយណាស់ ហើយស្ត្រីជាច្រើនមិនអាចចូលរួមក្នុងសកម្មភាពសង្គម និងនយោបាយទេ គឺអាស្រ័យដោយភាពក្រីក្រ។ ប្រាក់បៀវត្សទាបក្នុងវិស័យសាធារណៈ ក៏ប្រហែលជាធ្វើឱ្យស្ត្រីដែលមានស្ថានភាពសេដ្ឋកិច្ចមិនល្អ ដកថយពីការស្វែងរកតួនាទីនយោបាយផងដែរ។ ការចូលរួមក្នុងនយោបាយថ្នាក់មូលដ្ឋាន គឺជាជម្រើសមួយសម្រាប់ចំនួនស្ត្រីតិចតួចប៉ុណ្ណោះទេ ជាពិសេសស្ត្រីដែលមានឯករាជភាពខាងហិរញ្ញវត្ថុ មិនសូវទទួលបន្ទុកក្រុមគ្រួសារធ្ងន់ ឬមានការគាំទ្រយ៉ាងខ្លាំងពីសំណាក់ក្រុមគ្រួសារ និងស្វាមី (Thon, Ou ឆ្នាំ២០០៩)។

ដូចនៅក្នុងសង្គមឯទៀតជាច្រើនក្រោយសង្គ្រាម គេមើលឃើញមានអំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាលើផ្លូវភេទក្នុងកម្រិតមួយយ៉ាងខ្ពស់ ដែលមិនអាចទទួលយកបានកើតមានគ្រប់ទិសទីនៅកម្ពុជា។ មូលដ្ឋានច្បាប់ និងការអនុវត្តន៍ច្បាប់ទាំងនោះមិនទាន់គ្រប់គ្រាន់ ដើម្បីការពារស្ត្រីពីសំណាក់អំពើហិង្សាក្នុងគ្រួសារ ឬការពារស្ត្រីពីការរំលោភផ្លូវភេទបានជាទូទៅទេ។ ជាទូទៅ ការចូលរួមរបស់ស្ត្រីនៅមានកម្រិតអាស្រ័យដោយទំនាក់ទំនងអំណាចមិនស្មើគ្នាក្នុងបរិយាកាសក្រុមគ្រួសារសាធារណៈ និងសេដ្ឋកិច្ច។ កង្វះខាតកិច្ចការពារ ឧបសគ្គពេលវេលា និងការលំបាកផ្នែកសេដ្ឋកិច្ច រារាំងឱកាសចូលរួមរបស់ស្ត្រីក្នុងជីវភាពសាធារណៈ និងនយោបាយ។ ការចំណាយក្នុងការចូលរួមក្នុងជីវភាពសាធារណៈ និងនយោបាយមានភាពខុសគ្នាជាសមាមាត្រសម្រាប់ស្ត្រីខ្ពស់ជាងបុរស។ បញ្ហានេះ កាន់តែបង្ហាញឱ្យឃើញច្បាស់ថែមទៀតដោយ

ការបែងចែករវាងទីក្រុង និងជនបទ ការរារាំងដែលលើកឡើងខាងលើ កើតឡើងកាន់តែខ្លាំងច្រើនទៅៗ ចំពោះស្ត្រីដែលរស់នៅជនបទ។

ក្របខណ្ឌការងារសង្គម ក៏មានការពាក់ព័ន្ធថែមទៀតផងដែរ ចំពោះស្ត្រីដែលកាន់តំណែងតួនាទីក្នុងការសម្រេចចិត្ត។ ទោះបីជាត្រូវបានជាប់ឆ្នោតក៏ដោយ ស្ត្រីអាចច្រើនតែមានអារម្មណ៍ដូចចាញ់ បាត់បង់ទំនុកចិត្ត មិនត្រូវបានឱ្យចូលរួមក្នុងការសម្រេចចិត្ត និងមិនសូវបានចូលរួមនៅក្នុងក្រុមប្រឹក្សា (Maffii, Hong ឆ្នាំ២០០៨)។ អ្នកនយោបាយបុរសមួយចំនួននិយាយថា គេនឹងពេញចិត្តចំពោះការចូលរួមកាន់តែច្រើនរបស់ស្ត្រី ប៉ុន្តែគេមិនអាចផ្តល់ការទទួលខុសត្រូវច្រើនឱ្យស្ត្រីទេ ប្រសិនបើស្ត្រីមិនរួមចំណែក និងបង្ហាញជំនឿជឿជាក់ថែមទៀតក្នុងការចូលរួម។ នៅពេលនេះស្ត្រីនិយាយថា ត្រូវតែធ្វើឱ្យបានល្អជាងសហការីបុរស ដើម្បីទទួលបាននូវការគោរព និងឱ្យតម្លៃ។

បរិយាកាសនយោបាយកម្ពុជា គឺជានយោបាយមួយដែលត្រូវបានកំណត់រូបរាងលក្ខណៈជារចនាសម្ព័ន្ធខ្នងការពារ និងនយោបាយបក្សខុសទិសគ្នាដែលមានកម្រិតយ៉ាងខ្ពស់។ ដោយហេតុថា មូលដ្ឋាននេះគឺជារចនាសម្ព័ន្ធប្រព័ន្ធខ្នងការពារដែលយកបុរសជាធំលើស្ត្រី នៅតែមានការលំបាកក្នុងការចូលរួមក្នុងនយោបាយ (Oxfam-ចម្រើនស្ត្រី ឆ្នាំ២០០៨)។ បញ្ហានេះ ស្ត្រីស្ទើរតែមិនអាចចូលរួម និងទទួលបានការចុះឈ្មោះខ្ពស់ក្នុងបញ្ជីគណបក្ស បើមិនបានស្ថិតក្នុងផ្នែករចនាសម្ព័ន្ធនេះទេ។ ការពិភាក្សារវាងបក្សមួយ និងបក្សមួយ ព្រមទាំងកិច្ចសហប្រតិបត្តិការដើម្បីសម្រេចបានការជឿនលឿនសម្រាប់សង្គមទាំងមូលលើសពីកម្រិតបក្ស គឺជាឧបសគ្គមួយយ៉ាងធំអស្ចារ្យ។ ករណីសិក្សាមួយថ្មីៗនេះ បង្ហាញថា ស្ត្រីជាប្រធានភូមិភាគច្រើនធ្វើការគ្មានប្រសិទ្ធិភាពទេ ពីព្រោះសមាជិកក្រុមប្រឹក្សាមកពីគណៈបក្សផ្សេងៗតែងតែបដិសេធមិនសហការជាមួយមេភូមិទាំងនោះ (Thon, Ou,ឆ្នាំ២០០៩)។

អង្គការមិនមែនរដ្ឋាភិបាលខ្លះបានទទួលសេចក្តីរាយការណ៍ពីស្ត្រី ដែលមានអារម្មណ៍ថាមានការរេសីអើង និងបំភិតបំភ័យ ពេលកំពុងឃោសនារកសម្លេងឆ្នោត ឬចូលរួមក្នុងដំណើរការនយោបាយ។ ការមិនជឿជាក់អំពីឯករាជភាពតុលាការ គឺកើតឡើងគ្រប់ទិសទី ហើយស្ត្រីជាច្រើនកំពុងសង្ស័យថា តើតុលាការមានការប្តេជ្ញាចិត្តពិតប្រាកដក្នុងកិច្ចការពារសិទ្ធិស្ត្រី ដើម្បីឈរជាតំណាងក្នុងមណ្ឌលបោះឆ្នោតក្នុងលក្ខណៈមួយដែលមិនបង្កការលំបាកដល់សុវត្ថិភាព សេចក្តីថ្លៃថ្នូរ និងសមភាពរបស់ស្ត្រីឬទេ? បញ្ហានេះ បានរារាំងយ៉ាងខ្លាំងដល់ការចូលរួមរបស់ស្ត្រីក្នុងការសម្រេចចិត្តជាសាធារណៈ។ និទណ្ឌភាព (ធ្វើខុសតែមិនទទួលទោស) នៅតែមានទៀត ហើយស្ត្រីភាគច្រើននៅខ្វះទំនុកចិត្ត និងការលើកទឹកចិត្តក្នុងការនិយាយតបតក្នុងបរិយាកាសរើសអើងទៅលើស្ត្រីនេះ។ បញ្ហានេះ ត្រូវបានពង្រឹងថែមទៀតតាមរយៈច្បាប់ ដែលមិនទាន់បានឆ្លើយតបទៅនឹងបញ្ហាយេនឌ័របានគ្រប់គ្រាន់នៅឡើយទេ ព្រមទាំងមិនទាន់បានធានាដោយជាក់ស្តែងនូវការការពារទប់ទល់ការរើសអើងលើស្ត្រីនៅក្នុងប្រព័ន្ធយុត្តិធម៌ បរិយាកាសសេដ្ឋកិច្ច កន្លែងធ្វើការ និងក្រុមគ្រួសារជាដើម។

រចនាសម្ព័ន្ធដែលបានលើកឡើងខាងលើ នេះពុំមែនជាមូលដ្ឋានរឹងមាំសម្រាប់ការអនុវត្តន៍នីតិកម្មដ៏មានតម្លៃដែលត្រូវបានអនុម័តឱ្យបានជោគជ័យទេ។ កម្ពុជាត្រូវតែអនុវត្តវិធីសាស្ត្រឱ្យកាន់តែមានរចនាសម្ព័ន្ធជាងនេះទៅទៀតដើម្បីអាចយល់ និងលុបបំបាត់ចោលនូវប្រភពនៃការរើសអើងលើស្ត្រីក្នុងការសម្រេច

ចិត្ត។ កម្ពុជាក៏ត្រូវបង្ហាញនូវឆន្ទៈយ៉ាងច្បាស់ក្នុងការកែលំអរស្ថានភាពរបស់ស្ត្រី តាមរយៈការផ្តល់ថវិកាគ្រប់គ្រាន់នៅក្នុងផ្នែកនេះ ដែលជាការលើកទឹកចិត្តដល់ការអនុវត្តន៍ច្បាប់ពាក់ព័ន្ធនានា។

## ២.១ ការផ្សព្វផ្សាយសម្លេងស្ត្រីៈ ការកែប្រែសង្គមតាមរយៈការចូលរួម

ការចូលរួមក្នុងការងារនយោបាយមានន័យថា ជាការអនុវត្តន៍នូវសកម្មភាពមួយចំនួន ដែលមានកម្រិតក្នុងការចាត់ចែង រៀបចំខុសៗគ្នា ដើម្បីសម្រេចបាននូវការផ្លាស់ប្តូរក្របខណ្ឌអំណាចសង្គម។ ប្រសិនបើស្ត្រីកម្ពុជាច្រើនជាងពាក់កណ្តាលនៃប្រជាពលរដ្ឋសរុប ហើយមិនអាចចូលរួមក្នុងការសម្រេចចិត្តពិតៗ ហើយនៅស្ថិតក្រោមការគ្រប់គ្រងរបស់បុរសពិតមែន នោះតម្រូវការ និងចក្ខុវិស័យសមភាពយេនឌ័រមិនអាចទៅរួចបានទេ។ ដើម្បីអាចចូលរួមក្នុងនយោបាយបាន ស្ត្រីត្រូវតែមានការជឿជាក់លើខ្លួនឯង ស្វ័យភាព សេរីភាព និងសន្តិសុខ។

ទស្សនៈដែលលើកឡើងអំពី "ការចូលរួមក្នុងឆាកនយោបាយ" ជាការសម្លឹងមើលនូវការចូលរួមរបស់ពលរដ្ឋទាំងអស់ក្នុងនយោបាយ និងការធ្វើគោលនយោបាយ។ បញ្ហានេះ តម្រូវឱ្យមានទំនាក់ទំនងរវាងរដ្ឋាភិបាល និងសង្គម ដែលលើកទឹកចិត្តការចូលរួមរបស់ប្រជាពលរដ្ឋ និងទស្សនៈដែលមានច្រើន។ កិច្ចការនេះ ត្រូវមានការគាំទ្រតាមរយៈការពង្រឹងគណបក្សនយោបាយនានា ឬលើកទឹកចិត្តឱ្យមានការចូលរួមរបស់ក្រុមទាំងឡាយដែលត្រូវគេផាត់ឲ្យនៅក្រៅ ដែលនៅក្នុងនោះមានស្ត្រីជាដើម។ (Garcia ឆ្នាំ១៩៩៣ មានបញ្ជាក់ក្នុង Naz, ឆ្នាំ២០០២)។

## ២.២ ការចូលរួមរបស់ស្ត្រីក្នុងឆាកនយោបាយ

នៅទូទាំងពិភពលោកនេះ ការចូលរួមរបស់ស្ត្រីក្នុងការងារនយោបាយច្រើនតែជាការបង្ហាញឱ្យឃើញនូវមរតកនៃកង្វះតំណាងស្ត្រី។ បញ្ហានេះ បានកើតឡើងជាប្រវត្តិសាស្ត្រ អាស្រ័យដោយមូលហេតុមួយចំនួនគឺៈ ឥរិយាបទដែលមានរើសអើងពីសង្គម ខ្វះការអប់រំ ខ្វះការត្រៀមរៀបចំ ព្រមទាំងរបាំងរចនាសម្ព័ន្ធដែលរារាំងមិនឱ្យស្ត្រីអាចចូលរួមក្នុងចលនាប្រជាធិបតេយ្យបាន (Powly, ឆ្នាំ២០០៨)។ នៅកម្ពុជា អនុសញ្ញា CEDAW ការចូលរួមរបស់ស្ត្រីក្នុងនយោបាយត្រូវបានកំណត់ថាជាសិទ្ធិសម្រាប់ស្ត្រីៈ

- ចូលរួម និងជាផ្នែកនៃគណបក្សនយោបាយ
- ឈរឈ្មោះបោះឆ្នោតជាបេក្ខនារីនៅថ្នាក់មូលដ្ឋាន
- ត្រូវបានជ្រើសរើសតាមការបោះឆ្នោត/តំឡើងឋានៈ មុខតំណែង
- ដើរតួជាអ្នកធ្វើការសម្រេចចិត្តក្នុងរដ្ឋាភិបាលគ្រប់កម្រិតស្មើគ្នាជាមួយបុរស និងដោយគ្មានការរើសអើង
- ចូលរួមជាមួយអង្គការមិនមែនរដ្ឋាភិបាល និងសមាគមដែលទាក់ទងជាមួយជីវភាពសាធារណៈ និងនយោបាយរបស់ប្រទេស
- ស្វែងរកឱកាសរៀនសូត្រដើម្បីលើកកម្ពស់សមត្ថភាព និងចំណេះដឹង
- ប្រើប្រាស់សិទ្ធិក្នុងនាមជាពលរដ្ឋ

កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិបានកត់សម្គាល់ឃើញថា "នយោបាយ និងការចូលរួមត្រូវរាប់ចាប់ពីការងារផ្ទះ តាមរយៈការងារមូលដ្ឋានរហូតដល់ថ្នាក់ជាតិ។ ស្ត្រីត្រូវតែចូលរួមនៅថ្នាក់តូចមួយនៅក្នុងការងារផ្ទះ ថ្នាក់កណ្តាលរបស់អង្គការសហគមន៍ និងអាជ្ញាធរថ្នាក់មូលដ្ឋាន និងនៅថ្នាក់ជាតិរបស់គណបក្ស ដូចជារដ្ឋសភា និងរដ្ឋាភិបាលជាដើម។ វិមជ្ឈការដែលជាការបែងចែកប្រគល់អំណាច និងធនធានមើលទៅហាក់ដូចជាការបើកចំហរឆាកឱ្យបានកាន់តែធំជាងមុនសម្រាប់ឱ្យមានការចូលរួមកាន់តែមានន័យ និងមានភាពជាតំណាងរបស់ស្ត្រី" (UNDP ឆ្នាំ២០០០)។

## ៣. អនុសាសន៍

គោលការណ៍ណែនាំ ក៏បានផ្តល់អនុសាសន៍លុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទក្នុងឆាកនយោបាយ និងការសម្រេចចិត្តនៅកម្ពុជាដែលត្រូវតែដាក់បញ្ចូលសកម្មភាពទាំងបី នៃសិទ្ធិក្នុងការចូលរួមរបស់ស្ត្រីៈ

១. កសាង និងពង្រឹងមូលដ្ឋានគ្រឹះនៃប្រជាពលរដ្ឋ ឧទាហរណ៍ ការចូលរួមយ៉ាងសកម្មរបស់ស្ត្រីក្នុងវេទិកា និងទិដ្ឋភាពនៃការសម្រេចចិត្តក្នុងសហគមន៍ ក្នុងសិទ្ធិបោះឆ្នោតដោយសេរី (និងការយល់ដឹងអំពីសារសំខាន់ក្នុងការអនុវត្តន៍សិទ្ធិនេះ) និងការអនុវត្តន៍វិធានការដើម្បីកែលំអរទាំងស្ថានភាព និងតួនាទីក្នុងសង្គម។

២. បណ្តុះបណ្តាលស្ត្រី ដែលអាចក្លាយជាមេដឹកនាំនៅអនាគត ក្នុងគោលបំណងដើម្បីបម្រុង និងរុះរើចោលនូវទស្សនៈអំពីគំរូដឹកនាំរបស់បុរស និងដំណើរការការងារជាទស្សនៈថ្មីដូចជាសាមគ្គីភាព ការទទួលខុសត្រូវ និងស្វ័យភាព គួរត្រូវបានលើកទឹកចិត្ត។

៣.បណ្តុះបណ្តាលអំពីការយល់ដឹងយេនឌ័រ កាត់បន្ថយវិសមភាពយេនឌ័រ និងការផ្តល់អំណាចឱ្យស្ត្រី។

៤. សង្គមស៊ីវិលត្រូវតែហ្មត់ចត់ និងទទូចឱ្យគ្រប់ផ្នែកទាំងអស់ចាប់តាំងពីកម្មវិធីសិក្សាតាមសាលាដែលនៅតែនិយាយបង្អាប់ស្ត្រីជាទូទៅ ព្រមទាំងរារាំងមិនឱ្យស្ត្រីចូលរួមឱ្យបានពេញលេញក្នុងការសម្រេចចិត្ត នោះត្រូវតែលុបចោល។ គួរស្នើសុំឱ្យភ្នាក់ងារប្រព័ន្ធផ្សាយព័ត៌មាននានាឈប់លើកឡើងអំពីផ្នត់គំនិតអវិជ្ជមានលើស្ត្រី។

៥.យកចិត្តទុកដាក់ឱ្យកាន់តែខ្លាំងជាងមុន ចំពោះការអនុវត្តន៍នីតិកម្មពិតប្រាកដ និងប្រកបដោយប្រសិទ្ធិភាព។ ប្រើប្រាស់វិធីសាស្ត្រគុណភាព និងបរិមាណដើម្បីតាមដាន និងវាយតម្លៃលើបញ្ញត្តិនានា ដែលមានស្រាប់ និងធានាឱ្យមានថវិកាគ្រប់គ្រាន់ ព្រមទាំងការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយតម្លាភាព។

៦.គាំទ្រស្ត្រី និងក្រុមស្ត្រីទាំងឡាយក្នុងការជម្រុញឱ្យរដ្ឋាភិបាលទទួលខុសត្រូ វចំពោះការសន្យាតាមរយៈការចូលរួមយ៉ាងសកម្មរបស់ស្ត្រីក្នុងការប្រមូលទិន្ន័យ និងឃ្លាំមើលក្នុងចំណោមកិច្ចការទាំងឡាយ។

៧. ក្នុងគោលបំណង ដើម្បីឱ្យមានការសម្របសម្រួលប្រសើរជាងមុនអំពីសកម្មភាព និងការបណ្តុះបណ្តាល ដោយមានការផ្តោតការយកចិត្តទុកដាក់ ជាពិសេសចំពោះទំនាក់ទំនងរវាងសិទ្ធិស្ត្រី និងឧបសគ្គវប្បធម៌នានារបស់កម្ពុជាដែលរារាំងដល់សិទ្ធិស្ត្រី។

៨. ក្រសួងកិច្ចការនារី និងក្រសួងយុត្តិធម៌គួរតែបង្កើត និងអនុវត្តកម្មវិធីដើម្បីបង្កើនចំនួនស្ត្រីនៅក្នុងឋានៈអ្នកធ្វើការសម្រេចចិត្តក្នុងផ្នែកតុលាការ តាមរយៈវិធានការពិសេស និងលើកទឹកចិត្តស្ត្រីជានិស្សិតច្បាប់។

៩. គណបក្សនយោបាយ គួរបង្កើតកម្មវិធីដើម្បីផ្លាស់ភេទបេក្ខជននៅក្នុងបញ្ជីឈ្មោះបោះឆ្នោត។

១០.មន្ត្រីជាន់ខ្ពស់ជាបុរស និងបុរសទូទៅត្រូវចូលរួមវគ្គណ្តុះបណ្តាល ស្តីពីសកម្មភាពលើកកំពស់ការយល់ដឹងឱ្យបានកាន់តែច្រើនឡើងៗ ដោយផ្តោតការយកចិត្តទុកដាក់លើការជួយគ្នាទៅវិញទៅមករវាងបុរស និងស្ត្រី។ វគ្គបណ្តុះបណ្តាលស្តីពីការលើកកំពស់ការយល់ដឹងអំពីបញ្ហាយេនឌ័រត្រូវតែពិចារណាដោយក្រុមបុរសនៅកន្លែងការងារ។

១១.ផ្តោតការយកចិត្តទុកដាក់ ចំពោះការពិភាក្សាដេញដោលរវាងគណបក្ស និងគណបក្សដើម្បីឱ្យមានកិច្ចសហប្រតិបត្តិការ និងការដាក់បញ្ចូលសម្លេង និងតម្រូវការរបស់ស្ត្រីឱ្យបានកាន់តែប្រសើរជាងមុន ជំនួសឱ្យការផ្តោតការយកចិត្តទុកដាក់ទៅលើតែផលប្រយោជន៍បក្ស និងរចនាសម្ព័ន្ធ។

១២.ការគ្រប់គ្រងផែនការសកម្មភាពទូទៅទាំងអស់ គួរសំដៅទៅលើស្ត្រីក្នុងការសម្រេចចិត្ត និងដឹកនាំនៅក្នុងក្រសួងសាមី និងគោលនយោបាយផងដែរ។ ការគ្រប់គ្រងផែនការសកម្មភាពទូទៅទាំងអស់គួរពិចារណាកមធ្យោបាយដោះស្រាយអំពីវិធីសាស្ត្ររចនាសម្ព័ន្ធ នៅពេលវាយតម្លៃឧបសគ្គ ដែលរារាំងដល់ការរីកចំរើនរបស់ស្ត្រី។ ថវិកាដើម្បីធានាដល់ការអនុវត្តន៍ការគ្រប់គ្រងផែនការសកម្មភាពទូទៅ គឺជាកត្តាសំខាន់។

១៣. បង្កើនប្រាក់បៀវត្សរ៍នៅក្នុងផ្នែកសាធារណៈ ដើម្បីជម្រុញឱ្យមានការចូលរួមពីសំណាក់ស្ត្រីក្រីក្រ និងរស់នៅតាមជនបទ។ ប្រាក់បៀវត្សរ៍ត្រូវបើកឱ្យបានទាន់ពេលវេលា។ ការបង្កើនប្រាក់បៀវត្សនឹងធានាឱ្យស្ត្រីអាចចំណាយលើការអប់រំដែលអាចនាំឱ្យស្ត្រីមានការងារ និងទទួលបានប្រាក់ចំណូលច្រើនជាងមុន។ ភាពក្រីក្រតែងតែជាឧបសគ្គមួយមិនឱ្យស្ត្រីចូលរួមក្នុងវិស័យសាធារណៈ។

១៤.ពង្រឹងបញ្ហាយេនឌ័រ និងសិទ្ធិជនជាតិដើមភាគតិច ដើម្បីធានាឱ្យមានការចូលរួមពេញលេញរបស់ស្ត្រីជនជាតិដើមភាគតិច និងស្ត្រីពិការក្នុងដំណើរការនយោបាយ។

១៥.ធានាឱ្យប្រជាពលរដ្ឋជនជាតិដើមភាគតិច អាចប្រើប្រាស់រាល់សេវាកម្មរដ្ឋាភិបាលទាំងអស់ជាភាសារបស់អ្នកទាំងនោះ ព្រមទាំងរៀបចំឱ្យមានអ្នកបកប្រែដោយឥតគិតថ្លៃ។

១៦. ចាត់វិធានការច្បាស់លាស់ ដើម្បីទប់ស្កាត់ហិង្សា និងការគំរាមកំហែងដោយហិង្សាលើស្ត្រីដែលឈរឈ្មោះបោះឆ្នោត និងចូលរួមក្នុងសកម្មភាពនយោបាយ។ ដាក់កម្រិតឱ្យមានការដោះស្រាយផ្នែកច្បាប់ដោយឯករាជ្យ និងមានប្រសិទ្ធិភាពដើម្បីការពារសិទ្ធិរបស់ស្ត្រីទាំងនោះ។

តាមការយល់ដឹងពីស្ថានភាពនៅកម្ពុជា សូមឱ្យអ្នកនយោបាយស្ត្រី សកម្មជន និងអ្នកបោះឆ្នោតទាំងឡាយត្រូវចូលរួមកសាងរបៀបវារៈគោលនយោបាយប្រចាំតំបន់ ដែលលើកស្ទួយការចូលរួម និងជាតំណាងនៅក្នុងរដ្ឋាភិបាលគ្រប់លំដាប់ថ្នាក់ទាំងអស់ ព្រមទាំងផ្តល់ឱ្យស្ត្រីទាំងអស់នូវសិទ្ធិទទួលបានផលប្រយោជន៍ពេញលេញរបស់ពលរដ្ឋ។ សមភាពយេនឌ័រ និងប្រជាធិបតេយ្យគួរកសាងតាមរយៈការចូលរួមក្នុងនយោបាយ ប៉ុន្តែបញ្ហានេះ ពុំមែនជាការងារងាយស្រួល និងលឿន ព្រមទាំងរហ័សទាន់ចិត្តនោះទេ។ បុរស និងស្ត្រីត្រូវតែសហការគ្នា ដើម្បីបង្កើតនូវដំណើរការមួយដែលមានការផ្លាស់ប្តូរយ៉ាងខ្លាំង ដើម្បីដោះស្រាយបញ្ហាឫសគល់ដែលបណ្តាលឱ្យមានវិសមភាពនេះ។

# ជំពូក ៤. សិទ្ធិសុខភាព និងសិទ្ធិផ្លូវភេទ ព្រមទាំងសិទ្ធិក្នុងការបន្តពូជ

## ១. *ស្ថានភាព*

ស្ថានភាពបច្ចុប្បន្នរបស់ហេដ្ឋារចនាសម្ព័ន្ធសុខភាពកម្ពុជា មានលក្ខណៈទន់ខ្សោយ និងមានគម្លាតយ៉ាងធំ ដែលប៉ះពាល់ដល់ពលរដ្ឋកម្ពុជាទាំងមូល មិនមែនត្រឹមតែស្ត្រីនោះទេ។ ដើម្បីកែលំអរស្ថានភាពនេះ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើផែនការយុទ្ធសាស្ត្រសុខភាពសម្រាប់ឆ្នាំ២០០៨ - ២០១៥។

យោងតាមរបាយការណ៍រាជរដ្ឋាភិបាលកម្ពុជា ស្តីពីសមិទ្ធិផលក្នុងវិស័យសុខភាពឆ្នាំ២០០៨ បានឱ្យដឹងថា ចំនួនមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក និងមន្ទីរពេទ្យមានចំនួនកើនឡើង។ ទន្ទឹមនឹងនេះ ចំនួនរថយន្តសង្គ្រោះបន្ទាន់ក៏មានការកើនឡើងដែរ ហើយមន្ទីរពេទ្យ និងរថយន្តសង្គ្រោះទាំងនោះត្រូវបានបែងចែកនៅគ្រប់ភូមិសាស្ត្រទាំងអស់។ រដ្ឋាភិបាលក៏បានផ្តល់គ្រប់លទ្ធភាពទាំងអស់ឱ្យអង្គការជាតិ និងអន្តរជាតិនានា ព្រមទាំងភ្នាក់ងារអង្គការសហប្រជាជាតិ ដើម្បីប្រើប្រាស់មូលនិធិសមធម៌សម្រាប់ផ្តល់ឱ្យជនក្រីក្រ ដើម្បីទទួលបានសេវាកម្មសុខភាពនៅតាមមន្ទីរពេទ្យមូលដ្ឋាន។ ការងារនេះ ត្រូវបានអនុវត្តនៅមណ្ឌលសុខភាពចំនួន ៩៨ (ក្នុងចំណោមមណ្ឌលសុខភាពទាំងអស់៩៦៧ កន្លែងនៅទូទាំងប្រទេស) និងមន្ទីរពេទ្យបង្អែកចំនួន ៤៧ កន្លែង (ក្នុងចំណោម ៧៧) ក្នុងចំណោមនោះ មន្ទីរពេទ្យថ្នាក់ជាតិចំនួន៦ និងមន្ទីរពេទ្យបង្អែក៩ ត្រូវបានឧបត្ថម្ភដោយថវិកាជាតិ ហើយនៅសល់ពីនោះ គឺឧបត្ថម្ភថវិកាដោយដៃគូអភិវឌ្ឍន៍។



ប៉ុន្តែ ទោះបីជាមានការចាត់វិធានការដើម្បីកែលំអរការថែទាំស្ត្រីកម្ពុជាក្នុ ងផ្នែកសុខភាពផ្លូវភេទ និងបន្តពូជយ៉ាងណាក៏ដោយ ក៏នៅតែជាឧបសគ្គដ៏ធំមួយក្នុងចំណោមឧបសគ្គជាច្រើន គឺបញ្ហាជំនឿទស្សនៈរបស់ពលរដ្ឋកម្ពុជាចំពោះបញ្ហាផ្លូវភេទ។ ក្នុងសង្គមកម្ពុជា គេសង្កេតឃើញមានការហាមប្រាមមិនឱ្យនិយាយអំពីបញ្ហាផ្លូវភេទរបស់ស្ត្រីទេ។ បញ្ហានេះ បានបណ្តាលឱ្យមានគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរ ក្នុងការឆ្លងជម្ងឺទាក់ទងនឹងផ្លូវភេទ ព្រមទាំងមានការមានផ្ទៃពោះដែលមិនចង់បាន និងជាផលវិបាកក្នុងការរំលូតកូន។

នៅកម្ពុជាមានការឱ្យតម្លៃខ្ពស់លើស្ត្រីបរិសុទ្ធ គឺស្ត្រីណាដែលមិនធ្លាប់រួមភេទទាល់តែសោះ។ ដូច្នេះ ភាពបរិសុទ្ធត្រូវបានគេចាត់ទុក ថាជាគុណតម្លៃរបស់ស្ត្រីមិនទាន់រៀបការ ហើយការជាប់ពាក់ព័ន្ធខាងផ្លូវភេទធ្វើឱ្យសង្គមមិនឱ្យតម្លៃឡើយ។

នៅកម្ពុជា រដ្ឋាភិបាលពុំមានទិន្នន័យណាមួយ ដែលអាចជឿជាក់បានស្តីពីទិដ្ឋភាពភាគច្រើនរបស់សុខភាពស្ត្រីនៅឡើយទេ។ យោងតាមរបាយការណ៍ផ្លូវការ អាយុសង្ឃឹមទុករបស់ស្ត្រីបានកើនឡើងពី ៥៨ ឆ្នាំ នៅឆ្នាំ១៩៩៨ ដល់ជាង៦៥ឆ្នាំ នៅឆ្នាំ២០០៤។ ប៉ុន្តែ បញ្ហាកង្វះទិន្នន័យបច្ចុប្បន្នមិនអាចឱ្យអ្នកណាម្នាក់ធ្វើ

សេចក្តីសន្និដ្ឋាន ព្រមទាំងធ្វើការវាយតម្លៃនូវការរីកចម្រើនពិតប្រាកដបានផងទេ។ យោងតាមទិន្នន័យចុងក្រោយបង្អស់បានបង្ហាញឱ្យឃើញថា អាយុសង្ឃឹមទុករបស់ស្ត្រី គឺខ្ពស់ជាងអាយុរបស់បុរសជាង៦ឆ្នាំ (វិទ្យាស្ថានស្ថិតិជាតិឆ្នាំ២០០៤) ។ យោងតាមទិន្នន័យផ្សេងទៀត អត្រាស្លាប់របស់កុមារក្រោមអាយុ ៥ឆ្នាំក៏ត្រូវបានថយចុះផងដែរពីឆ្នាំ២០០០ ដល់ឆ្នាំ២០០៥ ហើយអត្រាស្លាប់របស់កុមារានៅតែបន្តខ្ពស់ជាងកុមារី។ នេះជាលទ្ធផលដែលរកឃើញពីគ្រប់សូចនាករបញ្ហាសុខភាពចាប់ពីឆ្នាំ២០០៥ ដែលជាឆ្នាំចុងក្រោយបង្អស់។ ដូច្នេះគេត្រូវការទិន្នន័យថ្មីៗ ដើម្បីឱ្យយល់ច្បាស់អំពីបញ្ហាសុខភាពស្ត្រីនៅកម្ពុជាបច្ចុប្បន្នរួមទាំងឱកាសប្រើប្រាស់ធនធានវេជ្ជសាស្ត្រ និងប្រសិទ្ធិភាពរបស់ធនធានទាំងនោះផងដែរ។

## ១.១ ច្បាប់ និងគោលនយោបាយ

គោលនយោបាយ ស្តីពីសុខភាពរបស់កម្ពុជា ជាធម្មតាគឺថា "ពលរដ្ឋកម្ពុជាទាំងអស់គ្រប់ភេទ អាយុ ទីកន្លែងរស់នៅ ឬលទ្ធភាពក្នុងការចំណាយត្រូវទទួលបានសេវាកម្មសុខភាពជាមូលដ្ឋានប្រកប ដោយគុណភាពល្អ និងជំនាញសំខាន់ៗស្មើៗគ្នា ដែលបម្រើដោយបុគ្គលិកមានសមត្ថភាពជំនាញផ្នែកសុខភាពក្នុងតម្លៃមួយដែលប្រជាពលរដ្ឋអាចទទួលយកបាន។ ត្រូវមានព័ត៌មានដែលអាចឱ្យអ្នកទាំងនោះដឹងបានអំពីជម្រើសនានាដែលប៉ះពាល់ដល់បញ្ហាសុខភាព និងសុខមាលភាពរបស់អ្នកទាំងនោះផ្ទាល់ ព្រមទាំងក្រុមគ្រួសារផងដែរ" (HSP ឆ្នាំ២០០៣)។ ស្របជាមួយគោលនយោបាយនេះ ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិបញ្ជាក់ថា ស្ថានភាពសុខភាពរបស់ប្រជាពលរដ្ឋទូទៅ គឺជាអាទិភាពខ្ពស់សម្រាប់ប្រទេស។ អាទិភាពទាំងសុខភាពបន្តពូជ សុខភាពផ្លូវចិត្ត សុខភាពមាតា សុខភាពកុមារ ជំងឺអេដស៍ ការគ្រប់គ្រងជម្ងឺឆ្លង ព្រមទាំងការប្រើប្រាស់ទឹក និងបញ្ហាអនាម័យជាដើម។

គោលនយោបាយផែនការគ្រួសាររបស់ក្រសួងសុខាភិបាលបញ្ជាក់ថា មនុស្សគ្រប់រូបត្រូវមានសិទ្ធិទទួលបានសេវាកម្មសុខភាពបន្តពូជស្មើៗគ្នា។ "ផែនការយុទ្ធសាស្ត្រផ្នែក ២០០៨-២០១៥" របស់ក្រសួងសុខាភិបាលបានផ្តល់អាទិភាពទៅលើ:

១. កាត់បន្ថយអត្រាមរណភាពមាតា មរណៈភាពកុមារ និងមរណភាពនៅពេលសម្រាល។ អាត្រាជម្ងឺមាតា កុមារ និងអត្រាជំងឺនៅពេលសម្រាល។ កែលំអរសុខភាពបន្តពូជ។

២. កាត់បន្ថយអត្រាមរណភាព និងការមានជម្ងឺដែលបណ្តាលមកពីជម្ងឺឆ្លង។

៣. កាត់បន្ថយបន្ទុកនៃជម្ងឺមិនឆ្លង និងបញ្ហាសុខភាពផ្សេងៗទៀត។

៤. ការធ្វើឱ្យមានសុខដុមរមនា និងស្របតាមខ្សែសង្វាក់គ្នា។

លើសពីនេះ ទៅទៀត "កម្មវិធីជាតិស្តីពីសុខភាពបន្តពូជ" អនុញ្ញាតឱ្យយុវវ័យមានសិទ្ធិដើម្បី:[៣១]

១. ទទួលព័ត៌មាន និងការអប់រំអំពីសុខភាពបន្តពូជ។

២. ទទួលការថែទាំសុខភាពដោយសម្ងាត់។

៣. ទទួលបានការព្យាបាលក្នុងសេចក្តីថ្លៃថ្នូរ ការគោរព ភាពគួរសម និងយកចិត្តទុកដាក់។

[៣១] ដកស្រង់ចេញពីសៀវភៅសុខភាពបន្តពូជរបស់យុវវ័យនៃកម្មវិធីសុខភាពបន្តពូជជាតិ ឆ្នាំ២០០៧។

៤. ធានារក្សាការសម្ងាត់នូវព័ត៌មានផ្ទាល់ខ្លួន។
៥. ពន្យល់តាមដំណើរការនៃការទទួលសេវាកម្មសុខភាព។
៦. អ្នកផ្តល់សេវា ដែលផ្តល់ការព្យាបាលត្រូវមានការទទួលការបណ្តុះបណ្តាល និងមានគុណភាពត្រឹមត្រូវ។
៧. បន្តការថែរក្សាព្យាបាលប្រសិនជាចាំបាច់។
៨. ទទួលការព្យាបាលពីសំណាក់អ្នកផ្តល់សេវាដែលទទួលស្គាល់ជាផ្លូវការ ។
៩. បង្ហាញនូវយោបល់ពីការផ្តល់សេវាកម្ម និងបណ្តឹងអំពីការមិនពេញចិត្តទាក់ទងនឹងសេវាសុខភាព ។
១០. ទទួលសេវាសុខភាពក្នុងបរិយាកាសសុវត្ថិភាព។
១១. ធ្វើការសម្រេចចិត្ត ដោយសេរីអំពីបញ្ហាទាក់ទងនឹងសុខភាពបន្តពូជន៍ និងសុខភាពផ្លូវភេទ។
១២. ទទួលបានការថែទាំសុខភាពបន្តពូជប្រកប ដោយគុណភាព និងអាចទទួលយកបានដោយមិនគិតអំពីភេទ ជាតិសាសន៍ ពណ៌សម្បុរ ស្ថានភាពអាពាហ៍ពិពាហ៍ ឬទីកន្លែងឡើយ។
១៣. ការគ្រប់គ្រង និងការការពារខ្លួនឯងផ្ទាល់។
១៤. សិទ្ធិ និងសេរីភាពក្នុងការលុបបំបាត់ការរំលោភបំពានផ្សេងៗ អំពើរើសអើង និងការបង្ខិតបង្ខំលើការសម្រេចចិត្តអំពីជីវិតផ្លូវភេទ។

រាជរដ្ឋាភិបាលកម្ពុជាក៏បានទទួលស្គាល់តម្រូវការក្នុងការការពារ នៃការរីករាលដាលជម្ងឺអេដស៍តាមរយៈការអនុម័ត:

- ច្បាប់ស្តីពីការទប់ស្កាត់ និងការត្រួតពិនិត្យជំងឺអេដស៍ និងប្រកាសឲ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នស/រកម/០៧០២/០១៥ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០២ និង
- ផែនការយុទ្ធសាស្ត្រជាតិទី២ សម្រាប់ការឆ្លើយតបយ៉ាងទូលំទូលាយ និងចម្រុះវិស័យចំពោះជម្ងឺអេដស៍ (២០០៦-២០១០) ដែលផ្តល់អនុសាសន៍ឱ្យបង្កើនការគ្របដណ្តប់លើអន្តរាគមន៍ទប់ស្កាត់ប្រកបដោយប្រសិទ្ធិភាពសម្រាប់ស្ត្រីបំរើការកំសាន្ត និងអតិថិជន និងបុរសដែលរួមភេទជាមួយបុរស ព្រមទាំងអ្នកប្រើប្រាស់សារធាតុញៀន និងការចម្លងពីស្វាមីទៅភរិយា រួមទាំងរូបភាពចម្បងនៃការចម្លងជំងឺអេដស៍នៅក្នុងប្រទេសកម្ពុជា។

ទោះបីជាមានចេតនា និងគោលបំណងល្អៗជាច្រើនយ៉ាងណាក៏ដោយ ក៏នៅតែមានចន្លោះ ដែលមើលឃើញយ៉ាងច្បាស់រវាងយុទ្ធសាស្ត្រដែលបានរៀបចំឡើង និងការអនុវត្តន៍យុទ្ធសាស្ត្រទាំងនោះផងដែរ។

មានការខ្វះខាតសំភារៈ ធនធាន ការបណ្តុះបណ្តាល និងបុគ្គលិកមានសមត្ថភាពដើម្បីធ្វើការលើបញ្ហាទាំងនេះ តាមបែបផែនសព្វមុខមួយ។ ជាផលវិបាកនៃទិន្នន័យដែលបានបង្ហាញឱ្យឃើញនូវចំនួនអត្រាមរណភាពមាតា ការមានផ្ទៃពោះដែលមិនសមតាមបំណង និងការរីករាលដាលនៃជម្ងឺឆ្លងតាមការរួមភេទនៅតែខ្ពស់នៅឡើយ។ កង្វះធនធាន និងថែទាំសុខភាពប្រកបដោយប្រសិទ្ធិភាព បង្កឱ្យមានហានីភ័យចំពោះស្ត្រីដែលពុំមានលទ្ធភាពចំណាយសម្រាប់ការសម្រាលកូននៅមណ្ឌលសុខភាព។ ដើម្បីដោះស្រាយនូវបញ្ហានេះ

ត្រូវផ្តោតកិច្ចខិតខំប្រឹងប្រែង និងឱ្យមានការរីកចម្រើនលើចំណុច៣គឺៈ លើកកម្ពស់ការយល់ដឹង ទប់ស្កាត់ និងព្យាបាល។

### ១.២ សុខភាពបន្តពូជ និងផ្លូវភេទ

"សុខភាពបន្តពូជ" គឺជាស្ថានភាពពេញលេញនៃរាងកាយ ផ្លូវចិត្ត សុខមាលភាពសង្គម ហើយមិនមែនត្រឹមតែជាការជាសះពីជម្ងឺផ្នែកបន្តពូជ និង/ឬពិការភាពប៉ុណ្ណោះទេ ។ សុខភាពបន្តពូជ មានន័យថា ប្រជាពលរដ្ឋទទួលបានសុវត្ថិភាពក្នុងជីវិតផ្លូវភេទដែលគេជ្រើសរើស។ "សុខភាពផ្លូវភេទ" និយាយចំពោះការទទួលខុសត្រូវ និងសុវត្ថិភាពផ្លូវភេទរវាងដៃគូ ដោយមិនគិតពីចំណង់ចំណូលចិត្តផ្លូវភេទទេ។ "សុវត្ថិភាពក្នុងការរួមភេទ" គឺជាលក្ខខណ្ឌការពារជម្ងឺឆ្លងតាមការរួមភេទ រួមមានទាំងជម្ងឺអេដស៍ និងការមានផ្ទៃពោះ ដែលមិនសមតាមបំណងផងដែរ។ "សុខភាពបន្តពូជ" សំដៅទៅលើដំណើរការបន្តពូជ មុខងារ និងប្រព័ន្ធគ្រប់ដំណាក់កាលជីវិតទាំងអស់។ "សុខភាពបន្តពូជ" មានគោលបំណងដើម្បីជួយឱ្យបុរស និងស្ត្រីមានការទទួលខុសត្រូវ សុវត្ថិភាព និងជីវិតផ្លូវភេទប្រកបដោយសុវត្ថិភាព ព្រមទាំងសមត្ថភាព និងសេរីភាពក្នុងការរៀបចំផែនការមានកូននៅពេលណា និងរបៀបណា។

ត្រូវប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីធ្វើការផ្សព្វផ្សាយព័ត៌មានអំពីសុខភាពផ្លូវភេទព្រមទាំងសំដៅបង្កើនការយល់ដឹង និងផ្លាស់ប្តូរឥរិយាបទសង្គមនៅកម្ពុជា។ កិច្ចខិតខំប្រឹងប្រែងត្រូវតែរៀបចំឡើងតាមយុទ្ធសាស្ត្រ ដើម្បីធានាឱ្យសុខភាពផ្លូវភេទត្រូវបានយល់អំពីសន្តិសុខ និងសេរីភាពសម្រាប់ស្ត្រីកម្ពុជា ។ ចំណេះដឹងអំពីសិទ្ធិផ្លូវភេទផ្ទាល់ខ្លួនរបស់ស្ត្រីទាំងនោះ និងស្វ័យភាពក្នុងការសម្រេចចិត្តអំពីបញ្ហានេះក៏មានសារៈ-សំខាន់ដែរ។

ក្នុងចំណោមប្រជាពលរដ្ឋកម្ពុជាដែលជាស្ត្រី គេសង្កេតឃើញមានបញ្ហាគួរឱ្យកត់សម្គាល់ ដោយមានការមិនសូវយល់ដឹងអំពីបញ្ហាផ្លូវភេទ ព្រមទាំងមានការភ័យខ្លាចជាទូទៅពីការមិនទទួលស្គាល់ក្នុងសហគមន៍ ប្រសិនបើអាកប្បកិរិយាផ្លូវភេទរបស់ពួកគេមានលក្ខណៈអវិជ្ជមាន។ នេះមានន័យថា អ្វីៗដែលទាក់ទងដល់ភេទ ពុំមែនជាកម្មសិទ្ធិពេញលេញរបស់បុគ្គលដែលជាស្ត្រីនោះទេ ផ្ទុយទៅវិញត្រូវស្ថិតក្រោមការពិនិត្យពិច័យពីសំណាក់ញាតិមិត្ត ស្វាមី និងអ្នកជិតខាងរបស់ស្ត្រីទាំងនោះទៅវិញ។ ចំពោះស្ត្រី ក៏មានការបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ផងដែរ។ ស្ត្រីដែលនៅមិនទាន់រៀបការនៅក្នុងវ័យណាមួយ មិនត្រូវបានទទួលការវាយតម្លៃជាវិជ្ជមានទេ។ លើសពីនេះ ទៅទៀត ទោះបីជាពុំមានទិន្នន័យផ្លូវការក៏ដោយក៏អាពាហ៍ពិពាហ៍ជាច្រើននាពេលបច្ចុប្បន្ននេះត្រូវបានផ្សំផ្គុំ ឬបញ្ចុះបញ្ចូលដោយឪពុកម្តាយ ឬទទួលយកដោយផ្អែកលើផលប្រយោជន៍ណាមួយចំនួនចំពោះគ្នាទៅវិញទៅមក។ ក្នុងអាពាហ៍ពិពាហ៍បែបនេះ ភាពបរិសុទ្ធរបស់កូនក្រមុំ គឺចាត់ទុកជាធាតុសំខាន់ ព្រមទាំងត្រូវហ៊ានធានាថាបានធំពេញវ័យឡើងជាស្ត្រី ។ អត្រារៀបការនៅវ័យក្មេងរបស់ស្ត្រីកម្ពុជានៅតែខ្ពស់នៅឡើយ ។ យោងតាមទិន្នន័យរបស់អង្គការសហប្រជាជាតិ កាលពីឆ្នាំ២០០៧ គឺ ១០,៥០% នៃស្ត្រីរៀបការនៅចន្លោះពីអាយុ១៥ ដល់ ១៩ឆ្នាំ ធៀបនឹងបុរសត្រឹមតែ ១,៦០% តែប៉ុណ្ណោះ។

ពេលស្ត្រីមានផ្ទៃពោះ នោះអាចមានការផ្លាស់ប្តូរយ៉ាងសំខាន់ក្នុងការទទួលខុសត្រូវ។ បន្ទាប់ពីខ្វះការគ្រប់គ្រងលើសិទ្ធិសុខភាពផ្លូវភេទ និងបន្តពូជ ស្ត្រីត្រូវតែទទួលខុសត្រូវទាំងអស់លើការមានផ្ទៃពោះ និងដំណើរការសម្រាលកូន។ ស្វាមីមិនសូវរវល់ពាក់ព័ន្ធក្នុងបញ្ហានេះទេ ហើយការថែទាំផ្ទៃពោះត្រូវធ្លាក់លើស្ត្រី

ដែលត្រូវបន្តភារកិច្ចប្រចាំថ្ងៃជាធម្មតានៅក្នុងផ្ទះសម្បែងផងដែរ។ ដោយពិនិត្យមើលភាពក្រីក្ររបស់គ្រួសារកម្ពុជាភាគច្រើន និងកង្វះធនធានថែទាំសុខភាពរបស់សហគមន៍ នោះស្ត្រីពិតជាមិនសូវបានទៅពិនិត្យផ្ទៃពោះជាប្រចាំទេ។ ស្ត្រីច្រើនតែសម្រាលកូននៅផ្ទះពីព្រោះស្ត្រីខ្វះខាតឱកាសសម្រាប់ធ្វើដំណើរទៅមន្ទីរពេទ្យ។ ដូច្នេះអត្រាមរណៈមាតារបស់ស្ត្រីកម្ពុជាក្នុងពេលសម្រាលកូននៅតែខ្ពស់ជាងគេបំផុតនៅអាស៊ី និងតំបន់អាស៊ីប៉ាស៊ីហ្វិក។ យោងតាមទិន្នន័យផ្លូវការរបស់អង្គការសហប្រជាជាតិ អត្រាមរណៈមាតាគឺ៥៤០នាក់ ក្នុងចំណោមស្ត្រី ១០០.០០០នាក់ ដែលសម្រាលកូនបាន (អ.ស.ប. ឆ្នាំ២០០៥) ប្រៀបធៀបជាមួយនឹង ៤៧២ នាក់ ក្នុងចំណោមស្ត្រី ១០០.០០០នាក់ដែលសម្រាលកូនបានកត់ត្រាដោយរដ្ឋាភិបាលក្នុងរយៈពេលដូចគ្នា (CDHS ឆ្នាំ២០០៥) និង ៤៣៧នាក់ ក្នុងចំណោមស្ត្រី ១០០.០០០ នាក់ដែលសម្រាលកូនក្នុងឆ្នាំ២០០៣ និង ៤៦១នាក់ក្នុងចំណោមស្ត្រី ១០០.០០០នាក់សម្រាលកូនក្នុងឆ្នាំ២០០៨[៣២]។ បើពិនិត្យមើលហានិភ័យលើបញ្ហានេះ ចំណុចសំខាន់ត្រូវសង្កត់ធ្ងន់ទៅលើតម្រូវការក្នុងការបង្កើតយុទ្ធសាស្ត្រសម្រាប់ដាក់បញ្ចូលការអប់រំផ្លូវភេទនៅតាមស្រទាប់វណ្ណៈផ្សេងៗក្នុងសង្គម។ ប៉ុន្តែហាក់ដូចជាទិដ្ឋភាពសំខាន់នៃការអប់រំផ្លូវភេទសម្រាប់តែស្ត្រី មិនត្រូវបានភ្ជាប់ទៅនឹងការបន្តពូជ និងភាពជាមាតាទេ។ ចំណុចសំខាន់ ត្រូវដោះស្រាយនូវទស្សនៈអំពីផ្លូវភេទ និងការងារដើម្បីផ្លាស់ប្តូរវិយាបទអំពីសិទ្ធិស្ត្រីក្នុងការរស់នៅដោយសេរី និងដោយគ្មានពិរុទ្ធ ឬការមិនទទួលស្គាល់ពីសង្គមអាស្រ័យដោយបញ្ហាខាងផ្លូវភេទ។

### *១.២.១ ជម្ងឺឆ្លងតាមការរួមភេទ និងបញ្ហាអេដស៍*

ទំនាក់ទំនងរវាង HIV/AIDS និងសុខភាពផ្លូវភេទ និងបន្តពូជត្រូវបានទទួលស្គាល់ច្បាស់លាស់។ ការឆ្លងរាលដាលជម្ងឺអេដស៍ដ៏ច្រើនសន្ធឹកសន្ធាប់ គឺត្រូវបានឆ្លងតាមរយៈការរួមភេទ ឬទាក់ទងនឹងការមានផ្ទៃពោះ ការសម្រាលកូន និងការបំបៅដោះ។ កត្តាសេដ្ឋកិច្ច និងសង្គមជាមូលដ្ឋាន ដូចជាភាពក្រីក្រ វិសមភាពយេនឌ័របានរួមចំណែកក្នុងការចម្លងជម្ងឺអេដស៍ និងធ្វើឱ្យសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ ចុះអន់ថយ។ ការភ្ជាប់ទំនាក់ទំនងចំពោះសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ ជាមួយនឹងបញ្ហាអេដស៍នឹងជាការផ្តល់ឱកាសយ៉ាងច្រើនដើម្បីទប់ស្កាត់ និងព្យាបាលជម្ងឺឆ្លងតាមការរួមភេទ ដូចជាជំងឺអេដស៍ជាដើម។ អាទិភាពផ្សេងៗទៀតរួមមាន ផែនការគ្រួសារ ការគាំពារមាតា និងសេវាកម្មសុខភាពកុមារ ព្រមទាំងការថែទាំអ្នកផ្ទុកមេរោគអេដស៍។

នៅកម្ពុជា ការយកចិត្តទុកដាក់សំខាន់ៗសម្រាប់សុខភាពបន្តពូជ រួមមានការព្យាបាល និងគ្រប់គ្រងការឆ្លងជម្ងឺ ដែលឆ្លងតាមរយៈការរួមភេទរួមមាន ជំងឺអេដស៍ និងការទប់ស្កាត់ការឆ្លងរាលដាលនៃជម្ងឺនេះពីម្តាយទៅកូន។ យុវវ័យ គឺជាចំណុចដែលត្រូវយកចិត្តទុកដាក់សំខាន់មួយផ្សេងទៀតអំពីសេវាកម្មសុខភាពបន្តពូជ ពីព្រោះអ្នកទាំងនោះមានតម្រូវការពិសេសក្នុងចន្លោះអន្តរកាលពីយុវវ័យ ទៅជាមនុស្សពេញវ័យ និងក្នុងដំណាក់កាលដំបូងនៃទំនាក់ទំនងផ្លូវភេទនេះ ក៏មានតម្រូវការឱ្យមានការឆ្លើយតបកាន់តែបន្ទាន់ទៅទៀត អាស្រ័យដោយមានការកើតឡើងនៃជម្ងឺអេដស៍។ ប៉ុន្តែអាស្រ័យដោយមូលហេតុមួយចំនួនសុខភាពបន្តពូជរបស់យុវវ័យត្រូវបានគេបំភ្លេចចោលនៅកម្ពុជា។ យុវវ័យមួយចំនួនខ្វះព័ត៌មាន ជំនាញ និង

---

[៣២] របាយការណ៍ជាតិទី៤ និងទី៥ ស្តីពីការអនុវត្តន៍អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទនៅកម្ពុជា (ខែឧសភា ឆ្នាំ២០១០)។

ឧបករណ៍ដើម្បីជៀសវាងពីការមានផ្ទៃពោះដែលមិនសមតាមបំណង និងទប់ស្កាត់ការឆ្លង ឬរាលដាលនៃជម្ងឺដែលឆ្លងតាមការរួមភេទ។

នៅឆ្នាំ១៩៩៤ សន្និសីទអន្តរជាតិស្តីពីប្រជាពលរដ្ឋ និងការអភិវឌ្ឍន៍បានគូសបញ្ជាក់ថា កម្មវិធីសកម្មភាព (កិច្ចព្រមព្រៀងនៅទីក្រុងគែរ៍) បានផ្តោតការយកចិត្តទុកដាក់លើការផ្តល់អំណាចឱ្យស្រ្តី និងបំពេញតម្រូវការរបស់ប្រជាពលរដ្ឋសម្រាប់ការអប់រំ និងសុខភាព រួមទាំងសុខភាពបន្តពូជជាដើម។ ចាប់តាំងពីពេលនោះមក សហគមន៍អន្តរជាតិក៏បានរៀបចំ និងតាមដានគោលនយោបាយ យុទ្ធសាស្រ្ត និងសកម្មភាពជាច្រើនយ៉ាងសកម្មដើម្បីធ្វើឱ្យគោលដៅនៃកិច្ចព្រមព្រៀងក្រុងគែរ៍ក្លាយជាការពិត។ ចំណុចរួមនៃគោលនយោបាយទាំងនេះ គឺសំដៅដោះស្រាយផលប៉ះពាល់ជម្ងឺអេដស៍ចំពោះបុគ្គលទាំងឡាយ និងការអភិវឌ្ឍន៍ជាតិទូទៅ។

អង្គការសហប្រជាជាតិទទួលបន្ទុកជំងឺអេដស៍ (UNAIDS) និងដៃគូ បានលើកស្ទួយគោល-នយោបាយ យុទ្ធសាស្រ្ត និងផែនការសកម្មភាពជាច្រើនយ៉ាងសកម្ម ដែលរៀបចំឡើងដើម្បីពង្រឹងទំនាក់ទំនងរវាងកម្មវិធីសម្រាប់ជំងឺអេដស៍ និងសុខភាពផ្លូវភេទ និងបន្តពូជ។ ឧទាហរណ៍ អ.ស.ប. បានផ្តល់អនុសាសន៍ ជាវិធីសាស្រ្តទូលំទូលាយមួយដើម្បីទប់ស្កាត់ការឆ្លងមេរោគអេដស៍ពីម្តាយទៅកូន ដូចជាមិនត្រឹមតែផ្តល់ការព្យាបាលដោយចលនា (Antiretroviral Therapy) ដល់ស្រ្តីមានផ្ទៃពោះ និងកុមារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវការការពារការឆ្លងមេរោគអេដស៍ផងដែរក្នុងចំណោមស្រ្តី និងស្រ្តីមានផ្ទៃពោះដែលមិនសមតាមបំណងក្នុងចំណោមស្រ្តីមានផ្ទុកមេរោគអេដស៍ផងដែរ។ វិធានការបែបនេះត្រូវតែលើកយកមកពិចារណានៅកម្ពុជា។

យោងតាមរបាយការណ៍ផ្លូវការរបស់មជ្ឈមណ្ឌលជាតិដើម្បីទប់ស្កាត់ជម្ងឺអេដស៍ សើរស្បែក និងជម្ងឺឆ្លងតាមការរួមភេទក្នុងឆ្នាំ២០០៨ បានឱ្យដឹងថា មាន៤៣% នៃស្រ្តីរៀបអាពាហ៍ពិពាហ៍ដែលផ្ទុកមេរោគអេដស៍នៅកម្ពុជាបានឆ្លងមេរោគពីស្វាមីរបស់ស្រ្តីទាំងនោះ។

អង្គការគំរូនៃរោគរាតត្បាតអាស៊ី (Asian Epidemic Model-AEM) បានប៉ាន់ស្មានថា នៅកម្ពុជាក្នុងឆ្នាំ២០១០ មានមនុស្សផ្ទុកមេរោគអេដស៍ចំនួន ៥១.២០០នាក់ ដែលក្នុងចំណោមនោះ ២៦.៨០០ជាស្រ្តី និង ២៤.៤០០ ជាបុរស[៣៣]។ ស្ថានភាពនេះគឺជាផលវិបាកនៃការផ្តល់ព័ត៌មានដែលមិនត្រឹមត្រូវ និងកង្វះឱកាសទទួលបានវិធានការទប់ស្កាត់ ដូចជាស្រោមអនាម័យជាដើម។

នៅកម្ពុជា បុរសអាចមានទំនាក់ទំនងជាមួយស្រ្តីខាងក្រៅចំណងអាពាហ៍ពិពាហ៍ ដោយគ្មានការប្រុងប្រយ័ត្នការពារខ្លួនពីជម្ងឺឆ្លងឡើយ ។ ជាធម្មតាបុរសៗចាត់ទុកថា នេះគឺជាសិទ្ធិរបស់អ្នកទាំងនោះក្នុងការទទួលបានទំនាក់ទំនងផ្លូវភេទជាមួយភរិយា ដោយមិនចាំបាច់ប្រយ័ត្នប្រយែងការពារជម្ងឺឆ្លងទេ។ បច្ចុប្បន្ននេះ ស្រ្តីមានសិទ្ធិតិចតួចណាស់ក្នុងការនិយាយអំពីការប្រើប្រាស់អ្វីៗដើម្បីការពារ ឬដើម្បីបដិសេធក្នុងការរួម

[៣៣] របាយការណ៍របស់មជ្ឈមណ្ឌលជាតិដើម្បីទប់ស្កាត់ជម្ងឺអេដស៍ សើស្បែក និងជម្ងឺឆ្លងតាមការរួមភេទ។

ភេទដោយគ្មានសុវត្ថិភាព សូម្បីតែនាងដឹងថាស្វាមីរបស់នាងធ្លាប់រួមភេទជាមួយស្ត្រីផ្សេងក៏ដោយ។ ដូច្នេះ ភរិយានោះជាស្ត្រីដែលងាយរងគ្រោះតាមរយៈការចំលងជំងឺតាមផ្លូវភេទពីស្វាមី។

### ១.៣ ការគាំពារមាតា

នៅឆ្នាំ២០០៨ ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីលើកកំពស់សុខភាពមាតា ក្រសួងសុខាភិបាលបានប្រកាសផែនការដើម្បីបង្កើតមណ្ឌលសុខភាពចំនួន៩៦៧កន្លែងនៅទូទាំងប្រទេស។ ផ្អែកតាមចំនួនសមាមាត្រប្រជាពលរដ្ឋ មណ្ឌលសុខភាពមួយកន្លែងអាចបំរើប្រជាពលរដ្ឋ ១២.០០០នាក់។ បច្ចុប្បន្ននេះទូទាំងប្រទេស មន្ទីរពេទ្យមានគ្រែចំនួន៨.៩៨៦ នេះមានន័យថា ជាមធ្យមគ្រែមួយសម្រាប់ប្រជាពលរដ្ឋចំនួន ១.៦១៣នាក់។

ដោយចំនួននេះ ហាក់ដូចជាគ្រប់គ្រាន់មើលទៅមិនគួរឱ្យចាប់អារម្មណ៍ទេ ពេលដែលគិតពីលក្ខណៈភូមិសាស្ត្រ។ ចំនួនមណ្ឌលសុខភាពនេះ បើគិតតាមទំហំដីវិញ គឺមានមណ្ឌលសុខភាពមួយក្នុងទំហំ ១០ គីឡូម៉ែត្រក្រឡា។ ចម្ងាយ ១០ គីឡូម៉ែត្រ អាចជាការពិបាកសម្រាប់ស្ត្រីមានផ្ទៃពោះក្នុងការធ្វើដំណើរ ជាពិសេសតំបន់ណា ដែលមានផ្លូវលំបាក តំបន់សមុទ្រ និងទន្លេជាដើម។ បញ្ហារួមផ្សំថែមទៀត គឺមណ្ឌលសុខភាពជាច្រើនពុំមានមធ្យោបាយដឹកជញ្ជូនស្ត្រីទៅមន្ទីរពេទ្យបង្អែកខេត្តទេ ហើយនេះជាការលំបាកមួយក្នុងពេលស្ត្រីមានផ្ទៃពោះ ។ នេះជាបញ្ហាមួយដែលត្រូវដោះស្រាយ។

មណ្ឌលសុខភាពជាច្រើនក៏ពុំមានកន្លែងដាក់គ្រែ និងកន្លែងរង់ចាំសម្រាប់ស្ត្រីមានផ្ទៃពោះឱ្យបានសមរម្យដែរ។ មណ្ឌលសុខភាពភាគច្រើនមិនបានបំពេញតាមតម្រូវការរបស់ស្ត្រីមានផ្ទៃពោះ ដែលត្រៀមខ្លួនសម្រាលកូនឡើយ។ ឧទាហរណ៍ តំបន់ជនបទដាច់ស្រយាលនៅខេត្តឧត្តរមានជ័យ បន្ទាយមានជ័យ ព្រះវិហារ សៀមរាប និងខេត្តព្រះសីហនុជាដើម មានគ្រែសម្រាលកូនសរុបតែ ១២ ប៉ុណ្ណោះ ក្នុងចំណោមមណ្ឌលសុខភាពទាំងអស់។ ចំនួននេះ ត្រូវតែបង្កើនដើម្បីធានាឱ្យលទ្ធផលសុខភាពស្ត្រីកាន់តែល្អប្រសើរឡើង។

ករណីសិក្សាមួយបានបង្ហាញនូវគ្រោះថ្នាក់មួយៈ កាលពីខែមីនា ឆ្នាំ២០០៩ ស្ត្រីម្នាក់រស់នៅក្នុងឃុំរហាល់សួង ដែលមានចម្ងាយ ៦ គីឡូម៉ែត្រពីមណ្ឌលសុខភាព កំពុងឈឺពោះជិតសម្រាលកូន។ នាងបានមកដល់មណ្ឌលសុខភាពឃុំព្រែកលួងក្នុងខេត្តបាត់ដំបងនៅពេលព្រឹក។ បុគ្គលិកទីនោះបានពិនិត្យនាង ហើយប្រាប់ថាមិនទាន់ដល់ពេលសម្រាលកូននៅឡើយទេ ហើយឱ្យនាងត្រឡប់ទៅផ្ទះវិញដោយពុំមានកន្លែងឱ្យនាងសម្រាកនៅទីនោះ។ នៅវេលាម៉ោង១២ព្រឹក ស្ត្រីនោះបានត្រឡប់មកវិញហើយក៏បានសម្រាលកូនមួយសន្ទុះក្រោយពីត្រឡប់មកដល់មណ្ឌលសុខភាពវិញ។ ក្រោយពីសម្រាលកូនរួចហើយ នាងទទួលការរងគ្រោះយ៉ាងខ្លាំងពីការធ្លាក់ឈាមយ៉ាងច្រើន និងធ្លាក់ឈាមកកទាំងដុំៗមកក្រៅ។ គ្រូពេទ្យក៏បានបញ្ជូនស្ត្រីនោះទៅមន្ទីរពេទ្យបង្អែកខេត្តជាបន្ទាន់។ ជាអកុសលស្ត្រីនោះ បានស្លាប់តាមផ្លូវក្នុងរយៈពេល១ម៉ោងក្រោយពីសម្រាលកូនរួច។ យោងតាមការសន្និដ្ឋានរបស់លោកវេជ្ជបណ្ឌិត ចិត្រា ប្រធានការិយាល័យមន្ទីរពេទ្យប្រតិបត្តិស្រុកសង្កែ ខេត្តបាត់ដំបងបានឱ្យដឹងថា ការស្លាប់នោះគឺ "បណ្តាលមកពីកង្វះកន្លែងរង់ចាំដែល

មិនអាចឱ្យយើងធ្វើការតាមដានបាន ប្រហែលជាមកពីឈាមកកនៅក្នុងកស្បូនដែលធ្វើឱ្យស្បូនខ្សោយមិនអាចខ្ទឹបទៅវិញបាន ហើយទីបំផុតបានបណ្តាលឱ្យធ្លាក់ឈាមច្រើន"។

ការបង់ប្រាក់ក្រៅផ្លូវការ នៅតែបន្តដើរតួជាឧបសគ្គមួយ ដែលរារាំងស្ត្រីមិនឲ្យចង់ទៅសម្រាលកូននៅមណ្ឌលសុខភាពនានា។ រាជរដ្ឋាភិបាលបានកំណត់នូវតម្លៃថេរមួយចំពោះការសម្រាលកូននៅតាមមន្ទីរពេទ្យនានាគឺ ៦០.០០០រៀល សម្រាប់ការសម្រាលកូននៅមណ្ឌលសុខភាព និង ៥០.០០០រៀល នៅតាមមន្ទីរពេទ្យបង្អែក។ ប៉ុន្តែគ្រូពេទ្យមួយចំនួននៅតែទារកំរៃថែមពីអ្នកជម្ងឺ។ ការធ្វើបែបនេះ បានធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ជនក្រីក្រ។

ស្ត្រីមួយចំនួនមិនបានទទួលការអប់រំអំពីសញ្ញាគ្រោះថ្នាក់ក្នុងពេលមានផ្ទៃពោះទេ ឬអំពីគ្រោះថ្នាក់ក្នុងការសម្រាលកូននៅផ្ទះឡើយ (សំរាលកូនតែម្នាក់ឯង ឬមានឆ្មបបុរាណ ដែលប្រហែលជាមិនបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ)។ អង្គការមួយចំនួនបានជួយធ្វើការផ្សព្វផ្សាយឯកសារអប់រំស្តីពីបញ្ហានេះ ប៉ុន្តែការយល់ដឹងមិនអាចទទួលបាន១០០%ទេ។

ការទារកម្រៃក្រៅផ្លូវការ នៅតែកើតមានដោយសារតែប្រាក់បៀវត្សទាបក្នុងចំណោមបុគ្គលិកពេទ្យទាំងនោះ។ គណៈកម្មាធិការ NGO-CEDAW សូមផ្តល់អនុសាសន៍ជូនរដ្ឋាភិបាល សូមលោកមេត្តាជួយដោះស្រាយបញ្ហាប្រាក់បៀវត្សរ៍ទាបរបស់បុគ្គលិក និងមន្ត្រីមណ្ឌលសុខភាពឱ្យបានជាបន្ទាន់។ ក្រោយពីទទួលបានប្រាក់បៀវត្សគ្រប់គ្រាន់ហើយ ត្រូវអនុវត្តច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ និងក្រមសីលធម៌គ្រូពេទ្យឱ្យបានតឹងរឹងនៅតាមមណ្ឌលសុខភាពនានា។ ប្រសិនបើមិនចាត់វិធានការនេះទេ នោះមិនអាចធានាសុវត្ថិភាពរបស់ស្ត្រីក្នុងពេលសម្រាលកូនបានទេ ហើយកម្ពុជានៅតែបន្តមានអត្រាមរណភាពមាតាក្នុងពេលសម្រាលកូន និងក្រោយសម្រាលកូននៅតែខ្ពស់ដដែល។ អត្រានេះ គឺស្មើរតែស្មើនឹងស្ត្រី ៦នាក់ស្លាប់ក្នុងមួយថ្ងៃ យោងតាមការប៉ាន់ស្មានរបស់អង្គការសុខភាពពិភពលោក។

រដ្ឋាភិបាលគួរបន្តធ្វើការបណ្តុះបណ្តាលជំនាញដល់ឆ្មបតាមភូមិនៅទូទាំងប្រទេស ដើម្បីធានាដល់សុវត្ថិភាពស្ត្រី ដែលមិនអាចទៅសម្រាលកូននៅមណ្ឌលសុខភាពបាន។ រដ្ឋាភិបាលក៏គួរពិចារណាក្នុងការផ្តល់ដែលមិនត្រឹមតែផ្តល់ឱ្យមន្ទីរពេទ្យបង្អែកប៉ុណ្ណោះទេ ប៉ុន្តែគួរផ្តល់ឧបករណ៍ពេទ្យថែមទៀតដល់មណ្ឌលសុខភាពផងដែរ ។

រដ្ឋាភិបាលក៏គួរតែពង្រីកកិច្ចខិតខំប្រឹងប្រែង ដើម្បីផ្តល់សេវាកម្មបណ្តុះបណ្តាលសុខភាពបន្តពូជផងដែរ។ ស្ត្រីត្រូវការយល់ដឹងព័ត៌មានបន្ថែមទៀតអំពីផលប្រយោជន៍នៃការពន្យាកំណើត ការពិនិត្យផ្ទៃពោះការថែទាំផ្ទៃពោះ ការធ្វើតេស្តឈាមរកមេរោគអេដស៍ និងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ។ ការអប់រំនឹងផ្តល់ផលប្រយោជន៍ទាំងសុខភាពសាធារណៈ និងថវិកាជាតិក្នុងការធ្វើឱ្យសុខភាពប្រជាពលរដ្ឋកាន់តែប្រសើរឡើង។ ឧទាហរណ៍ ការពន្យាកំណើតអាចកាត់បន្ថយអត្រាមរណៈភាពមាតា និងទារក។

រាជរដ្ឋាភិបាលបានធ្វើការផ្សព្វផ្សាយអំពីព័ត៌មានសុខភាពតាមរយៈវិទ្យុ និងទូរទស្សន៍ ទន្ទឹមនឹងនោះគួរលើកទឹកចិត្តដល់ប្រព័ន្ធផ្សាយព័ត៌មានឯកជន ដើម្បីចូលរួមជួយផ្សព្វផ្សាយផងដែរ។ ការផ្សាយអំពី

ព័ត៌មានសុខភាពត្រូវមានការបញ្ចុះថ្លៃ ឬឥតគិតថ្លៃ។ រដ្ឋាភិបាលគួរផ្តល់ការបណ្តុះបណ្តាល ការយល់ដឹងផ្នែកសុខភាពដល់កម្មវិធីវិទ្យុ និងទូរទស្សន៍ជ្រើសរើសមួយចំនួន ដូច្នេះកម្មវិធីទាំងនោះ អាចប្រើប្រាស់តួនាទីក្នុងប្រព័ន្ធផ្សាយព័ត៌មានដើម្បីអប់រំដល់សាធារណៈជនទូទៅ។



## ២. ប្រស្នា

ប្រស្នាដ៏ធំបំផុតចំពោះសុខភាពផ្លូវភេទ និងបន្តពូជកម្ពុជា គឺបញ្ហាទស្សនៈដែលសង្គមត្រូវតែទទួលស្គាល់ការពិតអំពីបញ្ហាផ្លូវភេទរបស់ស្ត្រី គឺមិនមែនជារឿងមួយដែលគួរឱ្យអាម៉ាស់ទេ។ ដំណើរការដើម្បីផ្តល់អំណាចឱ្យស្ត្រីមានជីវិតផ្លូវភេទ ដោយសុវត្ថិភាព និងសេរីភាព ជៀសផុតពីការអាប់ឱនកិត្តិយសក្នុងសង្គម ឬនាំមកនូវគ្រោះថ្នាក់ដល់សុខភាពរបស់ស្ត្រីទាំងនោះ បញ្ហានេះត្រូវតែដើរទន្ទឹមគ្នាជាមួយនឹងកំណើនការយល់ដឹងរបស់បុរសផងដែរ។ បុរសទាំងឡាយត្រូវតែគោរព និងយកចិត្តទុកដាក់ចំពោះបញ្ហាផ្លូវភេទរបស់ដៃគូ។ លើសពីនេះទៀត ហេដ្ឋារចនាសម្ព័ន្ធខាងសុខភាព ក៏នៅមានការខ្វះខាតនៅឡើយ។ គម្លាតរវាងច្បាប់បានតាក់តែងឡើង និងការអនុវត្តន៍ជាក់ស្តែងនៅក្នុងបញ្ហានេះនៅឆ្ងាយពីគ្នានៅឡើយ ហើយគម្លាតនេះក៏មិនបានខិតជិតគ្នាឱ្យលឿនល្មមដែរ។

ភាពក្រីក្រ និងការកាត់ផ្តាច់ពីគ្នាអាស្រ័យដោយកត្តាភូមិសាស្ត្របានរារាំងស្ត្រីពីការទទួលបានទាំងធនធានព័ត៌មាន និងវេជ្ជសាស្ត្រ។ ការចំណាយសម្រាប់សម្រាលកូននៅតាមមណ្ឌលសុខភាព គឺជាការចំណាយមួយខ្ពស់ដែលស្ត្រីជាច្រើនពុំមានលទ្ធភាពធ្វើទៅបាន ដោយត្រូវចំណាយលើការធ្វើដំណើរទៅមណ្ឌលសុខភាពនេះផងដែរ។ បច្ចុប្បន្ននេះ ស្ត្រីទាំងឡាយពុំមានការយល់ដឹងពិតប្រាកដ អំពីសក្តានុពលនៃហានីភ័យសុខភាពដែលស្ត្រីទាំងនោះប្រឈមមុខពេលមានផ្ទៃពោះឡើយ។

## ៣. អនុសាសន៍

១. បង្កើនថវិកាជាតិសម្រាប់សុខភាពឱ្យបានច្រើនសមរម្យល្មម។

២. ត្រូវមានការធានាដល់សុខភាពរបស់ប្រជាពលរដ្ឋ។ រដ្ឋត្រូវតែពិចារណាឱ្យបានពេញលេញចំពោះការទប់ស្កាត់ និងការព្យាបាលជម្ងឺ។ ពលរដ្ឋក្រីក្រត្រូវបានទទួលការពិនិត្យដោយឥតគិតថ្លៃនៅតាមមន្ទីរពេទ្យរដ្ឋនានា គិលានដ្ឋាន និងមជ្ឈមណ្ឌលគាំពារមាតាជាដើម[៣៤]។ ជាវិធានការពិសេសបណ្តោះអាសន្ន ដូចដែលមានចែងក្នុងមាត្រា៤ នៃអនុសញ្ញា CEDAW រដ្ឋត្រូវតែផ្តល់ជំនួយ និងការជួយឧបត្ថម្ភដល់ស្ត្រីមានផ្ទៃពោះ។

[៣៤] មាត្រា ៧៧ នៃរដ្ឋធម្មនុញ្ញកម្ពុជា។

៣.គ្រប់មណ្ឌលសុខភាពទាំងអស់ត្រូវផ្តល់ការពិនិត្យ និងព្យាបាលប្រកបដោយការសម្ងាត់។ ផ្សព្វផ្សាយព័ត៌មានអំពីបញ្ហាសុខភាពឱ្យបានទូលំទូលាយ ហើយលើកទឹកចិត្តពលរដ្ឋឱ្យបានទទួលសេវាកម្មរបស់រដ្ឋ។

៤.គ្រប់មន្ទីរពេទ្យបង្អែកទាំងអស់ត្រូវផ្តល់ការពិនិត្យផ្នែកវេជ្ជសាស្ត្រ និងការព្យាបាលដល់ប្រជាពលរដ្ឋគ្រប់រូបជាមួយនឹងការថែទាំយកចិត្តទុកដាក់ក្នុងកម្រិតមួយឱ្យបានសមរម្យ។

៥. បុគ្គលិកបម្រើសេវាកម្ម (នៅតាមមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក និងគ្លីនិកនានា) ត្រូវតែគាំទ្រ និងលើកទឹកចិត្តពលរដ្ឋគ្រប់រូបឱ្យទទួលបានព័ត៌មានថ្មីៗអំពីបញ្ហាសុខភាពបន្តពូជ។

៦. បុគ្គលិកបម្រើសេវាកម្មត្រូវពន្យល់ និងផ្តល់ចំណេះដឹងដល់ប្រជាពលរដ្ឋ ជាពិសេសក្រុមយុវវ័យអំពីបញ្ហាសុខភាព សង្គម និងសេដ្ឋកិច្ច។ ធ្វើបែបនេះអ្នកទាំងនោះអាចជៀសផុតពីការមានផ្ទៃពោះ ដែលមិនសមតាមបំណង។

៧. បុគ្គលិកបម្រើសេវាកម្មត្រូវបម្រើសេវា និងពិនិត្យដល់ពលរដ្ឋទាំងអស់ជាពិសេស (យុវជន) ទាក់ ទងនឹងបញ្ហាការពារកំណើត ពិនិត្យសុខភាព និងការព្យាបាលជម្ងឺឆ្លង ការថែទាំមុនពេលសម្រាលកូន ចំណីអាហារូបត្ថម្ភ និងអ្នកដែលញៀនគ្រឿងញៀន។

៨.ក្រសួងសុខាភិបាលត្រូវតែសាងសង់មណ្ឌលសុខភាពឱ្យបានគ្រប់គ្រាន់នៅគ្រប់តំបន់តាមជនបទទាំងអស់។

៩. បង្កើតឱ្យមានការដឹកជញ្ជូន និងការព្យាបាលដោយឥតគិតថ្លៃដល់ប្រជាពលរដ្ឋក្រីក្រ។

១០.នាយកដ្ឋានកិច្ចការនារីត្រូវរៀបចំកម្មវិធីផ្សព្វផ្សាយស្តីពីចំណេះដឹងសិទ្ធិសុខភាព និងផ្លូវភេទដល់ប្រជាពលរដ្ឋ ជាពិសេសស្ត្រី និងយុវតី។

១១.រៀបចំកម្មវិធីឱ្យបុរសចូលរួមចំណែកក្នុងដំណើរការមានផ្ទៃពោះ និងសម្រាលកូន ព្រមទាំងការចូលរួមទទួលខុសត្រូវ ក្នុងការធានានូវសុខមាលភាពរបស់ភរិយាផងដែរ។

១២.ធានាឱ្យមានការអនុវត្តន៍ច្បាប់ស្តីពីការឈប់សម្រាកបិតុភាព ដែលមានលក្ខណៈស្មើគ្នាជាមួយស្ត្រី ដើម្បីផ្តល់ឱកាសឱ្យបុរសបានជួយភរិយាដែលទើបសម្រាលកូន និងបានចូលរួមថែទាំកូនតាំងពីកើតលើកដំបូងផងដែរ។

១៣.បង្កើតឱ្យមានកម្មវិធីជួយឧបត្ថម្ភ ដែលផ្តោតសំខាន់ទៅលើការផ្លាស់ប្តូរសង្គម និងឥរិយាបទទាក់ទងនឹងការប្រើប្រាស់ស្រោមអនាម័យ។

១៤.ធ្វើការផ្សព្វផ្សាយ និងលើកទឹកចិត្តឱ្យមានការពិភាក្សាអំពីច្បាប់ស្តីពីការទប់ស្កាត់ និងត្រួតពិនិត្យមេរោគអេដស៍ ព្រមទាំងគោលការណ៍ណែនាំអនុវត្តន៍ច្បាប់នេះផងដែរ។

១៥.រៀបចំឱ្យមានការថែទាំសុខភាពមាតាមុនពេលឆ្លងទន្លេ និងសម្រាលកូនដោយឥតគិតថ្លៃសម្រាប់ស្ត្រីមានផ្ទៃពោះទាំងអស់។

១៦.ផ្សព្វផ្សាយព័ត៌មានត្រូវធ្វើការទប់ស្កាត់ ផ្តល់សេវាកម្ម និងការព្យាបាលដល់ស្ត្រីរងគ្រោះពីសំណាក់គ្រឿងញៀន ស្រា និងបារី។

# ជំពូក ៥. សេដ្ឋកិច្ច និងសិទ្ធិប្រើប្រាស់ធនធាន

## ១. *ស្ថានភាព*

សេដ្ឋកិច្ចកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់តាំងពីឆ្នាំ១៩៩២ បន្ទាប់ពីត្រូវបានកាត់ផ្តាច់ពីសង្គ្រាមផ្ទៃក្នុងអស់រយៈពេលជាងពីរទសវត្សរ៍។ សេដ្ឋកិច្ចបានចាប់ផ្តើមដំណើរការក្នុងក្របខណ្ឌម៉ាក្រូសេដ្ឋ-កិច្ចមួយប្រកបដោយស្ថេរភាព ព្រមទាំងស្ថិតក្នុងរបបសេដ្ឋកិច្ចទីផ្សារសេរី។ អត្រាកំណើនផលទុនជាតិសរុប (GDP) បានកើនឡើងខ្ពស់រហូតដល់ឆ្នាំ ២០០៨ ដោយមានកំណើនប្រចាំឆ្នាំជាមធ្យមកើនស្ទើរតែ៩% ក្នុងរយៈពេល១០ ឆ្នាំកន្លងមកនេះ។ ប៉ុន្តែ វិបត្តិសេដ្ឋកិច្ចពិភពលោក ក៏បណ្តាលឱ្យមានការប៉ះពាល់ជាអវិជ្ជមានមក លើសេដ្ឋកិច្ចជាតិដែរនៅកម្ពុជា។ នៅឆ្នាំ២០០៩ ប្រទេសនេះបានជួបប្រទៈ នូវការថយចុះផលទុនជាតិសរុបចំនួន ២% ទន្ទឹមនឹងប្រទេសអាស៊ីខាងត្បូងមួយចំនួន មានកំណើន ៥,២%។ នៅឆ្នាំ២០០៩ អត្រាអតិផរណាគឺ ៦,៧% (ធនាគារអភិវឌ្ឍន៍អាស៊ី ព័ត៌មានបច្ចុប្បន្នភាពសេដ្ឋកិច្ច AEM ២០១០)។ តម្រូវការផលិតផលក្នុងស្រុក និងការនាំចេញផលិតផលវាយនភ័ណ្ឌថយចុះបណ្តាលឱ្យមានការធ្លាក់ចុះសកម្មភាពសេដ្ឋកិច្ច ព្រមទាំងត្រូវបានរំពឹងទុកថា នឹងមានការបន្តងើបឡើងវិញយ៉ាងយឺតៗ។ ចំពោះទិន្នន័យចុងក្រោយ (UNDP ឆ្នាំ២០០៩) ចំណូលប្រចាំឆ្នាំជាមធ្យមសម្រាប់ប្រជាពលរដ្ឋម្នាក់គឺ ១.៨៤៨ដុល្លារ ចំណូលមធ្យមសម្រាប់បុរសគឺ ២.១៥៨ ដុល្លារ និងសម្រាប់ស្ត្រី ១.៤៦៥ ដុល្លារ។



ពាក់ព័ន្ធនឹងបញ្ហាសូចនាករយេនឌ័រ កម្ពុជាស្ថិតក្នុងលំដាប់លេខ១១៣ នៅក្នុងបញ្ជី GDI[៣៥] (សន្ទស្សន៍អភិវឌ្ឍន៍ទាក់ទងយេនឌ័រ) ហើយលេខ៩១ នៅក្នុងបញ្ជី GEM[៣៦] (វិធានការផ្តល់អំណាចយេនឌ័រ) នេះបើយោងរបាយការណ៍សិទ្ធិមនុស្សឆ្នាំ២០០៩ របស់អង្គការ UNDP។ ការធ្លាក់ចុះសេដ្ឋកិច្ចនៅពេលថ្មីៗនេះ រួមជាមួយការលំបាកក្នុងការធ្វើអាជីវកម្មលើធនធាននៅតាមតំបន់ជនបទ បានបណ្តាលឱ្យសូចនាករនៃការអភិវឌ្ឍន៍កម្ពុជាមានកំរិតទាបស្ថិតក្នុងចំណោមប្រទេសមួយចំនួនក្នុងទ្វីបនេះ។ យោងតាមរបាយការណ៍អភិវឌ្ឍន៍មនុស្សជាតិឆ្នាំ២០០៩ របស់ UNDP សន្ទស្សន៍អភិវឌ្ឍន៍មនុស្សគឺ ០,៥៩៣% ដែលរុញកម្ពុជាធ្លាក់ទៅដល់លេខទី១៣៧ ក្នុងចំណោមប្រទេសដែលត្រូវបានធ្វើការសិក្សាទាំងអស់ស្ថិតក្រោមប្រទេសកុងហ្គោ និងសហភាពមីយ៉ាន់ម៉ាទៅទៀត។ សន្ទស្សន៍ភាពក្រីក្រមនុស្សជាតិ គឺ៣០,៤% និងផលទុនជាតិសរុបសម្រាប់

[៣៥] សន្ទស្សន៍អភិវឌ្ឍន៍ទាក់ទងយេនឌ័រ។

[៣៦] វិធានការផ្តល់អំណាចយេនឌ័រ។

មនុស្សម្នាក់គឺ១.៨០២ ដុល្លារ ដែលធ្វើឱ្យកម្ពុជាស្ថិតក្នុងលំដាប់លេខទី១៤៣ ក្នុងចំណោមប្រទេសទាំងឡាយដែលត្រូវបានសិក្សា។

តាមរយៈការវិភាគបរិបទសេដ្ឋកិច្ចសង្គមពីសំណាក់ទស្សនៈសិទ្ធិមនុស្ស បានឱ្យដឹងថាកម្ពុជាបង្ហាញឱ្យឃើញមានភាពខុសគ្នាយ៉ាងខ្លាំង។ ប្រជាពលរដ្ឋប្រមាណ ២០% កំពុងគ្រប់គ្រងលើទ្រព្យសម្បត្តិជាតិពាក់កណ្តាល (ធនាគារពិភពលោក ឆ្នាំ២០០៨)។ វិសមភាពក្នុងការទទួលបានសេវាកម្មរវាងតំបន់ទីក្រុង និងជនបទក៏នៅជាបញ្ហាមួយដដែលដែរ។ សេវាកម្មសុខភាពនៅខេត្តភាគខាងជើងមួយចំនួន គឺសឹងតែគ្មានទាល់តែសោះ ដែលធ្វើឱ្យមានការចែកដាច់ពីគ្នា ដោយស្ត្រីម្នាក់សម្រាលកូននៅភ្នំពេញ គឺទំនងជាត្រូវបានជួយជ្រោមជ្រែងដោយឆ្មបមានគុណភាពដល់ទៅ៦ដងលើសពីស្ត្រីសម្រាលកូននៅខេត្តរតនៈគីរី និងមណ្ឌលគីរី។ បច្ចុប្បន្ននេះ បុរស ៤០% និង ស្ត្រី ៦០% ក្នុងតំបន់ទាំងពីរនេះ ពុំបានទទួលការអប់រំក្នុងប្រព័ន្ធត្រឹមត្រូវទេ បើធៀបនឹងភ្នំពេញមានត្រឹមតែ ១៥%(មជ្ឈមណ្ឌលដើម្បីសិទ្ធិសេដ្ឋកិច្ច និងសង្គម ឆ្នាំ២០០៩)។

គេឃើញមានឫសគល់មួយចំនួន ដែលបណ្តាលឱ្យមានភាពខុសគ្នានេះ ក្នុងនោះរួមមានទាំងកង្វះប្រសិទ្ធិភាពនៃក្របខណ្ឌច្បាប់ក្នុងកិច្ចការពារសិទ្ធិជាមូលដ្ឋាន កង្វះវិធានការរដ្ឋាភិបាល ដើម្បីកាត់បន្ថយវិសមភាព ព្រមទាំងអំពើពុករលួយដែលធ្វើឱ្យប៉ះពាល់ទាំងផ្នែកសាធារណៈ និងឯកជន។ ក្នុងបញ្ជីអំពើពុករលួយពិភពលោក កម្ពុជាជាប់លំដាប់លេខ ១៦៦ ដោយទទួលបានពិន្ទុត្រឹមតែ ១,៨ ប៉ុណ្ណោះក្នុងពិន្ទុ ១០[៣៧]។ ផលប៉ះពាល់របស់អំពើពុករលួយទៅលើសេដ្ឋកិច្ចជាតិ និងការចែករំលែកទ្រព្យធន គឺមានលក្ខណៈធ្ងន់ធ្ងរ ។ អំពើពុករលួយក៏បានជួយជម្រុញឱ្យមានការគៃបន្លំធនធាន ដែលបម្រុងទុកសម្រាប់ការចំណាយសាធារណៈផងដែរ កត្តានេះបានរុញច្រានកម្ពុជាឱ្យធ្លាក់ទៅដល់បាតបញ្ជីក្នុងចំណោមប្រទេសនានាអំពីការចំណាយសាធារណៈ ជាភាគរយនៃផលទុនជាតិសរុប (ធនាគារពិភពលោក ឆ្នាំ២០០៨)។ ជាលទ្ធផលនាំឱ្យមានការខ្វះខាតលើការចំណាយវិនិយោគលើហេដ្ឋរចនាសម្ព័ន្ធ និងសេវាកម្មសាធារណៈដូចជា ផ្នែកសុខភាព និងការអប់រំជាដើម។ អំពើពុករលួយក៏រួមចំណែកបង្កើនឱ្យមានវិសមភាពសង្គមផងដែរ ដោយសារតែធនធានសំខាន់ៗត្រូវបានប្រមូលផ្តុំ និងគ្រប់គ្រងដោយមនុស្សមួយក្តាប់តូចនៅក្នុងចំណោមប្រជាពលរដ្ឋទូទៅ។

ស្ត្រីកម្ពុជារហូតដល់ ៨១% មានអាយុពី ១៥ ដល់ ៦៤ឆ្នាំ ចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច ដែលតួលេខនេះខ្ពស់ជាងគេបំផុតនៅអាស៊ីអាគ្នេយ៍។ ប៉ុន្តែការចូលរួមរបស់ស្ត្រីកម្ពុជាក្នុងផ្នែកសេដ្ឋកិច្ចក្នុងប្រព័ន្ធនៅមានកម្រិតនៅឡើយ។ ស្ត្រីកម្ពុជាប្រហែល ១៧% ប៉ុណ្ណោះមានការងារធ្វើដោយទទួលបានប្រាក់បៀវត្សរ៍ ហើយ៨៣% នៃស្ត្រីស្ថិតក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលរួមមានការប្រកបរបរដោយខ្លួនឯង (ច្រើនតែជារបរទ្រង់ទ្រាយជាកសិកម្ម និងធ្វើការនៅក្នុងផ្ទះសម្បែង) រឺក៏ធ្វើការនៅក្នុងគ្រួសារ។ អត្រាអក្ខរភាពរបស់ស្ត្រីមានការងារធ្វើគឺ ៦៩% ធៀបទៅបុរសវិញគឺមានដល់ទៅ ៨៤%។ គម្លាតនេះ ធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ឱកាសសម្រាប់ស្ត្រីក្នុងការរកការងារធ្វើ។ បន្ថែមពីលើគម្លាតអប់រំនេះ កត្តាផ្សេងៗទៀតក៏បានរួមចំណែកក្នុងការធ្វើឱ្យស្ថានភាពសេដ្ឋកិច្ចរបស់ស្ត្រីស្រុតចុះផងដែរ។ កត្តាទាំងនេះ រួមមានកង្វះបទពិសោធន៍ និងជំនាញផ្នែកសហគ្រាស កង្វះការយល់ដឹងផ្នែកទីផ្សារ ផ្នត់គំនិត ការរើសអើងពីសំណាក់សង្គម កង្វះធនធាន ដូចជាឥណទាន ព្រមទាំងកង្វះមធ្យោបាយផលិតកម្ម។ តួនាទីទំនៀមទម្លាប់ក៏មានឥទ្ធិពលលើការចូលរួមរបស់ស្ត្រី

[៣៧] អង្គការតម្លាភាពអន្តរជាតិ: របាយការណ៍អំពើពុករលួយពិភពលោក ឆ្នាំ២០០៩ ។

ក្នុងវិស័យសេដ្ឋកិច្ចផងដែរ ក្នុងបញ្ហានេះគេគិតថាស្រ្តីត្រូវចំណាយពេលភាគច្រើនដើម្បីអនុវត្តតួនាទីប្រពៃណីនេះទៅវិញ។

ម្យ៉ាងវិញទៀត តួនាទីក្នុងគ្រួសាររបស់ស្ត្រីត្រូវបានឱ្យតម្លៃទាប។ ៩០% នៃពេលវេលាចំណាយសម្រាប់ការងារក្នុងផ្ទះ និងការថែទាំក្រុមគ្រួសារ ជាពេលវេលាចំណាយរបស់ស្រ្តី។ ស្រ្តីអាយុចន្លោះពី ១៨ ដល់៦០ឆ្នាំ ចំណាយពេលធ្វើការងារផ្ទះ៣ម៉ោងក្នុងមួយថ្ងៃលើសបុរស (៣,៣ ម៉ោងសម្រាប់ស្រ្តី ធៀបនឹង ០,៣ ម៉ោងសម្រាប់បុរស)។ ជាលទ្ធផល ស្រ្តីគ្មានពេលវេលាទំនេរសម្រាប់ធ្វើសកម្មភាពផ្ទាល់ខ្លួន ឬចូលរួមវគ្គបណ្តុះបណ្តាលដើម្បីបង្កើនវិជ្ជាជីវៈការងារទេ។ ការទទួលបន្ទុកជាអ្នកថែទាំកូនចៅ បងប្អូន និងធ្វើការងារផ្ទះ បានរារាំងស្រ្តីពីការចូលរួមក្នុងការងារផលិតកម្ម ការសម្រេចចិត្តក្នុងសហគមន៍ និងការរៀបចំផែនការ។

## ១.១ ច្បាប់ និងគោលនយោបាយ

សិទ្ធិស្រ្តីត្រូវបានធានាពេញលេញដោយរដ្ឋធម្មនុញ្ញ និងលិខិតូបករណ៍អន្តរជាតិមួយចំនួនដែលត្រូវបានផ្តល់សច្ចាប័នដោយព្រះរាជាណាចក្រកម្ពុជា។ មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញទទួលស្គាល់សិទ្ធិស្មើគ្នារវាងបុរស និងស្រ្តី ក្នុងការចូលរួមយ៉ាងសកម្មក្នុងសកម្មភាពសេដ្ឋកិច្ចសង្គម នយោបាយ និងវប្បធម៌របស់ជាតិ ដោយពុំមានការរើសអើងឡើយ។ មាត្រា ៣៦-១ នៃរដ្ឋធម្មនុញ្ញចែងថា "ប្រជាពលរដ្ឋកម្ពុជាទាំងពីរភេទមានសិទ្ធិជ្រើសរើសមុខរបរសមស្រប តាមសមត្ថភាពរបស់ខ្លួន តាមសេចក្តីត្រូវការរបស់សង្គម"។ គោលការណ៍នេះ បានស្របយ៉ាងពេញលេញតាមអនុសញ្ញាស្តីពីសិទ្ធិស្រ្តីដែលមានចែងក្នុងអនុសញ្ញារបស់ CEDAW ដូចមានចែងនៅក្នុងមាត្រា ១១ ១៣ និង១៤។ សិទ្ធិការងារក៏ត្រូវបានធានានៅក្នុងច្បាប់ការងាររបស់កម្ពុជា និងច្បាប់ស្តីពីរបបសេដ្ឋកិច្ចសង្គម។ ក្រោយមកអនុក្រិត្យមួយចំនួន ដែលចេញដោយក្រសួងពាក់ព័ន្ធ ដូចជាអនុក្រិត្យលើកឡើងអំពីប្រាក់ឈ្នួលអប្បបរមា សន្តិសុខសង្គម ព្រមទាំងអំពីសុវត្ថិភាព និងសុខភាពកន្លែងធ្វើការជាដើម។

នៅក្នុងសេចក្តីផ្តល់មតិឆ្នាំ២០០៦ គណៈកម្មាធិការនៃអង្គការសហប្រជាជាតិទទួលបន្ទុក CEDAW[៣៨] បានសំណូមពរឱ្យកម្ពុជាបង្កើនល្បឿន និងធានាឱ្យមានការចូលរួមស្មើគ្នារបស់ស្រ្តី និងបុរសក្នុងទីផ្សារការងារ។ គណៈកម្មាធិការនេះ បានសំណូមពរឱ្យធ្វើការចាត់វិធានការដើម្បីធានាឱ្យស្រ្តីទទួលបានប្រាក់ឈ្នួលទទួលបានសេវាសង្គម និងផលប្រយោជន៍ដទៃៗទៀតស្មើនឹងបុរសចំពោះការងារដូចគ្នា។ គណៈកម្មា-ធិការក៏បានសំណូមពរផងដែរឱ្យព្រះរាជាណាចក្រកម្ពុជា កំណត់និយមន័យឱ្យបានច្បាស់លាស់ចំពោះពាក្យថា "ការងារស្រដៀងគ្នា" និង "ការងារមានតម្លៃស្មើគ្នា" ព្រមទាំងសូមឱ្យមានការដាក់ទោសចំពោះអំពើរើសអើងលើស្រ្តីភេទក្នុងវិស័យការងារ រួមទាំងការដាក់ទោសទណ្ឌដូចបញ្ជាក់ខាងលើនេះ ចំពោះអំពើបៀតបៀនកេរ្តិ៍ខ្មាស ទាំងក្នុងផ្នែកសាធារណៈ និងឯកជនផងដែរ។ ចុងបញ្ចប់គណៈកម្មាធិការនេះ បានផ្តល់អនុសាសន៍ឱ្យធ្វើការអនុវត្តន៍បទដ្ឋានការងារ និងការផ្សព្វផ្សាយជាសាធារណៈឱ្យកាន់តែច្រើនថែមទៀតអំពីខ្លឹមសារនៃច្បាប់ការងារ ដើម្បីឲ្យស្រ្តីយល់ច្បាស់អំពីសិទ្ធិរបស់អ្នកទាំងអស់នោះ។

[៣៨] គណៈកម្មាធិការ អ.ស.ប.ស្តីពី CEDAW ។

រាជរដ្ឋាភិបាលកម្ពុជា បានបន្តការសន្យាដើម្បីលើកស្ទួយវិសមភាពយេនឌ័រតាមរយៈការទទួលស្គាល់ស្ត្រីជាសរសរទ្រូងនៃសេដ្ឋកិច្ច និងសង្គម។ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពខ្ពស់ដល់ការពង្រឹងនិងឋានៈរបស់ស្ត្រីកម្ពុជាក្នុងវិស័យសេដ្ឋកិច្ចតាមរយៈការបញ្ជ្រាបយេនឌ័រនៅគ្រប់វិស័យទាំងអស់ នៃផែនការយុទ្ធសាស្ត្រជាតិ។ ចំណុចសំខាន់យុទ្ធសាស្ត្រនេះ ផ្តោតទៅលើការកសាងសមត្ថភាព ការលុបបំបាត់នូវឥរិយាបទរើសអើងចំពោះស្ត្រី ព្រមទាំងការធានាដល់សិទ្ធិស្ត្រីដើម្បីឱ្យមានការចូលរួមយ៉ាងសកម្ម និងស្មើៗគ្នាក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។

ក្រសួងកិច្ចការនារីបានដើរតួនាទីយ៉ាងសកម្មក្នុងការសម្របសម្រួលឱ្យមានការដាក់បញ្ចូលយេនឌ័រទៅក្នុងយុទ្ធសាស្ត្រសេដ្ឋកិច្ច គោលនយោបាយ និងផែនការជាតិក្នុងគោលបំណងដើម្បីបង្កើនការចូលរួមរបស់ស្ត្រីក្នុងវិស័យសេដ្ឋកិច្ច។ ចំណុចសំខាន់ដើម្បីដោះស្រាយបញ្ហាការរើសអើងចំពោះស្ត្រីក្នុងវិស័យសេដ្ឋកិច្ច មានចែងនៅក្នុងគោលនយោបាយដូចខាងក្រោមនេះ៖

- ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ ដែលមានចែងអំពីវិធានការអាទិភាពមួយចំនួនដែលជាតួនាទីនិងឋានៈរបស់ស្ត្រីក្នុងវិស័យសេដ្ឋកិច្ច។ ក្នុងនោះ ក៏មានចែងអំពីវិធានការដើម្បីកាត់បន្ថយការរើសអើង ទាក់ទងនឹងយេនឌ័រក្នុងទីផ្សារការងារ និងលើកទឹកចិត្តឱ្យស្ត្រីចូលរួមកាន់តែខ្លាំងឡើងទៅក្នុងការងារកម្រិតខ្ពស់។
- យុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម និងធនធានទឹក ២០០៦-២០១០ (SAW) ដែលទទួលស្គាល់តម្រូវការដើម្បីផ្តល់អំណាចឱ្យស្ត្រី និងលើកកម្ពស់តួនាទីរបស់ស្ត្រីក្នុងការអភិវឌ្ឍន៍កសិកម្ម។ គោលបំណងរបស់យុទ្ធសាស្ត្រនេះ គឺដើម្បីផ្តល់ឱកាសឱ្យស្ត្រីបានទទួលផលប្រយោជន៍ពីកម្មវិធីដែលឧបត្ថម្ភដោយរដ្ឋាភិបាលយ៉ាងពេញលេញក្នុងការផ្គត់ផ្គង់ "សុវត្ថិភាពសន្តិសុខស្បៀង" ព្រមទាំងបង្ហាញនូវផលប្រយោជន៍របស់ស្ត្រីទាំងនោះផង។ យុទ្ធសាស្ត្រនេះ ក៏បានអំពាវនាវឱ្យផ្តល់ឱកាសដល់ស្ត្រីក្នុងការទទួលបានការស្រោចស្រព (ការបញ្ចូលទឹក) និងការពង្រឹកគណៈកម្មាធិការប្រើប្រាស់ទឹកដើម្បីធ្វើយ៉ាងណាឱ្យការប្រើប្រាស់ទឹកនេះ ប្រកបដោយការទទួលផលល្អ និងសមរម្យ។
- ផែនការសកម្មភាពបញ្ជ្រាបយេនឌ័ររបស់ក្រសួងពាណិជ្ជកម្ម និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលរួមមានការកសាងសមត្ថភាព ជំនាញ និងការជឿជាក់របស់ស្ត្រីក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដោយបង្កើនឱកាសឱ្យស្ត្រីដើម្បីទទួលសេវាឥណទាន ជម្រុញការចុះបញ្ជីពាណិជ្ជកម្មសហគ្រាសដែលជារបស់ស្ត្រី ព្រមទាំងបង្កើនការជម្រុញឱ្យស្ត្រីទទួលបានព័ត៌មាន ការដោះដូរទំនិញ និងសេវាកម្មនានាជាដើម។

## ២. *ស្ត្រីក្នុងវិស័យសេដ្ឋកិច្ចក្នុងប្រព័ន្ធ*

### ២.១ ស្ត្រីក្នុងវិស័យកាត់ដេរៈ ស្ត្រីជាមេដឹកនាំសហជីព

វិស័យកាត់ដេរត្រូវបានពិនិត្យឃើញថា ជាប្រភពសំខាន់ក្នុងការផ្តល់ការងារឱ្យស្ត្រីវ័យក្មេងមកពីជនបទ។ ទោះបីជាចំនួនស្ត្រីមានរហូតដល់ ៨៥% ក្នុងចំណោមកម្មកររោងចក្រទាំងអស់ក៏ដោយ ក៏កម្រមានស្ត្រីស្ថិតក្នុងតួនាទីជាប្រធានសហជីពដែរ។ ការអប់រំទាប កង្វះខាតពេលវេលា ជំនាញ និងបទពិសោធន៍ ព្រម

ទាំងកង្វះការជួយឧបត្ថម្ភពីសំណាក់ក្រុមគ្រួសារ និងម្ចាស់រោងចក្រនានា ទាំងអស់នោះហើយគឺជាកត្តារារាំងស្ត្រីពីការកាន់តំណែងជាមេដឹកនាំសហជីព។

ក្នុងករណីខ្លះទៀត ពាក់ព័ន្ធនឹងបញ្ហាសន្តិសុខផ្ទាល់ខ្លួន ក៏អាចរារាំងស្ត្រីពីការដើរតួជាមេដឹកនាំសហជីពដែរ។ អាស្រ័យដោយមានគម្លាតនៅក្នុងច្បាប់ និងកង្វះខាតវិធានការទប់ស្កាត់ពីសំណាក់រដ្ឋាភិបាល នោះមេដឹកនាំសហជីពបច្ចុប្បន្នកំពុងប្រឈមមុខនឹងការលំបាកជាច្រើនដូចជា ការគំរាមកំហែង និងការបំបាក់មុខពីសំណាក់ថៅកែជាដើម។ អ្នកស្រី ស ជាមេដឹកនាំសហជីព បានលាតត្រដាងថា នាងប្រឈមមុខនឹងការលំបាកជាច្រើនអំពីបញ្ហាមូលនិធិ ពេលវេលា សមត្ថភាព និងជំនាញ។ នាងបានបន្ថែមទៀតថា "ខ្ញុំត្រូវការប្រើប្រាស់កុំព្យូទ័រដើម្បីរៀបចំធ្វើបណ្ដឹងប្ដឹងក្រុមហ៊ុន (ចំពោះការរំលោភសិទ្ធិកម្មករ) ប៉ុន្តែខ្ញុំមិនចេះប្រើប្រាស់កំព្យូទ័រ ព្រមទាំងមិនសូវមានការយល់ដឹងអំពីផ្នែកច្បាប់។ ដូច្នេះហើយ ជាការលំបាកសម្រាប់ខ្ញុំក្នុងការធ្វើពាក្យបណ្ដឹងដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់កម្មករឱ្យបានពេញលេញ"។

អ្នកស្រី ឌី ជាអនុប្រធានសហជីពនៃរោងចក្រមួយនៅភ្នំពេញបានមានប្រសាសន៍ថា "អ្នកគ្រប់គ្រងមិនដែលហៅខ្ញុំចូលរួមប្រជុំ ដើម្បីឱ្យខ្ញុំមានឱកាសបញ្ចេញមតិយោបល់អំពីការលំបាករបស់កម្មករឡើយ"។ នាងក៏បានបន្ថែមទៀតថា "ថៅកែមិនដែលប្រព្រឹត្តចំពោះមេដឹកនាំបុរស និងស្ត្រីស្មើភាពគ្នាទេ។ មើលទៅបុរសហាក់ដូចជាធ្វើការតិចជាង ប៉ុន្តែទទួលបានប្រាក់បៀវត្សរ៍ច្រើនជាង ចំណែកឯស្ត្រីវិញបានខំប្រឹងប្រែងខ្លាំងណាស់លើការងារ ប៉ុន្តែទទួលបានប្រាក់បៀវត្សទាបជាងបុរស។ មានចំនុចមួយទៀតដែលរារាំងមិនឱ្យមានទំនាក់ទំនងល្អ គឺខ្ញុំគ្មានពេលវេលាដើម្បីចូលរួមជាមួយទីប្រឹក្សា និងអ្នកគ្រប់គ្រងរោងចក្រដែលតែងតែទៅភោជនីយដ្ឋាន និងច្រៀងនៅខារ៉ាអូខេជាមួយគ្នាទេ"។

អ្នកស្រី អេន ជាមេដឹកនាំសហជីពម្នាក់នៅភ្នំពេញបានរៀបរាប់ថា "ជាមេដឹកនាំសហជីពមានការលំបាកច្រើនណាស់។ ជួនកាលបណ្ដាលឱ្យមានបញ្ហារវាងខ្ញុំ និងស្វាមីខ្ញុំ ព្រមទាំងក្រុមគ្រួសាររបស់ខ្ញុំជាដើមផង"។ នាងបានបន្ថែមទៀតថា "ពេលមានបញ្ហាជម្លោះការងារកើតឡើង ខ្ញុំត្រូវតែប្រញាប់ទៅទីនោះ ដើម្បីជួយដោះស្រាយទំនាស់ ដូច្នេះខ្ញុំត្រូវខកខានក្នុងការធ្វើការងារ ព្រមទាំងគ្មានពេលធ្វើការថែមម៉ោងទៀតផង។ លើសពីនេះទៅទៀត ប្រសិនបើទំនាស់នោះតម្រូវឱ្យមានអន្តរាគមន៍ពីសំណាក់ក្រសួងការងារ ខ្ញុំត្រូវចំណាយពេល និងថវិកាផ្ទាល់ខ្លួនថែមទៀតសម្រាប់ធ្វើដំណើរតាមម៉ូតូឌុប និងទូរស័ព្ទដើម្បីទាក់ទងជាមួយអង្គការដែលជួយដោះស្រាយទំនាស់ការងារ និងមន្ត្រីនានា"។

មន្ត្រីជាន់ខ្ពស់ម្នាក់នៃមជ្ឈមណ្ឌលសិទ្ធិការងារកម្ពុជា ដែលជាសកម្មជនសិទ្ធិការងារបានលើកឡើងថា "ខ្ញុំធ្លាប់ជួបប្រជុំ និងពិភាក្សាជាមួយអ្នកមានទ្រព្យ និងអ្នកមានអំណាចជាច្រើននៅកម្ពុជាទាក់ទងការដោះស្រាយបញ្ហាកម្មករ" ប៉ុន្តែការជួបប្រជុំនោះ មិនមែនទៅត្រង់តែម្ដងទេ។ លោកបាននិយាយថា មានពេលមួយលោកត្រូវទីប្រឹក្សារបស់រោងចក្រនៅភ្នំពេញគំរាមកំហែង ហើយមានម្ដងនោះមន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាលម្នាក់បានជម្រាបលោកថា "ចំពោះពួកខ្ញុំវិញ បើអ្នកចង់ឈ្លោះ ពួកខ្ញុំអាចឈ្លោះបាន បើអ្នកចង់បានលុយ នោះពួកខ្ញុំមានលុយជូន ហើយបើអ្នកនិយាយអំពីច្បាប់ពួកខ្ញុំមិនខ្លាចញញើតទេ"។

ស្ត្រីម្នាក់ទៀតដែលជាមេដឹកនាំសហជីព ឈ្មោះ រ មានប្រសាសន៍ថា ពេលមួយអ្នកគ្រប់គ្រងរោងចក្រជាស្ត្រីម្នាក់បានចំអកឱ្យនាងដោយនិយាយថា "សុខចិត្តឱ្យត្រីឆ្អោត្របាក់វិញ ប្រសើរជាងឱ្យត្រីចង្វាបិច"។

អ្នកស្រី អូ ជាសកម្មជនសិទ្ធិការងារវ័យក្មេងម្នាក់ បានសម្រេចចិត្តបោះបង់ចោលការងារជាមន្ត្រីរៀបចំ និងចាត់ចែងបណ្តាញកម្មករ ដោយសារតែក្រុមគ្រួសាររបស់នាងមានការភ័យខ្លាចថា ថ្ងៃណាមួយគេអាចនឹងធ្វើឃាតនាង ដូចលោក ជា វិជ្ជា នៅកណ្តាលទីក្រុងភ្នំពេញកាលពីឆ្នាំ២០០៤។

### *២.១.១ លក្ខខណ្ឌ និងបរិយាកាសការងាររបស់ស្ត្រី*

អំពើពុករលួយ ការអនុវត្តន៍ច្បាប់គ្មានប្រសិទ្ធិភាព និងកង្វះបទដ្ឋានច្បាប់បាននាំឱ្យកម្មករស្ត្រីប្រឈមនឹងការលំបាកជាច្រើនក្នុងការងារ មានតាំងពីការធ្វើការថែមម៉ោងច្រើនហួសហេតុ រហូតដល់កង្វះទឹកស្អាតសម្រាប់បរិភោគនៅកន្លែងធ្វើការ។ មេដឹកនាំសហជីពរោងចក្រម្នាក់បានអះអាងថា អាស្រ័យដោយប្រាក់បៀវត្សគោលទាបពេក ដូច្នេះបង្ខំឱ្យកម្មករស្ត្រីត្រូវតែធ្វើការថែមម៉ោង ជាធម្មតារវាងពី ២ ទៅ ៤ម៉ោងក្នុង១ថ្ងៃ ដើម្បីទប់ទល់ការចំណាយជាមូលដ្ឋានដូចជា ឈ្នួលផ្ទះ ម្ហូបអាហារ និងថ្នាំពេទ្យជាដើម។ ហើយក៏នៅមានកម្មកររោងចក្រមួយចំនួនឈប់ពីការងាររោងចក្រ ងាកទៅរកការងារក្នុងវិស័យ "កំសាន្ត" ទៅវិញ។

ការបៀតបៀនកេរ្តិ៍ខ្មាស គឺជាបញ្ហាកង្វល់មួយទៀតសម្រាប់ស្ត្រីកម្មកររោងចក្រ។ កម្មករម្នាក់ក្នុងចំណោម ១០ នាក់បាននិយាយថា ពួកគេជាជនរងគ្រោះនៃអំពើបៀតបៀនកេរ្តិ៍ខ្មាសនៅកន្លែងធ្វើការ[៣៩]។ ចំនួនស្ត្រីដែលងាយរងគ្រោះសង្ឃឹមថានឹងកើនកាន់តែច្រើនឡើងៗ ដោយសារតែបញ្ហាវិបត្តិសេដ្ឋកិច្ចពិភពលោក ដែលបានបណ្តាលឱ្យរោងចក្រជិត ៧០ ត្រូវបិទ និងកម្មករជាង ៥១.០០០នាក់ បាត់បង់ការងារ។ ថ្វីត្បិតតែករណីបៀតបៀនកេរ្តិ៍ខ្មាសកើតឡើងឥតឈប់ឈរក៏ដោយ ក៏មកដល់ពេលនេះនៅមិនទាន់មានជនរងគ្រោះណាម្នាក់ដាក់ពាក្យបណ្តឹងទៅតុលាការកម្ពុជាឡើយ។ បញ្ហានេះអាស្រ័យដោយស្ត្រីកម្ពុជាខ្វះការយល់ដឹងអំពីច្បាប់ ដែលអាចការពារអ្នកទាំងនោះបានខ្វះទំនុកចិត្តលើប្រព័ន្ធតុលាការកម្ពុជា ព្រមទាំងពុំមានយន្តការសមស្របណាមួយដែលអាចជួយស្ត្រីរងគ្រោះទាំងនោះដាក់ពាក្យបណ្តឹងបាន។

## ២.២ ស្ត្រីក្នុងវិស័យសំណង់

ការយល់ដឹងអំពីសិទ្ធិការងាររបស់ស្ត្រីកម្មករបម្រើការងារក្នុងវិស័យសំណង់ គឺរឹតតែមានកម្រិតជាងស្ត្រីក្នុងវិស័យកាត់ដេរទៅទៀតផង។ ជាទូទៅស្ត្រីកម្មករសំណង់មានឱកាសក្នុងការទទួលបានការអប់រំបណ្តុះបណ្តាល និងព័ត៌មានអំពីសិទ្ធិក្នុងការបង្កើតសហជីព ទទួលបានសេវាសុខភាព និងបរិយាកាសការងារប្រកបដោយសុវត្ថិភាពតិចតួចជាទីបំផុត។

សហជីពកម្មករសំណង់នៅទន់ខ្សោយនៅឡើយ អាស្រ័យដោយការលំបាកក្នុងការរៀបចំបណ្តាញបើប្រៀបធៀបជាមួយនឹងសហជីពកម្មករកាត់ដេរ និងសហជីពអ្នកបម្រើសេវាកម្មក្នុងវិស័យទេសចរណ៍[៤០]។

ការងារសំណង់ចាត់ទុកជាការងារលំបាក និងគ្រោះថ្នាក់។ កម្មករភាគច្រើនទទួលបានការងារតាមរយៈមេការសំណង់ អ្នកម៉ៅការ ឬទាក់ទងផ្ទាល់តាមការដ្ឋានសំណង់ផ្សេងៗ។ ក្នុងពេលសម្រាកកម្មករទាំងនោះមិនអាចប្រមូលផ្តុំគ្នាបានស្រួលទេ ខុសពីកម្មកររោងចក្រដែលធ្វើការជាមួយគ្នា ហើយមានឱកាសចែក

---

[៣៩] អង្គការ CARE ឆ្នាំ២០០៥ អង្គការពលកម្មអន្តរជាតិ និងធនាគារពិភពលោក ឆ្នាំ២០០៦ ។

[៤០] អ្នកស្រី ចាន់ បុរី មន្ត្រីជាន់ខ្ពស់នៃសហព័ន្ធសហជីពកម្មករសំណង់កម្ពុជា។ ( WoFiCi-Cambodia )

រំលែកព័ត៌មានអំពីបញ្ហាសុខភាព ឬពិភាក្សាអំពីបញ្ហាសហជីព។ យោងតាមប្រសាសន៍របស់មន្ត្រីនៃមជ្ឈមណ្ឌលសិទ្ធិការងារកម្ពុជាបានឱ្យដឹងថា ស្ត្រីកម្មករសំណង់ភាគច្រើនធ្លាប់បានរងគ្រោះពីការកេងប្រវ័ញ្ចសេដ្ឋកិច្ច និងរំលោភបំពានផ្លូវភេទពីសំណាក់មេការ។ អ្នកមៅការម្នាក់ ដែលត្រូវបានជួលឱ្យសាងសង់របងជុំវិញរោងចក្រស្លូនកាណាឌីយ៉ាបានមានប្រសាសន៍ថា ស្ត្រីក៏អាចធ្វើការបានដូចបុរសដែរ ដូចជាការចងដែក ចាក់សរសរ លាយ និងជញ្ជូនស៊ីម៉ងត៍ជាដើម។ លោកនេះបន្តទៀតថា "រកកម្មករស្ត្រីមិនពិបាកទេ ថ្វីត្បិតតែប្រាក់ឈ្នួលក្នុង១ថ្ងៃ ត្រឹមតែពី៣.០០០រៀល ទៅ៥.០០០រៀល តែប៉ុណ្ណោះដែលតិចជាងកម្មករបុរស"។ លោកបន្ថែមថា លោកធ្លាប់ដើរមៅការសំណង់ជិត១០ឆ្នាំ កន្លងទៅហើយ លោកមិនដែលឃើញមានអាជ្ញាធរ ឬអង្គការណាមកសួរដេញដោលអំពីប្រាក់ឈ្នួលខុសគ្នានេះឡើយ។ សារព័ត៌មានភ្នំពេញប៉ុស្តិ៍ បានរាយការណ៍អំពីប្រាក់ឈ្នួលខុសគ្នារវាងបុរស និងស្ត្រីកាលពីខែមីនា ឆ្នាំ២០០៩។

ការងារសំណង់ អាចជាការងារគ្រោះថ្នាក់សម្រាប់កម្មករស្ត្រី ដែលភាគច្រើនការងារនេះច្រើនតែបុរសដែលធ្វើការងារនេះ។ ស្ត្រីកម្មករសំណង់វ័យក្មេងម្នាក់នៅកំពង់ស្ពឺ បានមកភ្នំពេញជាមួយប្អូនស្រីអាយុ១៩ឆ្នាំ ហើយរកការងារបានធ្វើនៅការដ្ឋានសំណង់មួយកន្លែងជិតក្រសួងមហាផ្ទៃ។ នាងបានរៀបរាប់អំពីអ្វីដែលបានកើតឡើងថា "គេបានបញ្ជូនខ្ញុំទាំងពីរទៅលាបផ្ទះល្វែងមួយនៅម្តុំផ្សារថ្មី។ ប៉ុន្តែមេការបានឱ្យខ្ញុំធ្វើការនៅកន្លែងខុសគ្នា។ ប្អូនស្រីខ្ញុំលាបនៅជាន់លើ ហើយខ្ញុំលាបក្នុងបន្ទប់មួយនៅជាន់ក្រោម។ ល្ងាចមួយនោះ ខ្ញុំឡើងទៅជាន់លើដើម្បីហៅប្អូនស្រីខ្ញុំទៅផ្ទះ រួចឃើញនាងអង្គុយយំកាន់អាវនាងជាប់នៅដើមទ្រូង។ នាងបានប្រាប់ខ្ញុំថា មេការបានរំលោភនាង។ មេការនោះតែងតែបបួល និងព្យាយាមសុំនាងទៅក្រៅជាមួយ ប៉ុន្តែនាងតែងតែបដិសេធ។ មេការនោះ បានសន្យាថានឹងឲ្យលុយនាង ប៉ុន្តែនាងមិនដែលទទួលយកលុយនោះទេ។ ក្រោយមកមេការនោះបានខឹងហើយទីបំផុតបានរំលោភនាង"។ ច្បាស់ណាស់ គឺស្ត្រីដែលជាបងនៅតែមានការភ័យខ្លាច ហើយបានបញ្ជាក់ថា "ខ្ញុំមិនហ៊ានប្តឹងទេ ខ្លាចមានការសងសឹក"។

អ្នកស្រី ម អាយុ ៣៥ ឆ្នាំ ធ្វើការជាមួយស្វាមីនាងជាកម្មករសំណង់នៅបុរីទួលសង្កែ។ នាងបានរាយរ៉ាប់ថា "ស្វាមីខ្ញុំ និងខ្ញុំធ្វើការដូចគ្នា ដូចជាជញ្ជូនឥដ្ឋការ៉ូ លាយស៊ីម៉ងត៍ ព្រមទាំងជញ្ជូនសំភារៈផ្សេងៗជាដើម។ ប្រាក់ឈ្នួលស្វាមីខ្ញុំបានទទួល ១៥.០០០រៀលក្នុងមួយថ្ងៃ ហើយខ្ញុំវិញបានតែ ៩.០០០រៀលប៉ុណ្ណោះ។ ខ្ញុំគិត ថាមេការឱ្យខ្ញុំតិចជាងស្វាមីខ្ញុំ ពីព្រោះខ្ញុំជាស្ត្រីមានកម្លាំងខ្សោយជាងគេ"។ ប្រាក់ឈ្នួលសម្រាប់កម្មករសំណង់មិនដូចគ្នាទេទៅតាមកន្លែងនីមួយៗ។ ប្រាក់ឈ្នួល គឺអាស្រ័យទៅតាមជំនាញក្នុងការតថ្លៃរបស់កម្មករ និងលទ្ធភាព ឬឆន្ទៈក្នុងការចំណាយរបស់មេការ។ អ្នកស្រី ចាន់ បុរី មន្ត្រីនៃសហព័ន្ធសហជីពកម្មករសំណង់កម្ពុជាបានកត់សម្គាល់ថា កម្មករសំណង់នៅកន្លែងខ្លះទទួលបាន៥ដុល្លារក្នុងមួយថ្ងៃ ចំណែកអ្នកផ្សេងទៀតអាចទទួលបានតិចតួច គឺត្រឹមតែ ៧.០០០រៀលក្នុង១ថ្ងៃ ប៉ុណ្ណោះទេ (ប្រហែល ១,៧៥ ដុល្លារ)។ មានមូលហេតុពីរចំបងចំពោះបញ្ហានេះ ទីមួយ គឺកម្មករសំណង់ពុំមានលិខិតណាមួយបញ្ជាក់អំពីសមត្ថភាព ឬបទពិសោធន៍របស់អ្នកទាំងនោះទេ។ ជាលទ្ធផល អ្នកទាំងនោះច្រើនតែគ្មានមូលដ្ឋានគ្រឹះរឹងមាំដើម្បីទាមទារឱ្យបានប្រាក់ឈ្នួលខ្ពស់ជាងនេះទេ។ ទីពីរ គឺមិនទាន់មានច្បាប់ និងគោលការណ៍ស្តីអំពីប្រាក់ឈ្នួលអប្បរមាសម្រាប់កម្មករសំណង់នៅឡើយ ដោយបច្ចុប្បន្ននេះច្បាប់គ្រាន់តែមានបញ្ជាក់អំពីប្រាក់ខែអប្បរមាសម្រាប់តែកម្មករក្នុងវិស័យកាត់ដេរ វាយនភណ្ឌ រោងចក្រស្បែកជើងតែប៉ុណ្ណោះ។

## ២.៣ ស្ត្រីក្នុងវិស័យសេវាកម្មកំសាន្ត

នៅតាមតំបន់ជនបទ ភាពក្រីក្រ គ្មានដីស្រែចម្ការ គ្មានការងារ អំពើជួញដូរមនុស្ស រំលោភសេព សន្ថវៈ ឬសូម្បីតែការបាត់បង់ព្រហ្មចារីយ៍ បានបង្ខំឱ្យស្ត្រីវ័យក្មេងជាច្រើនចាកចេញពីលំនៅដ្ឋាន ហើយធ្វើដំណើរទៅទីក្រុងដើម្បីស្វែងរកការងារធ្វើ។ ប៉ុន្តែឧស្សាហកម្មកាត់ដេរ ដែលមើលទៅឃើញថា ជាប្រភពសំខាន់ក្នុងការផ្តល់ការងារឱ្យស្ត្រីវ័យក្មេងមកពីជនបទនោះ មិនអាចទាញយកស្ត្រីទាំងនោះចូលទៅក្នុងទីផ្សារការងារបានទេ។ បញ្ហានេះ បានអូសទាញឱ្យស្ត្រីជាច្រើន ជាពិសេសស្ត្រីក្មេងៗចូលទៅបម្រើការងារផ្សេងវិញដែលគេហៅថា "វិស័យសេវាកម្មកំសាន្ត"។ ការងារប្រភេទនេះរួមមាន ស្ត្រីផ្សព្វផ្សាយលក់ស្រាបៀរ ស្ត្រីម៉ាស្សា និងបុគ្គលិកហាងខារ៉ាអូខេជាដើម ហើយខ្លះក៏ធ្វើជាស្ត្រីបម្រើផ្លូវភេទផ្ទាល់តែម្តង។ ការងារប្រភេទនេះបានរុញច្រានឱ្យស្ត្រីក្មេងៗធ្លាក់ចូលទៅក្នុងហានិភ័យនៃការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច និងការរំលោភផ្លូវភេទយ៉ាងធ្ងន់ធ្ងរ។ ស្ត្រី ៤នាក់ ក្នុងចំនោម ៥នាក់ ដែលធ្វើការក្នុងវិស័យសេវាកម្មកំសាន្តបែបនេះបាននិយាយថា ស្ត្រីទាំងអស់នោះជាជនរងគ្រោះពីសំណាក់ការបៀតបៀនកេរ្តិ៍ខ្មាស[៤១]។

## ២.៤ ការងារស្ត្រីក្នុងវិស័យសាធារណៈ

ការចូលរួមរបស់ស្ត្រីក្នុងវិស័យសាធារណៈ គឺនៅមានកម្រិតទាបនៅឡើយ។ បុរសមាន ៧៧% រីឯស្ត្រីត្រឹមតែ ២៣% ប៉ុណ្ណោះ ហើយនៅក្នុងតំណែងខ្ពស់ៗនោះ ស្ត្រីកាន់តែមានកំរិតទាបជាងនេះទៅទៀត។

គេសង្កេតឃើញថា ចំនួនស្ត្រីជារដ្ឋមន្ត្រីមានការថយចុះយ៉ាងខ្លាំងពី ៨% នៅឆ្នាំ ២០០៣ ថយមកនៅ ៧,៦% នៅឆ្នាំ២០០៥ និងថយចុះដល់ ៦% នៅឆ្នាំ២០០៧។ ប៉ុន្តែ មានការកើនឡើងគួរឱ្យកត់សម្គាល់នូវចំនួនស្ត្រីជារដ្ឋលេខាធិការពី ៦% នៅឆ្នាំ២០០៣ កើនដល់ ១៦% នៅឆ្នាំ២០០៧ ចំណែកតំណែងជាអនុរដ្ឋ-លេខាធិការវិញបានកើនឡើងពី ៥% នៅឆ្នាំ២០០៣ ដល់ ៣០% នៅឆ្នាំ២០០៧ ។ ពុំមាន ស្ត្រីកាន់តំណែងជាអភិបាលរងខេត្ត/អភិបាលរងស្រុកទេ ប៉ុន្តែរហូតដល់ឆ្នាំ២០០៨ ទើបមានស្ត្រីចំនួន ១១% បានកាន់តួនាទីខាងលើនេះ។ មកដល់ពេលនេះពុំទាន់មានស្ត្រីណាម្នាក់កាន់តំណែងជាអភិបាលខេត្ត រឺក្រុងនៅឡើយទេ។ ហើយនៅតាមការិយាល័យស្រុក និងខេត្ត ស្ត្រីបានកាន់តួនាទីជាប្រធានការិយាល័យមិនដល់ ២៥%ផងទេ។ នៅក្នុងក្រសួងទាំង ១៤ ស្ត្រីមានត្រឹមតែ ២០% នៃចំនួនមន្ត្រីរាជការទាំងអស់ប៉ុណ្ណោះ។

នៅក្នុងប្រព័ន្ធតុលាការ ស្ត្រីជាចៅក្រមមានត្រឹមតែ ៨,៥% និងជាព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញា ២,៧%។ ប៉ុន្តែស្ត្រីជាមេធាវីមានចំនួនច្រើន (១៧,៨%)។

មានការកើនឡើងនូវចំនួនស្ត្រីបំរើការងារជាតំណាងរាស្ត្រនៅក្នុងរដ្ឋសភាជាតិ និងក្រុមប្រឹក្សាឃុំសង្កាត់គួរឱ្យកត់សំម្គាល់។ តំណាងស្ត្រីបានកើនឡើងក្នុងចំណោមសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ពី ៨% នៅឆ្នាំ២០០២ ដល់ ១៤,៦% នៅឆ្នាំ២០០៧ ហើយនៅក្នុងរដ្ឋសភាជាតិកើនពី ១៩% នៅឆ្នាំ២០០៣ ដល់២២% នៅឆ្នាំ២០០៧។ ក៏ប៉ុន្តែ ចំនួនស្ត្រីជាតំណាងក្នុងព្រឹទ្ធសភាបានថយចុះ។ នៅឆ្នាំ២០០៤ មាន២១% នៃសមាជិកព្រឹទ្ធសភាជាស្ត្រី ក្រោយមកចំនួននោះបានថយចុះមកនៅត្រឹមតែ ១៥%ប៉ុណ្ណោះទេ។

[៤១] អង្គការ CARE ឆ្នាំ២០០៥ អង្គការពលកម្មអន្តរជាតិ និងធនាគារពិភពលោក ឆ្នាំ២០០៦ ។

# ៣. ស្ត្រីក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ

## ៣.១ ស្ត្រីបម្រើការងារតាមផ្ទះ

យោងតាមការសិក្សារបស់អង្គការអន្តោប្រវេសន៍អន្តរជាតិ IOM នៅឆ្នាំ២០០៧ មានស្ត្រីវ័យក្មេងជាច្រើនរហូតដល់ ៨៩% ធ្វើការជាអ្នកបម្រើតាមផ្ទះ ដែលមាននៅខេត្តកោះកុង ព្រះសីហនុ និងសៀមរាប។ ស្ថានភាពការងាររបស់ស្ត្រីទាំងអស់នោះ ជួបការលំបាកយ៉ាងខ្លាំង ដោយត្រូវធ្វើការជាមធ្យម ១៣,៥ម៉ោងក្នុងមួយថ្ងៃ។ ហើយក្នុងចំណោមស្ត្រីទាំងនោះមានតែ ៦៤% ប៉ុណ្ណោះដែលទទួលបានប្រាក់ឈ្នួលផ្ទាល់តែម្តង។

យោងតាមរបាយការណ៍បានឱ្យដឹងថា បញ្ហាកាន់តែធ្ងន់ធ្ងរជាងនេះទៅទៀតដោយស្ត្រីបម្រើការងារតាមផ្ទះចំនួន ១៦%ធ្លាប់ទទួលរងទារុណកម្ម និងរំលោភសេពសន្ថវៈដោយថៅកែជាបុរស។ ៣១% និយាយថា ស្ត្រីទាំងអស់នោះមិនដែលបានទទួលប្រាក់បៀវត្សរ៍ទេ ដែលមានន័យថា សាច់ញាតិរបស់អ្នកទាំងនោះជាអ្នកទទួលប្រាក់បៀវត្សនោះ នេះបើគេឲ្យប្រាក់បៀវត្សនេះមែននោះ។

មានការយល់ដឹង និងជួយឧបត្ថម្ភតិចតួចណាស់ចំពោះស្ត្រីដែលធ្វើការក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធនេះ។ ស្ត្រីនៅក្នុងផ្នែកនេះ ពុំបានទទួលកិច្ចការពារផ្នែកច្បាប់ និងសង្គមឡើយ ក្រោមច្បាប់ការងារបច្ចុប្បន្ននេះ ជាការរុញច្រានឱ្យអ្នកទាំងអស់នោះអាចជួបហានីភ័យនៃការកេងប្រវ័ញ្ចប្រាក់ឈ្នួល និងស្ថានភាពការងារយ៉ាងខ្ពស់។ ស្ត្រីអភ័ព្វខ្លះអាចក្លាយជាទាសករផ្លូវភេទក៏មានដែរ។

## ៣.២ ស្ត្រីក្នុងវិស័យកសិកម្ម

នៅកម្ពុជា ស្ត្រីគឺជាក្រុមមួយដែលមានដីធ្លីតិចជាងបុរស។ ចំនួនក្រុមគ្រួសារប្រហែល ៣៩% ដែលស្ត្រីជាមេគ្រួសារ មានដីស្រែត្រឹមតែជិតកន្លះហិកតាប៉ុណ្ណោះ ចំណែកឯក្រុមគ្រួសារចំនួន ១៨% ទៀតដែលបុរសជាមេគ្រួសារមានដីស្រែទំហំប៉ុនគ្នាដែរ។ ផ្ទុយទៅវិញ មួយភាគបី (ជាង៣៣%) នៃក្រុមគ្រួសារដែលមានមេគ្រួសារជាបុរសមានដីស្រែទំហំ ២ ហិកតា ឬលើសពីនេះទៅទៀត បើប្រៀបធៀបជាមួយក្រុមគ្រួសារចំនួន ១៧% ដែលស្ត្រីជាមេគ្រួសារមានដីទំហំប៉ុននេះដែរ។

យោងតាមការសិក្សាបែបលក្ខណៈគុណភាពមួយ[៤២] អំពីដំណើរការចុះបញ្ជីដីធ្លីជាប្រព័ន្ធនៅខេត្តកំពង់ធំ និងខេត្តកណ្តាល កាលពីដើមឆ្នាំ២០០៨ បានឱ្យដឹងថា រាជរដ្ឋាភិបាលកំពុងព្យាយាមធ្វើការបញ្ជ្រាបទស្សនៈយេនឌ័រទៅក្នុងគោលការណ៍កំណែទម្រង់ដីធ្លី និងច្បាប់។ ប៉ុន្តែក៏នៅមានការព្រួយបារម្ភអំពីស្ត្រីមួយចំនួនដែលបានបាត់បង់ឱកាសក្នុងការកាន់កាប់ និងចុះបញ្ជីដីធ្លីដោយស្របច្បាប់របស់អ្នកទាំងនោះ។ ចំពោះបញ្ហានេះ គេសង្កេតឃើញមានកត្តាជាច្រើនប៉ះពាល់ដល់បញ្ហាទាំងអស់នេះ ដូចជាស្ត្រីខ្វះការអប់រំ ព្រមទាំងការទទួលបានព័ត៌មានត្រឹមត្រូវនៅមានកំរិតនៅឡើយអំពីការចុះបញ្ជីដីធ្លីជាដើម។ បញ្ហានេះក៏រួមបញ្ចូលទាំងកង្វះព័ត៌មានអំពីនីតិវិធីនៃការលែងលះ ការចុះចោលលំនៅដ្ឋាន និងឥរិយាបថទំនៀមទម្លាប់ផង ដែលគេយល់ថា បុរសជាមេគ្រួសារមានសិទ្ធិផ្តាច់មុខក្នុងការគ្រប់គ្រង និងត្រួតត្រាលើទ្រព្យសម្បត្តិក្រុមគ្រួសារទាំងអស់។

---

[៤២] ការសិក្សាដោយលោក Heinrich Boll Stiftung នៅកម្ពុជា និងអង្គការយេនឌ័រ និងការអភិវឌ្ឍន៍កម្ពុជា ។

## ៣.៣ ស្ត្រីក្នុងវិស័យសហគ្រាសខ្នាតតូច

ស្ត្រីកម្ពុជាជាច្រើន បានក្លាយជាអ្នករកចំណូលសម្រាប់គ្រួសារយ៉ាងសកម្មតាំងពីក្មេង ហើយទន្ទឹមនឹងនេះក៏នៅតែបន្តធ្វើការងារផ្ទះរបស់ខ្លួនដោយគ្មានកម្រៃទៀតផង។ សកម្មភាពសេដ្ឋកិច្ចរបស់ស្ត្រីទាំងនោះច្រើនតែផ្តោតលើតម្រូវការប្រចាំថ្ងៃជាមូលដ្ឋាន ប៉ុន្តែកង្វះធនធាន និងការគ្រប់គ្រងធនធានមិនបានត្រឹមត្រូវច្រើនតែជាឧបសគ្គរាំងដល់ជោគជ័យនៃសហគ្រាសរបស់ស្ត្រីទាំងនោះ។

ស្ត្រីកម្ពុជាចូលរួមយ៉ាងសំខាន់ក្នុងវិស័យអាជីវកម្មខ្នាតតូច ប៉ុន្តែគេមិនសូវទទួលស្គាល់ និងឱ្យតម្លៃចំពោះការចូលរួមចំណែករបស់ស្ត្រីទាំងនោះទេ។ ពុំមានផ្នែកណាមួយមានទិន្នន័យអំពីចំនួនអាជីវកម្មខ្នាតតូចដែលប្រតិបត្តិដោយស្ត្រីឡើយ។ ភាគច្រើនគឺជាការងារធម្មតា និងគ្មានជំនាញច្បាស់លាស់។

រដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលបានរៀបចំកម្មវិធីអភិវឌ្ឍន៍ជាច្រើនក្នុងវិស័យនេះ ប៉ុន្តែកម្មវិធីទាំងនោះច្រើនតែពុំបានបំពេញតាមតម្រូវការជាក់ស្តែងរបស់ស្ត្រីទេ។ កង្វះទិន្នន័យជាឧបសគ្គដល់អ្នករៀបចំគោលនយោបាយដើម្បីយល់អំពីការលំបាករបស់ស្ត្រី និងរៀបចំផែនការឱ្យបានត្រឹមត្រូវ។ យុទ្ធសាស្ត្របច្ចុប្បន្នរបស់រដ្ឋាភិបាល គឺលើកកម្ពស់សេវាកម្មឥណទានរយៈពេលវែង និងមធ្យមភាគច្រើនសម្រាប់ស្ត្រីដែលជាកសិករ តាមរយៈការពង្រីកស្ថាប័នឥណទានខ្នាតតូចនៅជនបទ។ បច្ចុប្បន្ននេះ រដ្ឋាភិបាលបានចំណាយមូលនិធិឥណទានយ៉ាងច្រើននៅតាមខេត្តមួយចំនួនក្នុងគោលបំណង ដើម្បីជម្រុញការអភិវឌ្ឍន៍ផលិតផលកសិកម្ម និងដើម្បីផ្សារភ្ជាប់ផលិតផលទាំងនោះទៅនឹងតម្រូវការទីផ្សារក្នុងស្រុក និងបរទេស។

កន្លងមកគេបានបង្កើតមជ្ឈមណ្ឌលអភិវឌ្ឍន៍ចំនួន ១១កន្លែងនៅតាមបណ្តាខេត្តនានាក្នុងគោលបំណងដើម្បីបណ្តុះបណ្តាលស្ត្រីអំពីវិជ្ជាជីវៈជំនាញ សេវាកម្ម និងព័ត៌មានពាណិជ្ជកម្ម ដើម្បីពង្រឹងស្ត្រីអំពីការងារគ្រប់គ្រងសហគ្រាស និងបង្កើនឱកាស។ ក៏ប៉ុន្តែ យើងបានសង្កេតឃើញថា ជនក្រីក្រកម្ពុជាជាពិសេសស្ត្រីដែលបានទទួលឥណទានខ្នាតតូចទាំងនោះ ហាក់ដូចជាជាប់ជំពាក់បំណុលគេទៅវិញ ទន្ទឹមនឹងស្ថាប័នឥណទានចេះតែរីកចម្រើនទៅមុខឥតឈប់ឈរ។

លើសពីនេះទៅទៀត នៅពេលដែលសហគ្រាស ដែលពឹងផ្អែកលើការប្រមូលផល និងដំណើរការផលិតពីធនធានធម្មជាតិ ដូចជាការប្រមូលជ័រ នេសាទត្រី ជីកទំពាំង និងដេរស្លឹកត្រាំង និងផ្តៅជាដើមត្រូវបានបង្កើតឡើង ប្រតិបត្តិករច្រើនតែជួបប្រទះបញ្ហាមួយចំនួនទាក់ទងនឹងការចុះបញ្ជីពាណិជ្ជកម្ម សុំច្បាប់អនុញ្ញាត អំពើពុករលួយ ការបង់ពន្ធ និងការត្រួតពិនិត្យជាដើម។ បញ្ហាការិយាធិបតេយ្យបែបនេះ បានធ្វើឱ្យប្រាក់ចំណេញរបស់សហគ្រាសខ្នាតតូចថយចុះយ៉ាងខ្លាំង។ នីតិវិធីស្មុកស្មាញក្នុងការចាប់ផ្តើម និងប្រតិបត្តិការពាណិជ្ជកម្មជាបញ្ហាសំខាន់ ដែលច្រើនតែពុំអាចជំនះបាន នោះជាឧបសគ្គចំពោះស្ត្រីទាំងឡាយដែលមានការរៀនសូត្របានតិចតួច។

## ៣.៤ ភាពខុសគ្នាក្នុងការទទួលបានប្រាក់ចំណូល

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានធានាយ៉ាងពេញលេញនូវការងារស្មើគ្នារវាងបុរស និងស្ត្រី ព្រមទាំងប្តេជ្ញាលុបបំបាត់នូវរាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទផងដែរ។ កម្ពុជាក៏ជាប្រទេសហត្ថលេខីនៃអនុសញ្ញាលេខ១០០ របស់អង្គការពលកម្មអន្តរជាតិស្តីពីប្រាក់ឈ្នួលស្មើគ្នារវាងបុរស និងស្ត្រី

ចំពោះការងារមានតម្លៃស្មើគ្នា។ មាត្រា១០៤ នៃច្បាប់ការងារបញ្ជាក់ថា "ប្រាក់ឈ្នួលយ៉ាងតិចក៏ត្រូវតែសមាមាត្រជាមួយនឹងប្រាក់ឈ្នួលអប្បរមាដើម្បីធានាឱ្យកម្មករ និងនិយោជិតមានកម្រិតជីវភាពរស់នៅសមរម្យក្នុងសេចក្តីថ្លៃថ្នូរនៃមនុស្សជាតិ"។ ចំពោះបញ្ហា ដែលបានលើកឡើងខាងលើរដ្ឋាភិបាលកម្ពុជាមិនទាន់សម្រេចសិទ្ធិរបស់ប្រជាពលរដ្ឋបាននៅឡើយទេ ជាពិសេសក្នុងវិស័យសំណង់។ កម្ពុជានៅមិនទាន់មានការថែងអំពីប្រាក់ឈ្នួលអប្បរមាជាតិទេ។

ស្ត្រីធ្វើការក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធទទួលបានកម្រៃ ៣០% តិចជាងបុរសចំពោះការងារស្រដៀងគ្នា។ រីឯសេដ្ឋកិច្ចក្នុងប្រព័ន្ធ បញ្ហាប្រាក់ឈ្នួលខុសគ្នាកាន់តែច្រើនឡើងៗ ដោយសារតែបុរសកាន់តំណែងជាថ្នាក់គ្រប់គ្រងក្នុងចំនួនមួយវិសមាមាត្រ។ មកដល់ពេលនេះ ក្រៅពីការជូនដំណឹងចេញដោយក្រសួងការងារ ស្តីពីប្រាក់ឈ្នួលអប្បរមាសម្រាប់វិស័យកាត់ដេរ ផលិតកម្មស្បែកជើង និងវិស័យវាយនភណ្ឌ គេពុំឃើញមានការចេញបទដ្ឋានគតិយុត្តិផ្សេងៗទៀតដើម្បីធានាឱ្យបុរស និងស្ត្រីទទួលបានប្រាក់ឈ្នួលស្មើគ្នាទេ។ ស្ត្រីទាំងឡាយ ដែលធ្វើការក្នុងវិស័យសំណង់កាលពីមុនទទួលបានប្រាក់ឈ្នួលចន្លោះពី ៥.០០០ រៀល ទៅ ៧.០០០រៀលក្នុងមួយថ្ងៃ ចំណែកបុរសវិញទទួលបានពី ៧.០០០រៀល ទៅ ៨.០០០រៀល ក្នុងមួយថ្ងៃ និងមកដល់ពេលនេះប្រាក់ឈ្នួលឡើងខ្ពស់ជាងមុន ប្រហែលជាពី ១៣.០០០រៀល ទៅ ១៥.០០០រៀល ក្នុងមួយថ្ងៃសម្រាប់ស្ត្រី និងចំណែកឯបុរសវិញពី ១៧.០០០រៀល ទៅ ២០.០០០រៀលក្នុងមួយថ្ងៃ។ ពុំទាន់ឃើញមានវិធានការជាគោលការណ៍ណាមួយត្រូវបានកំណត់ឡើង ដើម្បីកាត់បន្ថយគម្លាតនេះឡើយ។ ហើយក៏ពុំឃើញមានការតវ៉ាចំពោះបញ្ហារើសអើងនេះ ព្រមទាំងគ្មានយន្តការណាមួយត្រូវបានបង្កើតឡើងដើម្បីត្រួតពិនិត្យមើល និងលើកទឹកចិត្តស្ត្រីឱ្យទាមទារចំពោះបញ្ហាគម្លាតនេះដែរ។

### ៣.៥ ស្ត្រី និងចំណាកស្រុក

អនុសាសន៍រួមលេខ ២៦ របស់អនុសញ្ញាសិទ្ធិស្ត្រីស្តីពីការចំណាកស្រុករបស់ស្ត្រីតម្រូវឱ្យសមាជិករដ្ឋនានា អនុវត្តកិច្ចការពារសិទ្ធិ និងសន្តិសុខរបស់ស្ត្រីក្នុងការធ្វើចំណាកស្រុក។

នៅក្នុងរបាយការណ៍ឆ្នាំ២០០៨ របស់ក្រសួងកិច្ចការនារី ដែលមានចំណងជើងថា ចំណែកស្មើគ្នាសម្រាប់ស្ត្រីបានសរសេរថា ស្ត្រីចំណាកស្រុកចូល និងចេញពីកម្ពុជា គឺបណ្តាលមកពីសម្ពាធសេដ្ឋកិច្ច ភាពក្រីក្រ និងកង្វះឱកាសសេដ្ឋកិច្ចនៅតាមតំបន់ជនបទក្នុងវិស័យផ្សេងៗ។

ប្រជាពលរដ្ឋកម្ពុជាជាង ៩.០០០ នាក់បានចុះឈ្មោះទៅធ្វើការនៅក្រៅប្រទេស ដែលក្នុងចំនួននោះ ៥.៣០៩នាក់ ជាស្ត្រី។ ស្ត្រីចំណាកស្រុក ដោយសារមិនបានរៀនសូត្រច្រើន និងខ្វះជំនាញខាងបច្ចេកទេស ធ្វើឱ្យស្ត្រីទាំងនោះមិនអាចរកការងារធ្វើបានដែលផ្តល់នូវប្រាក់ចំណូលខ្ពស់ទេ។ ស្ត្រីចំណាកស្រុកក៏តែងតែជួបប្រទះឧបសគ្គយ៉ាងច្រើន ដូចជាបញ្ហាសុខភាព ការងារដោយបង្ខិតបង្ខំ ទារុណកម្ម ឃាតកម្ម ការគាបសង្កត់ឱ្យធ្វើជាស្ត្រីបំរើសេវាកម្មកំសាន្ត អំពើជួញដូរមនុស្ស បញ្ហាគ្រឿងញៀន បញ្ហាអន្តោប្រវេសន៍ ការពិបាកក្នុងការមិនចេះភាសាបរទេស ការដកហូតឯកសារ និងស្ថានភាពការងារគ្រោះថ្នាក់ជាដើម។ កម្មករដែលធ្វើចំណាកស្រុកទៅបរទេសក៏អាចជួបប្រទះការលំបាកក្នុងការស្វែងរកជំនួយពីភ្នាក់ងារអនុវត្តច្បាប់ និងអង្គការមិនមែនរដ្ឋាភិបាលផងដែរនៅក្នុងប្រទេសដែលអ្នកទាំងអស់នោះកំពុងតែធ្វើការងារ។

ដើម្បីលើកកម្ពស់ពលករ ដែលចាកចេញពីប្រទេសទៅធ្វើការនៅបរទេស និងដើម្បីការពារពលករទាំងនោះពីការកេងប្រវ័ញ្ចជួញដូរមនុស្ស រដ្ឋាភិបាលបានចាត់វិធានការមួយចំនួនដើម្បីរៀបចំឱ្យមានគោលការណ៍សម្របសម្រួលគ្នាជាមួយប្រទេសថៃ ម៉ាឡេស៊ី និងសាធារណៈរដ្ឋកូរ៉េ។ កន្លងមកឃើញមានការផ្តួចផ្តើមបង្កើតឱ្យមានកិច្ចព្រមព្រៀងជាច្រើនជាមួយប្រទេសទាំងនោះ។ បច្ចុប្បន្ននេះ មានអនុស្សរណៈស្តីពីការយោគយល់គ្នា អំពីកិច្ចការពារអំពើជួញដូរមនុស្ស និងការជួយជនរងគ្រោះតាមរយៈបណ្តាញប្រទេសនៃអនុតំបន់មហាទន្លេមេគង្គ។ អនុស្សរណៈ ស្តីពីកិច្ចសហប្រតិបត្តិការដែលចុះហត្ថលេខាដោយកម្ពុជា ថៃ និងវៀតណាម ក៏បានចែងនូវបញ្ញត្តិមួយចំនួនស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ។ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទត្រូវបានអនុម័ត ហើយក្រុមការងារទប់ស្កាត់នឹងអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចពលកម្ម និងអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារក៏ត្រូវបានបង្កើតឡើងផងដែរ។

ក្រសួងកិច្ចការនារីបានឆ្លើយតបទៅនឹងយោបល់ចុងក្រោយ ដែលផ្តល់ដោយគណៈកម្មាធិការអនុសញ្ញាសិទ្ធិស្ត្រី តាមរយៈការបង្កើតនូវប្រព័ន្ធប្រមូលទិន្នន័យរួមមួយដើម្បីត្រួតពិនិត្យបញ្ហាចំណាកស្រុក។ ចំណែកឯក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៤ ដើម្បីជួយទីផ្សារការងារ និងផ្តល់ជំនាញឱ្យពលករ។ ក្រសួងនេះ ក៏បានរៀបចំផែនការយុទ្ធសាស្ត្រដើម្បីជួយសម្របសម្រួលឱ្យមានលំហូរពលករចំណាកស្រុកស្របច្បាប់ទៅក្រៅប្រទេស។ ប៉ុន្តែវិធានការការពារសម្រាប់ពលករទាំងនេះនៅពុំទាន់មានគ្រប់គ្រាន់នៅឡើយ ដោយពុំទាន់មានច្បាប់ណាមួយជាក់លាក់ស្តីពីពលករចំណាកស្រុកនៅឡើយទេ មកដល់បច្ចុប្បន្ននេះ។ លើសពីនេះទៅទៀត ច្បាប់ការងារកម្ពុជាបច្ចុប្បន្ននេះពុំមានយុត្តាធិការលើសិទ្ធិពលករចំណាកស្រុកដែលធ្វើការនៅក្រៅប្រទេសទេ។ បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជាកំពុងរៀបចំគម្រោងដើម្បីត្រួតពិនិត្យ និងកែលំអរស្ថានភាពការងាររបស់ពលរដ្ឋកម្ពុជាដែលធ្វើការងារនៅក្រៅប្រទេស។

## ៣.៦ ស្ត្រីជនជាតិដើមភាគតិច និងស្ត្រីពិការ

ជនជាតិដើមភាគតិចមួយចំនួនធំរស់នៅតំបន់ខ្ពង់រាប នៃភូមិភាគឦសានជាកសិករគ្រាន់តែចិញ្ចឹមជីវិតតែប៉ុណ្ណោះ តាមការប្រកបរបរកសិកម្មវិលជុំ។ គ្រួសារជាច្រើនបានផ្លាស់ប្តូរមុខដំណាំពីការធ្វើស្រែវិលជុំទៅជាដាំដំណាំពាណិជ្ជកម្ម/ឧស្សាហកម្មវិញដូចជា ស្វាយចន្ទី ស្វាយ និងថ្នាំជក់ ជានិន្នាការមួយដែលមានល្បឿនយ៉ាងលឿនក្នុងប៉ុន្មានឆ្នាំថ្មីៗកន្លងទៅនេះ។ កសិកម្មខ្នាតធំ គឺកៅស៊ូ កាហ្វេ និងស្វាយចន្ទី។ ចំណែកឯសកម្មភាពសេដ្ឋកិច្ចផ្សេងៗទៀតនៅក្នុងខេត្តមានដូចជា ការជីកត្បូង និងកាប់ឈើជាដើម។ ប្រជាពលរដ្ឋទាំងអស់សុទ្ធតែធ្វើការនៅក្នុងស្រែចម្ការ និងសួនបន្លែ។ សួនបន្លែច្រើនតែដាំនៅជិតៗផ្ទះ និងប្រភពទឹក ហើយផលិតផលទាំងនោះច្រើនតែដាំសម្រាប់ផ្គត់ផ្គង់តម្រូវការក្នុងក្រុមគ្រួសារប្រចាំថ្ងៃតែប៉ុណ្ណោះ ដោយនៅសល់ពីនោះអាចលក់ខ្លះនៅឯផ្សារ។ ជនជាតិដើមភាគតិចមួយចំនួនធំដាំពោត (៩៦%) និងស្រូវ(៩០%)។

ស្ត្រីជនជាតិដើមភាគតិចដើរតួនាទីយ៉ាងសំខាន់នៅក្នុងការងារកសិកម្ម និងប្រមូលអនុផលព្រៃឈើ។ ដោយបុរសភាគច្រើនដើរបរបាញ់សត្វ និងនេសាទត្រី ព្រមទាំងធ្វើការងារកសិកម្ម ដែលត្រូវការពលកម្មខ្លាំង ហើយចំពោះការងារទាំងនេះ ស្ត្រីត្រូវតែយកចិត្តទុកដាក់ និងប្រឹងប្រែងខ្លាំងជាងបុរសដោយស្ត្រីត្រូវថែទាំ និងទៅមើលចម្ការ ព្រមទាំងប្រមូលអនុផលព្រៃឈើជាប្រចាំ។ ស្ត្រីក៏ត្រូវរកអុស និងដងទឹក មើល

ថែទាំកូន សត្វចិញ្ចឹម និងរៀបចំសកម្មភាពប្រពៃណីផ្សេងៗទៀតផង។ លើសពីនេះទៅទៀត ស្ត្រីច្រើនតែជាអ្នកបេះបន្លែមកពីព្រៃដូចជា ទំពាំង ក្តួច ផ្សិត ដំឡូង ស្លឹកវាំង។ល។ និងផ្លែឈើធម្មជាតិ ដូចជាស្វាយ សាវម៉ាវ កំពីងរាជ ម៉ាក់ព្រេងម៉ាក់ប្រាងជាដើម...)[៨៣]។

ដោយដីភាគច្រើនត្រូវបានគេយកទៅធ្វើជាចម្ការធំៗ ដាំដំណាំឧស្សាហកម្ម ចម្ការដូងប្រេង និងកៅស៊ូជាដើម ស្ត្រីជនជាតិដើមទាំងនោះត្រូវទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដោយសារបាត់បង់ដីធ្លី។ ស្ត្រីទាំងនោះបាត់បង់ការគ្រប់គ្រងផ្នែកសំខាន់ៗជាច្រើនជុំវិញភូមិ ដែលអ្នកទាំងអស់នោះច្រើនតែដាំ និងរកបន្លែផ្សេងៗ។

ការវាយតម្លៃផលប៉ះពាល់របស់ទំនប់វារីអគ្គីសនីយ៉ាលីនៃទន្លេសេសាន ខេត្តរតនៈគីរី ស្ត្រីជនជាតិដើមភាគតិចបានត្អូញត្អែរអំពីការបាត់បង់ធនធានផ្សេងៗ សម្រាប់ចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់អ្នកទាំងនោះ។ ពីដើមស្ត្រីប្រើប្រាស់ថ្នងធ្វើពីឬស្សី ឬមោងអំបោះដើម្បីដងត្រី ដែលអ្នកទាំងអស់នោះតែងតែដងបានត្រីតូចៗ និងកំពឹសនៅតាមទន្លេ។ ស្ត្រីទាំងនោះ ក៏ដើរបេះបន្លែព្រៃផ្សេងៗ និងរកពងសត្វបក្សីនានានៅតាមមាត់ទន្លេក្នុងរដូវប្រាំង។ ក្រោយពីការកសាងទំនប់វារីអគ្គីសនីនេះមក អ្នកទាំងនោះមិនអាចរកបន្លែ និងត្រីទាំងនោះដូចពេលមុនៗដោយសុវត្ថិភាពបានទៀតទេ។ បញ្ហាទាំងនេះ បាននាំឱ្យមានអារម្មណ៍ថាបាត់បង់នូវឯករាជភាព ហើយបានបង្កើននូវការពឹងពាក់លើបុរសៗដើម្បីរកត្រី និងធនធានម្ហូបអាហារផ្សេងៗទៅវិញ។

យើងមិនអាចរកទិន្នន័យ ឬរបាយការណ៍នានាទាក់ទងនឹងស្ថានភាពស្ត្រីពិការបានទេនៅក្នុងទីផ្សារការងារ។ ប៉ុន្តែយើងក៏អាចសន្និដ្ឋានយ៉ាងសមហេតុសមផលបានដែរថា ស្ថានភាពរបស់ស្ត្រីជនជាតិដើមភាគតិចដែលពិការទាំងអស់នោះមុខជាមានសភាពពិបាកខ្លាំងជាងស្ត្រីដទៃៗ។ កង្វះឱកាសអភិវឌ្ឍសម្រាប់ស្ត្រីទាំងនេះអាចនាំឱ្យធ្លាក់ក្នុងភាពមួយគឺមិនយកចិត្តទុកដាក់ និងនៅក្រៅសង្គម។ ជាងនេះទៅទៀត ស្ត្រីពិការប្រឈមមុខឧបសគ្គជាច្រើនថែមទៀតចំពោះស្វ័យភាពសេដ្ឋកិច្ច និងផ្ទាល់ខ្លួនដែលរារាំងដល់លទ្ធភាពក្នុងការធ្វើយ៉ាងណាឱ្យអ្នកក្រៅបានឮ ឃើញ និងយកចិត្តទុកដាក់អំពីបញ្ហារបស់ស្ត្រីពិការទាំងនោះ។

## ៤. ប្រស្នា

ឧបសគ្គដ៏ធំមួយ ក្នុងចំណោមឧបសគ្គធំៗទាំងឡាយសម្រាប់ស្ត្រីពិការកម្ពុជាក្នុងទីផ្សារការងារ គឺការទទួលស្គាល់តួនាទីដ៏មានសារៈសំខាន់នៅក្នុងប្រព័ន្ធសេដ្ឋកិច្ច។ អាស្រ័យដោយប្រជាពលរដ្ឋកម្ពុជាភាគច្រើនលើសលប់រស់នៅតាមតំបន់ជនបទ និងមានសមត្ថភាពតិចតួចក្នុងការទិញដូរនៅក្នុងក្រុមគ្រួសារ នោះស្ត្រីវ័យក្មេងជាច្រើនពុំមានលទ្ធភាពទៅរៀននៅសាលា ហើយត្រឹមតែបានរៀនសូត្រអំពីកិច្ចការងារជាក់លាក់សម្រាប់ស្ត្រីនៅតាមផ្ទះប៉ុណ្ណោះ។ បញ្ហានេះ បាននាំមកនូវអត្រាអនក្ខរភាពខ្ពស់ ជំនាញតិចតួច ព្រមទាំងឱកាសតិចតួចដើម្បីរកការងារ ដែលអាចទទួលប្រាក់បៀវត្សបាន។ ជាលទ្ធផលស្ត្រីកម្ពុជាភាគច្រើនជ្រើសរើសយកតួនាទីស្ត្រីជា "ប្រពៃណី"។

---

[៨៣] ការសិក្សារបស់ NTFP ។

ឧបសគ្គផ្សេងៗទៀតរួមមាន:

- ខ្វះការទទួលព័ត៌មានគ្រប់គ្រាន់ទាក់ទងនឹងការងារពាណិជ្ជកម្ម មានគម្លាតយ៉ាងធំក្នុងចំណេះដឹងការងារគ្រប់គ្រង ការគ្រប់គ្រងថវិកា និងដំណើរការក្នុងការបើកមុខរបរជំនួញ។ បញ្ហាទាំងអស់នេះ បាននាំឱ្យស្ត្រីទាំងឡាយត្រូវបានឃ្លាតឆ្ងាយពីសកម្មភាពសហគ្រាសផ្សេងៗ ដោយគេគិតថាស្ត្រីពុំមែនជាភ្នាក់ងារទទួលខុសត្រូវទេ។
- ទទួលបានចំណូលតិចជាងបុរសចំពោះការងារដូចគ្នា ជាពិសេសក្នុងទីផ្សារការងារក្រៅប្រព័ន្ធ។ គម្លាតប្រាក់ឈ្នួលរវាងបុរស និងស្ត្រីនៅតែមាននៅឡើយ ធ្វើឱ្យមានការទទួលស្គាល់ស្របច្បាប់ចំពោះការមើលស្រាលលើសមត្ថភាពរបស់កម្មការិនីថែមទៀតផង។
- ការបែងចែកការងាររវាងភេទប្រុស និងស្រីនៅតែមាន។ ចំណុចសំខាន់របស់តួនាទីយេនឌ័រនៅកម្ពុជា និងផ្នត់គំនិតទូទៅអំពីសមត្ថភាពទាក់ទងនឹងយេនឌ័របានរារាំងស្ត្រីមិនអាចចូលបម្រើការងារបាននៅក្នុងច្រើនប្រភេទ។ គេយល់ថាស្ត្រីពុំមានសមត្ថភាព និងលទ្ធភាពគ្រប់គ្រាន់ដើម្បីធ្វើការងារមួយចំនួនបានទេ។ ផ្ទុយទៅវិញបញ្ហានេះទាក់ទងនឹងផ្នត់គំនិត និងរារាំងលទ្ធភាពក្នុងការធ្វើសកម្មភាព និងអភិវឌ្ឍនៅពេលអនាគត។
- ការអភិវឌ្ឍន៍ជំនាញនៅតំបន់ជនបទមានការយឺតយ៉ាវយ៉ាងខ្លាំង អាស្រ័យដោយការងារ និងកម្មវិធីបណ្តុះបណ្តាលនៅមានកម្រិត។ ស្ត្រីភាគច្រើនមិនមានធនធានផ្ទាល់ខ្លួន ឬមិនមានលទ្ធភាពទទួលបានធនធានទាំងនោះទេ នេះហើយដែលនាំឱ្យមានការលំបាកក្នុងការចាប់ផ្តើមធ្វើជំនួញអ្វីមួយ ដោយមិនពឹងគេដែលជាធម្មតាគឺជាបុរស។
- កង្វះកិច្ចការពារផ្នែកច្បាប់សម្រាប់ពលករក្នុងវិស័យក្រៅប្រព័ន្ធ។
- ស្ត្រីធ្វើការក្នុងផ្នែកការងារក្រៅប្រព័ន្ធ ងាយរងគ្រោះយ៉ាងខ្លាំងពីសំណាក់អំពើកេងប្រវ័ញ្ច រំលោភ និងយាយីរំខាន។ បញ្ហាទាំងនេះ ពុំមែនត្រឹមតែជាបញ្ហាទូទៅប៉ុណ្ណោះទេ ប៉ុន្តែជាបញ្ហាមួយដែលសង្គមមើលមិនឃើញទៀតផង ដោយបញ្ហាទាំងនេះមិនត្រូវបានរាយការណ៍ ហើយអាជ្ញាធរកម្រធ្វើអន្តរាគមន៍ណាស់។
- ពុំមានស្ត្រីគ្រប់គ្រាន់ចូលរួម និងបញ្ចេញមតិយោបល់អំពីបញ្ហាសេដ្ឋកិច្ច និងការធ្វើគោលនយោបាយឡើយ។
- ពុំមានស្ត្រីគ្រប់គ្រាន់ក្នុងតំណែងធ្វើការសម្រេចចិត្តសំខាន់ៗ ដែលនាំឱ្យប៉ះពាល់ដល់សិទ្ធិការងារ និងតម្រូវការសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋជាស្ត្រីភេទ។ ជាក់ស្តែងគេពុំឃើញមានការចាត់វិធានការណាមួយ ដើម្បីកែលំអរតួនាទីរបស់ស្ត្រីក្នុងទីផ្សារការងារកម្ពុជាឡើយ។ នៅក្នុងវិស័យនេះ គេឃើញមានសមាគម ឬបណ្តាញតិចតួចបំផុតដែលតំណាងឱ្យសម្លេងស្ត្រី។ លទ្ធភាពដើម្បីចាត់វិធានការនៅមានកម្រិត។

## ៥. អនុសាសន៍

សូមសំណូមពរដល់រដ្ឋាភិបាលៈ

១. អនុវត្តនីតិកម្ម និងអនុសញ្ញាស្តីពីសិទ្ធិស្ត្រីដែលមានស្រាប់ឱ្យមានប្រសិទ្ធិភាព ដើម្បីកែលំអរគោលនយោបាយសេដ្ឋកិច្ច និងដើម្បីធានាឱ្យស្ត្រីទទួលបានផលប្រយោជន៍ស្មើគ្នា ព្រមទាំងទទួលបាននូវឱកាសការងារថ្មីៗ។

២. ផ្តល់អាទិភាពឱ្យមានការចូលរួមរបស់ស្ត្រីក្នុងវិស័យកសិកម្ម និងធានាឱ្យស្ត្រីបានចូលរួមយ៉ាងសកម្ម និងទទួលបានប្រយោជន៍ពីលទ្ធផលនៃការរីកចម្រើនផ្នែកសេដ្ឋកិច្ច ។ រដ្ឋាភិបាលក៏គួរធានាឱ្យស្ត្រីមានសិទ្ធិស្មើគ្នា ជាមួយបុរសក្នុងគ្រប់វិស័យទាំងអស់ រួមទាំងសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិ និងទ្រព្យរួមគ្នាផង។ ស្ត្រីគួរទទួលបានកិច្ចការពារ និងគាំទ្រពីសំណាក់ការបណ្តេញចេញដោយខុសច្បាប់ ការរំលោភយកដីធ្លី និងបញ្ហាទាក់ទងនឹងការប្រើប្រាស់ទឹក ឬការបែងចែកធនធានធម្មជាតិនានា។

៣. ដាក់ផែនការដើម្បីលុបបំបាត់គម្លាតយេនឌ័រទៅក្នុងវិស័យកសិកម្ម និងជួយស្ត្រីឱ្យបានចូលក្នុងតំណែងដែលធ្វើការសម្រេចចិត្តនៅលំដាប់ថ្នាក់ទាំងអស់។ ចាំបាច់ត្រូវភ្ជាប់គោលការណ៍សមភាពយេនឌ័រ ជាមួយនឹងការយកឈ្នះលើឧបសគ្គសង្គមសម្រាប់ស្ត្រី។

៤. ផ្តល់អាទិភាពខ្ពស់ដល់ការប្រែក្លាយសហគ្រាសខ្នាតតូចក្រៅប្រព័ន្ធ ទៅជាសហគ្រាសខ្នាតតូចក្នុងប្រព័ន្ធវិញ ព្រមទាំងរៀបចំបណ្តុះបណ្តាលអំពីផែនការពាណិជ្ជកម្មដើម្បីធានាឱ្យមាននិរន្តភាពដល់សហគ្រាសខ្នាតតូចទាំងនោះ។ គួរផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើគុណភាព បញ្ហាសុខភាព ការចុះបញ្ជីពាណិជ្ជកម្ម បទដ្ឋានច្បាប់ ព្រមទាំងការអភិវឌ្ឍន៍ធនធានមនុស្ស និងការគ្រប់គ្រង។ លើកទឹកចិត្តឱ្យមានការបណ្តុះបណ្តាលស្ត្រីអំពីពាណិជ្ជកម្មតាមវគ្គរៀនសូត្រ និងសិក្ខាសាលា។

៥. ច្បាប់ការងារត្រូវតែការពារស្ត្រីទាំងឡាយ ដែលធ្វើការក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដូចជាអ្នកបម្រើតាមផ្ទះ (ដែលស្ត្រីវ័យក្មេងជាច្រើនកំពុងធ្វើការក្នុងវិស័យនេះ) ដើម្បីធានាកុំឱ្យពួកគេក្លាយជាជនរងគ្រោះពីការកេងប្រវ័ញ្ច ស្ថានភាពការងារដ៏លំបាក ឬការរំលោភជាដើម។

៦. ផ្តល់ឯកសារបច្ចេកទេស និងធនធានផលិតកម្មផ្សេងៗដល់កសិករដែលមានដីតូច ជាពិសេសកសិករជាស្ត្រីភេទ ដើម្បីជួយបង្កើនផលិតភាពកសិកម្ម។

៧. រៀបចំឱ្យមានប្រព័ន្ធផ្សាយព័ត៌មានពាក់ព័ន្ធការងារដើម្បីកាត់បន្ថយហានីភ័យ និងការចំណាយក្នុងពេលរកការងារធ្វើ និងដើម្បីជួយស្ត្រីក្នុងការសម្រេចចិត្តពាក់ព័ន្ធនឹងការងារឱ្យបានសមរម្យ។

៨. រៀបចំកម្មវិធីដើម្បីបង្កើនឱកាសការងារ ដូចជាកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ការគាំទ្រដល់ការងារធ្វើសម្រាប់ខ្លួនឯង និងជម្រុញឱ្យមានចលនាទៅមុខ (ឧទាហរណ៍ ការតាំងទីលំនៅការងារសំណង់ និងការកសាងភូមិថ្មីជាដើម)។

៩. ចាត់វិធានការមួយចំនួន ចំពោះពលករចំណាកស្រុកដែលធ្វើការនៅក្រៅប្រទេស ដូចជាការធានាឱ្យមានប្រព័ន្ធផ្ទេរ និងត្រឡប់មកវិញក្នុងតំបន់ និងពង្រឹងទំនាក់ទំនងជិតស្និទ្ធជាមួយក្រសួងនានា ដែលពាក់ព័ន្ធនឹងការងារចំណាកស្រុក និងជួញដូរមនុស្សនៅបរទេស។

១០. ធានាឱ្យប្រជាពលរដ្ឋកាន់តែច្រើនឡើង ជាពិសេសស្ត្រីក្រីក្រទទួលបានផលប្រយោជន៍ពីសេវាកម្មឥណទានខ្នាតតូចរបស់រដ្ឋាភិបាល ដើម្បីខ្ចីថវិការហូតដល់ ១.០០០ដុល្លារ ដោយមិនចាំបាច់ស្នើសុំឱ្យដាក់បញ្ចាំទ្រព្យសម្បត្តិអ្វីមួយ។

១១. រៀបចំគោលនយោបាយ ដែលលើកទឹកចិត្តស្ត្រី ជាពិសេសស្ត្រីក្រីក្រ ក្នុងការបង្កើតមុខរបរព្រមទាំងអាចបន្តការងារនេះតទៅមុខបាន ឧទាហរណ៍ គោលការណ៍ចុះបញ្ជីពាណិជ្ជកម្មងាយៗ ព្រមទាំងសម្រួលការបង់ពន្ធមិនឱ្យសាំញ៉ាំជាដើម។

១២. ផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិ ស្តីពីកិច្ចការពារសិទ្ធិរបស់ពលករចំណាកស្រុកសមាជិក និងក្រុមគ្រួសាររបស់អ្នកទាំងអស់នោះ។

## ជំពូក៦. អំពើហិង្សាទាក់ទងនឹងយេនឌ័រ: ហិង្សាក្នុងគ្រួសារ

### ១. ស្ថានភាព

ចំពោះពលរដ្ឋកម្ពុជាជាច្រើន ផ្ទះសម្បែងនៅតែជាកន្លែងដែលត្រួតត្រាដោយគួរឱ្យព្រួយបារម្ភខ្លាំង។ អ្វីដែលស្ត្រីទាំងនេះភ័យខ្លាចជាទីបំផុត គឺពុំមែនការឃាយីរខានពីសំណាក់មនុស្សចម្លែកទេ គឺភាពកាចសាហាវប្រចាំថ្ងៃដែលប្រព្រឹត្តដោយសាច់ញាតិមិត្តភ័ក្តិ និងមនុស្សជាទីស្រឡាញ់ទៅវិញ។ ការរំលោភបំពាននៅតាមផ្ទះសម្បែង គឺជាទម្រង់នៃអំពើហិង្សាមួយដែលកើតឡើងជាទូទៅបំផុតមកលើស្ត្រីភេទ ព្រមទាំងជាមូលហេតុចម្បងដែលនាំឱ្យមានរបួសស្នាមដល់ស្ត្រីស្ថិតក្នុងអាយុមានកូន។ ទោះជាមានបញ្ហាបែបនេះកើតឡើងច្រើនក៏ដោយ ក៏ការផ្សព្វផ្សាយអំពីបញ្ហានេះនៅតាមប្រព័ន្ធផ្សាយព័ត៌មាននានានៅមានកម្រិតទាបនៅឡើយ ដោយគេគិតថា បញ្ហាដែលកើតឡើងក្នុងរង្វង់ក្រុមគ្រួសារ ទោះបីជាធ្ងន់ធ្ងរយ៉ាងណាក៏ដោយក៏គេនៅតែគិតថាជារឿងផ្ទៃក្នុងក្រុមគ្រួសារប៉ុណ្ណោះ។

ដោយសារអំពើហិង្សាក្នុងគ្រួសារ ត្រូវបានគេចាត់ទុកថាជាបញ្ហាផ្ទៃក្នុងរបស់ក្រុមគ្រួសារ ដូច្នេះបញ្ហានេះមើលទៅហាក់ដូចជាមានការពាក់ព័ន្ធតិចតួចនៅក្នុងយុត្តិធម៌សង្គម និងសិទ្ធិមនុស្ស។ វាជាការផ្ទុយគ្នាស្រឡះដោយការរំលោភលើរាងកាយនៅក្រៅផ្ទះត្រូវបានចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ និងយល់ថាជាអំពើអាក្រក់ ប៉ុន្តែមិនគិតដូចគ្នាទេ នៅពេលដែលអំពើហិង្សាកើតឡើងនៅក្នុងរង្វង់គ្រួសារ សូម្បីតែមានច្បាប់ដែលចែង និងថ្កោលទោសអំពីបញ្ហានេះចំៗហើយក៏ដោយ។ តាមមើលទៅឃើញថា មានកត្តាជាច្រើនដែលរារាំងដល់ស្ត្រីមិនឱ្យរាយការណ៍អំពីបញ្ហាអំពើហិង្សាក្នុងគ្រួសារនេះ ដូចជាការទទួលស្គាល់របស់សហគមន៍ ការភ័យខ្លាចអាប់ឱនកិត្តិយស ការមិនទទួលស្គាល់ពីសង្គម ភាពឯកកោរបស់ជនរងគ្រោះ ព្រមទាំងការមិនបានយល់ពីច្បាប់ក្នុងការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារទេ។

យោងតាមការសិក្សាភាគច្រើននៅកម្ពុជា ចាប់តាំងពីទសវត្សមុនមកបានឆ្លុះបញ្ចាំងឱ្យឃើញថា ស្ត្រី ១នាក់ ក្នុងចំណោម ៥នាក់ ធ្លាប់បានទទួលរងគ្រោះពីសំណាក់អំពីហិង្សាក្នុងគ្រួសារក្នុងទម្រង់ណាមួយ (រួមទាំងអំពើហិង្សាផ្លូវភេទ)។ ទោះជាកើតឡើងច្រើនដល់កម្រិតនេះក៏ដោយ ក៏គេជឿជាក់ថាបញ្ហាអំពើហិង្សានេះនៅតែបានរាយការណ៍តិចតួចនៅឡើយ។ ការសិក្សាមួយរបស់ការស្រាវជ្រាវខាងសុខភាព និងប្រជាសាស្ត្រ (CDHS) បានឱ្យដឹងថាស្ត្រី ២២% ធ្លាប់រងគ្រោះពីការរំលោភលើរាងកាយ រំលោភលើផ្លូវភេទ និងផ្លូវចិត្តពីសំណាក់ស្វាមីរបស់ស្ត្រីទាំងអស់នោះ។ ស្ត្រី១នាក់ក្នុងចំណោមស្ត្រី ១០នាក់ ធ្លាប់ទទួលរងការរំលោភបំពានលើរាងកាយពិតៗតែម្តងពីសំណាក់ដៃគូក្នុងរយៈពេល១២ខែនៃការសិក្សានោះ។

តាមការស្រាវជ្រាវរកមូលហេតុនៃអំពើហិង្សាក្នុងគ្រួសារនៅកម្ពុជា បានបង្ហាញឱ្យឃើញថាបុរសជាច្រើនមានអារម្មណ៍ថា ត្រូវការអំណាចដើម្បីត្រួតត្រាលើភរិយារបស់បុរសទាំងនោះ ដាក់កម្រិតដល់ឥរិយាបទអាកប្បកិរិយា និងសកម្មភាពមួយចំនួន។ ស្ត្រីប្រមាណ ៨៥% ដែលបាននិយាយថាធ្លាប់រងគ្រោះពីសំណាក់អំពើហិង្សាក្នុងគ្រួសារ បាននិយាយថា ស្វាមីរបស់អ្នកនោះគឺ "ដាក់អំណាចត្រួតត្រាខ្លាំងណាស់"។ អំពើហិង្សាក្នុងគ្រួសារអាចប៉ះពាល់ដល់កុមារៈ ក្នុងការសិក្សាមួយរបស់ក្រសួងកិច្ចការនារីមាន ២៥% នៃបុរស និង ២០% នៃស្ត្រីបាននិយាយថាសុទ្ធតែធ្លាប់បានឃើញ ឪពុកវាយម្តាយដោយផ្ទាល់ភ្នែក។

## ១.១ និយមន័យ និងប្រភេទនៃអំពើហិង្សាក្នុងគ្រួសារ

អំពើហិង្សាក្នុងគ្រួសារ គឺជាការប្រើប្រាស់កម្លាំង ទាំងផ្លូវចិត្ត រាងកាយ ផ្លូវភេទ ឬសេដ្ឋកិច្ចដោយបុគ្គលម្នាក់ (ឬក្រុមមនុស្ស) ដើម្បីត្រួតត្រាលើមនុស្សដទៃរស់នៅក្នុងផ្ទះជាមួយគ្នា[44]។ ប្រភេទអំពើហិង្សាក្នុងគ្រួសាររួមមាន អំពើទាំងឡាយដែលបណ្តាលឱ្យមានការឈឺចាប់ដល់ខ្លួនប្រាណ ខូចខាតដល់រាងកាយ ឬបណ្តាលឱ្យស្លាប់ដូចជា ការទះ វាយ ទាត់ធាក់ ដាល់ ឬអំពើផ្សេងៗទៀតដែលនាំឱ្យគ្រោះថ្នាក់ដល់សុខភាព។ ទម្រង់អំពើហិង្សាទាក់ទងយេនឌ័រដែលកើតមានជាទូទៅគឺៈ

***<u>ហិង្សាផ្លូវភេទៈ</u>*** អំពើផ្លូវភេទ គឺការប៉ុនប៉ងដើម្បីទទួលបានការរួមភេទ ការនិយាយ ឬប្រាប់ជាមុនអំពីផ្លូវភេទ ដែលភាគីមួយទៀតមិនទទួលយក ឬអំពើបង្ខិតបង្ខំផ្លូវភេទលើមនុស្សណាម្នាក់ដោយផ្ទាល់។ ឧទាហរណ៍ ស្វាមីបង្ខំភរិយាឱ្យរួមភេទជាមួយ។

**<u>អំពើហិង្សាផ្លូវចិត្តៈ</u>** អំពើ ឬពាក្យសម្តីដែលបណ្តាលឱ្យមានសម្ពាធលើផ្លូវចិត្ត ឬដំណើរនៃការដឹងរបស់អ្នកណាម្នាក់ជាពិសេសលើស្ត្រីដូចជា ការគំរាមកំហែង គំរាមទារលុយ ជេរប្រមាថ បរិហារកេរ្តិ៍ ផ្តាច់ទំនាក់ទំនងពីសាច់ញាតិ ឬសកម្មភាពបង្ខំប្រឆាំងនឹងឆន្ទៈរបស់បុគ្គលណាម្នាក់ ឧទាហរណ៍ ការមើលវីដេអូអាសអាភាសជាដើម។

អំពើ ឬពាក្យសំដីដែលបណ្តាលឱ្យមានការភ័យខ្លាចដោយការបំភិតបំភ័យ ដូចជាការគំរាមកំហែង ជេរប្រមាថ អំពើកាចសាហាវ និងបង្ខំឱ្យផ្តាច់ការទាក់ទងជាមួយមិត្តភ័ក្ត និងក្រុមគ្រួសារជាដើម។

**<u>អំពើហិង្សាផ្នែកសេដ្ឋកិច្ចៈ</u>** អំពើទាំងឡាយណាដែលជាការដាក់កម្រិត ឬដកហូតសិទ្ធិទ្រព្យសម្បត្តិ ការប្រើប្រាស់ ការគ្រប់គ្រងក្នុងក្រុមគ្រួសារ ម្ហូបអាហារ សម្លៀកបំពាក់ ចំណូល ឬធនធានរបស់ជនណាម្នាក់ អាចរួមទាំងការបំផ្លាញ ឬដាក់កម្រិតមិនឱ្យមានសិទ្ធិលើទ្រព្យសម្បត្តិ ឬធនធានសេដ្ឋកិច្ចដោយបង្ខំ។

## ១.២ ច្បាប់ និងគោលនយោបាយ

តាំងពី៣០ឆ្នាំ កន្លងមក គេបានសង្កេតឃើញថា កម្ពុជាមានការអភិវឌ្ឍន៍យ៉ាងខ្លាំងក្នុងវិស័យសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ សុខភាព ការអប់រំ និងទេសចរជាដើម។ ការគោរពសិទ្ធិមនុស្សក៏មានការល្អប្រសើរជាងមុនក្នុងផ្នែកមួយចំនួន ដោយមានការជួយជ្រោមជ្រែងពីសំណាក់អង្គការមិនមែនរដ្ឋាភិបាល។ បែបនេះក្តីក៏នៅតែមានគម្លាតយ៉ាងធំនៅឡើយ ជាពិសេសផ្នែកសិទ្ធិស្ត្រី និងអំពើហិង្សាក្នុងគ្រួសារ។

កម្ពុជាបានអនុម័តច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារនៅឆ្នាំ២០០៥ ក្នុងគោលបំណងដើម្បីទប់ទល់ជាមួយអំពើហិង្សាក្នុងគ្រួសារ ការពារជនរងគ្រោះ និងពង្រឹងក្រុមគ្រួសារ។ ខ្លឹមសាររបស់ច្បាប់នឹងអាចមានជោគជ័យ ក៏ប៉ុន្តែការអនុវត្តន៍នៅទន់ខ្សោយនៅឡើយ។

---

[44] *វក្យាស័ព្ទយេនឌ័រមកពីក្រសួងកិច្ចការនារី ។*

ឧបសគ្គមួយដ៏ធំមួយគឺ "ច្បាប់ស្រី"។ ច្បាប់ស្រី គឺជាក្រមក្រៅផ្លូវការដែលដាក់កម្រិតឱ្យស្ត្រីធ្វើអាកប្បកិរិយាឱ្យបានសមរម្យជានារី និងស្ត្រី "គួរឱ្យគោរព"។ ការនិយាយខ្ចរខ្ចាយអំពីអំពើហិង្សាក្នុងគ្រួសារប្រៀបដូចជាការបង្ហាញនូវភាពដែលមិនស្អាតស្អំរបស់ក្រុមគ្រួសារទៅវិញ "ខោអាវមិនស្អាត" ដែលជាអំពើផ្ទុយទៅនឹងក្រិត្យក្រមនេះ។ ការអនុវត្តន៍ច្បាប់ត្រូវបានរារាំងដោយបញ្ហាកង្វះឯកសារ និងហេដ្ឋារចនាសម្ព័ន្ធ ដូចជា ជម្រក មេធាវី មានសមត្ថភាពប្រព័ន្ធជួយ ផ្នែកផ្លូវចិត្តដល់ជនរងគ្រោះ ចៅក្រមដែលឆាប់យល់អំពីបញ្ហា និងកម្មវិធីអប់រំជាដើម។ លើសពីនេះទៅទៀត ស្ត្រីកម្ពុជាភាគច្រើនពុំបានដឹងអំពីច្បាប់នេះទេ អាស្រ័យពុំទាន់មានការផ្សព្វផ្សាយទូលំទូលាយ និងអត្រាអនក្ខរភាពខ្ពស់ក្នុងចំណោមស្ត្រីនៅតាមជនបទជាដើម។ បញ្ហាអំពើហិង្សាក្នុងគ្រួសារត្រូវបានយល់ដឹងតិចតួចជាទីបំផុត ដោយខ្លះយល់ថា អំពើហិង្សា គឺជាវិធីសមរម្យមួយដើម្បីដោះស្រាយ និងប្រឈមជាមួយបញ្ហា។ បរិយាកាសខ្វះសីលធម៌ និងការបណ្តោយមិនរវល់បាននាំមកនូវកង្វះការឈឺចាប់ជាមួយនឹងស្ត្រីរងគ្រោះ។ សង្គមកម្ពុជាកំណត់ថាស្ត្រីត្រូវតែចុះចូលជាមួយបុរស ដែលជាអ្នកត្រូវត្រួតត្រាលើស្ត្រីសូម្បីតែការត្រួតត្រាដោយប្រើហិង្សាក៏ដោយ។



## ១.៣ ស្ត្រីជនជាតិដើមភាគតិច និងស្ត្រីពិការ

យោងតាមរបាយការណ៍របស់ PSF-ONGD[៨៥] (២០០៨) បានបង្ហាញឱ្យឃើញថា ស្ត្រីជនជាតិដើមភាគតិចចំនួន ១៥% ដែលបានសម្ភាសន៍ ធ្លាប់ទទួលរងគ្រោះពីសំណាក់អំពើហិង្សាក្នុងគ្រួសារ។ ប្រហែល ២៥% នៃស្ត្រីទាំងនេះបានយល់ថា អំពើហិង្សាក្នុងគ្រួសារ គឺជាអំពើត្រឹមត្រូវ (នៅទូទាំងប្រទេស ៥៥% CDH[៨៦] ឆ្នាំ ២០០៥) និង៦៧% មិនស្វែងរកជំនួយពីខាងក្រៅទេ (នៅទូទាំងប្រទេស ៨១% GTZ-PWR[៨៧] និងក្រសួងកិច្ចការនារី ឆ្នាំ២០០៩)។ ករណីអំពើហិង្សាក្នុងគ្រួសារភាគច្រើន គឺពាក់ព័ន្ធជាមួយការប្រើប្រាស់គ្រឿងស្រវឹង (៥៨%)។ ស្ត្រីមួយចំនួនបានត្អូញត្អែរថា "ត្រូវបានបង្ខំឱ្យរួមភេទជាមួយស្វាមី សូម្បីតែពេលមានជម្ងឺ ឬទើបតែសម្រាលកូនហើយក៏ដោយ"។

ប្រជាពលរដ្ឋនៅតាមភូមិជាង ៩០% បុរស (៩៤%) និងស្ត្រី (៩៥%) បាននិយាយថា សុទ្ធតែធ្លាប់បានដឹងអំពីហិង្សាក្នុងគ្រួសារក្នុងភូមិរបស់អ្នកទាំងនោះ។ ការយល់ដឹងរបស់មន្ត្រីអនុវត្តច្បាប់អំពីបញ្ហាអំពើហិង្សា

[៨៥] Psicólgos Sin Fronteras ONGD

[៨៦] ការសិក្សាអំពីសុខភាព និងប្រជាសាស្ត្រកម្ពុជា ។

[៨៧] Gesellschaft Fur Technische Zusammenarbeit (ក្រសួងសហព័ន្ធអាល្លឺម៉ង់)- ការលើកស្ទួយសិទ្ធិស្ត្រី ។

ក្នុងគ្រួសារនៅក្នុងភូមិ គឺខ្ពស់ជាងការយល់ដឹងរបស់ប្រជាពលរដ្ឋនៅក្នុងភូមិ តាមមើលទៅប្រហែលជាមកពីតួនាទីនៃការដឹកនាំ[៤៨]។

មន្ត្រីអនុវត្តច្បាប់ និងអ្នកភូមិបានបញ្ជាក់ថា ការរំលោភលើរាងកាយ និងពាក្យសម្តី គឺជាករណីកើតឡើងទូទៅជាងគេបំផុត។ អ្នកភូមិភាគច្រើនបានលើកឡើងអំពីការរំលោភដោយពាក្យសម្តី (៩៥%) ប៉ុន្តែការរំលោភលើរាងកាយក៏មិនទាបជាងឆ្ងាយដែរ (៧៥%) ។ មន្ត្រីអនុវត្តច្បាប់មានការយល់ដឹងអំពីប្រភេទនានានៃអំពើហិង្សាក្នុងគ្រួសារច្រើនជាងអ្នកភូមិ[៤៩]។ ការសិក្សាថ្នាក់មូលដ្ឋានក៏បានលាតត្រដាងឱ្យឃើញផងដែរថា ដំណោះស្រាយទូទៅបំផុតចំពោះបញ្ហាអំពើហិង្សាក្នុងគ្រួសារ គឺការអន្តរគមន៍ក្រៅផ្លូវការ ឬតាមប្រពៃណីពីសំណាក់អ្នកជិតខាង ឬមេភូមិ។ អ្នកភូមិជាអ្នកដើរតួនាទីយ៉ាងសំខាន់ក្នុងកិច្ចអន្តរាគមន៍ពេលមានអំពើហិង្សាក្នុងគ្រួសារកើតឡើង។ មន្ត្រីអនុវត្តច្បាប់ស្ទើរតែទាំងអស់បាននិយាយថា អ្នកជិតខាង ឬអ្នកភូមិផ្សេងៗទៀតនឹងធ្វើអន្តរាគមន៍ក្នុងករណីមានបញ្ហាបែបនេះកើតឡើង។ ៦២%នៃអ្នកភូមិ និង៨៥% នៃមន្ត្រីអនុវត្តច្បាប់បានលើកឡើងថា អ្នកជិតខាងតែងតែបានព្យាយាមបញ្ឈប់អំពើហិង្សា។ មេភូមិក៏ហាក់ដូចជាដើរតួនាទីយ៉ាងសំខាន់ដែរ។ ៨២% នៃមន្ត្រីអនុវត្តច្បាប់ និង៦៨%អ្នកភូមិបាននិយាយថាកាលពីមុនមេភូមិបានធ្វើអន្តរាគមន៍ក្នុងករណីអំពើហិង្សាក្នុងគ្រួសារ[៥០]។

មន្ត្រីអនុវត្តច្បាប់ស្ទើរតែទាំងអស់ (៩៧%) បាននិយាយថា អ្នកទាំងនោះនឹងចាត់វិធានការអន្តរាគមន៍ក្នុងករណីអំពើហិង្សាក្នុងគ្រួសារ ប៉ុន្តែអ្នកភូមិមានត្រឹមតែ៧២% ប៉ុណ្ណោះដែលហ៊ានអន្តរាគមន៍បែបនេះ។ កិច្ចអន្តរាគមន៍ទូទៅបំផុតដែលបានលើកឡើង គឺទៅដល់ផ្ទះជនរងគ្រោះតែម្តងហើយឃាត់ជនដែលប្រព្រឹត្តបទល្មើស (ស្ត្រី ៧១% បុរស ៤៨% និងមន្ត្រីអនុវត្តច្បាប់ ៦៩%)[៥១]។

កិច្ចអន្តរាគមន៍ ៣ ប្រភេទទៀតត្រូវកត់សម្គាល់ពីសំណាក់អ្នកចូលរួមសម្ភាសន៍គឺ: ១- ការពិគ្រោះយោបល់ ២- រកជំនួយផ្នែកវេជ្ជសាស្ត្រ ៣- រកជំនួយផ្នែកច្បាប់។ ចំពោះស្ត្រីពិការពុំមានទិន្នន័យគួរឱ្យជឿជាក់បានទេអំពីបញ្ហានេះ ដូច្នេះយើងគ្រាន់តែសន្និដ្ឋានអំពីស្ថានភាពអំពើហិង្សាក្នុងគ្រួសាររបស់អ្នកទាំងនោះ។ ប៉ុន្តែបើពិនិត្យមើលត្រឹមតែភាពលាក់កំបាំង និងស្ងប់ស្ងៀមរបស់អ្នកទាំងនោះ គឺជាក្រុមមួយងាយរងគ្រោះជាទីបំផុត។

### ១.៤ ការផ្សព្វផ្សាយ និងការអនុវត្តន៍ច្បាប់

ទោះបីជារដ្ឋាភិបាល និងសង្គមស៊ីវិលបានចាត់វិធានការជាជំហានៗដើម្បីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារយ៉ាងណាក៏ដោយ ក៏បញ្ហានៅតែកើតមានដោយសារតែ:

[៤៨] UNDP (ឆ្នាំ២០០៩). គម្រោងសន្ទនាជាមួយសហគមន៍៖ របាយការណ៍សិក្សាស្រាវជ្រាវថ្នាក់មូលដ្ឋាន គោលដៅពណ៌បៃតង ភ្នំពេញ។

[៤៩] Ibid. ឯកសារដដែល ដូចខាងលើ ។

[៥០] Ibid.ឯកសារដដែល ដូចខាងលើ ។

[៥១] Ibid ឯកសារដដែល ដូចខាងលើ ។

**បញ្ហាផ្សព្វផ្សាយច្បាប់:** ជាទូទៅនៅតាមតំបន់ជនបទប្រជាពលរដ្ឋមិនសូវបានដឹងអំពីច្បាប់ទេ។ មន្ត្រីអនុវត្តច្បាប់មួយចំនួននៅតាមជនបទ មិនទាន់បានទទួលច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារនៅឡើយដែរ ហើយមនុស្សជាច្រើនពុំបានដឹងអំពីច្បាប់នេះទេ ដោយសារតែការផ្សព្វផ្សាយនៅមានកម្រិតនៅឡើយ។

**បញ្ហាអនុវត្តច្បាប់:** អាជ្ញាធរមូលដ្ឋានមួយចំនួននៅតែបន្តធ្វើការសម្រុះសម្រួលដដែលក្នុងករណីអំពើហិង្សាក្នុងគ្រួសារ ដើម្បីជៀសវាងការលែងលះគ្នា។ អាជ្ញាធរមួយចំនួននេះ ហាក់ដូចជាពុំទាន់យល់បានទេថា យោងតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារមានតែតុលាការប៉ុណ្ណោះទេ ដែលមានអំណាចធ្វើការសម្រុះសម្រួលបែបនេះបាន។ ច្បាប់នេះ មិនបានផ្តល់អំណាចឱ្យអាជ្ញាធរមូលដ្ឋានធ្វើការសម្រុះសម្រួលក្នុងបញ្ហាទំនាស់ទេ ។ ក្រុមអង្គការសង្គមស៊ីវិលក៍បាននិយាយថា ករណីអំពើហិង្សាក្នុងគ្រួសារជាច្រើនមិនត្រូវបានបញ្ជូនទៅតុលាការដើម្បីផ្តន្ទាទោសទេ ដែលជាទង្វើផ្ទុយទៅនឹងមាត្រា១៥ នៃច្បាប់អាពាហ៍ពិពាហ៍។ អាជ្ញាធរច្រើនតែបង្ខំឱ្យគូភាគីស្វាមីភរិយាទាំងពីរនាក់ធ្វើការសម្រុះសម្រួលគ្នា ដោយពុំគិតពីភាពធ្ងន់ធ្ងរនៃករណីឡើយ។

**ការផ្សះផ្សារ:** អាជ្ញាធរនៅតែបន្តបង្ខំស្ត្រីឱ្យចុះចាញ់ ចំពោះមនុស្សដែលរំលោភបំពានលើស្ត្រី ដោយអាជ្ញាធរយល់ថា បុរស គឺជាអ្នកដឹកនាំក្នុងក្រុមគ្រួសារ ហើយជាទូទៅប្រាប់ជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារថា កុំធ្វើឱ្យស្វាមីខឹង។ អាជ្ញាធរទាំងនោះក៏អាចផ្តល់នូវដំបូន្មានមិនសមរម្យខ្លះដែរ ដូចជាការប្រាប់ស្ត្រីថា នាងគួរតែ "សើចញញឹមឱ្យបានច្រើនជាងនេះដាក់ស្វាមី ព្រមទាំងនិយាយដោយសម្តីទន់ភ្លន់ និងផ្អែមល្ហែមទៅកាន់ស្វាមី"។ គោលដៅក្នុងការ "ជួយ" នេះគឺជាការលើកទឹកចិត្តឱ្យជនរងគ្រោះ ដែលនៅរស់រានមានជីវិតពីអំពើហិង្សាក្នុងគ្រួសារ បន្តរស់នៅជាមួយជនដែលរំលោភបំពានលើនាងតទៅទៀត។ ឥរិយាបទបែបនេះជាការលេចចេញពីឥទ្ធិពលនៃប្រពៃណី និងទំនៀមទម្លាប់ ប៉ុន្តែនាំឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរចំពោះជនដែលនៅរស់រានមានជីវិតពីអំពើហិង្សាក្នុងគ្រួសារ ព្រមទាំងកូនចៅរបស់អ្នកទាំងនោះផងដែរ។

**តំណាងផ្លូវច្បាប់ក្នុងករណីអំពើហិង្សាក្នុងគ្រួសារ:** ក្រុមអ្នកច្បាប់ការពារសិទ្ធិមនុស្សកម្ពុជា (CDP) ប្រមូលព័ត៌មានបានយ៉ាងច្រើនអំពីករណីអំពើហិង្សាក្នុងគ្រួសារ។ ក្នុងចំណោមករណីចំនួន១០០ គ្មានជនរងគ្រោះណាម្នាក់បានដាក់បណ្តឹងប្តឹងឱ្យមានការចោទប្រកាន់ស្វាមីរបស់អ្នកទាំងនោះទេ ទោះបីជាដឹងថាអ្នកទាំងនោះមានសិទ្ធិធ្វើបែបនេះក៏ដោយ។ នីតិវិធីព្រហ្មទណ្ឌត្រូវបានអនុវត្តតែពេលណា ដែលជនរងគ្រោះបាត់បង់អាយុជីវិតប៉ុណ្ណោះ។

**ការរំលោភផ្លូវភេទ:** ជនរងគ្រោះដោយអំពើរំលោភផ្លូវភេទភាគច្រើនទទួលអារម្មណ៍អាម៉ាស់យ៉ាងខ្លាំង។ ជនរងគ្រោះទាំងនោះមិនហ៊ាននិយាយអំពីរឿងបែបនេះទេ។ ស្ត្រីដែលជាជនរងគ្រោះនេះ ត្រូវបានរើសអើងដោយប្រយោលតាមរយៈការមិនផ្តល់ឱកាសឱ្យបានជួបមន្ត្រីដែលជាស្ត្រី ដែលអាចមានការយល់អារម្មណ៍របស់ជនរងគ្រោះបានច្រើន។ អង្គការសង្គមស៊ីវិលជាច្រើនបានធ្វើការបណ្តុះបណ្តាលដល់អាជ្ញាធរក្នុងការដោះស្រាយបញ្ហារំលោភផ្លូវភេទនេះ ប៉ុន្តែកន្លងមកឥទ្ធិពលនៃការបណ្តុះបណ្តាលបានតិចតួចទៅវិញ។

## ២. មូលហេតុចំបងដើម្បីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនៅកម្ពុជា

អំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងរង្វង់ក្រុមគ្រួសារ ច្រើនតែបន្សល់ទុកតកូនចៅជំនាន់ក្រោយៗទៀត។ កូនៗរបស់ជនណា ដែលធ្លាប់រំលោភបំពានលើរាងកាយដោយហិង្សា ច្រើនតែធ្លាក់ចូលទៅក្នុងអំពើហិង្សាក្នុងគ្រួសារដែរ ដោយខ្លះក្លាយជាអ្នកប្រព្រឹត្ត និងខ្លះទៀតក្លាយជាជនរងគ្រោះជាដើម។ តាមការសិក្សាក៏បានបង្ហាញឱ្យឃើញផងដែរថា កូនៗដែលកើតក្នុងគ្រួសារដែលមានអំពើហិង្សា ច្រើនតែប្រព្រឹត្តអំពើហិង្សាលើកូនៗរបស់អ្នកទាំងនោះ ព្រមទាំងប្រព្រឹត្តអំពើហិង្សាខាងក្រៅផ្ទះផងដែរ។ វដ្តនៃអំពើដ៏កាចសាហាវនេះត្រូវតែលុបបំបាត់ចោលឱ្យអស់។

គេបានរកឃើញថា មានភាពស្របគ្នាយ៉ាងខ្លាំងរវាងអាកប្បកិរិយាខាងក្នុង និងក្រៅផ្ទះ។ ប្រសិនបើប្រព័ន្ធគាបសង្កត់លើស្ត្រី និងកុមារីមានលក្ខណៈអនុគ្រោះនៅក្នុងក្រុមគ្រួសារ នោះបញ្ហានេះ ក៏ត្រូវបានអនុគ្រោះនៅក្នុងសង្គមទាំងមូលដែរ ។ ការសិក្សាលើបញ្ហានេះបានបង្ហាញដដែលៗថា អំពើហិង្សាក្នុងគ្រួសារជាកត្តាសំខាន់នៃបញ្ហាសង្គម ដូចជានាំឱ្យកូនៗក្លាយជាកុមារអនាថា កើតមានពលកម្មកុមារ និងពេស្យាចារកុមារជាដើម។




នេះក៏ជាបញ្ហាសុខភាពសាធារណៈដែរ។ អំពើហិង្សាបាននាំមកនូវភាពទន់ខ្សោយជូនកាលអស់មួយជីវិត ប៉ះពាល់លើរាងកាយ ផ្លូវចិត្ត ជីវភាពសង្គមរបស់ស្ត្រី និងកុមារី។

អំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងគ្រួសារប៉ះពាល់ដល់ការអភិវឌ្ឍន៍ និងផលិតភាពនៃគ្រប់សង្គមទាំងអស់។ ជាទូទៅបច្ចុប្បន្ននេះ ស្ត្រីត្រូវបានចាត់ទុកជាសរសរទ្រូងនៃការអភិវឌ្ឍន៍ប្រកបដោយនិរន្តភាព។ កិច្ចការពារសិទ្ធិរបស់អ្នកទាំងនោះ និងការលើកកំពស់ស្ថានភាព គឺជាការងារមានសារៈសំខាន់បំផុតក្នុងដំណើរការផ្សេងៗ តាំងពីការធ្វើផែនការគ្រួសាររហូតដល់ការផលិតស្បៀងអាហារ។ បំណងប្រាថ្នា និងសមិទ្ធិផលរបស់ស្ត្រីត្រូវរងផលប៉ះពាល់អវិជ្ជមានដោយអំពើហិង្សា និងការគំរាមកំហែងដោយហិង្សានៅក្នុងចិត្ត។ ឥទ្ធិពលអវិជ្ជមាន នៃអំពើហិង្សាអាចចាក់ឬសគល់យ៉ាងជ្រៅតាំងពីវ័យកុមារ ពេលដែលរូបរាងនៃអំពើហិង្សាចាប់ផ្តើមរំខានដល់ការស្រមៃរបស់កុមារអំពីអ្វី ដែលអ្នកទាំងនោះអាចធ្វើបាន និងពីអ្វីដែលចង់ធ្វើនៅពេលធំឡើង។ នេះគឺជាមេរៀនដែលអ្នកទាំងនោះមិនអាចបំភ្លេចបានឡើយ។

## ៣. ប្រស្នា

**ការប្រកាន់ឥរិយាបទៈ** ក្នុងគ្រប់សង្គមទាំងអស់ ភាពក្រីក្រ ការរើសអើង ការបំភ្លេចចោល និងអស្ថេរភាពសង្គម គឺជាកត្តាដែលបណ្តាលឱ្យមានអំពើហិង្សាលើស្ត្រី។ ប៉ុន្តែសត្រូវដ៏យូរអង្វែងនៃសន្តិសុខ និង

សេចក្តីថ្លៃថ្នូររបស់ស្ត្រី គឺឥទ្ធិពលវប្បធម៌ដែលទុកឱ្យបុរសជាអ្នកត្រួតត្រា ហើយធ្វើអោយស្ត្រីនៅក្រោមអំណាច ។ ឥទ្ធិពលនេះ ច្រើនតែត្រូវបានបិទបាំងថាជា "ប្រពៃណី"។ ប៉ុន្តែអំពើហិង្សាគាបសង្កត់លើស្ត្រី និងកុមារីគ្មានអ្វីប្រែប្រួលសោះ។ នេះគឺជាឧបករណ៍អំណាច ដែលអាចមានការផ្លាស់ប្តូរដូចជាការប្រកាន់ពូជសាសន៍ដែរ។ ប៉ុន្តែដោយសារបញ្ហានេះពាក់ព័ន្ធនឹងឫសគល់វប្បធម៌ខ្លាំងពេក ដូច្នេះការខិតខំដើម្បីកែប្រែឥរិយាបទអវិជ្ជមានរបស់បុរសប្រព្រឹត្តចំពោះស្ត្រី តម្រូវឱ្យមានវិធានការមិនត្រឹមតែធ្វើតាមវិធីសាស្ត្រច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែត្រូវធ្វើតាមវិធានការអត់ធ្មត់ និងយុទ្ធសាស្ត្រដ៏ឈ្លាសវៃ អនុវត្តលើចំណុចប្រឈមជាច្រើន។

**អាជ្ញាធរ:** យោងតាមការសិក្សារបស់ DCA/CA នៅឆ្នាំ២០០៩ បានឱ្យដឹងថា អំពើពុករលួយ គឺជាឧបសគ្គចម្បងចំពោះកិច្ចអន្តរាគមន៍ករណីអំពើហិង្សាក្នុងគ្រួសារ។ អាជ្ញាធរ ដូចជាប្រធានភូមិ មេឃុំ និងនគរបាលមូលដ្ឋានជាដើម នៅតែគិតថាអំពើហិង្សាក្នុងគ្រួសារ គឺជាបទល្មើសតូចតាចដែលធ្វើឱ្យគេអនុវត្តច្បាប់មិនបានត្រឹមត្រូវ ព្រមទាំងធ្វើឱ្យស្ថានភាពបញ្ហានេះកាន់តែពិបាកខ្លាំងឡើងៗ។ ហើយអ្វីដែលកាន់តែពិបាកថែមទៀត គឺមន្ត្រីទាំងឡាយសុទ្ធតែធ្វើការពឹងផ្អែកទៅលើប្រាក់កម្រៃ។ ស្ត្រីជាច្រើនពុំមានលទ្ធភាព និងមិនចង់សូកអាជ្ញាធរ ដើម្បីឱ្យជួយដោះស្រាយបញ្ហារបស់អ្នកទាំងនោះទេ។ ហេតុនេះហើយទើបមានការរើសអើងចំពោះស្ត្រីក្រីក្រ ដែលអ្នកទាំងនោះតែងតែមិនសូវទទួលបានការជួយឱ្យទាន់ពេលវេលា និងមានប្រសិទ្ធិភាពពីសំណាក់អាជ្ញាធរមានសមត្ថកិច្ចឡើយ។

**ជនរងគ្រោះដែលជាស្ត្រី:** ភាគច្រើនតែងតែពឹងផ្អែកលើស្វាមីទាំងស្រុង បញ្ហានេះហើយអាចមានឥទ្ធិពលលើស្ត្រីក្នុងការជៀសវាងមិនហ៊ានប្រឈមមុខនឹងស្វាមីតាមផ្លូវច្បាប់ទេ។ ស្ត្រីក៏អាចខ្វះទំនុកចិត្តលើប្រសិទ្ធិភាពរបស់អាជ្ញាធរក្នុងការធ្វើអន្តរាគមន៍ផងដែរ ដោយសារអាជ្ញាធរច្រើនតែពឹងផ្អែកលើការផ្សះផ្សារខ្លាំងហួសហេតុពេក ដែលអាចនាំឱ្យអំពើហិង្សាក្នុងគ្រួសារកាន់តែធ្ងន់ធ្ងរជាងមុនទៅទៀត។ ទន្ទឹមនឹងនេះក៏មានស្ត្រីមួយចំនួនភ័យខ្លាចការសងសឹកពីសំណាក់ស្វាមីផងដែរ។

**មន្ត្រីកិច្ចការនារី:** មន្ទីរកិច្ចការនារីខេត្តត្រូវបានបង្កើតឡើងក្នុងខេត្ត-ក្រុងចំនួន២០ ហើយនៅក្នុងមន្ទីរនីមួយៗ រួមមានប្រធាន អនុប្រធាន និងប្រធានការិយាល័យមានពីពីរទៅបីនាក់ ដែលត្រូវបានជ្រើសរើសដោយអភិបាលខេត្ត។ មន្ត្រីកិច្ចការនារីមួយចំនួនត្រូវបានទទួលស្គាល់ដោយច្បាប់ថាជា "មន្ត្រីយុត្តិធម៌" ប៉ុន្តែមន្ត្រីជាច្រើននៅមិនទាន់បានធ្វើសម្បថចូលកាន់តំណែង ឬមិនទាន់បានទទួលការតែងតាំងស្របច្បាប់ដោយអនុក្រឹត្យនៅឡើយទេ។ រដ្ឋាភិបាលកំពុងប្រឹងប្រែងដើម្បីរក្សានូវតួនាទីនេះ ប៉ុន្តែមានខេត្តចំនួនប្រាំនៅមិនទាន់បានជ្រើសតាំងមន្ត្រីទាំងនោះនៅឡើយទេ ដូចជាខេត្តកោះកុង ព្រះសីហនុ មណ្ឌលគីរី ព្រះវិហារ និងឧត្តរមានជ័យជាដើម។ កន្លងមកការងាររៀបចំយន្តការ ដោយផ្លូវច្បាប់ដើម្បីការពារអំពើរំលោភនៅមិនទាន់ជឿនលឿននៅឡើយ។

**មេឃុំ ចៅសង្កាត់:** ច្បាប់បានតម្រូវឱ្យមេឃុំធ្វើអន្តរាគមន៍ក្នុងករណីអំពើហិង្សាក្នុងគ្រួសារ ហើយត្រូវតែចេញនូវសេចក្តីសម្រេចរដ្ឋបាលដើម្បីរក្សាសុវត្ថិភាពរបស់ជនរងគ្រោះ។ ប៉ុន្តែយោងតាមការសិក្សាស្រាវជ្រាវភាគច្រើនបានឱ្យដឹងថា មេឃុំមួយចំនួនតូចប៉ុណ្ណោះបានធ្វើអន្តរាគមន៍ក្នុងករណីអំពើហិង្សាក្នុងគ្រួសារនេះ។ ដោយមេឃុំភាគច្រើនបានយល់ថា មិនត្រូវចាត់វិធានការទេ ពីព្រោះមិនទាន់ទទួលបានប្រកាសពីរដ្ឋាភិបាលនៅឡើយ។ បញ្ហានេះ បានធ្វើឱ្យមានផលប៉ះពាល់ជាអវិជ្ជមានដល់ជំនឿជឿជាក់របស់ស្ត្រីចំពោះលទ្ធភាពរបស់អាជ្ញាធរក្នុងការធ្វើអន្តរាគមន៍ប្រកបដោយជោគជ័យ។

**សុវត្ថិភាព និងការភៀសខ្លួនៈ** ជនរងគ្រោះស្ត្រីត្រូវការកន្លែងភៀសខ្លួនមានសុវត្ថិភាពពេលរត់គេច ពីអំពើហិង្សាក្នុងគ្រួសារ។ បញ្ហានេះ ជាការលំបាកសម្រាប់អាជ្ញាធរមូលដ្ឋាន ដោយសារតែកង្វះខាតជម្រក មានសុវត្ថិភាព។

## ៤. អនុសាសន៍

សូមសំណូមពររដ្ឋាភិបាលសូមមេត្តាៈ

១) ផ្សព្វផ្សាយច្បាប់នានាដល់ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈទាំងអស់។

២) បង្កើនចំនួនស្ត្រីក្នុងតួនាទី ដែលត្រូវធ្វើការសម្រេចចិត្តនៅគ្រប់លំដាប់ថ្នាក់ទាំងអស់ក្នុងជួររដ្ឋាភិបាលដើម្បីឱ្យជនរគ្រោះ ដោយអំពើហិង្សាក្នុងគ្រួសារមានអារម្មណ៍កក់ក្ដៅជាងមុនក្នុងការស្វែងរកជំនួយ។

៣) ធ្វើការបណ្តុះបណ្តាលច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ ដែលពាក់ព័ន្ធដល់អាជ្ញាធរមានសមត្ថកិច្ចទូទាំងប្រទេស។

៤) ប្រឹងប្រែងបង្កើនចំនួនចៅក្រម មេធាវី និងមន្ត្រីនគរបាលស្ត្រីឱ្យបានកាន់តែច្រើនជាងមុន។

៥) ប្រឹងប្រែងបង្កើនបរិមាណជម្រកសុវត្ថិភាព និងសេវាសង្គមឱ្យបានច្រើនជាងមុន រួមទាំងការបណ្តុះបណ្តាល វិជ្ជាជីវៈ នៅពេលណាដែលចាំបាច់សម្រាប់ជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ។

៦) ស្នើឱ្យមានការបង្កើនចំនួនថវិកាជាតិ ដើម្បីអនុវត្តកម្មវិធីប្រឆាំងអំពើហិង្សាក្នុងគ្រួសារឱ្យបានសមរម្យ។

៧) ជម្រុញឱ្យមានសហគ្រាស ដែលកាន់កាប់ដោយស្ត្រីដើម្បីឱ្យស្ត្រីកាន់តែមានឯករាជ្យភាពខាងហិរញ្ញវត្ថុ។

៨) ផ្តល់មូលនិធិឱ្យបានច្រើនថែមទៀតដល់ជំនួយផ្នែកច្បាប់ដល់ជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ និងកម្មវិធីអប់រំស្ត្រីអំពីសិទ្ធិរបស់អ្នកទាំងនោះ។

៩) លើកស្ទួយការតាមដានឱ្យបានខ្លាំងក្លា និងដោយមិនលំអៀងយេនឌ័រដោយអាជ្ញាធរអំពីបណ្តឹងអំពើហិង្សាក្នុងគ្រួសារ។

១០) អនុវត្តការអប់រំដោយឥតគិតថ្លៃចំពោះកុមារី និងស្ត្រីទាំងអស់។

១១) ផ្តល់ការព្យាបាលសុខភាពដោយឥតគិតថ្លៃដល់គ្រួសារក្រីក្រ។

## ជំពូក ៧. អំពើហិង្សាទាក់ទងនឹងយេនឌ័រៈ អំពើរំលោភសេពសន្ថវៈ ការជួញដូរ និងការបៀតបៀនកេរ្តិ៍ខ្មាស

### ១. ស្ថានភាព

អំពើហិង្សាទាក់ទងនឹងយេនឌ័រកើតឡើងទូទៅនៅកម្ពុជា ទោះបីជាត្រូវបានរាយការណ៍មិនបានគ្រប់ករណីក៏ដោយ។ បញ្ហាអំពើហិង្សាក្នុងគ្រួសារនៅតែមានកម្រិតខ្ពស់នៅឡើយ ចាប់តាំងពីទសវត្សកន្លងមក ចំណែកឯរបាយការណ៍ស្តីពីអំពើរំលោភសេពសន្ថវៈមានការកើនឡើង។ គេពុំអាចរកទិន្នន័យ ដែលអាចជឿជាក់បានអំពីអំពើកេងប្រវ័ញ្ចផ្លូវភេទដែលកើតឡើងឥតឈប់ឈរ ទោះជាបញ្ហានេះហាក់ដូចជាចាក់ឫសមាំក្នុងសង្គមកម្ពុជាក៏ដោយ[៥២]។ ជាប្រពៃណី ទំនាក់ទំនងយេនឌ័របានដាក់ឱ្យស្ត្រីនៅទាបជាងបុរស ដោយស្ត្រីទទួលបានអប់រំរៀនសូត្រទាបជាង និងកាន់តំណែងដែលមានអំណាចតិចតួច។ អំពើហិង្សាដែលទាក់ទងនឹងយេនឌ័រជាធម្មតាត្រូវបានបិទបាំងដោយសារតែភាពស្ងៀមស្ងាត់ និងភាពអៀនខ្មាស់ដោយមានយល់ខុសថា ការនិយាយអំពីបញ្ហានេះឡើងអាចនាំមកនូវការអាប់ឱនកិត្តិយស។ បញ្ហានេះ ក៏ត្រូវពិនិត្យមើលក្នុងបរិបទវប្បធម៌នៃអំពើហិង្សា និងនិទ្ទណ្ឌភាពទូទៅនៅកម្ពុជាផងដែរ ដោយអំពើហិង្សាគឺជាវិធីមួយសម្រាប់ដោះស្រាយបញ្ហាជំលោះដែលសង្គមទទួលយកបាន ហើយជនល្មើសកម្រត្រូវបានផ្តន្ទាទោសណាស់[៥៣]។

រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលបានប្រឹងប្រែងការពារសិទ្ធិស្ត្រីអំពីបញ្ហាដូចជា អំពើហិង្សាក្នុងគ្រួសារ ការជួញដូរមនុស្ស និងរំលោភសេពសន្ថវៈជាដើម។ ផែនការសកម្មភាពជាតិដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី ត្រូវបានអនុម័តដោយក្រុមប្រឹក្សារដ្ឋមន្ត្រីជាគោលការណ៍សម្រាប់ការធ្វើអន្តរាគមន៍បន្ត។ ការពង្រឹងក្របខណ្ឌច្បាប់ដែលត្រូវប្រើប្រាស់សម្រាប់ដោះស្រាយអំពើហិង្សាលើស្ត្រី មានការរីកចម្រើនទៅមុខយ៉ាងច្រើន។ ច្បាប់ទាំងអស់ចំនួន៨ ត្រូវបានអនុម័តឡើងដើម្បីការពារសិទ្ធិស្ត្រី នេះមិនរាប់ទាំងច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាទេ ដែលរួមមានបញ្ញត្តិមួយចំនួនការពារសិទ្ធិស្ត្រីផងដែរ[៥៤]។ កម្ពុជាបានចុះសច្ចាប័នលើអនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ(CEDAW)[៥៥] កម្ពុជាក៏ជាសមាជិកនៃអង្គការពលកម្មពិភពលោក (ILO) ផងដែរ ហើយក៏បានផ្តល់សច្ចាប័នលើលិខិតូបករណ៍អន្តរជាតិជាង១០ ដែលមានចែងអំពីកិច្ចការពារកម្មករស្ត្រីជាមូលដ្ឋាន។ កម្ពុជាក៏បានសន្យា សម្រេចឱ្យបាននូវគោលការណ៍អភិវឌ្ឍន៍សហស្សវត្សផងដែរ។

ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងបែបនេះក្តី ធាតុពិតគឺថាស្ត្រីកម្ពុជានៅតែប្រឈមមុខនឹងហានិភ័យនៃអំពើរំលោភសេពសន្ថវៈ ជួញដូរ អាជីវកម្មផ្លូវភេទ និងអំពើយាយីបំពានផ្លូវភេទ ដែលមិនអាចទទួលយកបាន។

---

[៥២] ចំណែកស្មើភាពសម្រាប់ស្ត្រី- ការវាយតម្លៃយេនឌ័រកម្ពុជា ក្រសួងកិច្ចការនារីកម្ពុជា ខែមេសា ឆ្នាំ២០០៨ ។

[៥៣] ចំណែកស្មើភាពសម្រាប់ស្ត្រី- ការវាយតម្លៃយេនឌ័រកម្ពុជា ក្រសួងកិច្ចការនារីកម្ពុជា ខែមេសា ឆ្នាំ២០០៨ ។

[៥៤] http://www.embassy.org/cambodia/government/constitution.htm

[៥៥] http://www.un.org/womenwatch/daw/cedaw/states.htm

## ១.១ ច្បាប់ និងគោលនយោបាយ

*ការរំលោភសេពសន្ថវៈ និងបៀតបៀនកេរ្តិ៍ខ្មាស់:*

អំពើរំលោភសេពសន្ថវៈ ការរំលោភលើរាងកាយ និងការរំលោភលើផ្លូវភេទសុទ្ធតែជាបទល្មើសព្រហ្មទណ្ឌក្រោមច្បាប់កម្ពុជា។ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះបានចែងអំពីការទទួលខុសត្រូវរបស់អាជ្ញាធរមូលដ្ឋាន ដើម្បីធ្វើអន្តរាគមន៍ក្នុងករណីអំពើហិង្សាក្នុងគ្រួសារ ព្រមទាំងអនុញ្ញាតឱ្យតុលាការចេញដីកាការពារស្ត្រីកុំឱ្យរងគ្រោះ ដោយអំពើហិង្សាថែមទៀតផង។ អំពើបំពាបំពានផ្លូវភេទ និងបៀតបៀនកេរ្តិ៍ខ្មាស់នៅកន្លែងធ្វើការត្រូវបានហាមឃាត់ដោយមាត្រា១៧២ នៃច្បាប់ការងារកម្ពុជា។ ពិធីសារដើម្បីទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្មអំពើជួញដូរមនុស្ស ជាពិសេសជួញដូរស្ត្រី និង កុមារថ្មីៗនេះ ត្រូវបានរដ្ឋសភាផ្តល់ការឯកភាពរួចហើយ[៥៦]។

មានទណ្ឌកម្មជាច្រើនដែលត្រូវអនុវត្តចំពោះបទល្មើសទាំងនេះ៖

- អំពើរំលោភសេពសន្ថវៈ៖ ដាក់ពន្ធនាគារពី ៥ ទៅ ១០ ឆ្នាំ។
- បទប្រទូស្តកេរ្តិ៍ខ្មាស់ (បៀតបៀនកេរ្តិ៍ខ្មាស់) /ការបំពានផ្លូវភេទ: ដាក់ពន្ធនាគារ ១ ឆ្នាំ ទៅ ៣ ឆ្នាំ ព្រមទាំងត្រូវពិន័យជាប្រាក់ពី ២លាន ទៅ ៦លានរៀល។
- បទរុកគួនខាងផ្លូវភេទ និងរូបភាពអាសគ្រាម: ដាក់ពន្ធនាគារពី ៦ ថ្ងៃ ដល់ ៣ ខែ ព្រមទាំងត្រូវពិន័យជាប្រាក់ពី ១០០,០០០រៀល ទៅ ៥០០,០០០រៀល។
- មាត្រា៣៥១ ចែងពីអំពើរំលោភសេពសន្ថវៈលើអនីតិជនប្រព្រឹត្តដោយសាច់ញាតិ សម្រេចថា: អំពើរំលោភសេពសន្ថវៈលើអនីតិជនអាយុក្រោម១៨ឆ្នាំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ដល់ ១០ឆ្នាំ ប្រសិនបើជនល្មើសនោះជាញាតិរបស់ជនរងគ្រោះ។ សាច់ញាតិដូចជា ជីតា ឪពុកម្តាយមីង ឪពុកមា ដែលប្រព្រឹត្តអំពើរួមភេទជាមួយចៅ កូន ក្មួយប្រុស/ស្រី អាយុក្រោម ១៨ឆ្នាំ នឹងត្រូវផ្តន្ទាទោសដូចបញ្ជាក់ខាងលើ ទោះបីជាអំពើនោះប្រព្រឹត្តទៅដោយមានការព្រមព្រៀង ឬមិនព្រមព្រៀងក្តី។

***អំពើជួញដូរ:***

មាត្រា៤៦ នៃរដ្ឋធម្មនុញ្ញកម្ពុជាហាមប្រាមអំពើជួញដូរមនុស្សក្នុងគោលបំណងពេស្យាចារ និងអំពើអាសគ្រាមនានា។

មាត្រា៣ នៃច្បាប់ជួញដូរមនុស្សបានឱ្យនិយមន័យនៃបទល្មើសជួញដូរថា: "*មនុស្សណាដែលលួងលោមជនណាម្នាក់ ប្រុស ឬស្រី អនីតិជន ឬមនុស្សពេញវ័យ ទោះបីជាសញ្ជាតិណាក៏ដោយ តាមវិធីបោកបញ្ឆោត ឬតាមមធ្យោបាយផ្សេងៗ ដោយការសន្យាឱ្យប្រាក់កាស ឬគ្រឿងអលង្ការ ទោះបីជាមាន ការយល់ព្រម ឬគ្មានការយល់ព្រមពីមនុស្សដែលជាប់ពាក់ព័ន្ធនោះ ឬតាមវិធីបង្ខិតបង្ខំ គំរាមកំហែង ឬដោយប្រើថ្នាំ*

[៥៦] មាត្រា ២៣៩ ២៤៦ និង២៥០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ ។

*សណ្តំដើម្បីចាប់ជម្រិតនាង/គាត់យកទៅជួញដូរ/លក់ ឬធ្វើជាពេស្យាចារជាដើម... អ្នកផ្សំគំនិត អ្នកជួញដូរ/ អ្នកលក់ អ្នកទិញ ត្រូវផ្តន្ទាទោសដូចជនល្មើសដែរ។ អ្នកផ្តល់ប្រាក់កាស ឬមធ្យោបាយក្នុងការប្រព្រឹត្តបទល្មើសបែបនេះ ក៏ត្រូវចាត់ទុកជាអ្នកផ្សំគំនិតផងដែរ"*។

ទោះបីជានិយមន័យនៃពាក្យជួញដូរមនុស្ស មើលទៅហាក់ដូចជាលំអិតណាស់ហើយក៏ដោយ ក៏ច្បាប់នេះ មិនបានរាប់បញ្ចូលនូវអំពើជាច្រើនទៀត ដែលអាចចាត់ទុកថាជាអំពើជួញដូរមនុស្សផងដែរ។ និយមន័យនេះ បានគ្របដណ្តប់លើទម្រង់ជួញដូរមនុស្សទូទៅជាច្រើន ដូចជាការសន្យាឱ្យប្រាក់កាស ការប្រើប្រាស់ការគំរាមកំហែង ការបង្ខំ ឬប្រើថ្នាំសណ្តំ និងបោកបញ្ឆោតជាដើម។

ដើម្បីបង្ក្រាបរាល់ទម្រង់នៃអំពើជួញដូរទាំងអស់ និយមន័យត្រូវឱ្យមានលក្ខណៈទូលំទូលាយដើម្បីក្តោបយកគ្រប់វិធីទាំងអស់នៃអំពើជួញដូរមនុស្ស។ ឧទាហរណ៍ និយមន័យបច្ចុប្បន្ននេះ ពុំបានលើកឡើងឱ្យបានច្បាស់ ឬចំៗចំពោះករណីដែលឪពុកម្តាយលក់កូនដើម្បីសងបំណុលគេទេ ដែលរឿងនេះជាបញ្ហាមួយកើតឡើងជាទូទៅនៅកម្ពុជា។ កុមារីដែលគេជួញដូរនោះ មិនត្រូវបានលួងលោម ឬសន្យាផ្តល់ប្រាក់កាស ឬសូម្បីតែការបង្ខិតបង្ខំឱ្យទៅជាមួយជនល្មើសជួញដូរក៏គ្មានដែរ នាងគ្រាន់តែធ្វើតាមបំណងរបស់ឪពុកម្តាយ និងដើម្បីជួយក្រុមគ្រួសារតែប៉ុណ្ណោះ។ ពិតណាស់នាងត្រូវបានជួញដូរ ប៉ុន្តែច្បាប់ជួញដូរមនុស្សបច្ចុប្បន្ននេះ ពុំបានលើកឡើងអំពីចំណុចនេះទេ។ នៅឆ្នាំ១៩៩៦ កម្ពុជាបានអនុម័តច្បាប់ស្តីពីការបង្ក្រាបអំពើចាប់ជម្រិតជួញដូរ និងអាជីវកម្មមនុស្ស (ច្បាប់ជួញដូរ) ដើម្បីឆ្លើយតបទៅនឹងការរីកលូតលាស់នៃអំពើជួញដូរមនុស្សយ៉ាងលឿន អាស្រ័យដោយមានតម្រូវការស្ត្រីបំរើផ្លូវភេទខ្ពស់។ ជាថ្មីម្តងទៀត ច្បាប់នេះមិនទាន់បានចាត់ទុកកុមារីដែលត្រូវលក់ដោយឪពុកម្តាយ ថាជាជនរងគ្រោះនៃអំពើជួញដូរមនុស្សទេ។

ពិធីសាររបស់អង្គការសហប្រជាជាតិស្តីពីការទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្មលើអំពើជួញដូរមនុស្ស ជាពិសេសជួញដូរស្ត្រី និងកុមារបានចែងនិយមន័យនៃអំពើជួញដូរមនុស្សយ៉ាងទូលំទូលាយដែលត្រូវបានទទួលស្គាល់តាមបទដ្ឋានអន្តរជាតិ។ *(ក) "អំពើជួញដូរមនុស្ស" គឺជាអំពើទាំងឡាយរួមមាន ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់ទីសំចត ឬការទទួលមនុស្សដោយមធ្យោបាយគំរាមកំហែង ឬប្រើប្រាស់ការបង្ខិតបង្ខំ ឬការបង្ខំដោយទម្រង់ណាមួយ ការចាប់ជម្រិត ការបោកបញ្ឆោត ការរំលោភអំណាច ឬ ស្ថានភាពងាយរងគ្រោះ ឬការផ្តល់/ទទួលការទូទាត់ ឬប្រយោជន៍អ្វីមួយដើម្បីទទួលបានការយល់ព្រមពីនរណាម្នាក់ដែលកំពុងគ្រប់គ្រងលើជនណាម្នាក់ ក្នុងគោលបំណងដើម្បីធ្វើអាជីវកម្ម។ អាជីវកម្មរួមមានជាអតិបរមាអាជីវកម្មពេស្យាចារលើនរណាម្នាក់ ឬអាជីវកម្មផ្លូវភេទក្នុងទម្រង់ផ្សេងទៀត ការងារ ឬសេវាកម្មដោយបង្ខំ អំពើទាសភាព ឬអំពើស្រដៀងទាសភាព សេវគតិភាព ឬការវះកាត់យកសរីរាង្គ។ (ខ) ការយល់ព្រមរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្សក្នុងចេតនាធ្វើអាជីវកម្មដូចមានចែងនៅក្នុងកថាខណ្ឌ(ក)ខាងលើ នៃមាត្រានេះនឹងមិនពាក់ព័ន្ធគ្នាទេក្នុងករណីដែលមធ្យោបាយណាមួយដែលមានចែងនៅក្នុងកថាខណ្ឌ(ក) ត្រូវបានប្រើប្រាស់។ (គ) ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់ទីសំចត/ទទួល កុមារក្នុងគោលបំណងដើម្បីធ្វើអាជីវកម្ម នោះនឹងត្រូវចាត់ទុកជា "អំពើជួញដូរមនុស្ស" ទោះបីជាអំពើនេះ មិនទាក់ទងជាមួយមធ្យោបាយណាមួយដែលបានចែងនៅក្នុងកថាខណ្ឌ(ក) នៃមាត្រានេះក៏ដោយ"*។

និយមន័យទាំងនេះ បានដាក់បញ្ចូលនូវភាពសាំញ៉ាំនៃការដឹកជញ្ជូន ដែលអាចពាក់ព័ន្ធនឹងការរំលោភដោយអំណាចផងដែរ ជាពិសេសអំណាចរបស់បុរសលើស្ត្រី ការឆបោក ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងករណីជួញដូរជាច្រើន និងការកេងយកចំណេញពីភាពងាយរងគ្រោះរបស់មនុស្ស។

ទោះបីជាមានសេវាកម្មច្បាប់ទាំងនេះក៏ដោយ ក៏ការអនុវត្តន៍យុទ្ធសាស្ត្រទូទៅដើម្បីប្រយុទ្ធប្រឆាំងនឹងទម្រង់នៃអំពើហិង្សាដូចដែលបានលើកឡើង ស្ត្រីបានរងគ្រោះយ៉ាងខ្លាំងពីបញ្ហាកង្វះហេដ្ឋារចនាសម្ព័ន្ធពិតប្រាកដដើម្បីលុបបំបាត់អំពើជួញដូរប្រកបដោយប្រសិទ្ធិភាព។

## ១.២ *ការរំលោភសេពសន្ថវៈ*

គឺជាបញ្ហាធ្ងន់ធ្ងរនៅកម្ពុជា។ បញ្ហានេះ ឃើញមានចុះផ្សាយសឹងតែរាល់ថ្ងៃក្នុងសារព័តមានក្នុងស្រុក។ ជនរងគ្រោះភាគច្រើនមិនហ៊ានលាតត្រដាងមុខជនល្មើសទេ ពីព្រោះអ្នកទាំងនោះខ្លាចអាប់ឱនកិត្តិយស។ ការបាត់បង់ព្រហ្មចារីយ៍របស់ស្ត្រីមុនពេលរៀបការ គឺជាការនាំមកនូវភាពអាម៉ាស់ដល់ស្ត្រីខ្លួនឯងផ្ទាល់ និងកិត្តិយយ ព្រមទាំងឋានៈរបស់ក្រុមគ្រួសារផងដែរ។ អាស្រ័យដោយកង្វះសេចក្តីរាយការណ៍ និងវប្បធម៌និទ្ទណ្ឌភាព ជនល្មើសច្រើនតែរួចខ្លួន ហើយប្រព្រឹត្តអំពើបែបនេះម្តងហើយម្តងទៀតឥតឈប់ឈរ។

តាមទិន្នន័យបានបង្ហាញឲ្យឃើញថា អំពើរំលោភសេពសន្ថវៈ និងរំលោភផ្លូវភេទតាមទម្រង់ផ្សេងៗដូចជារំលោភដោយហិង្សា រំលោភជាក្រុម និងរំលោភកុមារជាដើម កើតឡើងច្រើនលើសលប់ ទោះបីជាគេមិនអាចដឹងថាបញ្ហានេះធ្ងន់ធ្ងរដល់កម្រិតណាមួយក៏ដោយ។ បញ្ហារំលោភសេពសន្ថវៈនៅកម្ពុជា ត្រូវតែពិនិត្យមើលក្នុងបរិបទឥរិយាបទវប្បធម៌ និងសង្គមរបស់កម្ពុជាចំពោះស្ត្រី និងបញ្ហាផ្លូវភេទ។ នៅកម្ពុជាគេគិតថាបុរសមានតម្លៃខ្ពស់ជាងស្ត្រី ដូច្នេះហើយស្ត្រីត្រូវតែស្តាប់បង្គាប់បុរស[៨៧]។ ដោយសារតែបញ្ហានេះហើយទើបបុរសជាច្រើនមិនគោរពសិទ្ធិស្ត្រីដែលត្រូវមានសេរីភាពរួចផុតពីអំពើហិង្សាផ្លូវភេទ និងហិង្សាផ្សេងៗទៀត ហើយស្ត្រីជាច្រើនមិនមានជំនឿជឿជាក់ក្នុងការប្រើប្រាស់សិទ្ធិនេះទេ។

តាមប្រពៃណី ស្ត្រីត្រូវស្ថិតនៅជាស្ត្រីព្រហ្មចារីយ៍រហូតដល់ពេលរៀបការ ហើយស្ត្រីណាដែលបាត់បង់ព្រហ្មចារីយ៍មុនពេលរៀបការ (ទោះបីដោយសារគេចាប់រំលោភ) ក៏ដោយ ត្រូវបានគេចាត់ទុកថា "មិនអាចរៀបការបានទេ"។ ភាពអាម៉ាស់ និងអាស្រូវកេរ្តិ៍ឈ្មោះដោយសារអំពើរំលោភនេះ (អារម្មណ៍របស់ជនរងគ្រោះក្នុងប្រទេសជាច្រើន) ហើយបញ្ហានេះ នៅកម្ពុជាត្រូវបានបន្ថែមទម្ងន់ឲ្យកាន់តែធ្ងន់ថែមទៀតដោយសារតែឥរិយាបទសង្គមទូទៅ។

ក្រមព្រហ្មទណ្ឌថ្មីបានចែងថា "គ្រប់អំពើបញ្ចូលអង្គជាតិតាមបែបណាក៏ដោយ ឬអំពើបញ្ចូលឧបករណ៍ណាមួយទៅក្នុងអង្គជាតិ ដែលប្រព្រឹត្តទៅលើអ្នកដទៃ ទោះបីមានភេទដូចគ្នា ឬមិនដូចគ្នាក៏ដោយដោយការប្រើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬដោយការឆ្មក់ឱកាស គឺជាបទរំលោភសេពសន្ថវៈ។" (មាត្រា២៣៩) ។

---

[៨៧] ច្បាប់ស្រី ។

ទាំងអស់នេះ បានជួយពង្រឹងនូវការប្រើប្រាស់ពាក្យពេចន៍ក្នុងច្បាប់ចាស់ គឺ "បទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ សម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល" ហៅកាត់ថា ច្បាប់ព្រហ្មទណ្ឌអន្តរកាល ដែលឲ្យនិយមន័យអំពើរំលោភសេពសន្ថវៈថា "បទរំលោភសេពសន្ថវៈ គឺគ្រប់អំពើបញ្ចូលអង្គជាតិដោយឃោរឃៅ ដោយបង្ខំ ឬដោយមិនដឹងខ្លួនជាមុន"។ ច្បាប់ថ្មីបានបំភ្លឺនិយមន័យដូចតទៅនេះ៖ "អំពើរំលោភសេពសន្ថវៈ គឺជាគ្រប់អំពើបញ្ចូលអង្គជាតិ" ដែលពាក់ព័ន្ធនឹងការ "ប្រើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬការឆក់ឱកាស"។ ក្រមព្រហ្មទណ្ឌថ្មីនាពេលនេះ បាននាំមកនូវការស្រាយបំភ្លឺមួយដែលជំនួសពាក្យមិនច្បាស់លាស់គឺពាក្យ "ឃោរឃៅ" ជំនួសដោយពាក្យ "ហិង្សា" និង "គំរាមកំហែង" ទៅវិញ។ ក្រមព្រហ្មទណ្ឌថ្មីនេះ ក៏បានកំណត់អាយុយល់ព្រមត្រឹម ១៥ឆ្នាំ ដែលចំណុចនេះពុំមានចែងទេ ក្នុងក្រមព្រហ្មទណ្ឌមុន (ច្បាប់ព្រហ្មទណ្ឌអន្តរកាល)។

ក៏ប៉ុន្តែអ្នកតាក់តែងក្រមព្រហ្មទណ្ឌថ្មីនេះ ពុំបានដាក់បញ្ចូលភាសាមួយដើម្បីបង្ហាញឲ្យបានច្បាស់ថា អំពើរំលោភសេពសន្ថវៈ មានន័យស្មើនឹងការរួមភេទដោយគ្មានការយល់ព្រមដោយសេរី និងពិតប្រាកដទាំងពីរភាគី។ ការខ្វះចន្លោះបែបនេះ ជាបញ្ហាមួយធ្ងន់ធ្ងរ ជាពិសេសអាចនាំឲ្យមានបុរេវិនិច្ឆ័យចំពោះជនរងគ្រោះ ដោយអំពើរំលោភសេពសន្ថវៈនេះ។ ការខ្វះចន្លោះនោះ អាចធ្វើឲ្យចៅក្រមដែលផ្តោតទៅលើតែភស្តុតាងជាក់ស្តែងរបស់ជនរងគ្រោះក្នុងការទប់ទល់នឹងអំពើរំលោភសេពសន្ថវៈនេះ ដោយធ្វើឱ្យចៅក្រមអាចភ្លេចគិតពីអារម្មណ៍របស់ជនរងគ្រោះ ដែលមិនព្រមរួមភេទ (គ្មានការយល់ព្រមដោយសេរី)។ ការបន្ថែមនៅក្នុងក្រមព្រហ្មទណ្ឌថ្មីនូវពាក្យ "គំរាមកំហែង" អាចជួយបំពេញការខ្វះចន្លោះនេះយ៉ាងច្រើនទៅវិញ ក៏ប៉ុន្តែអាជ្ញាធរ និងតុលាការត្រូវតែបកស្រាយពាក្យនេះឲ្យបានច្បាស់លាស់។ អាជ្ញាធរ និងតុលាការក៏ត្រូវបង្ហាញផងដែរថា មាត្រា២៣៩ មិនអនុញ្ញាតឲ្យមានការលើកលែងទេ រួមទាំងបញ្ហារំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ផងដែរ។ លើសពីនេះទៅទៀត អ្នកតាក់តែងក្រមព្រហ្មទណ្ឌថ្មីនេះ បាត់បង់ឱកាសក្នុងការបញ្ជាក់ឲ្យបានច្បាស់លាស់ថា អំពើរំលោភសេពសន្ថវៈ និងអំពើហិង្សាផ្លូវភេទផ្សេងទៀតគឺជាបទល្មើសព្រហ្មទណ្ឌប៉ះពាល់រាងកាយ និងផ្លូវចិត្តរបស់ជនរងគ្រោះ[៥៨]។

ឯកសារស្រាវជ្រាវស្តីពី "អំពើហិង្សាលើស្ត្រី និងអាជីវកម្មផ្លូវភេទ[៥៩]" មកពីក្រសួងកិច្ចការនារី បានបង្ហាញឲ្យឃើញថា ការកើតមានឡើងនៃអំពើរំលោភសេពសន្ថវៈ មានការរាយការណ៍តិចជាងចំនួនដែលកើតមានពិតប្រាកដ ហើយមានការលំបាកក្នុងការប៉ាន់ប្រមាណអំពីអាត្រានៃការរាលដាលបញ្ហានេះ។ ក៏ប៉ុន្តែអង្គការមិនមែនរដ្ឋាភិបាល និងប្រព័ន្ធផ្សាយព័ត៌មាននានាបានទទួលរបាយការណ៍អំពីបញ្ហារំលោភសេពសន្ថវៈនេះកាន់តែច្រើនឡើងៗពីមួយឆ្នាំទៅមួយឆ្នាំ។ អង្គការលីកាដូ[៦០] ជាអង្គការក្នុងស្រុកមួយ ដែលមានសាខាការិយាល័យនៅក្នុងខេត្តចំនួន១២ និងនៅភ្នំពេញ បានរាយការណ៍អំពីការកើនឡើងនូវចំនួនករណីរំលោភសេពសន្ថវៈដែលបានចងក្រងទុកជាឯកសារពី ៦៦ ករណីក្នុងឆ្នាំ២០០៥ រហូតដល់២៩៧ ករណីក្នុងឆ្នាំ២០១០ (ក្នុងនោះរួមមាន២២២ ករណីជាករណីអនីតិជន និង៦ករណីទៀតជាករណីរំលោភសម្លាប់)។

[៥៨] Breaking the Silence ហិង្សាផ្លូវភេទនៅកម្ពុជា អង្គការលើកលែងទោសអន្តរជាតិ ឆ្នាំ២០១០ ។

[៥៩] អំពើហិង្សាលើស្ត្រី និងអាជីវកម្មផ្លូវភេទ- ក្រសួងកិច្ចការនារី ។

[៦០] http://www.licadho-cambodia.org/

បញ្ហារំលោភបូកនៃបុរសមួយក្រុមមិនទូទៅ កើតឡើងកាន់តែច្រើន ក្នុងនោះក៏មានបុរសក្មេងៗនៅតំបន់ទីក្រុង និងនិស្សិតនៅតាមសកលវិទ្យាល័យមួយចំនួនផងដែរ។ ប៉ុន្តែចំនួនករណីបែបនេះ មិនច្រើនដូចករណីរំលោភដោយបុគ្គលម្នាក់ៗឡើយ។ យោងតាមឯកសារ ដែលលើកឡើងខាងលើបានឲ្យដឹងថា អំពើរំលោភបូកលើស្ត្រីបំរើផ្លូវភេទ (បំរើការកំសាន្ត) ស្ត្រីកម្មកររោងចក្រ ស្ត្រីបម្រើការងារក្នុងវិស័យ ដែលងាយរងគ្រោះ ដូចជាស្ត្រីស្រាបៀរ និងស្ត្រីខារ៉ាអូខេជាដើម នៅតែបន្តរាយការណ៍មកអង្គការមិនមែនរដ្ឋាភិបាល និងប្រព័ន្ធផ្សាយព័ត៌មានជាបន្តបន្ទាប់។ បញ្ហាអំពើរំលោភបូកមានការកើនឡើងច្រើនក្នុងចំណោមស្ត្រីបំរើការកំសាន្ត និងស្ត្រីផ្សេងៗទៀត។ នៅឆ្នាំ២០១០ អង្គការលីកាដូបានទទួលរបាយការណ៍អំពីករណីរំលោភបូកចំនួន១៤ ករណី។

### *១.២.១ របាយការណ៍ស្តីពីអំពើរំលោភសេពសន្ថវៈ និងបំពានផ្លូវភេទ*

ទោះបីជាបានដឹងថា អំពើរំលោភសេពសន្ថវៈមានកម្រិតខ្ពស់ក៏ដោយ ក៏ការទប់ស្កាត់បញ្ហានេះនៅកម្ពុជាក៏នៅតែមានលក្ខណៈស្មុកស្មាញខ្លាំងណាស់ អាស្រ័យដោយកត្តាមួយចំនួនដូចខាងក្រោមៈ

- ពលរដ្ឋកម្ពុជាភាគច្រើនបានចាត់ទុក អំពើរំលោភសេពសន្ថវៈ ថាជាបទល្មើសធ្ងន់ធ្ងរ ក៏ប៉ុន្តែការជំទាស់ និងការស្តីបន្ទោសពីសង្គមអាចមានលក្ខណៈទន់ខ្សោយ នៅពេលដែលជនល្មើសជាសង្សារ ឬជាសាច់ញាតិ។
- រំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ ត្រូវបានចាត់បញ្ចូលជាបទល្មើសព្រហ្មទណ្ឌនៅក្នុងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ។ ក៏ប៉ុន្តែច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះនេះ ពុំបានចែងអំពីបញ្ញត្តិផ្តន្ទាទោសទេ។ ដូច្នេះបទល្មើសព្រហ្មទណ្ឌទាំងនេះ សុទ្ធត្រូវបានផ្តន្ទាទោសក្រោមក្រមព្រហ្មទណ្ឌថ្មី[៦១]។
- អំពើរំលោភសេពសន្ថវៈជាក្រុម ឬ "បូក" ត្រូវបានយុវជនមួយចំនួនយល់ថាជាល្បែង ឬជាកីឡាមួយប្រភេទ។ អ្នកចូលរួមប្រព្រឹត្តិបទល្មើស ដែលគ្មានអារម្មណ៍ឈឺចាប់ និងការផាត់ចោលជនរងគ្រោះពីសង្គម ជាការជម្រុញឲ្យមានការប្រព្រឹត្តិបែបនេះបន្តទៀត។
- ជនរងគ្រោះ ដោយអំពើរំលោភសេពសន្ថវៈជាច្រើនមិនទទួលបានយុត្តធម៌ សូម្បីតែការចាប់ផ្តើមដំណើរការរឿងក្តីក៏មិនអាចទៅរួចដែរ អាស្រ័យដោយឧបាយកលផ្នែកច្បាប់ពុំមានប្រសិទ្ធិភាព ខ្វះជំនួយហេដ្ឋារចនាសម្ព័ន្ធផ្នែករកយុត្តិធម៌ស្តីពីការរំលោភសេពសន្ថវៈ និងបញ្ហាការចំណាយប្រាក់កាសលើការងារបណ្តឹង។

នៅក្នុងច្បាប់ទាំងឡាយទាក់ទងនឹងអំពើរំលោភសេពសន្ថវៈ ពុំមានបញ្ញត្តិណាមួយនិយាយអំពីជំនួយ ឬការស្តារនិតីសម្បទាដល់ជនរងគ្រោះឡើយ។ អនុសាសន៍ទូទៅលេខ១៩ របស់អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទបញ្ជាក់ថា "គួរអនុវត្តវិធានការការពារ ដូចជាទីជំរក

[៦១] Breaking the Silence ហិង្សាផ្លូវភេទនៅកម្ពុជា អង្គការលើកលែងទោសអន្តរជាតិ ឆ្នាំ២០១០ ។

ការពិគ្រោះយោបល់ ការស្តារនីតិសម្បទា និងសេវាកម្មជំនួយសម្រាប់ស្ត្រីដែលជាជនរងគ្រោះដោយអំពើហិង្សា ឬអ្នកដែលជួបប្រទះហានិភ័យនៃអំពើហិង្សាជាដើម"។

### *១.២.២ ករណីសិក្សា*

**<u>ករណីទី ១៖</u>**

នារីម្នាក់អាយុ ១៩ ឆ្នាំ "គ.ស" ត្រូវបានឪពុក និងបងប្រុសរបស់នាងរំលោភសេពសន្ថវៈពេលទៅរកអុសក្នុងព្រៃ។ ពេលនោះនាងទើបតែអាយុ១៣ឆ្នាំ ទេ។ ជនរងគ្រោះបាននិយាយថា នាងទៅរកអុសក្នុងព្រៃតែម្នាក់ឯង ហើយពេលដែលនាងកំពុងរើសអុសនោះ ស្រាប់តែបងប្រុសរបស់នាងបានចាប់នាងរំលោភសេពសន្ថវៈ។ នាងចង់និយាយរឿងនេះ ប្រាប់គេឲ្យបានដឹងដែរ ប៉ុន្តែបងប្រុសបានគំរាមថា បើហ៊ានប្រាប់គេនាងនឹងត្រូវទទួលទណ្ឌកម្មថែមទៀត។ ១០ថ្ងៃក្រោយមក បងប្រុសរបស់នាងបានចាប់រំលោភសេពសន្ថវៈនាងម្តងទៀត។ នាងមិនហ៊ាននិយាយរឿងនេះប្រាប់អ្នកណាទេ ដោយមានការភ័យខ្លាច។ ក្រោយមកនាងក៏មានផ្ទៃពោះ ហើយមីងរបស់នាងក៏បានដឹងអំពីរឿងនោះ (នាងរស់នៅជាមួយមីងក្នុងពេលនោះ)។ មីងរបស់នាងបានជួយនាងក្នុងការរំលូតកូនចេញ។ មួយខែក្រោយពីរំលូតកូនចេញ ឪពុករបស់នាងបានយកនាងទៅរស់នៅជាមួយគាត់វិញ។ ពេលនោះបងប្រុសរបស់នាងបានរំលោភសេពសន្ថវៈនាងទៀត។ ពីរខែក្រោយមកឪពុករបស់នាងបានរំលោភសេពសន្ថវៈ និងគំរាមនាងក្នុងវាលស្រែ។

ក្រោយមកទៀត បងប្រុសរបស់នាងក៏បានយកនាងមករស់នៅជាមួយគាត់នៅខេត្តផ្សេង ហើយបងនោះក៏បានរំលោភសេពសន្ថវៈនាងពីរដងថែមទៀត។ ពេលនោះនាងគិតថា នាងមិនអាចទ្រាំនឹងបញ្ហាបែបនេះបានតទៀតទេ ហើយក៏បានសម្រេចចិត្តរត់ចោលបងទៅភ្នំពេញ ពេលមកដល់ភ្នំពេញនាងក៏បានចុះឈ្មោះក្នុងក្រុមហ៊ុនមួយដើម្បីទៅធ្វើការនៅប្រទេសម៉ាឡេស៊ី។ ប៉ុន្តែពេលនាងនៅភ្នំពេញស្រាប់តែមានជម្ងឺធ្លាក់ឈាម ហើយត្រូវចូលទៅសម្រាកនៅមន្ទីរពេទ្យ។ ក្រោយមកគេបានបញ្ជូននាងទៅស្រុកវិញ ហើយពេលនោះនាងបានរាយការណ៍អំពីបញ្ហារបស់នាងទៅប្រធានភូមិ រួចគេបានបញ្ជូននាងទៅអង្គការលីកាដូ។

នាយរងការិយាល័យ អំពើជួញដូរមនុស្ស និងការពារអនីតិជន បានសួរចម្លើយឪពុកនាងនៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៩។ ក្រោយមកគេបានបញ្ជូនទៅឃុំឃាំងបណ្តោះអាសន្នរង់ចាំការកាត់ទោស។ ចំណែកឯបងប្រុសរបស់នាងបានរត់គេចខ្លួនបាត់។

**<u>ករណីទី២៖</u>**

ស្ត្រីម្នាក់អាយុ ២៩ ឆ្នាំ ត្រូវបានបុរសច្រើននាក់ចាប់រំលោភសេពសន្ថវៈ។ គេបានជួបស្ត្រីនោះក្នុងពេលដែលនាងប្រុងលោតទឹកសម្លាប់ខ្លួននៅលើស្ពានកំពតដោយអ្នកនេសាទធ្វើដំណើរកាត់តាមនោះ ហើយបានរាយការណ៍ប្រាប់នគរបាល។ ភ្លាមៗនោះ នគរបាលក៏បានសាកសួរអំពីមូលហេតុដែលនាងចង់លោតសម្លាប់ខ្លួននេះ ហើយដោយមានការជួយពីអង្គការលីកាដូ និងអង្គការអភិវឌ្ឍន៍មនុស្សគរ ថ្លង់ នគរបាលអាចមានលទ្ធភាពសន្ទនាជាមួយនាងបាន ហើយបានរកឃើញថា នាងត្រូវបានបុរសច្រើននាក់ចាប់រំលោភ។

បទល្មើសនោះ បានកើតឡើងនៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៩ ពេលដែលនាងកំពុងអង្គុយរង់ចាំនៅខាងក្រៅក្លឹបរាត្រីមួយ។ នាងត្រូវបានគេចាប់នាងយកទៅផ្ទះមួយ ហើយបុរសម្នាក់បានរំលោភសេព

សន្ថវៈនាង។ បីថ្ងៃក្រោយមក បុរសពីរនាក់បានចូលមកក្នុងផ្ទះនោះ ហើយក៏បានរំលោភសេពសន្ថវៈនាងទៀត ។ ពីរថ្ងៃក្រោយមកទើបបុរសទាំង ៣នាក់ដោះលែងនាងវិញ។ នៅពេលនោះ នារីរងគ្រោះសម្រេចចិត្តថានឹងសម្លាប់ខ្លួន ហើយក៏បានឡើងលើស្ពាន។ ក្រោយមកនគរបាលក៏បានរកឃើញផ្ទះដែលគេនាំយកនាងទៅរំលោភសេពសន្ថវៈ។ ម្ចាស់ផ្ទះបាននិយាយថា នៅថ្ងៃកើតហេតុនោះ គាត់បានឃើញជនល្មើសនាំជនរងគ្រោះចូលមកក្នុងផ្ទះ។ នគរបាលមិនបានចាប់ខ្លួនជនសង្ស័យទេ។

**១.៣ ការជួញដូរ និងការធ្វើអាជីវកម្មផ្លូវភេទ**

អំពើជួញដូរ និងអំពើអាជីវកម្មផ្លូវភេទកើតឡើងតាមរបៀបខុសៗគ្នា:

**ការជួញដូរមនុស្សបែបពាណិជ្ជកម្ម:** អំពើជួញដូរមនុស្សបែបនេះ ពាក់ព័ន្ធជាមួយការផ្តល់អំណាចគ្រប់គ្រងខុសច្បាប់លើមនុស្សណាម្នាក់ដោយមនុស្សម្នាក់ទៀត ឬជាការទទួលសិទ្ធិគ្រប់គ្រងដោយខុសច្បាប់របស់មនុស្សណាម្នាក់ជាថ្នូរនឹងប្រាក់កាស។ ក្នុងករណីបែបនេះ ជនរងគ្រោះច្រើនតែជាស្ត្រី និងកុមារ។

**អំពើឆបោកតាមរយៈការរកការងារធ្វើ:** បញ្ហានេះ សំដៅទៅលើការរកការងារធ្វើដោយពួកអ្នកចំណាកស្រុកដែលពុំសូវបានដឹងព័ត៌មានច្រើន។ ជាធម្មតាអំពើជួញដូរមនុស្សបែបនេះ កើតឡើងដោយមានមេខ្យល់ជាអ្នកដឹកនាំ។

**អាពាហ៍ពិពាហ៍ក្លែងក្លាយ:** បញ្ហានេះ សំដៅលើអាពាហ៍ពិពាហ៍រវាងនារីខ្មែរ និងបុរសបរទេស ដែលភាគច្រើនឪពុកម្តាយជាអ្នកជម្រុញ ឬមានការយល់ព្រមដោយស្ត្រីផ្ទាល់ក៏មាន ប៉ុន្តែស្ត្រីដែលរៀបការនោះពុំសូវដឹងព័ត៌មានច្បាស់លាស់អំពីបញ្ហាដែលនឹងកើតឡើងចំពោះខ្លួននៅពេលក្រោយឡើយ។ ជាធម្មតាបញ្ហានេះក៏កើតឡើងតាមរយៈមេខ្យល់ដែរ។

**សុំកូន:** សំដៅលើបញ្ហាដែលកុមារតូចៗ (ជាធម្មតាកុមារី) ដែលត្រូវបានគេសុំធ្វើជាកូនចិញ្ចឹម ហើយក្រោយមកត្រូវបានលក់ឲ្យធ្វើជាស្ត្រីបំរើការកំសាន្ត ធ្វើការ ឬអាចយកទៅវះកាត់យកសរីរាង្គក៏មានដែរ។

**អាជីវកម្មលើពលកម្មកុមារ:** សំដៅទៅលើការបង្ខិតបង្ខំកុមារ ជាពិសេសកុមារីឲ្យធ្វើការដោយគ្មានប្រាក់ឈ្នួល ឬធ្វើការដើម្បីសងបំណុលឪពុកម្តាយ ក្នុងករណីនេះកុមារបានបាត់បង់ឱកាសសិក្សារៀនសូត្រ និងសេចក្តីសុខក្នុងវ័យកុមារ ។

**អំពើហិង្សាក្នុងគ្រួសារ:** សំដៅទៅលើស្ថានភាពដែលកុមារចាកចេញពីផ្ទះសម្បែង ដោយសារអំពើហិង្សាក្នុងគ្រួសារ ដូចជាកុមារអាចរងគ្រោះដោយអំពើជួញដូរជាដើម។ ជាពិសេសកុមារីអាចត្រូវបានជួញដូរដើម្បីធ្វើអាជីវកម្មផ្លូវភេទ។

បុរស ស្ត្រី និងកុមារកម្ពុជា ត្រូវគេលក់ដូរក្នុងអាជីវកម្មផ្លូវភេទ និងអាជីវកម្មខាងកំលាំងពលកម្មទៅប្រទេសថៃ ម៉ាឡេស៊ី ម៉ាកាវ និងតៃវ៉ាន់ ជាដើម។ ក្នុងបញ្ហាបែបនេះ ស្ត្រីដែលត្រូវបានគេយកទៅបម្រើតាមផ្ទះ ច្រើនតែត្រូវបានបង្ខំឲ្យរួមភេទជាមួយម្ចាស់ផ្ទះ។ បុរសត្រូវបានគេលក់ដូរយកទៅធ្វើជាកម្មករនេសាទ សំណង់ និងក្នុងវិស័យឧស្សាហកម្មផ្សេងៗទៀតដោយបង្ខំ។ កម្ពុជា គឺជាចំណុចឆ្លងកាត់សម្រាប់មនុស្សដែល

ត្រូវគេជួញដូរពីវៀតណាមទៅប្រទេសថៃ និងជាចំណុចគោលដៅសម្រាប់ស្ត្រី និងកុមារដែលត្រូវជួញដូរពីវៀតណាមទៅចិន[៦២]។

អំពើជួញដូរក្នុងប្រទេសក៏ជាបញ្ហាគួរឲ្យចាប់អារម្មណ៍ផងដែរ។ មានករណីជួញដូរស្ត្រី និងកុមារជាច្រើនពីជនបទមកទីក្រុងក្នុងគោលបំណងដើម្បីអាជីវកម្មផ្លូវភេទ។ ក្នុងករណីជាច្រើន កុមារីត្រូវបានគ្រួសារលក់ ដោយចាញ់បោកគេ ថាយកទៅធ្វើការជាអ្នកបម្រើក្នុងផ្ទះ ប៉ុន្តែក្រោយមកបែរជាត្រូវបានគេបង្ខិតបង្ខំឲ្យក្លាយជាទាសករផ្លូវភេទទៅវិញ។



អំពើជួញដូរមនុស្ស គឺជាទម្រង់ទាសករមួយប្រភេទ។ កត្តាសំខាន់ដែលប៉ះពាល់ដល់ការជួញដូរស្ត្រីនៅកម្ពុជា គឺភាពក្រីក្រ និងចំណាកស្រុក បញ្ហាទាំងពីរនេះ គឺជាប់ទាក់ទងគ្នាទៅវិញទៅមក។ គ្រួសារដែលជួបការលំបាកក្នុងជីវភាពរស់នៅ និងភាពក្រីក្រអាចទទួលអារម្មណ៍គាបសង្កត់ ឲ្យលក់ដូរកូនស្រីរបស់ខ្លួនដើម្បីសងបំណុលគេ ដែលគ្រួសារបានជំពាក់។ ក្រោយពេលត្រូវជួញដូរ ជនរងគ្រោះត្រូវគេបង្ខំឲ្យធ្វើការជាទម្ងន់ ដើម្បីសងបំណុលរបស់គ្រួសារ។ ជាពិសេសស្ត្រីដែលរស់នៅតំបន់ជិតព្រំដែន ច្រើនតែងាយរងគ្រោះដោយត្រូវបានគេជួញដូរក្នុងពេលធ្វើចំណាកស្រុក ដោយស្ត្រីទាំងនោះបានធ្វើដំណើរទៅតំបន់ផ្សេងៗជាច្រើនដើម្បីរកការងារធ្វើ។ ក្នុងពេលធ្វើចំណាកស្រុកនេះ ស្ត្រីច្រើនតែត្រូវគេបោកប្រាស់អំពីការរកការងារធ្វើតាមរយៈមេខ្យល់ ដែលសន្យាជួយជូនទៅគោលដៅជាថ្នូរនឹងប្រាក់ឈ្នួលនៃការជូនផ្លូវនោះ។ បញ្ហាបែបនេះគេហៅ"ការជ្រើសរើស"។ ក្នុងករណីដូច្នេះ ស្ត្រីពុំបានដឹងព័ត៌មានអ្វីទាល់តែសោះ ហើយត្រូវពឹងផ្អែកលើមេខ្យល់ទាំងស្រុងចំពោះមធ្យោបាយធ្វើដំណើរ ស្នាក់នៅ ចំណីអាហារ ការងារ និងភាសា (ប្រសិនបើត្រូវទៅបរទេស)។ នៅចំណុចនេះហើយ ដែលស្ត្រីច្រើនតែត្រូវបានគេជួញដូរ និងលក់ឲ្យទៅធ្វើការងារដោយបង្ខំ។ ទន្ទឹមនឹងនោះចំណងបំណុលក៏ត្រូវបានកើតឡើងដែរ ដោយគេបានប្រាប់ជនរងគ្រោះថា ខ្លួនបានជំពាក់ប្រាក់មនុស្សដែលជូននាងមកនូវថ្លៃធ្វើដំណើរ និងការចំណាយផ្សេងៗ។ ហើយដើម្បីសងបំណុលទាំងអស់នោះ នាងត្រូវតែធ្វើជាស្ត្រីពេស្យា ឬការងារដោយបង្ខំណាមួយ។

ក្រុមជួញដូរមនុស្សច្រើនបោកបញ្ឆោតស្ត្រីដែលងាយរងគ្រោះបំផុត ដូចជាស្ត្រីក្រីក្រ ខ្វះការអប់រំ និងពុំបានដឹងអំពីសិទ្ធិរបស់អ្នកទាំងអស់នោះជាដើម។ ជាធម្មតាស្ត្រី ដែលត្រូវបានជួញដូរច្រើនតែរងគ្រោះពីសំណាក់ការរំលោភលើសិទ្ធិជាច្រើនករណី។ ឧទាហរណ៍ ស្ត្រីរងគ្រោះដែលត្រូវបានលក់ក្នុងអាជីវកម្មផ្លូវភេទច្រើនតែទទួលរងអំពើរំលោភសេពសន្ថវៈជាប្រចាំ។ ទន្ទឹមនឹងនេះនាងក៏អាចត្រូវរងការវាយដំ ឬមេបនបង្ខំឲ្យប្រើប្រាស់គ្រឿងញៀនដើម្បីធ្វើឲ្យនាងចុះចូលជាមួយគេជានិច្ច ហើយមិនរត់គេចទៅណា។ ស្រដៀងគ្នានេះ

[៦២] http://www.humantrafficking.org/countries/cambodia

ដែរ ស្ត្រីណាដែលគេបង្ខំឲ្យធ្វើការងារក្នុងផ្ទះក៏អាចងាយរងគ្រោះពីការរំលោភបំពានលើរាងកាយ និងផ្លូវភេទដែរពីសំណាក់ចៅកែ និងមនុស្សផ្សេងៗទៀតនៅក្នុងផ្ទះនោះ ។

<u>ករណីសិក្សា: រឿងរបស់សោភា</u>

ខ្ញុំឈ្មោះ សោភា អាយុ១៩ឆ្នាំ។ ថ្ងៃមួយនៅចុងឆ្នាំ២០០៣ មីងខ្ញុំបានមកលេងគ្រួសាររបស់ខ្ញុំ។ ប្រៀបធៀបជាមួយក្រុមគ្រួសាររបស់ខ្ញុំ មីងខ្ញុំជាអ្នកធូរធារណាស់ ហើយគាត់តែងតែមកលេងក្រុមគ្រួសារខ្ញុំ ព្រមទាំងឲ្យលុយដោយសារតែពួកខ្ញុំក្រីក្រពេក។ ពេលគាត់មកលេង ពេលនោះគាត់បាននិយាយថា ខ្ញុំគួរតែទៅទីក្រុងដើម្បីរកការងារធ្វើ។ គាត់និយាយថា ខ្ញុំអាចរកប្រាក់កាសបានច្រើន ហើយបើទៅគាត់នឹងជួយរកការងារឲ្យខ្ញុំនៅក្នុងហាងលក់អាហារ។ ខ្ញុំមិនចង់ទៅទាល់តែសោះ ពីព្រោះខ្ញុំមិនចង់ចាកចេញពីក្រុមគ្រួសារទៅរស់នៅទីក្រុងឡើយ។ ខ្ញុំធ្លាប់បានទៅទីក្រុងពីរបីដងប៉ុណ្ណោះ ហើយជានិច្ចកាលខ្ញុំទៅជាមួយឪពុកម្តាយខ្ញុំ។ ប៉ុន្តែដោយសារតែឪពុកម្តាយខ្ញុំក្រីក្រពេក ហើយខ្ញុំដឹងថាពួកគេត្រូវការប្រាក់កាស ខ្ញុំក៏ធ្វើតាមបំណងរបស់ឪពុកម្តាយខ្ញុំ គឺទៅទីក្រុងជាមួយមីងខ្ញុំ។ ពេលខ្ញុំមកដល់ទីក្រុង មីងខ្ញុំបាននាំខ្ញុំទៅហាងខារ៉ាអូខេមួយកន្លែង ជាកន្លែងដែលគាត់និយាយថា គាត់ធ្វើការនៅទីនោះ។ ខ្ញុំគិតថាការងារទីនោះគ្រាន់តែឲ្យខ្ញុំបម្រើភេសជ្ជៈ និងជូតតុតែប៉ុណ្ណោះទេ។ ស្រាប់តែមីងខ្ញុំនាំខ្ញុំទៅក្នុងបន្ទប់មួយនៅខាងក្រោយ ហើយនិយាយថាខ្ញុំត្រូវរួមភេទជាមួយបុរសៗ ហើយគាត់ថាឲ្យខ្ញុំ២០ដុល្លាក្នុងមួយខែ។ ខ្ញុំតក់ស្លុតយ៉ាងខ្លាំង ហើយខ្ញុំមិនដឹងត្រូវធ្វើយ៉ាងម៉េចទេ។ ខ្ញុំនៅតែក្នុងបន្ទប់ខាងក្រោយនោះ ហើយយំឥតឈប់។ ក្រោយមកខ្ញុំបានប្រាប់មីងខ្ញុំថា ខ្ញុំមិនរួមភេទជាមួយបុរសណាទេ ហើយសុំត្រឡប់ទៅផ្ទះវិញ។ ខ្ញុំប្រាប់គាត់ថា ឪពុកម្តាយខ្ញុំមិនឲ្យខ្ញុំធ្វើបែបនេះទេ។ មីងខ្ញុំតបមកខ្ញុំវិញថា គាត់មិនខ្វល់ទេ ហើយគាត់យកខ្សែភ្លើងមកវាយខ្ញុំនៅលើខ្នងរហូតដល់ចេញឈាម ។ ខ្ញុំយំពេញមួយយប់។ ស្អែកឡើងត្រូវរួមភេទជាមួយបុរសជាច្រើននាក់។ ខ្ញុំបានបាត់បង់ភាពបរិសុទ្ធរបស់ខ្ញុំ ហើយខ្ញុំមានអារម្មណ៍អាម៉ាស់ជាខ្លាំង ចំពោះបញ្ហាដែលបានកើតឡើងនេះ។

"ប្រាំពីរថ្ងៃក្រោយមក ខ្ញុំមិនអាចទ្រាំរស់នៅទីនោះបានទៀតទេ។ ថ្ងៃមួយខ្ញុំបានប្រាប់មីងខ្ញុំថា ខ្ញុំចង់ទៅផ្សារដើម្បីទិញស្បែកជើង។ ខ្ញុំគិតថា ដោយសារតែខ្ញុំធ្លាប់រួមភេទជាមួយបុរសជាច្រើននាក់រួចមកហើយ ដូច្នេះមីងខ្ញុំមិននឹកស្មានថាខ្ញុំរត់គេចទេ ទើបគាត់អនុញ្ញាតឲ្យខ្ញុំទៅផ្សារតែឯង។ ពេលនោះ ខ្ញុំណាត់ជួបជាមួយបងថ្លៃខ្ញុំនៅផ្សារ ហើយយើងអាចជិះម៉ូតូទៅផ្ទះរបស់គាត់ ពេលដល់ទីនោះខ្ញុំបានរៀបរាប់ប្រាប់គាត់អំពីរឿងរ៉ាវដែលកើតឡើងចំពោះខ្ញុំ។ ខ្ញុំមិនចង់ហ៊ានប្រាប់គាត់ទេ ប៉ុន្តែគាត់ស្តាប់ដោយយកចិត្តទុកដាក់ និងជឿខ្ញុំ។ គាត់គិតថា មីងខ្ញុំធ្វើបែបនេះចំពោះខ្ញុំ ជាអំពើអាក្រក់ណាស់ ហើយយើងគួរតែរាយការណ៍ប្រាប់នគរបាល។ គាត់បានជូនខ្ញុំទៅប្តឹងនៅប៉ុស្តិ៍នគរបាលនៅថ្ងៃនោះ។ ក្រោយមកបងថ្លៃខ្ញុំបានប្រាប់រឿងរ៉ាវនេះទៅឪពុកម្តាយខ្ញុំ។" ពេលឪពុកម្តាយខ្ញុំបានដឹងរឿងនេះ ពួកគាត់មានការតក់ស្លុតយ៉ាងខ្លាំងចំពោះអ្វីៗដែលបានកើតឡើង ហើយបានប្រាប់ខ្ញុំថាកុំឲ្យរាយការណ៍ប្រាប់នគរបាល ហើយគួរតែដកពាក្យបណ្តឹងវិញទៅ។ "ពេលខ្ញុំសួរថាហេតុម៉េចបានជាត្រូវដកពាក្យបណ្តឹង ឪពុកម្តាយខ្ញុំមានប្រសាសន៍ថា មីងខ្ញុំជាអ្នកមានទ្រព្យធនច្រើនណាស់ យើងមិនគួរខឹងគាត់ទេ បើយើងប្តឹងគាត់អាចបង្កឲ្យមានបញ្ហាលំបាក។ ខ្ញុំនៅតែខឹងមីងខ្ញុំយ៉ាងខ្លាំង ហើយខ្ញុំមិនយល់ព្រមតាមឪពុកម្តាយខ្ញុំទេ។ ដោយមានការជួយពីសំណាក់អង្គការមិនមែនរដ្ឋាភិបាលផងនោះ ខ្ញុំនៅតែបន្តប្តឹងទៅនគរបាលទៀត។ ប៉ុន្តែក្រោយមក នៅក្នុងសប្តាហ៍នោះ គេបានចុះផ្សាយរូបថតខ្ញុំ និងរឿងរ៉ាវរបស់ខ្ញុំនៅលើទំព័រសារព័ត៌មាន តាមមើលទៅទំនងជានគរបាលបានរាយការណ៍រឿងរបស់ខ្ញុំទៅ

ខាងសារព័ត៌មាន។ ខ្ញុំដឹងថាមនុស្សគ្រប់គ្នានៅក្នុងភូមិខ្ញុំពិតជាបានដឹងអំពីរឿងខ្ញុំ ហើយខ្ញុំមានអារម្មណ៍អាម៉ាស់យ៉ាងខ្លាំងចំពោះឪពុកម្តាយខ្ញុំ។ ទីបំផុតខ្ញុំត្រូវឡើងតុលាការ ៣ដងដើម្បីបកស្រាយរឿងរ៉ាវ ដែលបានកើតឡើង។ អង្គការមិនមែនរដ្ឋាភិបាលមួយបានជួយរកមេធាវីឲ្យខ្ញុំ ប៉ុន្តែខ្ញុំនៅតែពិបាកពេលទៅតុលាការម្តងៗ ខ្ញុំត្រូវនិយាយម្តងហើយម្តងទៀតអំពីរឿងដែលគេបង្ខំខ្ញុំធ្វើ ហើយមនុស្សនៅក្នុងតុលាការសុទ្ធតែប្រុសៗដែលជាអ្នកសួរខ្ញុំ ធ្វើឲ្យខ្មាស់គេណាស់។ មេធាវីខ្ញុំបានលើកទឹកចិត្តឲ្យខ្ញុំបន្តរឿងនេះទៅមុខទៀត ហើយនិយាយថា មិនមែនតែខ្ញុំម្នាក់ឯងទេ ធ្លាប់មានស្ត្រីៗជាច្រើនមានរឿងដូចនេះដែរ។ ទោះបីជាខ្ញុំទៅតុលាការជាច្រើនដងក៏ដោយ ក៏គេមិនទាន់ចាប់មីងខ្ញុំទៀត ហើយខ្ញុំមិនដឹងថារឿងខ្ញុំ ទៅថ្ងៃមុខនឹងទៅយ៉ាងណាទេ”។

## ១.៤ បទរុកគួនខាងផ្លូវភេទ (Sexual Harrasment)

បទរុកគួនខាងផ្លូវភេទ (មាត្រា២៥០ នៃក្រមព្រហ្មទណ្ឌ) គឺជា "អំពើដែលបុគ្គលម្នាក់រំលោភអំណាចដែលមុខងាររបស់ខ្លួនប្រគល់ឲ្យធ្វើការគាបសង្កត់ម្តងហើយម្តងទៀតទៅលើអ្នកដទៃ ក្នុងគោលបំណងទទួលការអនុគ្រោះខាងផ្លូវភេទ”។ គេពិបាករកទិន្នន័យអំពីបញ្ហានេះខ្លាំងណាស់ ដោយកន្លងមកមានការសិក្សាតិចតួចបំផុតអំពីបញ្ហានេះ ហើយមានតែវិស័យកាត់ដេរ និងស្ត្រីលក់ស្រាបៀរតែប៉ុណ្ណោះដែលធ្លាប់ត្រូវបានធ្វើការសិក្សាស្រាវជ្រាវ។ របាយការណ៍ស្តីពី "អំពើហិង្សាលើស្ត្រី និងអាជីវកម្មផ្លូវភេទ”[៦៣] ចងក្រងដោយក្រសួងកិច្ចការនារី បានសរសេរថា កម្មករស្ត្រី១នាក់ ក្នុងចំណោម១០នាក់ ធ្លាប់រងការរុកគួនខាងផ្លូវភេទនៅកន្លែងធ្វើការ ចំណែកឯស្ត្រីលក់ស្រាបៀវិញ ៤នាក់ ក្នុងចំណោម៥នាក់ សុទ្ធតែបានជួបប្រទះរឿងបែបនេះដែរ។ ស្ត្រីលក់ស្រាបៀប្រមាណ៨០% ធ្លាប់មានទំនាក់ទំនងផ្លូវភេទដែលមិនមានបំណង ហើយប្រមាណ ៣៨%ទៀតត្រូវប្រព្រឹត្តការរួមភេទដោយបង្ខំនៅកន្លែងធ្វើការ។ ស្ត្រីប្រកបរបរបំរើការកំសាន្តដោយផ្ទាល់ និងដោយប្រយោលជាប្រភេទស្ត្រីដែលជួបប្រទះរឿងរ៉ាវនៃការរុកគួនខាងផ្លូវភេទក្នុងកម្រិតខ្ពស់ជាងគេ ទាំងរំលោភសេពសន្ថវៈ និងបំពានផ្លូវភេទ។

## ១.៥ ប្រស្នា

**ការស្តីបន្ទោសជនរងគ្រោះ ឬប្រព័ន្ធលាក់បាំងៈ** ក្នុងស្ថានភាពហិង្សាផ្លូវភេទដូចជា(រំលោភសេពសន្ថវៈ ការជួញដូរ ការធ្វើអាជីវកម្មផ្លូវភេទ និងការរុកគួនខាងផ្លូវភេទ) សុទ្ធត្រូវបានគេទម្លាក់ការទទួលខុសត្រូវទៅលើស្ត្រី ព្រមទាំងការទទួលនូវចំណែកផលវិបាកមិនស្មើ និងមិនយុត្តិធម៌ថែមទៀតរវាងស្ត្រី និងបុរស។ ដោយជនល្មើសអាចរស់នៅក្នុងជីវិតមួយ ដែលគ្មានអាស្រូវកេរ្តិ៍ឈ្មោះក្នុងសង្គមអ្វីឡើយ ចំណែកឯស្ត្រីវិញត្រូវបានគេកត់សម្គាល់ថា ជាស្ត្រីដែលធ្លាប់ត្រូវបានបង្ខូចរួចហើយ ព្រមទាំងក្លាយជាស្ត្រីគ្មានតម្លៃទៀតទេ ដែលនេះជាស្ថានភាពមួយនាំឲ្យមានភាពអាម៉ាស់ និងមានអារម្មណ៍ថាជាការខុសឆ្គង។ ក្នុងសង្គមកម្ពុជា ភាពបរិសុទ្ធរបស់ស្ត្រីត្រូវបានគេចាត់ទុកថា មានសារៈសំខាន់សម្រាប់អាពាហ៍ពិពាហ៍ និងភាពជាម្តាយ។ ដូច្នេះជនរងគ្រោះ ដោយអំពើហិង្សាផ្លូវភេទត្រូវបានគេយល់ថាជាស្ត្រីដែលមិនល្អរួចទៅហើយ ទោះបីជាបញ្ហានោះ ជាការរួមភេទដោយគ្មានការព្រមព្រៀង ឬដោយត្រូវគេប្រើហិង្សាមកលើយ៉ាងណាក៏ដោយ ។ "ច្បាប់ស្រី” បានចែងយ៉ាងច្បាស់ថា ស្ត្រីអភ័ព្វបែបនេះ គឺជាកំហុសរបស់ស្ត្រី ហើយអាចបណ្តាល

[៦៣] អំពើហិង្សាលើស្ត្រី និងអាជីវកម្មផ្លូវភេទ ក្រសួងកិច្ចការនារី ។

មកពីស្ត្រីទាំងនោះមានអាកប្បកិរិយាមិនល្អផងទើបបានជាមានបញ្ហាបែបនេះកើតឡើង។ នេះគឺជាទស្សនៈមិនត្រឹមត្រូវទាល់តែសោះ។

ដោយគ្រាន់តែនិយាយអំពីសក្តានុពលនៃការខូចខាតដល់ខ្លួន ដែលជនរងគ្រោះអាចរងការឈឺចាប់ថែមទៀត ប្រសិនបើនាងហ៊ានរាយការណ៍អំពីបញ្ហាបទល្មើសផ្លូវភេទដែលកើតឡើង។ នោះគេអាចយល់បានថា ស្ត្រីជាច្រើនបានជ្រើសរើសយកការឈឺចាប់យ៉ាងស្ងៀមស្ងាត់ និងឯកោតែម្នាក់ឯងទៅវិញ។ ស្ត្រីកម្ពុជាពុំអាចរកបរិយាកាសដែលមានជំនួយផ្នែកចិត្តសាស្ត្របាន ហើយក៏មិនអាចរកសហគមន៍ដែលយកចិត្តទុកដាក់ជួយបញ្ហារបស់ស្ត្រីទាំងនោះបានដែរ។ ក្នុងន័យនេះ ឧបសគ្គដែលប្រឈមដ៏ធំបំផុតក្នុងការបញ្ចប់ស្ថានភាពដែលមិនអាចជៀសផុតនេះគឺ:

១) ជាធម្មតា អំពើហិង្សាលើស្ត្រីគេមិនចាត់ទុកថា ជាបទល្មើសព្រហ្មទណ្ឌទេ ហើយគ្មានទោសចំពោះជនល្មើសទេ បញ្ហានេះកាន់តែទម្លាក់ទឹកចិត្តជនរងគ្រោះមិនឲ្យនិយាយអំពីអ្នកប្រព្រឹត្តមកលើនាងថែមទៀត ព្រមទាំងធ្វើឲ្យស្ត្រីពិបាកក្នុងការយកឈ្នះលើបញ្ហាចិត្តសាស្ត្រ ដែលទាក់ទងនឹងអំពើហិង្សានោះថែមទៀត។

២) យន្តការការពារជនរងគ្រោះនៅមានកម្រិតនៅឡើយ ដោយការបណ្តុះបណ្តាលនៅមានកម្រិតខ្សោយ ព្រមទាំងធនធានក៏នៅមានការខ្វះខាតច្រើន។

៣) ជនរងគ្រោះ ត្រូវចំណាយថវិកាច្រើនក្នុងដំណើរការបណ្តឹងផ្នែកច្បាប់ ហើយដោយស្ត្រីភាគច្រើនខ្វះមធ្យោបាយផ្នែកហិរញ្ញវត្ថុ ដូច្នេះមធ្យោបាយដោះស្រាយតាមច្បាប់កម្រត្រូវបានបន្តអនុវត្តតទៅទៀតណាស់។

៤) កង្វះការផ្តន្ទាទោសចំពោះអំពើរំលោភសេពសន្ថវៈ និងជួញដូរផ្លូវភេទនោះនាំឲ្យជនល្មើសមានអារម្មណ៍ថា ពួកគេអាចទទួលបានការអនុញ្ញាតឱ្យប្រព្រឹត្តបទល្មើសបែបនេះ។ ជនរងគ្រោះដោយអំពើរំលោភសេពសន្ថវៈមួយចំនួនមានអារម្មណ៍ថា ជនល្មើសដែលប្រព្រឹត្តពុំត្រូវបានផ្តន្ទាទោសទេ ហើយភាពអស់សង្ឃឹមនេះអាចរារាំងដល់ស្ត្រីទាំងនោះ មិនឲ្យរាយការណ៍បទល្មើសរំលោភសេពសន្ថវៈថែមទៀត។ ប៉ុន្តែឧបសគ្គដែលធំជាងគេបំផុតចំពោះការផ្តន្ទាទោសជនល្មើសក្នុងអំពើរំលោភសេពសន្ថវៈ គឺការអនុវត្តន៍ខុសច្បាប់ ដោយការសងសំណងរដ្ឋប្បវេណី។ សំណងរដ្ឋប្បវេណីនេះ គឺជាការដោះស្រាយក្រៅប្រព័ន្ធតុលាការដោយមានប្រសិទ្ធិភាពរវាងជនរងគ្រោះ និងជនល្មើស។ ជនល្មើសបង់ប្រាក់ឲ្យជនរងគ្រោះកុំឲ្យប្តឹង។ បញ្ហាបែបនេះ ច្រើនកើតឡើងនៅពេលដែលជនល្មើសជាអ្នកធូរធារ ឬមានអំណាចជាអាជ្ញាធរ។

៥) ពុំមានហេដ្ឋារចនាសម្ព័ន្ធដើម្បីធ្វើការស៊ើបអង្កេត និងផ្តន្ទាទោសករណីជួញដូរ និងការធ្វើអាជីវកម្មផ្លូវភេទទេដែលបណ្តាលឲ្យមានការលំបាកក្នុងការចាប់ជនល្មើសយកទៅតុលាការ។

៦) បទរុកគួនខាងផ្លូវភេទក៏ស្ថិតនៅតែក្រោមការឃ្លាំមើលដដែល ដែលតាមមើលទៅគ្មានអង្គការណា ក្រៅពីអង្គការពលកម្មអន្តរជាតិដែលដោះស្រាយបញ្ហានេះទេ។

## ២. *អនុសាសន៍*

សូមរាជរដ្ឋាភិបាលលោកមេត្តា:

១) ជានាឲ្យការអនុវត្តន៍ច្បាប់ទាំងអស់ ដែលទាក់ទងនឹងអំពើហិង្សាលើស្ត្រី ស្របតាមខ្លឹមសាររបស់
CEDAW និងលិខិតុបករណ៍អន្តរជាតិនានា។

២) អនុវត្តក្រមព្រហ្មទណ្ឌថ្មីគ្រង់ជំពូក ដែលចែងអំពីការរំលោភសេពសន្ថវៈដែលកំណត់និយមន័យទូលំទូលាយអំពីធាតុ "យល់ព្រម"។

៣) អនុវត្តក្រមព្រហ្មទណ្ឌថ្មីក្នុងករណីរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍។

៤) អនុវត្ត "ច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ" រួមទាំងអំពើជួញដូរកំលាំងពលកម្មឆ្លងដែន និងជួញដូរអនីតិជនផងដែរ។ ត្រូវតែផ្តន្ទាទោសជនល្មើសតាមច្បាប់។ បញ្ញត្តិដែលចែងអំពីកិច្ចការពារជនរងគ្រោះ ដោយអំពើជួញដូរ រួមទាំងការស្តារនីតិ - សម្បទា និងការធ្វើមាតុភូមិនិវត្តក្នុងករណីចាំបាច់ ព្រមទាំងអនុវត្តសេវាកម្មជំនួយចាំបាច់មួយចំនួនទៀតផង។

៥) ចុះយុទ្ធនាការតស៊ូមតិជាប្រចាំដើម្បីអប់រំពលរដ្ឋកម្ពុជា (ផ្តោតលើស្ត្រី) អំពីប្រធានបទរំលោភសេពសន្ថវៈ សិទ្ធិរបស់ជនរងគ្រោះដោយអំពើរំលោភសេពសន្ថវៈ ច្បាប់ស្តីពីបញ្ហារំលោភសេពសន្ថវៈ និងដំណើរការនៃបទព្រហ្មទណ្ឌផងដែរ។

៦) អប់រំមន្រ្តីផ្នែកច្បាប់ និងតុលាការអំពីការបកស្រាយបញ្ញត្តិទាក់ទងនឹងបទល្មើសរំលោភសេព - សន្ថវៈឲ្យបានត្រឹមត្រូវ។

៧) ផ្តន្ទាទោសមន្ត្រីណាដែលបកស្រាយខុស និងរំលោភច្បាប់ រួមទាំងអ្នកដែលចូលរួម ឬសម្របសម្រួលក្នុងការដោះស្រាយដោយសំណងរដ្ឋប្បវេណីផង។

៨) ផ្តល់ការប្រឹក្សាយោបល់ និងជម្រកស្តារនីតិសម្បទាដល់ជនរងគ្រោះដោយអំពើរំលោភ និងជួញដូរ។

៩) បើកវគ្គបណ្តុះបណ្តាលជាបន្តបន្ទាប់អំពីបទល្មើសជួញដូរដល់នគរបាល និងមន្ត្រីព្រំដែន ដែលមានភារកិច្ចទាក់ទងនឹងអំពើជួញដូរ និងមជ្ឈមណ្ឌលពាណិជ្ជកម្មផ្លូវភេទ។

១០) សហការជាមួយសង្គមស៊ីវិល ដើម្បីឱ្យមានការយកចិត្តទុកដាក់លើបញ្ហា ដែលបន្ទាន់ជាទីបំផុតចំពោះអំពើហិង្សាលើស្ត្រី ព្រមទាំងប្រើប្រាស់រាល់ឱកាសទាំងអស់ដើម្បីទទូចឲ្យរដ្ឋាភិបាលកម្ពុជាសម្រេចឲ្យបានកាតព្វកិច្ចក្រោមអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ។

១១. រៀបចំមូលដ្ឋានយុទ្ធសាស្រ្តការងារ ដើម្បីធ្វើឲ្យមានការផ្លាស់ប្តូរជាវិជ្ជមាននូវទស្សនៈពី

យេនឌ័រទាំងឡាយចំពោះបញ្ហាផ្លូវភេទរបស់ស្ត្រី។

១២) ផ្សព្វផ្សាយចំណេះដឹងអំពីសិទ្ធិស្ត្រី ដែលត្រូវរួចផុតពីការឈឺចាប់ ដែលស្ត្រីត្រូវតែទទួលបាននូវសេចក្តីសុចរិត ផ្លូវកាយ និងសីលធម៌ ហើយត្រូវតែរក្សានូវសេចក្តីថ្លៃថ្នូររបស់ស្ត្រីឲ្យបាន និងមិនត្រូវបង្ខំស្ត្រីឲ្យធ្វើអ្វីមួយដែលមិនស្របតាមឆន្ទៈរបស់អ្នកទាំងនោះឡើយ។

## សេចក្តីសន្និដ្ឋាន



សុភាសិតរបស់កម្ពុជាដ៏ល្បីល្បាញមួយបាននិយាយថា "បុរសគឺជាមាស ហើយស្ត្រីជាសំពត់សរ"។ សុភាសិតនេះនៅតែត្រូវបានគេយកមកប្រើប្រាស់ជាប់ជាប្រចាំរហូតដល់សព្វថ្ងៃនេះនៅក្នុងមនោគមវិជ្ជារបស់ប្រទេសកម្ពុជា។ សុភាសិតនេះបានធ្វើឲ្យគំនិតដែលគិតថាបុរសមានតម្លៃខ្ពស់ជាងស្ត្រីដែលមានរូបរាងស្អាត ងាយរងគ្រោះ និងងាយប្រឡាក់។ ប្រសិនបើសំពត់សរ "ប្រឡាក់" នោះនឹងមិនងាយសំអាតឲ្យបានជ្រះស្អាតដូចដើមទេ។ ដោយមូលហេតុនេះហើយទើបក្រសួងកិច្ចការនារីបានប្រើប្រាស់ពំនោលមួយឃ្លាថា "ស្ត្រីគឺជាត្បូង" ដើម្បីទប់ទល់នឹងសុភាសិតថា "បុរសជាមាស"។ ក្រសួងបានបើកយុទ្ធនាការយុទ្ធសាស្ត្រ៥ឆ្នាំ ដើម្បីដាក់ទស្សនៈយេនឌ័រចូលទៅក្នុងស្ថាប័នរដ្ឋទាំងអស់។ គោលបំណងសំខាន់របស់រដ្ឋាភិបាលស្របតាមកម្មវិធីនេះគឺដើម្បីកាត់បន្ថយភាពក្រីក្រក្នុងចំណោមស្ត្រី[៦៤]។

ប្រទេសមួយដូចជាកម្ពុជានេះ កំពុងតស៊ូយ៉ាងខ្លាំងដើម្បីកាត់បន្ថយភាពក្រីក្រ មិនអាចសម្រេចបានការអភិវឌ្ឍន៍ប្រកបដោយសុខដុមរមនាណាមួយ ដោយពុំមានការចូលរួមចំណែកឲ្យបានពេញលេញពីសំណាក់ស្ត្រីនៅក្នុងគ្រប់វិស័យនៃសង្គមទាំងអស់ឡើយ។

លក្ខខណ្ឌដើម្បីលើកកំពស់ស្ថានភាពស្ត្រីនៅកម្ពុជាគឺ:

១) សុខភាពល្អ ដែលផ្តល់នូវភាពជាសះភ្លាមៗផ្នែករាងកាយ និងផ្លូវចិត្ត។

២)ការអប់រំប្រាកដប្រជា ដែលជាលក្ខខណ្ឌដំបូង ដើម្បីធ្វើឲ្យយល់កាន់តែច្បាស់ជាងមុនអំពីបរិយាកាសសង្គម និងវិជ្ជាជីវៈ។

៣) មានសិទ្ធិទទួលបានយុត្តិធម៌ និងការងារត្រឹមត្រូវ ដែលផ្តល់ស្វ័យភាពសេដ្ឋកិច្ច ជាមួយនឹងការអប់រំដែលជាទ្រព្យសម្បត្តិពិសេសបំផុតសម្រាប់ការពារស្ត្រីពីអំពើហិង្សា និងការរំលោភបំពានផ្សេងៗ។

យើងទាំងអស់គ្នាសូមសំណូមពរ ដោយទទូចដល់រដ្ឋាភិបាលសូមលោកមេត្តាបន្តកិច្ចប្រឹងប្រែងក្នុងការដោះស្រាយបញ្ហាទន់ខ្សោយក្នុងប្រព័ន្ធសុខាភិបាល ដែលនៅតែបណ្តាលឱ្យអត្រាមរណៈភាពមាតា

---

[៦៤] ស្ត្រីកម្ពុជាមានធនធានតិចជាងបុរស៤ដង ។

នៅតែមានកម្រិតខ្ពស់នៅឡើយ។ មានកិច្ចការជាច្រើនទៀតដែលត្រូវធ្វើដើម្បីបង្កើនការយល់ដឹង និងបណ្តុះបណ្តាលបុគ្គលិកសុខាភិបាល ឆ្មប និងសាធារណៈជនទូទៅ ដើម្បីសម្រេចបានសន្តិសុខសុខភាពរបស់ស្ត្រី។ ជាពិសេសពេលមានផ្ទៃពោះ និងពេលរួមភេទ ស្ត្រីទាំងនោះសុទ្ធតែងាយឆ្លងមេរោគអេដស៍ ប្រសិនបើស្វាមី ឬដៃគូរបស់អ្នកទាំងនោះ មានផ្ទុកមេរោគអេដស៍ ឬជម្ងឺកាមរោគនោះ។

សូមឱ្យរដ្ឋាភិបាលលោកមេត្តាឧបត្ថម្ភថវិកាដល់កម្មវិធីលើកកំពស់ការយល់ដឹង និងផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ ដើម្បីជៀសវាងការចំណាយច្រើនដូចការផ្សាយពាណិជ្ជកម្មជាដើម។ ទន្ទឹមនឹងកម្មវិធីលើកកំពស់ការយល់ដឹង និងផ្សព្វផ្សាយ ព្រមទាំងត្រូវប្រឹងប្រែងដើម្បីកែលំអរ និងបង្កើនចំនួនមណ្ឌលសុខភាពនៅតាមតំបន់ជនបទដាច់ស្រយាលឱ្យកាន់តែច្រើនជាងមុនផង។ ត្រូវផ្តោតការយកចិត្តទុកដាក់ក្នុងការផ្គត់ផ្គង់ឧបករណ៍ជាមូលដ្ឋាន ដើម្បីឱ្យមានលទ្ធភាពកាន់តែប្រសើរឡើងក្នុងការដោះស្រាយបញ្ហាផ្នែកសុខភាពបន្ទាន់ រួមទាំងការមានផ្ទៃពោះ និងសម្រាលកូនផង។ យុទ្ធនាការលើកកំពស់ការយល់ដឹង និងការជម្រុញប្រើប្រាស់ស្រោមអនាម័យដោយឥតគិតថ្លៃ អាចជួយឱ្យស្ត្រីការពារខ្លួន និងដៃគូពីការឆ្លងជម្ងឺអេដស៍ និងកាមរោគបានកាន់តែប្រសើរជាងមុន។ មន្ទីរពេទ្យ និងមណ្ឌលសុខភាពនានា ត្រូវតែទទួលការលើកទឹកចិត្ត និងថវិកាឧបត្ថម្ភដើម្បីផ្តល់ការធ្វើតេស្តដោយមិនយកកំរៃខាងជំងឺអេដស៍ និងកាមរោគផ្សេងៗ។

ឥឡូវដល់ពេលវេលាត្រូវតែបន្តការខិតខំប្រឹងប្រែង ដើម្បីកែលំអរស្ថានភាពអប់រំដែលមិនសូវល្អនៅកម្ពុជា (ការថយចុះធនធាន កង្វះខាតគ្រូ និងកង្វះការបណ្តុះបណ្តាល អំពើពុករលួយ គុណភាពបង្រៀនទាប រៀនតែមួយពេល ថ្នាក់រៀនចង្អៀត អត្រាឈប់រៀននៅតែខ្ពស់)។ ជាធម្មតា ស្ថានភាពរបស់កុមារីពិបាកជាងស្ថានភាពរបស់កុមារា ហើយអត្រាឈប់រៀនរបស់កុមារីខ្ពស់ជាងកុមារា។ ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងផ្សព្វផ្សាយរបស់រដ្ឋាភិបាលទូលំទូលាយយ៉ាងណាក៏ដោយ ក៏លទ្ធផលទទួលបាននៅតែមិនទាន់ដូចការសង្ឃឹមទុកនៅឡើយទេ។

ក្រសួងអប់រំបានប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីបង្កើនចំនួនសិស្សស្រីនៅគ្រប់កម្រិតថ្នាក់ទាំងអស់ ប៉ុន្តែតាមតួលេខបច្ចុប្បន្នបង្ហាញឱ្យឃើញថា ចំនួនកុមារីចុះឈ្មោះចូលរៀនក្នុងមួយឆ្នាំៗនៅតែតិចជាងកុមារាឆ្ងាយណាស់។

នៅក្នុងស្ថានភាពរើសអើងលើស្ត្រីនៅកម្ពុជា អាស្រ័យដោយសម្ពាធសេដ្ឋកិច្ច ការរៀនសូត្ររបស់កុមារីអាយុពី១៥ឆ្នាំ ទៅ១៧ឆ្នាំ ច្រើនតែត្រូវបានជំនួសដោយការងារទៅវិញ ។

វិសមភាពរវាងបុរស និងស្ត្រីបានធ្វើឱ្យមានការប៉ះពាល់ជាអវិជ្ជមានលើស្ថានភាពស្ត្រីនៅកន្លែងធ្វើការ។ បញ្ហានេះ បានកាត់បន្ថយលទ្ធភាពទទួលបានព័ត៌មានរបស់ស្ត្រី និងលទ្ធភាពក្នុងការការពារសិទ្ធិរបស់ស្ត្រីទាំងនោះ ការពារកម្រិតប្រាក់ឈ្នួល និងទប់ទល់ជាមួយការរុកគួនខាងផ្លូវភេទ។ អាស្រ័យដោយគ្មានច្បាប់ជាក់លាក់ណាមួយដើម្បីដាក់ទណ្ឌកម្មចំពោះការរើសអើងយ៉េនឌ័រនៅកន្លែងធ្វើការងារ ជាធម្មតាស្ត្រីច្រើនតែទទួលបានប្រាក់ឈ្នួលទាបជាងបុរស ព្រមទាំងប្រឈមនឹងការលំបាកជាច្រើន ក្នុងការធ្វើឱ្យអ្នកគ្រប់គ្រងគោរពសិទ្ធិ ដូចជាការឈប់សម្រាកមាតុភាពជាដើម។

ភាពក្រីក្រ ការអប់រំទាប និងកង្វះឱកាសការងារនៅតាមជនបទ បានជម្រុញឱ្យស្ត្រីក្មេងៗជាច្រើនចាកចេញពីលំនៅដ្ឋាន និងធ្វើការនៅក្នុងទីផ្សារដែលពោរពេញទៅដោយហានិភ័យខ្ពស់ (កន្លែងកំសាន្ត ម៉ាស្សា ខារ៉ាអូខេ និងបនពេស្យា) ជាដើម ដែលសុទ្ធតែជាកន្លែងធ្វើឱ្យអ្នកទាំងអស់នោះងាយរងគ្រោះពីសំណាក់អំពើអាជីវកម្ម និងការរំលោភបំពានផ្លូវភេទ។

ហេតុនេះ យើងទាំងអស់គ្នាសន្និដ្ឋានថា រដ្ឋាភិបាលនៅសល់ផ្លូវវែងឆ្ងាយទៀតដើម្បីធ្វើដំណើរ ហើយសូមផ្តល់អនុសាសន៍យ៉ាងមុតមាំជូនរដ្ឋាភិបាល សូមបន្តការទទួលខុសត្រូវក្នុងការអនុវត្តន៍អនុសាសន៍របស់គណៈកម្មាធិការនៃអង្គការសហប្រជាជាតិទទួលបន្ទុក CEDAW ប្រកបដោយប្រសិទ្ធិភាព។

យើងទាំងអស់គ្នា ត្រូវតែសហការជាមួយគ្នាដើម្បីកែលំអរស្ថានភាពស្ត្រីនៅកម្ពុជា និងរៀបចំអនាគតប្រទេសរបស់យើង។

# ឧបសម្ព័ន្ធ

## ឯកសារយោង


Amnesty International, Breaking The Silence, Sexual Violence in Cambodia, 2010

An M., Bush, S. Lake, B., Lopez S., McCants, JS., Skidmore, P. and Velasco, C., Idealism Without Illusions: Lessons from Post-Conflict Elections in Cambodia, Rwanda and Sudan, Princeton University, 2008

Asia Pacific Forum on Women, Law and Development. Seethings and Seatings: Strategies for Women´s Political Participation in Asia Pacific, 2005

Baureaksmey, Kim/ Schuette, Susanne 2007. Gender and Women Politics in Cambodia. Scoping study for the work of the Southeast Asia Program of the Heinrich Boell Foundation, Cambodia. Phnom Penh

Beijing 5 Working Group, Cambodia NGO Report on the Implementation of the Beijing Platform for Action', 2000

Brereton H., Lim V., Men's Talk/ Men Attitudes Towards Men, Women, and Violence Against Women in Cambodia, 2008

Bremmer J., Frost A., Haub C., Mather M., Ringheim K. & Zuelhke E., World Population Highlights: Key Findings from PRB's 2010 World Population Data Sheet, Population Bulletin, vol.65 (___), Population Reference Bureau, 2010 www.prb.org

Bridge Gender and Climate Change, Mapping the linkages. A scoping study on knowledge and gaps, 2008.

CAMBOW. The Cambodia Committee of Women. Violence Against Women: How Cambodian Laws Discriminate Against Women, 2007

CARE International Cambodia, A Good Wife: Discussions with Married Women about Life, Health, Marriage and Sexuality, 2001

CPWP, Committee to Promote Women in Politics: CDRI, COMFREL, CWPD, GAD/C, NICFEC, SILAKA,

WfP, and WMC. Report on Women in decision-making/ political participation of women, 2010.

CEDAW, Convention on the Elimination of Discrimination Against Women, 1979

Committee on the Elimination of all Forms of Discrimination against Women (CEDAW) 2006.

Concluding comments of the Committee on the Elimination of Discrimination Against Women. 34th session. CEDAW/C/KHM/CO/3. New York

Committee to Promote Women in Politics (CPWP) 2008. Collected Statistics on Women in Decision Making. Presentation at Reception Party of newly elected female members of the National Assembly in Cambodia in October 2008.

Committee to Promote Women in Politics (CPWP) 2009. Findings of interviews conducted with 59 members of Commune Committees for Women and Children (CCWC) in 9 provinces.

Committee for Free and Fair Elections in Cambodia (COMFREL) 2009a. Women`s Participation in

Politics and 2009 National Assembly Elections. Report. Phnom Penh

Committee for Free and Fair Elections in Cambodia (COMFREL) 2009b. Survey Report on Voters List and Registration. Phnom Penh

Desa, UN, The World´s Women 2010, Trends and Statistics, 2010

Domrei Research and Consulting, Sonroh Somruel & Violence Against Women in Cambodia, 2008

Drezin Jenny; Lioyd-Laney, Megan, Making a Difference: Strategic Communications to End Violence against Women, 2003

Donovan Robert J; Vlais Rodney, Vic Health Review of Communication Components of Social Marketing/Public Education Campaigns Focusing on Violence Against Women, 2005

Gender and Development for Cambodia (GAD/C), Deoum Troung Pram Hath in Modern Cambodia. A qualitative Exploration of Gender Norms, Masculinity and Domestic Violence, 2010

Dutta S., Energy as a Key Variable in Eradicating Extreme Poverty and Hunger: A Gender and Energy Perspective on Empirical Evidence on MDG #1 (draft). Report to DfID[៦៥] KaR R-8346 Gender as a Key Variable in Energy, 2005.

Economist Intelligence Unit, Country Report Cambodia*,* 1997

ESCAP/ADB/UNDP, Paths to 2015, MDG Priorities in Asia, Asia-Pacific MDG Report 2010/11, 2010

ICESCR, International Covenant on Economic, Social and Cultural Rights), 1976

*IFAD,* International Fund for Agricultural Development, Asia and the Pacific Division*, Gender Mainstreaming: IFAD's Experience in the Asia and the Pacific Region and Lessons Learned, 1999*

www.ifad.org/gender/progress/pi.

ILO, Global Employment Trends, 2010

Kelkar G. and Nathan D., Gender relation and the energy transition in the rural Asia. UNIFEM, South Asia Regional Office, 2002

Lambrou Y. and Piana G., Energy and Gender Issues in Rural Sustainable Development. Food and Agriculture Organization (FAO), United Nations, 2006

LICADHO, Licadho Women´s Rights Activity Report, 2009

LICADHO, Promoting and defending human rights in Cambodia. Case studies and NGO perceptions, 2009

LICADHO, Violence Against Women in Cambodia 2006, 2007

LICADHO, In Abstentia: The Right of Appeal & Cambodia's Inmate Transportation Crisis, 2010

LICADHO, Women's Rights Pilot Project 2007

LICADHO, The Situation of Women in Cambodia Report 2004

LICADHO, Rape and Indecent Assault in Cambodia Report 2004

LICADHO, Attacks & Threats Against Human Rights Defenders in Cambodia 2008-2009

Maffii, Margherita⁄Kong, Sineath 2008. Promoting Political Participation of Indigenous Women in Cambodia. Heinrich Boell Stiftung⁄GTZ. Phnom Penh

Matinga M., Energy as a Key Variable in Reducing Child Mortality: A Gender and Energy Perspective on Empirical Evidence on MDG #4. Report to DfID KaR R-8346 Gender as a Key Variable in Energy, 2005.

Matinga M., Energy as a Key Variable in Reducing HIV/AIDS and Major Diseases: A Gender and Energy Perspective on Empirical Evidence on MDG #6. Report to DfID KaR R-8346 Gender as a Key Variable in Energy, 2005

Millennium Development Goals, 2000.

Millennium Development Goals Report 2010 – Gender Brochure, United Nations Department of Economic and Social Affairs (DESA), July 2010

---

[៦៥] UK Department For International Development (DFID) is a United Kingdom government department

Millennium Development Reports 2010, UN, New York, 2010.

Ministry of Health, Health Strategic Plan 2008-2015. Accountability Efficiency Quality Equity Women in decision-making/ political participation of women[២២], 2010

Ministry of Women`s Affairs 2008. A Fair Share for Women. Cambodia Gender Assessment. Phnom Penh

Ministry of Women's Affairs, Ministry of Education, Youth and Sport, & Open Institute. (2010). Women and ICT in Education and Employment. Phnom Penh.

MoWA. Ministry of Women´s Affairs, A Fair Share for Women. Cambodia Gender Assessment, April 2008, Phnom Penh.

MoWA. Ministry of Women's Affairs Neary Rattanak II: Five Year Strategy 2005-2009

National Center for HIV/AIDS, Dermatology and STD, Report on women health improvement. Annual Report, 2009

National Election Commission (NEC) 2009. Final Results of Council Elections and Seat Divisions. Phnom Penh

NGO Forum on Cambodia Kathleen. Land is Life. Land conflict interventions in Cambodia. A review of cases Licadho: Prison Conditions in Cambodia 2008: Women in Prison, Phnom Penh, 2009

NGO Working Group 2009. Parallel Report in Cambodia. Submitted to the United Nations Committee on Economic, Social and Cultural Rights (ICESCR).

NIS, Report on the Socio-Economic Survey of Cambodia 1993/1994 1993/1994, 1995

Open Institute, Summary of the Cambodia Country Issue Paper on Violence Against Women and Information and Communication Technology, 2009

Oxfam⁄ Women for Prosperity (WfP) 2008. Strengthening the Voices of Women Leaders. Lessons from Cambodia. Programme Insights.

Pangjuani A., Energy as a Key Variable in Promoting Gender Equality and Empowering Women: A Gender and Energy Perspective on MDG #3, draft. Report to DfID KaR R-8346 Gender as a Key Variable in Energy, 2005

Polestico R. V., Gender and Energy in Southeast Asia, 2008

Polestico R. V., Gender and Energy in Southeast Asia. Energia vol.5, 2002.

RGC, National Poverty Reduction Strategy 2003-2005, 2002

RGC, Initial, Second and Third Report on the Implementation of CEDAW, Phnom Penh: RCG, 2003

RGC, Rectangular Strategy for Growth, Employment, Equity and Efficiency, Phnom Penh: RGC, 2004

RGC 2004. The Rectangular Strategy for Growth, Employment, Equity and Efficiency in Cambodia. Phnom Penh

RGC 2005a. Ministry of Planning. Cambodia Millennium Development Goals Report CMDG. Phnom Penh

RGC 2005b. Ministry of Women`s Affairs Five Year Strategic Plan 2005-2009. Neary Rattanak II. Phnom Penh

RGC 2005c. National Strategic Development Plan 2006-2010. Phnom Penh

SAWA, Up to the Sky. A Study on Gender Issues in Irrigation in Cambodia, provinces of Takeo and Prey Veng. Ahlers and Vlaar, The Netherlands, 1995

SECRETARIAT OF STATE FOR WOMEN´S AFFAIRS, Cambodia's Country Report, Women: Key to National Reconstruction, Phnom Penh, 1995

Secretariat Energia, International Network on Gender and Sustainable Energy, Synthesis report ENERGIA/DfID Collaborative Research Group on Gender and Energy (CRGGE), 2006

Paz Y Desarrollo, Situation of Indigenous Women in Cambodia with Focus in Northeast Region, 2010

TCI, Cambodia Agricultural Development Options Review (Phase I). Sector Review, FAO, 1994

Thon, Vimealea⁄ Ou, Sivhouch 2009. Leadership in Cambodian Local Politics, in : CDRI (ed.). Annual Development Review 2008-09, pp. 115-137

UN Convention on the Elimination of All Forms of Discrimination against Women, adopted and opened for signature, ratification and accession by General Assembly resolution 34/180 of 18 December, entry into force 3 September 1981, in accordance with article 27(1) 41, 1979

UNCTAD, Trade and Development: Opportunities and Challenges for Developing Countries, 2004

UNDP, UNESCAP Project on Capacity Building on Integration of Energy and Rural Development Planning, 2003

UNDP, Asia Pacific Human Development Report. Power, Voice and Rights. A turning Point for gender Equality in Asia and the Pacific, 2010

UNDP Cambodia and VBNK, Talking about Domestic Violence, 2010

UNESCAP, Energy and Environment Toolkit, UNDP' and Mainstreaming Gender in Energy Polices, 2007, http://www.undp.org/energy/genenergykit/intro2_1.htm

UNICEF Cambodia, The Situation of Children and Women. Phnom Penh.
The World Guide, 1997/98

UNIFEM, Time for action. Implementing CEDAW in Southeast Asia (Canadian International Development agency) 2009

UNIFEM, Who Answers to women? Gender and Accountability. Progress of the world´s women, 2009

United Nations 1995. Beijing Declaration and Platform for Action

United Nations Development Programme (UNDP) 2007. Report on the 2007 Commune Council Elections in Cambodia.

UNTAC Provisions Relating to the Judiciary and Criminal Law, and Procedure, adopted by the Supreme National Council on 10 September, 1992

UNTAC, Energy and Environment Toolkit, UNDP' and 'Mainstreaming Gender in Energy Polices', http://www.un.org/en/peacekeeping/missions/past/untacbackgr1.html

Vutheaery, Kong⁄ Platt, Adam 2007. Evaluation of the Women`s Leadership Programme Partnership for Gender Equity Phase II Ministry of Women`s Affairs⁄UNDP. Phnom Penh

Wacquant L., Punishing the poor there new Government of social insecurity. (Durham, NC: Duke University Press, forthcoming in 2006, University of California, Berkeley, 2006

Woodside Ch. Energy independence: Your everyday Guide to reducing fuel consumption, 2008

WMC, Women Media Center, Questionnaires for writing Cambodian Shadow Report, 2009

Women for Prosperity (WfP) 16 September 2009. Consultation held with the author. Phnom Penh

World Bank, World Bank Atlas, Washington DC, 1996

World Bank, Staff Appraisal Report. Cambodia Agriculture Productivity Improvement Project, 1997

World Health Organization, Fuel for life-Household Energy and Health National Institute of Cambodia, 2006 http://www.nis.gov.kh/index.php/statistics/surveys/cdhs2005/39

# ពាក្យបំព្រួញ

| | |
|---|---|
| CCC | គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា |
| CEDAW | អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ |
| CHRAC | គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា |
| CMDGs | គោលដៅអភិវឌ្ឍសហសវត្សន៍របស់កម្ពុជា |
| CNCW | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី |
| CRC | អនុសញ្ញាស្តីពីសិទ្ធិកុមារ |
| HIV/AIDS | មេរោគដែលធ្វើឱ្យភាពស៊ាំរបស់មនុស្សចុះខ្សោយ |
| HSS HIV | ផ្នែកទ្រទ្រង់សុខភាពជំងឺអេដស៍ |
| ICSESCR | កត្តិការសញ្ញាអន្តរជាតិស្តីពី សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ |
| ICTs | បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ |
| IMR | អត្រាមរណៈកុមារ |
| IWRAW | អង្គការឃ្លាំមើលសកម្មភាពសិទ្ធិស្ត្រីអន្តរជាតិអាស៊ីប៉ាស៊ីហ្វិក |
| MoH | ក្រសួងសុខាភិបាល |
| MoWA | ក្រសួងកិច្ចការនារី |
| MoSVY | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| NCHADS | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ |
| NIC | វិទ្យាស្ថានជាតិកម្ពុជា |
| NIS | វិទ្យាស្ថានជាតិស្ថិតិ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| STD | ជម្ងឺឆ្លងតាមការរួមភេទ |
| UNCOHCR | ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា |
| UNDP | កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា |
| UNHCR | ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភាសន៍ខ្លួន |
| UNIFEM | មូលនិធិអភិវឌ្ឍន៍អង្គការសហប្រជាជាតិដើម្បីស្ត្រី |
| UNTAC | អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិ |
| WTO | អង្គការពាណិជ្ជកម្មពិភពលោក |

## បញ្ជីអង្គការសមាជិក NGO-CEDAW

| | ឈ្មោះអក្សរកាត់ | ឈ្មោះពេញ |
|---|---|---|
| 1 | ADHOC | សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា |
| 2 | AFD | សមាគមអភិវឌ្ឍន៍កសិករ |
| 3 | AFESIP | អាហ្វេស៊ីបកម្ពុជា |
| 4 | AHRDHE | សមាគមដើម្បីអភិវឌ្ឍន៍ធនធានមនុស្ស និងអប់រំសុខភាព |
| 5 | AMARA | អង្គការអមរា |
| 6 | ARR | អង្គការអរុណរះ |
| 7 | BSO | អង្គការបន្ទាយស្រី |
| 8 | BWAP | អង្គការកម្មវិធីស្ត្រីអប់រំជំងឺអេដស៍ខេត្តបាត់ដំបង |
| 9 | CADPP | សមាគមអភិវឌ្ឍន៍ប្រជាពលរដ្ឋក្រីក្រ |
| 10 | CARAM | អង្គការខារ៉ាមកម្ពុជា |
| 11 | CAREPO | អង្គការការពារយុត្តិធម៌ និងសិទ្ធិកម្ពុជា |
| 12 | CCIM | មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ |
| 13 | CCPCR | មជ្ឈមណ្ឌលកម្ពុជាដើម្បីការពារសិទ្ធិកុមារ |
| 14 | CDCam | អភិរក្ស និងអភិវឌ្ឍន៍កម្ពុជា |
| 15 | CDP | ក្រុមអ្នកច្បាប់ការពារសិទ្ធិមនុស្សកម្ពុជា |
| 16 | CDPO | អង្គការជនពិការកម្ពុជា |
| 17 | CDRCP | មជ្ឈមណ្ឌលកម្ពុជាសង្គ្រោះទុគ៌តជន និងអភិវឌ្ឍន៍ |
| 18 | CODO | អង្គការអភិវឌ្ឍន៍សហគមន៍ |
| 19 | COSECAM | សម្ព័ន្ធអង្គការក្រៅរដ្ឋាភិបាលដើម្បីដោះស្រាយបញ្ហាកេងប្រវ័ញ្ចផ្លូវភេទលើកុមារក្នុងប្រទេសកម្ពុជា |
| 20 | CPWP | គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ |
| 21 | CRD | ក្រុមអ្នកស្រាវជ្រាវកម្ពុជាដើម្បីអភិវឌ្ឍន៍ |
| 22 | CSD | មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម |
| 23 | CSP | ក្រុមសុវណ្ណភូមិ |
| 24 | CWCC | អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ |
| 25 | CWDA | ភ្នាក់ងារអភិវឌ្ឍន៍ស្ត្រីកម្ពុជា |
| 26 | CWPD | សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ |
| 27 | DAC | សមាគមអភិវឌ្ឍន៍នៃកម្ពុជា |
| 28 | DOCS | អភិវឌ្ឍន៍ដើម្បីសង្គមកម្ពុជា |
| 29 | E.D.C.O | សហគមន៍អភិវឌ្ឍន៍សេដ្ឋកិច្ច |
| 30 | FAA | សមាគមវិចិត្រសិល្បៈ |
| 31 | FLO | មណ្ឌលកុមារកំព្រាពន្លឺអនាគត |
| 32 | FLOW | អង្គការពន្លឺស្ត្រី |
| 33 | GAD/C | អង្គការយេនឌ័រ និងការអភិវឌ្ឍន៍ដើម្បីកម្ពុជា |
| 34 | GGAC | សមាគមកាយឫទ្ធិនារីកម្ពុជា |
| 35 | IDA | សមាគមឥន្ទ្រទេវី |
| 36 | KHEMARA | អង្គការខេមរា |

| | | |
|---|---|---|
| 37 | K.I.F.H.R.D.A | សមាគមបញ្ញវ័ន្តខ្មែរដើម្បីអភិវឌ្ឍន៍ធនធានមនុស្ស |
| 38 | KKKHRA | សមាគមការពារសិទ្ធិមនុស្សខ្មែរកម្ពុជាក្រោម |
| 39 | KWCD | សហប្រតិបត្តិការស្ត្រីខ្មែរដើម្បីអភិវឌ្ឍន៍ |
| 40 | KWVC | មជ្ឈមណ្ឌលសម្លេងស្ត្រីខ្មែរ |
| 41 | KYA | សមាគមយុវជនខ្មែរ |
| 42 | LAC | អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា |
| 43 | LICADHO | អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ |
| 44 | MEC | អង្គការវេជ្ជសាស្ត្រក្នុងក្តីសង្ឃឹមកម្ពុជា |
| 45 | ML & NV | អង្គការព្រហ្មវិហារធម៌នៃមាតា |
| 46 | NAPA | សមាគមចំរើនជាតិ |
| 47 | NEP | ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល |
| 48 | NGO Forum | វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា |
| 49 | NICFEC | គណៈកម្មាធិការអព្យាក្រិត និងយុត្តិធម៌ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា |
| 50 | OGB | OXFAM ចក្រភពអង់គ្លេស |
| 51 | OI | វិទ្យាស្ថានបើកទូលាយ |
| 52 | PADV | អង្គការប្រឆាំងអំពើហិង្សាក្នុងគ្រួសារ |
| 53 | PCC | បំលាស់ប្តូរជាវិជ្ជមានសម្រាប់កម្ពុជា |
| 54 | PYD | អង្គការសន្តិភាព និងការអភិវឌ្ឍន៍ |
| 55 | RAA | សមាគមរស្មីកសិកម្ម |
| 56 | RHB | រចនាសិប្បកម្មបាត់ដំបង |
| 57 | RHAC | សមាគមថៃទាំសុខភាពគ្រួសារកម្ពុជា |
| 58 | SABORAS | អង្គការសប្បុរស |
| 59 | SERRC | SERRC |
| 60 | SILAKA | អង្គការសីលការ |
| 61 | SK | អង្គការស្តារកម្ពុជា |
| 62 | USG | ក្រុមប្រតិបត្តិការអភិវឌ្ឍន៍តំបន់ជាយក្រុង |
| 63 | VAWCC | អង្គការប្រឆាំងអំពើហិង្សាលើស្ត្រី និងកុមារនៅកម្ពុជា |
| 64 | VIGILANCE | អង្គការរក្សាការពារសិទ្ធិមនុស្សកម្ពុជា |
| 65 | VYCD | សមាគមយុវជនស្ម័គ្រចិត្តដើម្បីលទ្ធិប្រជាធិបតេយ្យ |
| 66 | WDA | សមាគមអភិវឌ្ឍន៍ស្ត្រី |
| 67 | WFP | អង្គការចំរើនស្ត្រី |
| 68 | WLA | សមាគមពន្លឺស្ត្រីកម្ពុជា |
| 69 | WMC | មណ្ឌលព័ត៌មានស្ត្រីកម្ពុជា |
| 70 | WODAC | អភិវឌ្ឍន៍ស្ត្រី និងសហគមន៍ |
| 71 | WOSO | អង្គការសង្គ្រោះស្ត្រី |
| 72 | YRDP | កម្មវិធីអភិវឌ្ឍន៍ធនធានយុវជន |

# បញ្ជីអង្គការសមាជិក CAMBOW

| ឈ្មោះអក្សរកាត់ | | ឈ្មោះពេញ |
|---|---|---|
| 1 | Banteay Srei | អង្គការបន្ទាយស្រី |
| 2 | LICADHO | អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ |
| 3 | CWCC | អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ |
| 4 | CCPCR | មជ្ឈមណ្ឌលកម្ពុជាដើម្បីការពារសិទ្ធិកុមារ |
| 5 | CDP | ក្រុមអ្នកច្បាប់ការពារសិទ្ធិមនុស្សកម្ពុជា |
| 6 | CDRCP | មជ្ឈមណ្ឌលកម្ពុជាសង្គ្រោះទុរគតជន និងអភិវឌ្ឍន៍ |
| 7 | ADHOC | សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា |
| 8 | CLO | អង្គការពលកម្មកម្ពុជា |
| 9 | CWLD | សម្ព័ន្ធស្ត្រីកម្ពុជាដើម្បីអភិវឌ្ឍន៍ |
| 10 | CWCD | សមាគមអភិវឌ្ឍន៍វប្បធម៌ស្ត្រីកម្ពុជា |
| 11 | CWDA | ភ្នាក់ងារអភិវឌ្ឍន៍ស្ត្រីកម្ពុជា |
| 12 | CSD | មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម |
| 13 | CCIM | មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ |
| 14 | DAC | សមាគមអភិវឌ្ឍន៍កម្ពុជា |
| 15 | GAD/C | អង្គការយេនឌ័រ និងការអភិវឌ្ឍន៍ដើម្បីកម្ពុជា |
| 16 | HAGAR | អង្គការហាការ |
| 17 | OUTREACH | អង្គការកម្ពុជាដើម្បីអភិវឌ្ឍន៍ និងលើកស្ទួយសិទ្ធិ |
| 18 | IDA | សមាគមឥន្ទ្រទេវី |
| 19 | KHEMARA | អង្គការខេមរា |
| 20 | KID | វិទ្យាស្ថានខ្មែរសម្រាប់លទ្ធិប្រជាធិបតេយ្យ |
| 21 | KWCD | សហប្រតិបត្តិការស្ត្រីខ្មែរដើម្បីអភិវឌ្ឍន៍ |
| 22 | KWVC | មជ្ឈមណ្ឌលសម្លេងស្ត្រីខ្មែរ |
| 23 | LAC | អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា |
| 24 | MKD | អង្គការមាតាខ្មែរអភិវឌ្ឍន៍ |
| 25 | MLNV | អង្គការព្រហ្មវិហារធម៌នៃមាតា |
| 26 | WVC | មជ្ឈមណ្ឌលនារាថ្មីនៃអង្គការទស្សនៈពិភពលោក-កម្ពុជា |
| 27 | NICFEC | គណៈកម្មាធិការអព្យាក្រិត និងយុត្តិធម៌ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា |
| 28 | CWARO | អង្គការជំនួយកុមារ និងស្ត្រីជនបទ |
| 29 | PADV | អង្គការប្រឆាំងអំពើហិង្សាក្នុងគ្រួសារ |
| 30 | STAR Kampuchea | អង្គការស្តារកម្ពុជា |
| 31 | CHRTF | ក្រុមកិច្ចការពិសេសសិទ្ធិមនុស្សកម្ពុជា |
| 32 | USG | ក្រុមប្រតិបត្តិការអភិវឌ្ឍន៍តំបន់ជាយក្រុង |
| 33 | VAWCC | អង្គការប្រឆាំងអំពើហិង្សាលើស្ត្រី និងកុមារនៅកម្ពុជា |
| 34 | VYCD | សមាគមយុវជនស្ម័គ្រចិត្តដើម្បីលទ្ធិប្រជាធិបតេយ្យ |
| 35 | WOSO | អង្គការសង្គ្រោះស្ត្រី |

christian aid JOINT PROGRAMME

Agence canadienne de développement international

Canadian International Development Agency

MINISTERIO DE ASUNTOS EXTERIORES Y DE COOPERACIÓN

aecid

pd PAZ Y DESARROLLO

**របាយការណ៍នេះ បោះពុម្ពក្រោមជំនួយ**
**ពីព្រះវិហារដាណឺម៉ាក និងជំនួយរបស់វិហារគ្រិស្ត (DCA/CA), អង្គការសន្តិភាព**
**និងអភិវឌ្ឍន៍ (Paz Y Desarrollo) និងទីភ្នាក់ងារអេស្ប៉ាញសម្រាប់**
**សហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិ (AECID) និងទីភ្នាក់ងារសម្រាប់ការ**
**អភិវឌ្ឍន៍នៃប្រទេសកាណាដា**